USAID
ជំនួយពីពលរដ្ឋអាមេរិក

# កម្មវិធីសាកល្បងទប់ស្កាត់សិស្សបោះបង់សាលា
## ការពិនិត្យឡើងវិញនូវឯកសារស្រាវជ្រាវ



កិច្ចសន្យាលេខ៖ EDH-I-00-05-00029-00
បេសកកម្មការងារ៖ AID-OAA-TO-10-00010

ថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០១១

ការសិក្សាស្រាវជ្រាវនេះត្រូវបានធ្វើឡើងសម្រាប់ពិនិត្យឡើងវិញដោយទីភ្នាក់ងារសហរដ្ឋអាមេរិកដើម្បីអភិវឌ្ឍន៍អន្តរជាតិ(USAID) និងត្រូវបានរៀបចំដោយក្រុមហ៊ុន គ្រីអេធីវ អាសូស៊ីអេត អ៊ីនធើណេសិនណាល (Creative Associates International ) ។

## ទីភ្នាក់ងារសហរដ្ឋអាមេរិកដើម្បីអភិវឌ្ឍន៍អន្តរជាតិ( USAID )

## ពីប្រជាពលរដ្ឋអាមេរិក

# កម្មវិធីសាកល្បងទប់ស្កាត់សិស្សបោះបង់សាលា

# ការពិនិត្យឡើងវិញនូវឯកសារស្រាវជ្រាវ

**កិច្ចសន្យាលេខ៖** EDH-I-00-05-00029-00

**បេសកកម្មការងារ៖** AID-OAA-TO-10-00010

**ថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០១១**

ការសិក្សាស្រាវជ្រាវនេះត្រូវបានធ្វើឡើងសម្រាប់ពិនិត្យឡើងវិញដោយទីភ្នាក់ងារសហរដ្ឋអាមេរិកដើម្បីអភិវឌ្ឍន៍អន្តរជាតិ(USAID) និងត្រូវបានរៀបចំដោយក្រុមហ៊ុន **គ្រីអេធីវ អាសូស៊ីអេត អ៊ីនធឺណេសិនណល** (Creative Associates International ) ។

# កម្មវិធីសាកល្បងទប់ស្កាត់សិស្សបោះបង់សាលា

# ការពិនិត្យឡើងវិញនូវឯកសារស្រាវជ្រាវ

ដាក់ជូន ៖

ទីភ្នាក់ងារសហរដ្ឋអាមេរិកដើម្បីអភិវឌ្ឍន៍អន្តរជាតិ
នៅរដ្ឋធានី វ៉ាស៊ីនតោនឌីស៊ី

ដាក់ជូនដោយ ៖

Creative Associates International

នៅរដ្ឋធានី វ៉ាស៊ីនតោនឌីស៊ី

ថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០១១

**តម្រូវការដាក់ជូនទៅ** DEC

| | | |
|---|---|---|
| ក | ការប្រគល់កិច្ចសន្យារបស់ទីភ្នាក់ងារសហរដ្ឋអាមេរិកដើម្បីអភិវឌ្ឍន៍អន្តរជាតិ(USAID) | កិច្ចសន្យាលេខ:EDH-I-00-05-00029-00<br>បេសកកម្មការងារ:<br>AID-OAA-TO-10-00010 |
| ខ | ចំណងជើងគោលដៅនិងលេខរបស់ទីភ្នាក់ងារសហរដ្ឋអាមេរិកដើម្បីអភិវឌ្ឍន៍អន្តរជាតិ (USAID) | ការវិនិយោគទៅលើប្រជាជន |
| គ | ចំណងជើងគម្រោង និងលេខរបស់ទីភ្នាក់ងារសហរដ្ឋអាមេរិកដើម្បីអភិវឌ្ឍន៍អន្តរជាតិ(USAID) | កម្មវិធីសាកល្បងទប់ស្កាត់សិស្សបោះបង់សាលា (SDPP) នៅ តំបន់អាស៊ី និងមជ្ឈឹមបូព៌ានៃទីភ្នាក់ងារសហរដ្ឋអាមេរិកដើម្បីអភិវឌ្ឍន៍អន្តរជាតិ(USAID) |
| ឃ | ផ្នែកនៃកម្មវិធី និងធាតុផ្សំនៃកម្មវិធីរបស់ទីភ្នាក់ងារសហរដ្ឋអាមេរិកដើម្បីអភិវឌ្ឍន៍អន្តរជាតិ | ការអប់រំ (ផ្នែកនៃកម្មវិធី ៣.២)<br>ការអប់រំកម្រិតមូលដ្ឋាន (ធាតុផ្សំនៃកម្មវិធី ៣.២.១) |
| ង | ចំណងជើងសៀវភៅ | ការពិនិត្យឡើងវិញនូវឯកសារស្រាវជ្រាវ-ការទប់ស្កាត់សិស្ស បោះបង់សាលា |
| ច | ឈ្មោះអ្នកនិពន្ធ | លោកស្រីបណ្ឌិត Lorie Brush,<br>លោកស្រី JenniferShin, លោកស្រី Rajani Shrestha,<br>លោកស្រី Karen Tietjen |
| ឆ | ឈ្មោះអ្នកទទួលកិច្ចសន្យា | ក្រុមហ៊ុនគ្រីអេធីវ អាសូស៊ីអេត អាំងធឺណេសិនណាល (Creative Associates International) ដែលមានអាស័យដ្ឋាន<br>5301 Wisconsin Avenue, NW, Suite 700<br>Washington, DC 20015<br>ទូរស័ព្ទលេខ៖២០២៩៦៦-៥៨០៤ |

| | | |
|---|---|---|
| | | ទូរសារលេខៈ ២០២៣៦៣-៤៧៧១<br>អ៊ីមែលៈ KarenT@creativeDC.com |
| ជ | ឧបត្ថម្ភដោយអង្គភាពប្រតិបត្តិការ នៃទីភ្នាក់ងារសហរដ្ឋអាមេរិកដើម្បីអភិវឌ្ឍន៍អន្តរជាតិ(USAID) និង អ្នកតំណាងបច្ចេកទេសរបស់អ្នកទទួលកិច្ចសន្យា(COTR) | AME/ME/TS<br>លោកស្រី Rebecca Adams, អ្នកតំណាងបច្ចេកទេសរបស់អ្នកទទួលកិច្ចសន្យា (COTR) |
| ឈ | កាលបរិច្ឆេទបោះពុម្ព ផ្សាយ | ថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០១១ |
| ញ | ភាសាប្រើប្រាស់ក្នុងឯកសារ | អង់គ្លេស និងខ្មែរ |

របាយការណ៍នេះអាចចេញជារូបរាងបាន ដោយសារតែប្រជាជនអាមេរិកតាមរយៈទីភ្នាក់ងារសហរដ្ឋអាមេរិកដើម្បីអភិវឌ្ឍន៍អន្តរជាតិ(USAID) ។ ខ្លឹមសារនៃរបាយការណ៍នេះគឺជាការទទួលខុសត្រូវទាំងស្រុងរបស់ **គ្រីអេធីវ អាសូស៊ីអេត អាំងធឺណេសិនណាល** (Creative Associates International) និងមិនឆ្លុះបញ្ចាំងពីទស្សនៈរបស់ទីភ្នាក់ងារសហរដ្ឋអាមេរិកដើម្បីអភិវឌ្ឍន៍អន្តរជាតិ (USAID) ឬ រដ្ឋាភិបាលសហរដ្ឋអាមេរិកឡើយ ។

# មាតិកា


**បញ្ជីតារាង** ........ Error! Bookmark not defined.

**បញ្ជីពាក្យកាត់** ........ v

**សេចក្តីសង្ខេបសំខាន់** ........ vii

**១.០ សេចក្តីផ្តើម** ........ **1**

១.១ គោលបំណងនៃការពិនិត្យឡើងវិញ ........ 1

១.២ និយមន័យនៃពាក្យ "សិស្សបោះបង់សាលា" ........ 2

១.៣ វិធីសាស្រ្តនៃការពិនិត្យឡើងវិញ និងជ្រើសរើសអន្តរាគមន៍ ........ 4

១.៤ ការរៀបចំរបាយការណ៍ ........ 7

**២.០ ស្ថានភាព និងលក្ខណៈសម្គាល់កុមារនិងយុវជនប្រឈមនឹងការបោះបង់សាលា** ........ **9**

២.១ ទំហំនៃបញ្ហាសិស្សបោះបង់សាលា ........ 9

២.២ កត្តាដែលមានទំនាក់ទំនងនឹងកុមារបោះបង់សាលា ........ 12

**៣.០ អន្តរាគមន៍ដើម្បីទប់ស្កាត់សិស្សបោះបង់សាលា** ........ **20**

៣.១ ការបែងចែកប្រភេទអន្តរាគមន៍ ........ 20

៣.២ លទ្ធផលនៃការវាយតម្លៃលម្អិតអំពីកម្មវិធីអន្តរាគមន៍សិស្សបោះបង់សាលា ........ 24

៣.២.១ ការជ្រើសរើសអន្តរាគមន៍ ........ 24

៣.២.២ ការបរិយាយអំពីអន្តរាគមន៍ដែលត្រូវបានវាយតម្លៃលម្អិត ........ 28

៣.២.៣ ការវាយតម្លៃលើប្រសិទ្ធភាពនៃកម្មវិធី ........ 35

៣.៣ ការបរិយាយនៃកម្មវិធីអន្តរាគមន៍សិស្សបោះបង់សាលាដែលមិនបានឆ្លើយតបទៅនឹងលក្ខណៈវិនិច្ឆ័យរបស់កម្មវិធីសាកល្បងទប់ស្កាត់សិស្សបោះបង់សាលា ........ 44

៣.៣.១ ការជ្រើសរើសអន្តរាគមន៍ ........ 44

៣.៣.២ ការបរិយាយអំពីអន្តរាគមន៍ដែលមិនបានឆ្លើយតបទៅនឹងលក្ខណៈវិនិច្ឆ័យរបស់កម្មវិធីទប់ស្កាត់សិស្សបោះបង់សាលា ...... 45
៣.៣.៣ ការវាយតម្លៃលើប្រសិទ្ធភាពនៃកម្មវិធី ...... 49
**៤.0 សេចក្តីសន្និដ្ឋាន និងអនុសាសន៍ ...... 51**
ឯកសារយោង ...... 56
**ឧបសម្ព័ន្ធ ក ៖ ស្ថិតិអប់រំសម្រាប់ប្រទេសដែលមានកម្មវិធីសាកល្បងទប់ស្កាត់សិស្សបោះបង់សាលា .. 67**
**ឧបសម្ព័ន្ធ ខ ៖ កត្តាហានិភ័យនៃការបោះបង់សាលា ...... 73**
**ឧបសម្ព័ន្ធ គ៖ សេចក្តីសង្ខេបនៃការសិក្សាពីអន្តរាគមន៍ចំពោះការបោះបង់សាលាដែលឆ្លើយតបទៅនឹងលក្ខណៈវិនិច្ឆ័យរបស់កម្មវិធីសាកល្បងទប់ស្កាត់សិស្សបោះបង់សាលា ...... 91**
**ឧបសម្ព័ន្ធ ឃ ៖ សេចក្តីសង្ខេបពីការសិក្សានៃអន្តរាគមន៍ដែលមិនបានឆ្លើយតបនូវរាល់លក្ខណៈវិនិច្ឆ័យលម្អិតរបស់កម្មវិធីសាកល្បងទប់ស្កាត់សិស្សបោះបង់សាលា ...... 219**

# បញ្ជីតារាង

តារាងទី១ ៖ ទិន្នន័យស្តីពីសិស្សបោះបង់សាលា

តារាងទី២ ៖ ចំនួន(ភាគរយ)នៃការសិក្សាដែលបង្ហាញថាកត្តាហានិភ័យនីមួយៗជះអានុភាព លើការបោះបង់សាលា

តារាងទី៣ ៖ កត្តាហានិភ័យសំខាន់ៗនៅកម្រិតសាលា(សម្រាប់សហរដ្ឋអាមេរិកប៉ុណ្ណោះ)

តារាងទី៤ ៖ ទំនាក់ទំនងរវាងកត្តាហានិភ័យ និងប្រភេទអន្តរាគមន៍

តារាងទី៥ ៖ បញ្ជីកម្មវិធីអន្តរាគមន៍ដែលបានឆ្លងកាត់ការវាយតម្លៃយ៉ាងលម្អិត

តារាងទី៦ ៖ការបែងចែកប្រភេទនៃកម្មវិធីអន្តរាគមន៍សិស្សបោះបង់សាលាដែលបានឆ្លងកាត់ការវាយតម្លៃយ៉ាងលម្អិត

តារាងទី៧ ៖ សំណើអន្តរាគមន៍ដែលបានមកពីការស្រាវជ្រាវនៅប្រទេសកំពុងអភិវឌ្ឍ

តារាងទី៨ ៖អថេរលទ្ធផលទទួលអានុភាពពីសេវាអន្តរាគមន៍អន្តរជាតិដែលឆ្លងកាត់ការវាយតម្លៃយ៉ាងលម្អិត

តារាងទី៩ ៖ បញ្ជីកម្មវិធីអន្តរាគមន៍សិស្សបោះបង់សាលាដែលមិនបានឆ្លើយតបទៅនឹងលក្ខណៈវិនិច្ឆ័យរបស់កម្មវិធីសាកល្បងទប់ស្កាត់សិស្សបោះបង់សាលា

តារាងទី១០ ៖ ការបែងចែកប្រភេទកម្មវិធីអន្តរាគមន៍សិស្សបោះបង់សាលាដែល មិនបានគោរពតាមលក្ខណៈវិនិច្ឆ័យផ្អែកលើភស្តុតាងរបស់កម្មវិធីសាកល្បងទប់ស្កាត់សិស្សបោះបង់សាលា

តារាងទី១១ ៖ កត្តាផ្លាស់ប្តូរលទ្ធផលដែលទទួលអានុភាពពីសេវាអន្តរាគមន៍នីមួយៗដែលមិនបានគោរពតាមលក្ខណៈវិនិច្ឆ័យវាយតម្លៃរបស់កម្មវិធីសាកល្បងទប់ស្កាត់សិស្សបោះបង់សាលា

តារាង ក-១ ៖ ស្ថិតិអប់រំសម្រាប់ប្រទេសដែលមានកម្មវិធីសាកល្បងទប់ស្កាត់សិស្សបោះបង់សាលា

តារាង ខ-១ ៖ កត្តាហានិភ័យនៃការបោះបង់សាលាក្នុងសហរដ្ឋអាមេរិក និងបណ្តាប្រទេសនៃអង្គការសហការ និងអភិវឌ្ឍសេដ្ឋកិច្ច (OECD)

តារាង ខ-២ ៖ កត្តាហានិភ័យនៃការបោះបង់សាលាក្នុងប្រទេសកំពុងអភិវឌ្ឍ

តារាង គ-១ ៖ កម្មវិធីអន្តរាគមន៍សិស្សបោះបង់សាលាដែលគោរពបានគ្រប់តាមលក្ខណៈវិនិច្ឆ័យរបស់កម្មវិធីសាកល្បងទប់ស្កាត់សិស្សបោះបង់សាលា

តារាង ឃ-១ ៖ កម្មវិធីអន្តរាគមន៍ជាលក្ខណៈអន្តរជាតិចំពោះការបោះបង់សាលាដែលមិនបានគោរពឲ្យបានគ្រប់តាមលក្ខណៈវិនិច្ឆ័យរបស់កម្មវិធីសាកល្បងទប់ស្កាត់សិស្សបោះបង់សាលា (ដាក់តាមអក្ខរក្រមអង់គ្លេសតាមឈ្មោះប្រទេស)

# បញ្ជីពាក្យកាត់

| | |
|---|---|
| ALAS | សមិទ្ធិផលសម្រាប់ប្រជាជនអាមេរិកឡាទីនតាមរយៈភាពជោគជ័យខាងការសិក្សា ដែលជាកម្មវិធីសាកល្បងទប់ស្កាត់សិស្សបោះបង់សាលាក្នុងសហរដ្ឋអាមេរិក |
| BRIGHT | ការឆ្លើយតបរបស់ជនជាតិបួគីណាដើម្បីលើកស្ទួយឲ្យកុមារមានឱកាសទទួលបានជោគជ័យ ដែលជាកម្មវិធីលើកកម្ពស់ការអប់រំក្នុងប្រទេសបួគីណាហ្វាសូ |
| CREATE | សមាគមស្រាវជ្រាវអំពីការទទួលបានការអប់រំ សាកល វិទ្យាល័យ ស៊ុយសិក |
| EdStats | ស្ថិតិអប់រំ |
| EMIS | ប្រព័ន្ធគ្រប់គ្រងព័ត៌មានអប់រំ |
| FFE | ស្បៀងអាហារដើម្បីការអប់រំ ដែលជាកម្មវិធីសាកល្បងទប់ស្កាត់សិស្សបោះបង់សាលាក្នុងប្រទេសបង់ក្លាដេស |
| HIV/AIDS | មេរោគអេដស៍/ជំងឺអេដស៍ |
| NDPC | មជ្ឈមណ្ឌលជាតិទប់ស្កាត់សិស្សបោះបង់សាលា |
| OECD | អង្គការសហការ និងអភិវឌ្ឍសេដ្ឋកិច្ច |
| PACES | កម្មវិធីសាកល្បងទប់ស្កាត់សិស្សបោះបង់សាលាក្នុងប្រទេសកូឡុំប៊ី |
| PATH | កម្មវិធីលើកកម្ពស់សុខភាព និងការអប់រំ ដែលជាកម្មវិធីសាកល្បងទប់ស្កាត់សិស្សបោះបង់សាលាក្នុងប្រទេសចាម៉ៃកា |

| | |
|---|---|
| PRAF | កម្មវិធីសាកល្បងទប់ស្កាត់សិស្សបោះបង់សាលាក្នុងប្រទេសហុងឌុយរ៉ាស់ |
| PROGRESA | កម្មវិធីសាកល្បងទប់ស្កាត់សិស្សបោះបង់សាលាក្នុងប្រទេសមិចស៊ិចកូ |
| QED | គម្រោងផ្អែកលើការពិសោធន៍ |
| RCT | គម្រោងព្រាវៗប្រៀបធៀបក្រុមមិនទទួលអន្តរាគមន៍ពីគម្រោង/ក្រុមទទួលអន្តរាគមន៍ពីគម្រោង |
| SDPP | កម្មវិធីសាកល្បងទប់ស្កាត់សិស្សបោះបង់សាលា |
| SEAMEO | អង្គការគ្រប់គ្រងវិស័យអប់រំអាស៊ីអាគ្នេយ៍ |
| UIS | វិទ្យាស្ថានស្ថិតិរបស់អង្គការសហប្រជាជាតិទទួលបន្ទុកផ្នែកអប់រំ វិទ្យាសាស្ត្រ និងវប្បធម៌ |
| UNESCO | អង្គការសហប្រជាជាតិទទួលបន្ទុកផ្នែកអប់រំ វិទ្យាសាស្ត្រ និងវប្បធម៌ |
| U.S. | សហរដ្ឋអាមេរិក |
| USAID | ទីភ្នាក់ងារសហរដ្ឋអាមេរិកដើម្បីអភិវឌ្ឍន៍អន្តរជាតិ |

# សេចក្តីសង្ខេបសំខាន់

គោលបំណងនៃកម្មវិធីសាកល្បងទប់ស្កាត់សិស្សបោះបង់សាលា(SDPP) គឺដើម្បីសាកល្បងលើប្រសិទ្ធភាពនៃកម្មវិធីសាកល្បងទប់ស្កាត់សិស្សបោះបង់សាលា ក្នុងបណ្តាប្រទេសទាំងបួននៃតំបន់អាស៊ីមជ្ឈឹមបូព៌ារបស់ទីភ្នាក់ងារសហរដ្ឋអាមេរិកដើម្បីអភិវឌ្ឍន៍អន្តរជាតិ (USAID) រួមមាន ៖ ប្រទេសកម្ពុជា ឥណ្ឌា តាជីគីស្ថាន និងប្រទេសទីម័រលែស ។ ក្នុងឆ្នាំដំបូងនៃគម្រោងនេះ កម្មវិធីសាកល្បងទប់ស្កាត់សិស្សបោះបង់សាលា(SDPP) ត្រូវគ្រោងរៀបចំអន្តរាគមន៍ទាំងនេះ ហើយក្នុងរយៈពេលពីរឆ្នាំបន្ទាប់ ត្រូវអនុវត្តគម្រោងអន្តរាគមន៍ទាំងនេះ និងវាយតម្លៃភាពជោគជ័យនៃអន្តរាគមន៍ទាំងនោះដើម្បីទប់ស្កាត់កំណើននៃកុមារបោះបង់សាលា ។

កម្មវិធីសាកល្បងទប់ស្កាត់សិស្សបោះបង់សាលា(SDPP) កំណត់និយមន័យពាក្យថា សិស្សបោះបង់សាលា ថាជាសិស្សដែលមិនបានបញ្ចប់វគ្គអប់រំកម្រិតមូលដ្ឋានក្នុងប្រទេសមួយ ហើយគម្រោងមានតួនាទីរៀបចំគម្រោងអន្តរាគមន៍ដល់សិស្សនៅបឋមសិក្សា ឬមធ្យមសិក្សា ទៅតាមតម្រូវការនៃប្រទេសនីមួយៗ និងលក្ខណៈសម្គាល់របស់សិស្សបោះបង់សាលា ។ ទិន្នន័យអង្គការសហប្រជាជាតិទទួលបន្ទុកផ្នែកអប់រំ វិទ្យាសាស្ត្រ និងវប្បធម៌ (យូណេស្កូ) នៅក្នុងប្រទេសគោលដៅទាំងបួនបង្ហាញពីលក្ខណៈផ្សេងគ្នានៃការចូលរួមនៅសាលារៀន ។ បើនិយាយពីកុមារក្នុងប្រទេសតាជីគីស្ថានពួកគេកម្របោះបង់សាលានៅវគ្គអប់រំកម្រិតបឋមសិក្សាណាស់ ដោយគេឃើញថាអត្រាពិតនៃការចូលរៀននៅក្នុងវគ្គអប់រំនេះមានចំនួន៩៧% ។ ពេលដែលគេបារម្ភចំពោះកុមារបោះបង់សាលាក្នុងប្រទេសនេះគឺនៅវគ្គអប់រំកម្រិតមធ្យមសិក្សា ។ តែបើនិយាយពីប្រទេសកម្ពុជា ឥណ្ឌា និងប្រទេសទីម័រលែសវិញ ប្រទេសទាំងនេះមានអត្រាពិតនៃការចូលរៀននៅបឋមសិក្សាតិចជាងប្រទេសតាជីគីស្ថានពី ៧៦ ទៅ ៩០ភាគរយ ដោយលើកឡើងពីភាពលំបាកសម្រាប់ក្រុមកុមារខ្លះក្នុងការទទួលបាន ឬបន្តការសិក្សានៅបឋមសិក្សា ហើយអត្រាចុះឈ្មោះចូលរៀននៅកម្រិតមធ្យមសិក្សាកាន់តែទាបទៅៗ ។

ឯកសារស្រាវជ្រាវនេះ ផ្តល់រូបភាពយ៉ាងច្បាស់អំពីលក្ខណៈសម្គាល់របស់កុមារបោះបង់សាលា។ នៅសហរដ្ឋអាមេរិក និងបណ្តាប្រទេសនៃអង្គការសហការ និងអភិវឌ្ឍសេដ្ឋកិច្ច ជារឿយៗកុមារមិនសូវមានភាពជោគជ័យក្នុងការសិក្សានោះទេ ពួកគេរៀនត្រួតថ្នាក់ មករៀនមិនទៀងទាត់ មិនសូវចាប់អារម្មណ៍ ឬមិនមានការប្តេជ្ញាចិត្តក្នុងសិក្សា ហើយកុមារភាគច្រើនមានបញ្ហាផ្នែកវិន័យ ។ កុមារទាំងនេះភាគច្រើនមកពីគ្រួសារក្រីក្រ ។ នៅតាមបណ្តាប្រទេសកំពុងអភិវឌ្ឍ បម្រែបម្រួលសេដ្ឋកិច្ចជាកត្តាសំខាន់ចំពោះស្ថានភាពសេដ្ឋកិច្ចគ្រួសារ ដែលតម្រូវឲ្យកុមាររកប្រាក់ ឬជួយគ្រួសារតាមរយៈធ្វើ

ការងារផ្ទះ ។ ក្រៅពីកង្វល់ផ្នែកហិរញ្ញវត្ថុ នៅមានបញ្ហាបួនផ្សេងទៀតដែលគេឃើញមានដូចគ្នានៅសហរដ្ឋអាមេរិក និងបណ្តាប្រទេសនៃអង្គការសហការ និងអភិវឌ្ឍសេដ្ឋកិច្ច រួមមាន ៖ សមិទ្ធិផលនៃការសិក្សាទាប ការរៀនត្រួតថ្នាក់ ឬលើសអាយុ វត្តមានចូលរៀនតិចតួច និងការមិនសូវចាប់អារម្មណ៍ក្នុងការសិក្សា ។ លើសពីនេះទៅទៀត នៅតាមបណ្តាប្រទេសកំពុងអភិវឌ្ឍ សិស្សបោះបង់សាលាភាគច្រើនជាកុមារីឬ ភាគច្រើនដោយសារមានបញ្ហាពិការភាពឬ បញ្ហាសុខភាព រៀននៅសាលាឆ្ងាយពីផ្ទះ និងរស់នៅក្នុងតំបន់ជនបទ។

ឯកសារស្រាវជ្រាវនេះ រកឃើញកម្មវិធីសាកល្បងទប់ស្កាត់សិស្សបោះបង់សាលាចំនួន២៦ ដែលឆ្លើយតបទៅនឹងលក្ខណៈវិនិច្ឆ័យលម្អិតអំពីភាពពាក់ព័ន្ធនៃប្រធានបទ (រួមមាន ការវាស់វែងនៃការចូលរៀន ការនៅរៀន ការរៀនបានរីកចម្រើននៅសាលា) ភាពពាក់ព័ន្ធនៃគម្រោងពេលវេលា (កម្មវិធី និងការវាយតម្លៃត្រូវធ្វើឡើងពីឆ្នាំ១៩៩០ ដល់ឆ្នាំ២០១០) ភាពពាក់ពាក់នៃគំរូតាង(ផ្តោតលើសិស្សនៅរៀនដែលប្រឈមនឹងការបោះបង់សាលា) និងភាពពាក់ព័ន្ធនៃគម្រោងវាយតម្លៃ (គម្រោងព្រាវៗប្រៀបធៀបក្រុមមិនទទួលអន្តរាគមន៍ពីគម្រោង/ក្រុមទទួលអន្តរាគមន៍ពីគម្រោង ឬគម្រោងផ្អែកលើការពិសោធន៍)។ ក្នុងចំណោមកម្មវិធីទាំង២៦នេះ មានកម្មវិធីចំនួន០៦ត្រូវបានប្រតិបត្តិការនៅសហរដ្ឋអាមេរិក និងកម្មវិធីចំនួន២០ត្រូវបានប្រតិបត្តិការនៅបណ្តាប្រទេសកំពុងអភិវឌ្ឍ ។

កម្មវិធីសិស្សបោះបង់សាលានៅសហរដ្ឋអាមេរិក មានលក្ខណៈខុសគ្នាពីកម្មវិធីសិស្សបោះបង់សាលានៅបណ្តាប្រទេសផ្សេងទៀត នៅក្នុងក្រុមគោលដៅសម្រាប់អន្តរាគមន៍នានា និងនៅក្នុងប្រភេទនៃការផ្តល់សេវា ប៉ុន្តែវាមានលក្ខណៈស្រដៀងគ្នានឹងវិធីសាស្រ្តនៃការវាយតម្លៃ ពោលគឺ កម្មវិធីរបស់សហរដ្ឋអាមេរិកភាគច្រើនផ្តោតសំខាន់ទៅលើសិស្សអនុវិទ្យាល័យ និងវិទ្យាល័យ ចំណែកឯកម្មវិធីដែលអនុវត្តនៅបណ្តាប្រទេសផ្សេងទៀត ភាគច្រើនផ្តោតទៅលើសិស្សថ្នាក់បឋមសិក្សាជាគោលដៅទៅវិញ។ ការសិក្សាភាគច្រើននៅក្នុងក្រុមទាំងពីរ ដែលឆ្លើយតបទៅនឹងស្តង់ដារដ៏រឹងមាំរបស់យើងចំពោះភាពពាក់ព័ន្ធនៃគម្រោងស្រាវជ្រាវ គឺជាគម្រោងប្រៀបធៀបព្រាវៗដោយផ្តល់សមត្ថភាពពិតប្រាកដក្នុងការបង្ហាញភាពខុសគ្នានៃអានុភាពជាពិសេសទៅលើក្រុមសិស្សដែលមានស្ថានភាពស្មើគ្នា។

ការផ្តល់សេវានៅក្នុងកម្មវិធីសិស្សបោះបង់សាលា នៅសហរដ្ឋអាមេរិកមានលក្ខណៈខុសគ្នាពីការផ្តល់សេវានៅបណ្តាប្រទេសកំពុងអភិវឌ្ឍ នៅក្នុងជម្រើសសេវាជាក់លាក់ដែលនឹងត្រូវផ្តល់ និងសេវាចម្រុះ។ សហរដ្ឋអាមេរិកមានការពេញចិត្តយ៉ាងខ្លាំងក្នុងការផ្តល់ការគាំទ្រផ្នែកសិក្សាប្រភេទមួយ

ចំនួន និងសេវាផ្ទាល់ខ្លួន/សង្គម ដើម្បីឲ្យកុមារប្រឈមនឹងការបោះបង់សាលាអាចចាប់បានជំនាញលើមុខវិជ្ជារបស់ពួកគេ និងទទួលបានជំនួយគាំទ្រ ដើម្បីជួយពួកគេក្នុងការដោះស្រាយបញ្ហាផ្ទាល់ខ្លួន ឬបញ្ហាសង្គម ដែលពួកគេកំពុងប្រឈមមុខ។ កម្មវិធី៥ ក្នុងចំណោមកម្មវិធីចំនួន៦របស់សហរដ្ឋអាមេរិករួមមាន សមាសភាគផ្នែកសិក្សាមួយចំនួន ហើយកម្មវិធីទាំងអស់នេះរួមមានសមាសភាគផ្ទាល់ខ្លួន/ សង្គម។ ក្រៅពីនេះ ពាក់កណ្ដាលនៃកម្មវិធីរបស់សហរដ្ឋអាមេរិកមានសមាសភាពផ្នែករចនាសម្ព័ន្ធ ការផ្លាស់ប្ដូរបរិយាកាសរៀនសូត្រ ដោយបង្កើតក្រុមនៃថ្នាក់ដែលមានសិស្សតិចតួច ឬផ្លាស់ប្ដូរកម្មវិធីសិក្សាដើម្បីឲ្យសិស្សចូលរៀនកាន់តែច្រើនឡើងថែមទៀត។ កម្មវិធីទាំងនេះមិនបានផ្ដល់ហិរញ្ញវត្ថុប្រាក់លើកទឹកចិត្ត ឬសេវាសុខភាពនោះទេ។ ទោះជាយ៉ាងនោះក្ដី នៅក្នុងប្រទេសកំពុងអភិវឌ្ឍ ប្រាក់លើកទឹកចិត្ត ដើម្បីបញ្ជូនកុមារទៅសាលារៀនគឺជាការធម្មតាទៅហើយ។ កម្មវិធី១៣ ក្នុងចំណោមកម្មវិធីដែលត្រូវបានវាយតម្លៃលម្អិតចំនួន២០ (៦៥ភាគរយ) បានផ្ដល់ជាការផ្ទេរប្រាក់ អាហារូបករណ៍ សក្ខីបត្រ(ប័ណ្ណលក់ទំនិញ) អាហារសម្រាប់គ្រួសារ បរិក្ខារសាលារៀន ឬឯកសណ្ឋានសិស្ស នៅពេលដែលកុមារចូលរៀនទៀងទាត់ ហើយ១១ករណីក្នុងចំណោមករណីទាំងនេះ អន្តរាគមន៍ផ្នែកហិរញ្ញវត្ថុគឺជាជម្រើសតែមួយគត់ដែលត្រូវបានគេ យកមកអនុវត្ត។ កម្មវិធីអន្តរជាតិតិចជាង១/៣(មួយភាគបី) មានជាអាទិ៍ សមាសភាគផ្នែកសិក្សា ផ្នែកសុខភាព ឬផ្នែករចនាសម្ព័ន្ធ មានតែកម្មវិធីមួយប៉ុណ្ណោះដែល ផ្ដល់ការគាំទ្រផ្នែកផ្ទាល់ខ្លួន/សង្គម។

លទ្ធផលសម្រាប់អន្តរាគមន៍នៃប្រភេទផ្សេងគ្នាត្រូវដាក់បញ្ចូលគ្នា ដើម្បីឲ្យមានប្រសិទ្ធភាពក្នុងការបង្កើនការចូលរៀន ការកាត់បន្ថយអត្រាសិស្សបោះបង់សាលា ឬការធានាថា សិស្សរៀនបានរីកចម្រើននៅសាលារៀន។ អន្តរាគមន៍ផ្នែកហិរញ្ញវត្ថុដែលត្រូវបានវាយតម្លៃលម្អិតបានបង្ហាញពីការផ្លាស់ប្ដូរជាវិជ្ជមានដ៏គួរឲ្យកត់សម្គាល់ ១២ករណី ក្នុងចំណោម១៣ករណី(៩២ភាគរយ) ការផ្លាស់ប្ដូររចនា សម្ព័ន្ធទទួលបានជោគជ័យ៣ករណី ក្នុងចំណោម៤ករណី (៧៥ភាគរយ) ការគាំទ្រផ្នែកសិក្សាមានប្រសិទ្ធភាព២ករណី ក្នុងចំណោម៤ករណី (៥០ភាគរយ) ហើយអន្តរាគមន៍ផ្នែកសុខភាពមានអានុភាពលើលទ្ធផលនៃការអប់រំ នៅក្នុងការសិក្សា២ ក្នុងចំណោមការសិក្សា៥ករណី(៤០ភាគរយ)។ អន្តរាគមន៍ផ្ទាល់ខ្លួន/សង្គមទទួលបានជោគជ័យ ប៉ុន្តែដោយសារតែអន្តរាគមន៍នេះមានអន្តរាគមន៍ប្រភេទផ្សេងទៀតបានជានាំឲ្យអូសបន្លាយករណីសិក្សាដែលថា អន្តរាគមន៍ប្រភេទនេះមានប្រសិទ្ធភាព១០០ភាគ រយ។

មេរៀនសំខាន់ៗបីសម្រាប់កម្មវិធីសាកល្បងទប់ស្កាត់សិស្សបោះបង់សាលា បានកើតចេញពីការពិនិត្យឡើងវិញនូវកម្មវិធីអន្តរាគមន៍សិស្សបោះបង់សាលានេះ។ ទីមួយ ឯកសារស្រាវជ្រាវនេះបង្ហាញថា កត្តាមួយចំនួនដែលស្ដែងចេញនូវឥរិយាបថរបស់កុមារនៅសាលារៀនគឺមានទំនាក់ទំនង

ទៅនឹងសិស្សបោះបង់សាលា ពោលគឺ ពួកគេរៀនបានពិន្ទុទាប រៀនត្រូតថ្នាក់ ឬហួសអាយុចូលរៀន មករៀនមិនទៀងទាត់ និងមិនសូវមានចំណាប់អារម្មណ៍ក្នុងការសិក្សា។ គេគ្រោងរៀបចំកម្មវិធីអន្តរាគមន៍នេះឡើង ក្នុងគោលបំណងដើម្បីកាត់បន្ថយបញ្ហាចម្បងរបស់សិស្សទាក់ទងនឹងការអប់រំ។ ទីពីរ ជារឿយៗ កម្មវិធីអន្តរាគមន៍ទាំងនេះតែងតែកំណត់ក្រុមកុមារគោលដៅតាមរយៈលក្ខណៈសម្គាល់ផ្សេងៗ ដូចជា យេនឌ័រ(កុមារី) ពិការភាព ឬបញ្ហាសុខភាព ឬការរស់នៅក្នុងតំបន់ជនបទ ឬនៅឆ្ងាយពីសាលារៀន ពីព្រោះលក្ខណៈសម្គាល់ទាំងនេះក៏អាចកំណត់បានថា កុមារទំនងជាបោះបង់សាលាកាន់តែច្រើនឡើង។ កម្មវិធីដែលគ្រោងរៀបចំសម្រាប់តំបន់ជាក់លាក់ណាមួយនោះត្រូវលើកឡើងពីកត្តានានាដែលមានសារៈសំខាន់សម្រាប់កុមារ និងគ្រួសារនៅក្នុងតំបន់នោះ។ នៅទីបញ្ចប់អន្តរាគមន៍នីមួយៗតម្រូវឲ្យមានការវាយតម្លៃ ដែលត្រូវបានធ្វើផែនការតាមវិធីសាស្ត្រច្បាស់លាស់ ក្នុងពេលដំណាលគ្នាដែលអន្តរាគមន៍នេះត្រូវបានពិចារណា និងត្រូវបានអនុវត្តឲ្យបានឆាប់រហ័ស និងដោយយកចិត្តទុកដាក់តាមតែអាចធ្វើទៅបាន។

## ១សេចក្តីផ្តើម ០.

### ១គោលបំណងនៃការពិនិត្យឡើងវិញ ១.

កម្មវិធីសាកល្បងទប់ស្កាត់សិស្សបោះបង់សាលា (SDPP) ត្រូវបានបង្កើតឡើងក្នុងគោលបំណងដើម្បីផ្តល់ការណែនាំ ផ្អែកលើភស្តុតាងដល់បេសកកម្មរបស់ទីភ្នាក់ងារសហរដ្ឋអាមេរិកដើម្បីអភិវឌ្ឍន៍អន្តរជាតិ (USAID) និងបណ្តាប្រទេសនានានៅអាស៊ី និងមជ្ឈឹមបូព៌ាស្តីពីការទប់ស្កាត់សិស្សបោះបង់សាលា ដោយសាកល្បងលើប្រសិទ្ធភាពនៃអន្តរាគមន៍ទប់ស្កាត់សិស្សបោះបង់សាលានៅក្នុងប្រទេសគោលដៅចំនួន៤ មានជាអាទិ៍ ប្រទេសកម្ពុជា ឥណ្ឌា តាជីគីស្ថាន និងទីម័រលែស។ នៅឆ្នាំដំបូងនៃគម្រោងនេះ បុគ្គលិកកម្មវិធីសាកល្បងទប់ស្កាត់សិស្សបោះបង់សាលានៅសហរដ្ឋអាមេរិក និងប្រទេសនីមួយៗក្នុងចំណោមប្រទេសទាំងបួននេះ ត្រូវធ្វើការពិនិត្យឡើងវិញលើឯកសារស្រាវជ្រាវកំណត់កម្មវិធីអន្តរាគមន៍ដែលត្រូវបានវាយតម្លៃលម្អិត ដើម្បីកាត់បន្ថយចំនួនសិស្សបោះបង់សាលា និងគ្រោងរៀបចំអន្តរាគមន៍ ដែលអាចនឹងទទួលបានជោគជ័យខ្ពស់បំផុតសម្រាប់ប្រទេសនីមួយៗ ក្នុងចំណោមប្រទេសគោលដៅទាំងនេះ។ ក្នុងរយៈពេលពីរឆ្នាំបន្ទាប់នៃគម្រោងនេះ បុគ្គលិកទាំងនេះត្រូវអនុវត្តគម្រោងទាំងនេះ និងវាយតម្លៃថា តើពួកគេនឹងទទួលជោគជ័យក្នុងការទប់ស្កាត់កុមារកុំឲ្យបោះបង់សាលា មុនពេលបញ្ចប់វដ្តអប់រំកម្រិតមូលដ្ឋានរបស់ពួកគេដោយរបៀបណា។

ការពិនិត្យឡើងវិញលើឯកសារស្រាវជ្រាវស្តីពីសិស្សបោះបង់សាលា នៅពេលចាប់ផ្តើមគម្រោងនៃកម្មវិធីសាកល្បងទប់ស្កាត់សិស្សបោះបង់សាលា មានគោលបំណងច្រើនយ៉ាង។ ទីមួយ មុនពេលគ្រោងរៀបចំគំនិតផ្តួចផ្តើមថ្មី អ្វីដែលសំខាន់នោះគឺត្រូវឈ្វេងយល់ឲ្យបានស៊ីជម្រៅអំពីបញ្ហាដែលត្រូវដោះស្រាយ និងអន្តរាគមន៍នានាដែលត្រូវបានសាកល្បងកន្លងមក។ ក្នុងកិច្ចខិតខំប្រឹងប្រែងដើម្បីកាត់បន្ថយលំហូរនៃសិស្សបោះបង់សាលានៅទូទាំងពិភពលោក អ្នកស្រាវជ្រាវទាំងនេះបានត្រួតពិនិត្យយ៉ាងជិតដល់លើលក្ខណៈសម្គាល់នៃកុមារដែលបោះបង់សាលា ក៏ដូចជាបរិបទនៃគ្រួសារ សហគមន៍ និងសាលារៀនរបស់ពួកគេ។ បន្ទាប់មក ពួកគេបានសាកល្បងកម្មវិធីសាកល្បងទប់ស្កាត់ប្រភេទផ្សេងៗគ្នា ដែលកម្មវិធីមួយចំនួនក្នុងចំណោមកម្មវិធីទាំងនេះ ទទួលបានជោគជ័យច្រើនជាងកម្មវិធីផ្សេងទៀត។ ការយល់ដឹងអំពីការស្រាវជ្រាវនេះនឹងណែនាំអំពីភារកិច្ចបន្ថែមទៀតនៅក្នុងកម្មវិធីសាកល្បងទប់ស្កាត់សិស្សបោះបង់សាលា។

ទីពីរ អ្នករៀបចំផែនការកម្មវិធីទាំងនេះកាន់តែមានការយល់ដឹងអំពីសារៈសំខាន់នៃការធ្វើសេចក្តីសម្រេចចិត្តលើគម្រោងនៃកម្មវិធី ផ្អែកលើភស្តុតាងច្បាស់លាស់អំពីប្រសិទ្ធភាពនៃគោលវិធីស្រដៀង

គ្នា។ ការពិនិត្យឡើងវិញនូវលទ្ធផលនៃការវាយតម្លៃលើអន្តរាគមន៍ ដែលប្រើប្រាស់បច្ចេកទេសវាយតម្លៃលម្អិត អាចប្រាប់អ្នករៀបចំគម្រោងជ្រើសរើសអំពីកត្តាបរិបទ ដើម្បីយកមកពិចារណានៅក្នុងគម្រោង ប្រភេទនៃសកម្មភាពដែលត្រូវអនុវត្តឲ្យបានសមស្របបំផុត និងប្រភេទនៃការបណ្តុះបណ្តាលដែលអ្នកអនុវត្តត្រូវការ ដើម្បីធ្វើឲ្យគម្រោងនេះមានប្រសិទ្ធភាព។

ទីបី ភាពជោគជ័យនៃគម្រោងនេះគឺជាការសំខាន់ ដែលអ្នកអនុវត្តត្រូវផ្សាភ្ជាប់សនិទានភាពរបស់ពួកគេ និងទទួលបាននូវការគាំទ្រដ៏ទូលំទូលាយនៅក្នុងបណ្តាប្រទេសនានា ដែលពួកគេកំពុងធ្វើការ។ ការផ្សព្វផ្សាយចំណេះដឹងនេះដល់អ្នកដទៃអំពីការផ្តល់សេវានៅក្នុងអន្តរាគមន៍ ការចំណាយផ្សេងៗ និងអានុភាពនេះអាចទាក់ទាញក្រុមមនុស្សសំខាន់ៗឲ្យគាំទ្រដល់កិច្ចខិតខំប្រឹងប្រែងក្នុងប្រទេស ដែលគេរំពឹងថានឹងមាននិរន្តរភាព នៅពេលដែលការផ្តល់មូលនិធិលើកដំបូងចប់។

ទីបួន ការពិនិត្យឡើងវិញនូវឯកសារស្រាវជ្រាវនេះអាចផ្តល់ការណែនាំដល់អ្នកបង្កើតគោលនយោបាយ អ្នករៀបចំគម្រោងកម្មវិធី និងអ្នកស្រាវជ្រាវផ្សេងទៀត នៅក្នុងប្រទេសជាច្រើន ដែលកំពុងព្យាយាមដោះស្រាយបញ្ហាប្រភេទដូចគ្នាចំពោះកុមារបោះបង់ការសិក្សា ដែលមិនបានបញ្ចប់វដ្តអប់រំកម្រិតមូលដ្ឋាន។ ការធ្វើសេចក្តីសង្ខេបអំពីការសិក្សាដែលត្រូវបានអនុវត្ត ការទាញយកគំនិតនៅក្នុងតារាងដែលងាយស្រួលដល់អ្នកប្រើប្រាស់ និងការបង្ហាញពីលទ្ធផលរកឃើញសំខាន់ៗ អាចជួយដល់អ្នកដទៃ នៅពេលដែលពួកគេរកឃើញវិធីដ៏ប្រសើរបំផុតដើម្បីជួយដល់កុមារនៅលើពិភពលោក។

## ១"សិស្សបោះបង់សាលា" និយមន័យនៃពាក្យ ២.

មុនពេលព្យាយាមពិនិត្យមើលអន្តរាគមន៍ទាំងនេះ យើងចាំបាច់ត្រូវយល់ជារួម អំពីពាក្យ "សិស្សបោះបង់សាលា" ដូចដែលគេយកមកប្រើនៅក្នុងគម្រោងសាកល្បងទប់ស្កាត់សិស្សបោះបង់សាលា(SDPP)នេះ។ វាពិតជាគ្មានការព្រមព្រៀងជាសាកលអំពីនិយមន័យនេះនោះទេ។ អង្គការយូណេស្កូ(២០០៥) ចាត់ទុកសិស្សបោះបង់សាលាថាជា "កុមារដែលបានចុះឈ្មោះចូលរៀន ក្រោយមកឈប់រៀន។" ដើម្បីពិចារណាឲ្យបានច្បាស់លាស់ថា កុមារទាំងនេះជាអ្នកណានោះ ការសំខាន់យើងត្រូវកំណត់ដោយយកចិត្តទុកដាក់ទៅលើ (ក)កម្រិតនៃការអប់រំនៅសាលារៀន និង(ខ) អ្វីដែលមានន័យថា "នៅរៀន"។

សំណើសុំបេសកកម្មការងារ សម្រាប់កម្មវិធីសាកល្បងទប់ស្កាត់សិស្សបោះបង់សាលា កំណត់សិស្សបោះបង់សាលាថាជា "សិស្សដែលមិនបានបញ្ចប់វគ្គអប់រំកម្រិតមូលដ្ឋានពេញលេញ នៅក្នុងប្រទេស" (ទំព័រទី២០) និងបញ្ជាក់ថា កម្មវិធីនេះត្រូវធ្វើការជាមួយកម្រិតអប់រំថ្នាក់បឋមសិក្សា និងមធ្យមសិក្សា ដោយកំណត់និយមន័យច្បាស់លាស់អំពីឆ្នាំនៃការអប់រំ ដែលនឹងត្រូវធ្វើការពិចារណា ក្នុងគោលបំណងដើម្បីសម្រេចថា តើត្រូវដាក់បញ្ចូលកម្មវិធីអប់រំក្រៅប្រព័ន្ធនៅក្នុងនិយមន័យអំពី "សាលារៀន" ដែរឬយ៉ាងណា កម្មវិធីសាកល្បងទប់ស្កាត់សិស្សបោះបង់សាលានឹងយកនិយមន័យតាមអង្គការយូណេស្កូ ដែលបញ្ជាក់ថា កុមារនៅក្នុងការអប់រំក្រៅប្រព័ន្ធត្រូវបានរាប់បញ្ចូលថា ជាកុមារដែល"នៅរៀន" នៅពេលដែលកម្មវិធីអប់រំក្រៅប្រព័ន្ធនោះត្រូវបានទទួលស្គាល់ថា មានតម្លៃស្មើនឹងការអប់រំថ្នាក់បឋមសិក្សាផ្លូវការ។

ដើម្បីពិចារណាថា តើសិស្សណា "នៅក្រៅសាលា" ហើយសិស្សណា "នៅរៀន"នោះ អង្គការយូណេស្កូកំណត់ក្រុមទីមួយនោះថា ជាកុមារដែល "មិនបានចូលរៀន ក្នុងអំឡុងឆ្នាំសិក្សាដែលមានបញ្ហា" ហើយចាត់ទុកក្រុមទីពីរថា ជាកុមារដែលបានចូលរៀនយ៉ាងហោចមួយថ្ងៃ។ ដូច្នេះ កុមារម្នាក់ត្រូវបានចាត់ទុកជា *សិស្សបោះបង់សាលា* ប្រសិនបើកុមារនោះបានចូលរៀនយ៉ាងតិចមួយថ្ងៃ ហើយបន្ទាប់មកឈប់រៀននៅឆ្នាំនោះ។ សមាគមស្រាវជ្រាវអំពីការទទួលបានការអប់រំ (CREATE ឆ្នាំ២០១០) បានពន្យល់ពីហេតុផលនោះថា:

(1) កុមារអាចឈប់រៀន ដោយសារតែតម្រូវការសេដ្ឋកិច្ចបណ្តោះអាសន្ន។ កុមារនោះអាចទៅដាំដំណាំ ឬប្រមូលផលដំណាំរយៈពេលមួយខែ នៅពេលណាមួយ ឬត្រូវបានបញ្ជូនទៅផ្ទះសាច់ញាតិ ឬបញ្ជូនទៅធ្វើការដើម្បីរកប្រាក់ ហើយពួកគេរំពឹងថានឹងវិលត្រឡប់មករៀនវិញ នៅក្នុងឆ្នាំដែលពួកគេបានបញ្ចប់ភារកិច្ចរបស់ខ្លួនរួចរាល់។

(2) កុមារមិនអាចចូលរៀនបន្ទាប់ពីមានហេតុការណ៍សំខាន់ៗ ដូចជា មរណភាពឪពុក/ ម្តាយ ឬចំណាកស្រុកនៃគ្រួសារ ប៉ុន្តែគេរំពឹងថា កុមារនោះនឹងវិលមករៀនវិញ ។

(3) កុមារដែលមិនបានចូលរៀនរយៈពេលយូរ ប្រហែលជាចង់វិលមករៀនវិញ ប៉ុន្តែពួកគេ "ហួសអាយុចូលរៀន"ទៅហើយ ជាហេតុនាំឲ្យពួកគេមានការខ្មាសអៀន ហើយនៅប្រទេសខ្លះ ពួកគេមិនត្រូវបានអនុញ្ញាតឲ្យចូលរៀន ដោយយោងតាមគោលនយោបាយរបស់ប្រទេសនោះ។

តាមរយៈការឈ្វេងយល់អំពីផ្លូវកុមារដើរដើម្បីបញ្ចប់ភាពនៅក្រៅសាលា និងការទទួលស្គាល់និយមន័យរបស់អង្គការយូណេស្កូស្តីពីការចូលរៀនរបស់កុមារ ក្នុងអំឡុងឆ្នាំសិក្សា កម្មវិធីសាកល្បង

ទប់ស្កាត់សិស្សបោះបង់សាលាអាចគ្រោងរៀបចំអន្តរាគមន៍ ដែលផ្លាស់ប្តូរទិសដៅរបស់កុមារ និង បញ្ជូនពួកគេឲ្យទៅរៀនវិញ។

## ១និងជ្រើសរើសអន្តរាគមន៍ វិធីសាស្ត្រនៃការពិនិត្យឡើងវិញ ៣.

ដើម្បីស្វែងរកឯកសារស្រាវជ្រាវមកពិនិត្យមើលឡើងវិញ បុគ្គលិកកម្មវិធីសាកល្បងទប់ស្កាត់សិស្សបោះបង់សាលាបានស្រាវជ្រាវរកឯកសារយោងសម្រាប់គម្រោងដែលទាក់ទងនឹង "សិស្សបោះបង់សាលា" "សិស្សអវត្តមានច្រើន" និង "សិស្សរៀនត្រួតថ្នាក់"។ ជម្រើសនៃ "សិស្សអវត្តមានច្រើន" ផ្តើមចេញពីនិយមន័យរបស់អង្គការយូណេស្កូ ផ្អែកលើវត្តមានជាក់ស្តែងរបស់កុមារនៅសាលារៀន ឬអវត្តមានពីសាលា ដើម្បីកំណត់អំពីស្ថានភាពរបស់កុមារនោះ។ ជួនកាល ការអវត្តមានច្រើនអាចស្មើនឹងបោះបង់សាលា ហើយដូចដែលបានពិភាក្សាចុងក្រោយនៅក្នុងរបាយការណ៍នេះ ជារឿយៗ វាជាបុព្វហេតុដែលនាំឲ្យសិស្សបោះបង់សាលាជារៀងរហូត។ ដូច្នេះ ការរៀនត្រួតថ្នាក់គឺជាបញ្ហាដែលសាលាត្រូវឆ្លើយតបឲ្យបានញឹកញាប់ទៅនឹងសិស្សដែលមិនសូវចូលរៀន ឬមិនបានចូលរៀនសោះ ហើយបញ្ហានេះក៏ជាបុព្វហេតុមួយដែលនាំឲ្យសិស្សបោះបង់សាលាផងដែរ។ កម្មវិធីសាកល្បងទប់ស្កាត់សិស្សបោះបង់សាលាក៏បានយកពាក្យ "សិស្សរៀនត្រួតថ្នាក់" នេះ មកប្រើប្រាស់ជាឃ្លាមួយនៅក្នុងការសិក្សាស្រាវជ្រាវផងដែរ។

បុគ្គលិករបស់កម្មវិធីនេះបានស្រាវជ្រាវអំពីការសិក្សាវាយតម្លៃ (ក) តាមប្រព័ន្ធអ៊ីនធើនែត (ខ) ទិន្នានុប្បវត្តិតាមបណ្ណាល័យ (គ) តាមវេបសាយរបស់អង្គការនានា នៅសហរដ្ឋអាមេរិក ពាក់ព័ន្ធនឹងបញ្ហាសិស្សបោះបង់សាលា (ឧ. What Works Clearinghouse, មជ្ឈមណ្ឌលជាតិទប់ស្កាត់សិស្សបោះបង់សាលា, មជ្ឈមណ្ឌលវិទ្យាល័យ) អង្គការអនុវត្តកម្មវិធីស្រដៀងគ្នានៅក្រៅប្រទេស (ឧ. OECD, CREATE, អង្គការយូណេស្កូ មូលនិធិកុមាររបស់អង្គការសហប្រជាជាតិ) និងអង្គការដែលអនុវត្ត និងវាយតម្លៃគម្រោងអប់រំអន្តរជាតិ (ឧ. បណ្ឌិត្យសភាដើម្បីអភិវឌ្ឍការអប់រំ, វិទ្យាស្ថានស្រាវជ្រាវអាមេរិក, ប្រព័ន្ធគ្រប់គ្រងអន្តរជាតិ, កម្មវិធីកែលម្អគុណភាពអប់រំ, ធនាគារពិភពលោក)។ បន្ទាប់មកបុគ្គលិកកម្មវិធីនេះបានពិនិត្យតាមដានទៅលើឯកសារយោងណាមួយនៅក្នុងឯកសារ និងរបាយការណ៍ទាំងនេះ។ ភាគច្រើន អ្វីដែលយើងបានរកឃើញនេះរៀបរាប់អំពីលក្ខណៈសម្គាល់សិស្សដែលបោះបង់សាលា ដូច្នេះដើម្បីវាយតម្លៃបន្ថែមទៅលើកម្មវិធីអន្តរាគមន៍សិស្សបោះបង់សាលា យើងក៏បានទាក់ទងអ្នកស្រាវជ្រាវដែលគេស្គាល់ថា បានធ្វើការវាយតម្លៃដើម្បីឲ្យប្រាកដថា យើងមានរបាយការណ៍ពេញលេញ និងថ្មីបំផុតអំពីគម្រោងទាំងអស់។ លើសពីនេះទៅទៀត យើងបានប្រគល់ភារកិច្ចឲ្យបុគ្គលិក

ក្នុងប្រទេសរបស់យើងដើម្បីស្វែងរកទិន្នន័យស្តីពីសិស្សបោះបង់សាលា និងស្រាវជ្រាវរកអត្ថបទនៅក្នុងប្រទេសរបស់ពួកគេ។

ដើម្បីជ្រើសរើសគោលវិធីអន្តរាគមន៍ប្រកបដោយប្រសិទ្ធភាព បុគ្គលិកកម្មវិធីសាកល្បងទប់ស្កាត់សិស្សបោះបង់សាលាបានជួបពិភាក្សាអស់រយៈពេលជិតមួយថ្ងៃ ដើម្បីពិនិត្យឡើងវិញនូវការវាយតម្លៃដ៏សំខាន់នីមួយៗ។ អន្តរាគមន៍ "ប្រកបដោយប្រសិទ្ធភាព" ដែលនឹងត្រូវជ្រើសរើសនេះ មានបំណងធ្វើឲ្យកុមារនៅរៀនបន្ត និងត្រូវបានវាយតម្លៃយ៉ាងលម្អិត។ អន្តរាគមន៍នីមួយៗត្រូវឆ្លើយតបទៅនឹងលក្ខណៈវិនិច្ឆ័យដូចខាងក្រោម៖

- *ភាពពាក់ព័ន្ធនៃប្រធានបទ/លទ្ធផល។* ការវាយតម្លៃនេះត្រូវរាប់បញ្ចូលខ្នាតវាស់ស្ទង់កុមារគ្រប់អាយុចូលរៀន ដែលនៅរៀន (ឧ. នៅរៀនរហូតដល់ចប់ឆ្នាំ ឬចុះឈ្មោះចូលរៀនជាថ្មីនៅឆ្នាំបន្ទាប់) រៀនបានរីកចម្រើននៅសាលា (ឧ. ឡើងថ្នាក់ ឬរៀនចប់ថ្នាក់ខ្ពស់បំផុតនៅក្នុង វដ្តអប់រំ) ឬការចូលរៀន (ឧ. មករៀនទៀតទាត់) រាល់សូចនាករទាំងអស់ដែលកុមារមិនបានបោះបង់ការសិក្សា។ អន្តរាគមន៍ជាច្រើនដើម្បីលើកកម្ពស់គុណភាពសាលារៀន ក៏អាចកាត់បន្ថយអត្រាសិស្សបោះបង់សាលា ប៉ុន្តែការសិក្សាលើកម្មវិធីបែបនេះនឹងត្រូវបានដាក់បញ្ចូលទៅក្នុងការពិនិត្យឡើងវិញនូវឯកសារស្រាវជ្រាវ ប្រសិនបើពួកគេវាស់វែងលទ្ធផលមួយក្នុងចំណោមលទ្ធផលបីដែលត្រូវបានបញ្ជាក់នោះ។

- *ភាពពាក់ព័ន្ធនៃគម្រោងពេលវេលា។* កម្មវិធីអន្តរាគមន៍នីមួយៗត្រូវតែធ្វើឡើងថ្មីៗឲ្យ បានគ្រប់គ្រាន់ ដើម្បីអាចយកមកអនុវត្តបាននៅឆ្នាំ២០១១ និងត្រូវបានវាយតម្លៃនៅចន្លោះឆ្នាំ១៩៩០ និងឆ្នាំ២០១០។

- *ការពាក់ព័ន្ធនៃគំរោង។* បន្ទាប់ពីមានការណែនាំពីទីភ្នាក់ងារសហរដ្ឋអាមេរិកដើម្បីអភិវឌ្ឍន៍អន្តរជាតិដល់កម្មវិធីសាកល្បងទប់ស្កាត់សិស្សបោះបង់សាលានេះមក អន្តរាគមន៍នេះត្រូវផ្តោតទៅលើសិស្សក្នុងសាលាដែលប្រឈមនឹងការបោះបង់ និង ត្រូវរៀបរាប់អំពីបរិបទ រយៈពេលនៃការអនុវត្តគម្រោង ការផ្តល់សេវា តម្រូវការការ បណ្តុះបណ្តាលបុគ្គលិក ហើយវិសេសវិសាលជាងនេះ គឺការចំណាយ។

- *ភាពពាក់ព័ន្ធនៃគម្រោងសិក្សាស្រាវជ្រាវ។* លក្ខណៈវិនិច្ឆ័យដែលត្រូវបានបង្កើតឡើងនៅក្នុងសៀវភៅ What Works Clearinghouse, ជាផ្នែកមួយនៃក្រសួងអប់រំនៅសហរដ្ឋអាមេរិក ដែលបានកំណត់ស្តង់ដារតឹងរ៉ឹងដើម្បីធ្វើការវាយតម្លៃលើប្រសិទ្ធភាពនៃកិច្ចខិតខំប្រឹងប្រែងកែទម្រង់សាលារៀន ការវាយតម្លៃលើអន្តរាគមន៍គឺ (ក)គម្រោង*ព្រាវៗប្រៀបធៀប*ក្រុមមិនទទួលអន្តរាគមន៍ពីគម្រោង/*ក្រុមទទួលអន្តរាគមន៍ពីគម្រោង* ឬ គម្រោងផ្អែកលើការពិសោធន៍ ដោយប្រើក្រុម*ទទួលអន្តរាគមន៍ពីគម្រោង* និងក្រុមប្រៀបធៀបសមស្របទៅនឹងទិន្នន័យមូលដ្ឋាន និងដោយឆ្លងកាត់អត្រាវិចវិលទាប ឬដោយប្រើគម្រោងបញ្ចប់ការថយចុះធៀបនឹងអត្រាវិចវិលទាប។

ការវាយតម្លៃ២៦ករណី ដែលឆ្លើយតបនូវរាល់លក្ខណៈវិនិច្ឆ័យទាំងអស់ ត្រូវបានចាត់ទុកជា "អន្តរាគមន៍ដែលត្រូវបានវាយតម្លៃលម្អិត" និងត្រូវបានពិភាក្សារយៈពេលវែងនៅក្នុងរបាយការណ៍នេះ ហើយត្រូវបានសង្ខេបនៅក្នុងឧបសម្ព័ន្ធ "គ"។ ការវាយតម្លៃ៨ករណីដែលមិនបានឆ្លើយតបទៅនឹងលក្ខណៈវិនិច្ឆ័យទាំងនេះ ក៏ត្រូវបានលើកយកមកបង្ហាញផងដែរ ប៉ុន្តែមិនត្រូវបានលម្អិតឲ្យបានស៊ីជម្រៅនោះទេ (សូមមើលឧបសម្ព័ន្ធ "ឃ")។

**គម្រោងវាយតម្លៃល្អិត**

នៅក្នុង *គម្រោង**ព្រាវៗប្រៀបធៀបក្រុមមិនទទួល**អន្តរាគមន៍ពីគម្រោង/ក្រុម**ទទួលអន្តរាគមន៍ពី**គម្រោង (RCT)* កុមារដែលមានសិទ្ធិចូលរួម ត្រូវបានចាត់តាំងនៅក្នុង ***ក្រុមទទួលអន្តរាគមន៍ពីគម្រោង*** ឬ ***ក្រុមមិនទទួលអន្តរាគមន៍**ពីគម្រោង* ដោយប្រើតារាងចំនួនព្រាវៗ ឬដោយដាក់បញ្ចូល និងចាត់តាំងកុមារផ្សេងទៀតនៅក្នុងក្រុមទទួលអន្តរាគមន៍ពីគម្រោង។ នៅក្នុង *គម្រោងផ្អែកលើ**ការពិសោធន៍** (QED)* អ្នកស្រាវជ្រាវប្រៀបធៀបសាលារៀន ឬកុមារ ដោយប្រើលក្ខណៈសម្គាល់ដែលពាក់ព័ន្ធ ឧទាហរណ៍ ពួកគេអាចអនុវត្តអន្តរាគមន៍នៅសាលារៀន និងជ្រើសរើសសាលារៀនដែលនៅក្បែរនោះដើម្បីធ្វើការប្រៀបធៀប ដោយធានាថា កុមារមាន លក្ខណៈសម្គាល់សារតា និងបទពិសោធន៍នៅសាលារៀនស្រដៀងគ្នា (គោលវិធី"ប្រៀបធៀបជាក្រុម")។ ជាទូទៅ *គម្រោងបញ្ចប់ការថយចុះ (RD)* ត្រូវបានប្រើ នៅពេលកុមារដែលមានសិទ្ធិចូលរួមក្នុងអន្តរាគមន៍ទាំងអស់ទទួលបានការអន្តរាគមន៍នោះ។ ដើម្បីកំណត់ក្រុមទទួលអន្តរាគមន៍ពីគម្រោង និងក្រុមប្រៀបធៀប អ្នកស្រាវជ្រាវប្រើប្រាស់កុមារ/គ្រួសារ ដែលមានពិន្ទុក្រោមគេ ប៉ុន្តែនៅជិតនឹងបន្ទាត់នៃភាពស្របច្បាប់ និងទទួលបានអន្តរាគមន៍ជា "ការចូលរួមសាកល្បង" និងអ្នកដែលមានពិន្ទុលើសគេ ប៉ុន្តែនៅ ជិតបន្ទាត់ និងមិនទទួលបានអន្តរាគមន៍ជា"ការប្រៀប ធៀប"។

## ១.៤ ការរៀបចំរបាយការណ៍

ឯកសារដែលនៅសល់ត្រូវបែងចែកជាបួនផ្នែក។ ផ្នែកទីពីរបង្ហាញពីស្ថានភាព ឬការបរិយាយអំពីលក្ខណៈសម្គាល់នៃកុមារ និងយុវជនដែលប្រឈមនឹងការបោះបង់សាលា។ ផ្នែកនេះចាប់ផ្តើមដោយការពិភាក្សាអំពីទំហំនៃបញ្ហាសិស្សបោះបង់សាលា បន្ទាប់មករៀបរាប់កត្តាហានិភ័យ ដែលតែងតែកើតមាននៅក្នុងឯកសារស្រាវជ្រាវនេះ ដើម្បីកំណត់ក្រុមកុមារដែលប្រឈមនឹងការបោះបង់សាលាមុនពេលបញ្ចប់ការសិក្សា។ គេអាចវាស់វែងកត្តាហានិភ័យមួយចំនួនក្នុងចំណោមកត្តាហានិភ័យទាំងនេះនៅសាលាបឋមសិក្សាមុនគេ ហើយកត្តាហានិភ័យផ្សេងទៀតអាចជាការសំខាន់ ពីព្រោះកុមារចូលរៀននៅឆ្នាំសិក្សាថ្នាក់អនុវិទ្យាល័យ ឬវិទ្យាល័យ។ ផ្នែកទីបីពិភាក្សាអំពីភស្តុតាងទាក់ទងនឹងកម្មវិធីអន្តរាគមន៍ ដោយលើកឡើងអំពីការចាត់ចំណាត់ថ្នាក់នៃកម្មវិធីអន្តរាគមន៍ដើម្បីទប់ស្កាត់សិស្សបោះបង់សាលា ដោយរៀបរាប់ថាការចាត់ចំណាត់ថ្នាក់នៅក្នុងកត្តាហានិភ័យ ដែលត្រូវបានលើកមកពិភាក្សានៅក្នុងផ្នែកទីមួយ ដោយពិនិត្យមើលកម្មវិធីអន្តរាគមន៍ប្រកបដោយប្រសិទ្ធភាពរយៈពេលវែង និងវាយតម្លៃលើកម្មវិធីដែលមិនបានឆ្លើយតបនូវរាល់លក្ខណៈវិនិច្ឆ័យលើការវាយតម្លៃទាំងនេះ។ ផ្នែកទីបួន ដាក់ចេញនូវអនុសាសន៍ស្តីពីគម្រោងអន្តរាគមន៍សិស្សបោះបង់សាលាដែលបានមកពីការសិក្សា

ស្រាវជ្រាវអំពីលក្ខណៈសម្គាល់នៃកុមារដែលបោះបង់សាលា និងអន្តរាគមន៍ដែលជួយទប់ស្កាត់សិស្សបោះបង់នេះ។

របាយការណ៍នេះមានបួនឧបសម្ព័ន្ធៈ (ក)តារាងបង្ហាញពីស្ថិតិអប់រំសំខាន់ៗប្រចាំប្រទេសនីមួយៗ ក្នុងចំណោមប្រទេសអនុវត្តកម្មវិធីសាកល្បងទប់ស្កាត់សិស្សបោះបង់សាលាទាំងបួន (ខ) តារាងបង្ហាញពីឯកសារស្រាវជ្រាវដែលពិភាក្សាអំពីកត្តាហានិភ័យផ្សេងៗគ្នាពាក់ព័ន្ធនឹងសិស្សបោះបង់សាលា (គ)តារាងបរិយាយអំពីអន្តរាគមន៍សិស្សបោះបង់សាលាដែលត្រូវបានវាយតម្លៃលម្អិតទាំង២៦ករណីបន្ទាប់មកមានសេចក្តីសង្ខេប១ទៅ២ទំព័រនិង (ឃ)តារាងបរិយាយអំពីអន្តរាគមន៍ទាំង៨ ដែលមិនបានឆ្លើយតបទៅនឹងលក្ខណៈវិនិច្ឆ័យលើការវាយតម្លៃលម្អិតនៃ កម្មវិធីសាកល្បងទប់ស្កាត់សិស្សបោះបង់សាលា។

## ២.០ ស្ថានភាព និងលក្ខណៈសម្គាល់កុមារនិងយុវជនប្រឈមនឹងការបោះបង់សាលា

## ២ទំហំនៃ ១.បញ្ហាសិស្សបោះបង់សាលា

ក្នុងរយៈពេលពីរទសវត្សរ៍កន្លងមកនេះ គំនិតផ្តួចផ្តើមអន្តរជាតិជាច្រើនបានផ្តោតទៅលើការផ្តល់ឱកាសឲ្យកុមារទទួលបានការអប់រំកម្រិតមូលដ្ឋានជាសាកល ហើយមានការរីកចម្រើនគួរឲ្យកត់សម្គាល់។ យោងតាមអង្គការយូណេស្កូ(ឆ្នាំ២០១០)បានឲ្យដឹងថា ចំនួនសរុបនៃកុមារនៅក្រៅសាលាបានធ្លាក់ចុះមកនៅត្រឹមប្រមាណ៣៨ភាគរយ ក្នុងរយៈពេល៦ឆ្នាំ ពោលគឺ ពី១១៥លាននាក់នៅឆ្នាំ ២០០១/០២ មកនៅត្រឹម៧១លាននាក់នៅឆ្នាំ២០០៧។ កុមារនៅក្រៅសាលាប្រហែល៤៤ភាគរយមិនដែលចូលរៀនទេ។ ក្នុងចំណោមកុមារដែលបានចូលរៀនពិតប្រាកដ៥៦ភាគរយ កុមារដែលប្រឈមនឹងការបោះបង់សាលាមុនពេលបញ្ចប់វដ្តអប់រំកម្រិតមូលដ្ឋាន ឬមិនបានចូលរៀននៅវដ្តបន្ទាប់គឺមានចំនួនច្រើន។

ទំហំនៃបញ្ហានេះមានលក្ខណៈខុសគ្នាតាមតំបន់ និងនៅក្នុងតំបន់។ នៅអនុតំបន់សាហារ៉ានៃប្រទេសអាហ្វ្រិក កុមារថ្នាក់បឋមសិក្សាដែលនៅក្រៅសាលាចំនួន៦៤ភាគរយទំនងជាមិនបានមកចុះឈ្មោះចូលរៀននោះទេ ចំណែកឯនៅអាស៊ី និងប៉ាស៊ីហ្វិកខាងកើត ខាងត្បូង និងខាងលិច កុមារនៅក្រៅសាលាតែ២០ ទៅ៣០ភាគរយទំនងជាមិនមកចុះឈ្មោះចូលរៀននោះទេ ប៉ុន្តែពួកគេបោះបង់សាលាដល់ទៅ៦០ភាគរយ។ ក្តីរំពឹងនៃការនៅរៀនបន្ត គឺមានតិចតួចនៅប្រទេសឥណ្ឌា ប៉ាគីស្ថាន បង់ក្លាដេស និងណេប៉ាល់ ពោលគឺ កុមារនៅក្រៅសាលា៧០ភាគរយនៅប្រទេសឥណ្ឌាបានបោះបង់សាលា ៥០ភាគរយនៅប្រទេសប៉ាគីស្ថាន និង៤០ភាគរយនៅប្រទេសបង់ក្លាដេស និងណេប៉ាល់។ នៅអាស៊ីកណ្តាលភាគរយនៃកុមារនៅក្រៅសាលាដែលគ្រប់អាយុចូលរៀនថ្នាក់បឋមសិក្សាបានបោះបង់សាលា (៣៨%) ច្រើនជាងមិនបានចុះឈ្មោះចូលរៀន(៣៥%) ឬចូលរៀនយឺត (២៧%)។

សម្រាប់ប្រទេសដែលផ្តោតទៅលើបេសកកម្មការងារ តារាងទី១បង្ហាញពីទិន្នន័យថ្មីបំផុតស្តីពីអត្រាពិតនៃការចូលរៀន (NER) ពីវិទ្យាស្ថានមូលដ្ឋានទិន្នន័យស្ថិតិនៃអង្គការយូណេស្កូ និងទិន្នន័យស្តីពីអត្រាសិស្សបោះបង់សាលាពីមូលដ្ឋានទិន្នន័យ EdStats នៃធនាគារពិភពលោក។ សូមសម្គាល់ថាទិន្នន័យនេះបានមកពីទិន្នន័យដែលអាចរកបាននៅឆ្នាំចុងក្រោយបង្អស់ ដែលមានលក្ខណៈខុសគ្នានៅតាមប្រទេសនីមួយៗ និងមូលដ្ឋានទិន្នន័យនៃប្រទេសនោះ។ ក្រុមនីមួយៗនៅក្នុងប្រទេសបានបង្ហាញពីលក្ខណៈខុសគ្នាពីរ នៃការចុះឈ្មោះចូលរៀន។ ម៉្យាងវិញទៀត កុមារនៅប្រទេសតាជីគីស្ថានស្ទើរតែទាំងអស់បានចុះឈ្មោះចូលរៀន ហើយកម្រនឹងឈប់រៀនក្នុងអំឡុងឆ្នាំសិក្សា (ថ្នាក់ទី១ ដល់ទី៩)។ អ

ត្រាពិតនៃការចូលរៀន (NER) ក្នុងឆ្នាំ២០០៨ គឺមានកុមារី៩៥ភាគរយ និងកុមារា៩៩ភាគរយស្ថិតនៅក្នុងក្រុមគ្រប់អាយុចូលរៀន។ ទោះបីជាស្ថិតិស្តីពីអត្រាសិស្សបោះបង់សាលាមិនអាចរកបានពីមូលដ្ឋានទិន្នន័យ EdStats ក៏ដោយ ក៏ប្រព័ន្ធគ្រប់គ្រងព័ត៌មានស្តីពីការអប់រំ(EMIS) នៅប្រទេសតាជីគីស្ថានឆ្នាំ២០០៩-១០ បានបង្ហាញថា អត្រាសិស្សបោះបង់សាលាថ្នាក់បឋមសិក្សាមានតិចជាង១ភាគរយសម្រាប់ថ្នាក់ទី១ ដល់ទី៤ និង៤ភាគរយសម្រាប់ថ្នាក់ទី៥ដល់ទី៩។ អត្រាពិតនៃការចូលរៀន (NER) នៅសាលាមធ្យមសិក្សា (ថ្នាក់ទី១០ និងទី១១) មានកុមារីចំនួន៧៧ភាគរយ និងកុមារាចំនួន៨៨ភាគរយ ហើយទិន្នន័យជាតិបានរាយការណ៍ថា អត្រាសិស្សបោះបង់សាលាថ្នាក់មធ្យមសិក្សាមានចំនួន៥ភាគរយ[1]។ ទោះបីជាអត្រាចុះឈ្មោះចូលរៀនទាំងនេះ ខ្ពស់សម្រាប់សាលាមធ្យមសិក្សានៅក្នុងបណ្តាប្រទេសកំពុងអភិវឌ្ឍក៏ដោយ ក៏វាជាការសំខាន់ផងដែរក្នុងការសម្គាល់ថា អត្រាចុះឈ្មោះចូលរៀនសម្រាប់កុមារីទាបជាងអត្រាចុះឈ្មោះចូលរៀនសម្រាប់កុមារា។ ដូច្នេះ កុមារភាគច្រើននៅប្រទេសតាជីគីស្ថានពិតជាបានមកចុះឈ្មោះចូលរៀន ហើយសាលារៀននៅទីនោះពិតជាធ្លាប់ជួបប្រទះបញ្ហាសិស្សបោះបង់សាលាមួយចំនួន ដែលបានកើតឡើងភាគច្រើនក្នុងអំឡុងឆ្នាំសិក្សាថ្នាក់មធ្យមសិក្សា នៅពេលនោះកុមារីទំនងជាបោះបង់សាលាច្រើនជាងកុមារា។

---

[1]អត្រាបោះបង់គណនាផ្អែកលើអត្រាចូលរៀនគ្រប់ថ្នាក់លើកលែងតែថ្នាក់ទី៩ ៕ថ្នាក់ទី៩ការបោះបង់ក្នុងថ្នាក់គឺ គណនាផ្អែកលើចំនួនសិស្សដែលរៀនចប់ថ្នាក់ទី៕ ៩

## តារាងទី១៖ ទិន្នន័យស្តីពីសិស្សបោះបង់សាលា[2]

| ប្រទេស | អត្រាពិតនៃការចូលរៀន នៅថ្នាក់បឋមសិក្សា | | អត្រាបោះបង់សាលា នៅថ្នាក់បឋមសិក្សា | | អត្រាពិតនៃការចូលរៀន នៅថ្នាក់មធ្យមសិក្សា | |
|---|---|---|---|---|---|---|
| | កុមារី | កុមារា | កុមារី | កុមារា | កុមារី | កុមារា |
| កម្ពុជា (2007) | 88% | 92% | 43% | 48% | 32% | 36% |
| ឥណ្ឌា (2005) | 87% | 91% | 35% | 34% | គ្មានទិន្នន័យ | គ្មានទិន្នន័យ |
| តាជីគីស្ថាន (2008) | 95% | 99% | គ្មានទិន្នន័យ | គ្មានទិន្នន័យ | 77% | 88% |
| ទីម័រលែស (2008) | 74% | 77% | 32% | 22% | 33%(2007) | 30% (2007) |

ម្យ៉ាងវិញទៀត ប្រទេសកម្ពុជា ឥណ្ឌា និងទីម័រលែស មានអត្រាពិតនៃការចូលរៀនទាបជាងសម្រាប់សាលាបឋមសិក្សា (ពី៧៤%នៃកុមារីនៅទីម័រលែសទៅនឹង៩២%នៃកុមារានៅកម្ពុជា) និងអត្រាសិស្សបោះបង់សាលាថ្នាក់មធ្យមសិក្សាខ្ពស់ជាងច្រើន (ពី២២%នៃកុមារានៅទីម័រលែស ទៅនឹង៤៨%នៃកុមារានៅកម្ពុជា) ដោយលើកឡើងពីការលំបាកជាច្រើនសម្រាប់ក្រុមកុមារតូចៗមួយចំនួនក្នុងការចូលរៀន ឬនៅរៀនបន្តនៅសាលាបឋមសិក្សា។ បន្ទាប់មក ប្រទេសកម្ពុជា និងទីម័រលែសបង្ហាញថា អត្រាពិតនៃការចូលរៀនសម្រាប់កុមារថ្នាក់មធ្យមសិក្សាទាបជាង អត្រាពិតនៃការចូលរៀននៅក្នុងប្រទេសតាជីគីស្ថាន ដោយមានប្រហែលតែមួយភាគបីប៉ុណ្ណោះបានចុះឈ្មោះចូលរៀន ដោយលើកឡើងថា កុមារមួយចំនួនតូចបានខិតខំរៀនរហូតដល់ចប់វគ្គអប់រំកម្រិតមូលដ្ឋាន។ ការបោះបង់សាលាគឺជាបញ្ហាចម្បងមួយនៅក្នុងប្រទេសទាំងនេះ ហើយបញ្ហាទាំងនេះចាប់ផ្តើមកើតមាននៅថ្នាក់បឋមសិក្សា និងមានការកើនឡើង នៅពេលដែលកុមារមានអាយុកាន់តែច្រើន។ (ដើម្បីបង្ហាញឲ្យកាន់តែច្បាស់ថែមទៀតអំពីទិន្នន័យទាំងនេះ សូមមើលឧបសម្ព័ន្ធ "ក")។

[2] អត្រាពិតនៃការចូលរៀន(NER) ទទួលបានពីមូលដ្ឋានទិន្នន័យនៃវិទ្យាស្ថានស្ថិតិរបស់ UNESCO, អត្រាបោះបង់បានមកពីទិន្នន័យស្ថិតិអភិវឌ្ឍវិស័យអប់រំរបស់ធនាគារពិភពលោក។ រាល់ព័ត៌មានទាំងអស់បង្ហាញពីស្ថិតិដែលអាចរកនៅឆ្នាំចុងក្រោយបង្អស់។

**២បង់សាលាកត្តាដែលមានទំនាក់ទំនងនឹងកុមារបោះ ២.**

ក្នុងការពិនិត្យមើលលក្ខណៈសម្គាល់នៃកុមារដែលបោះបង់សាលា វាមានប្រយោជន៍ក្នុងការពិនិត្យទៅលើការងារដ៏ច្រើនដែលគេបានធ្វើដើម្បីកុមារ និងយុវជននៅសហរដ្ឋអាមេរិក ពីព្រោះការស្រាវជ្រាវនេះមានលក្ខណៈលម្អិត និងទូលំទូលាយ ហើយនៅក្នុងករណីភាគច្រើនវាឆ្លើយតបទៅនឹងស្តង់ដារតឹងរ៉ឹងសម្រាប់គម្រោងស្រាវជ្រាវ និងការវិភាគ។ វាជាការសំខាន់ក្នុងការសម្គាល់ថា សិស្សបោះបង់សាលាភាគច្រើននៅសហរដ្ឋអាមេរិកគឺជាកុមារដែលរៀននៅថ្នាក់មធ្យមសិក្សា ពីព្រោះច្បាប់នៅប្រទេសនេះតម្រូវឲ្យកុមារគ្រប់រូបរៀនរហូតដល់អាយុយ៉ាងតិច១៦ឆ្នាំ ហើយច្បាប់នេះចែងថា ត្រូវជួលមន្ត្រីទទួលបន្ទុកសិស្សគេចសាលាឲ្យតាមដានកុមារដែលគេចសាលាឲ្យបានជាប្រចាំ។ ព័ត៌មាននេះអាចមានសារៈប្រយោជន៍នៅក្នុងបណ្តាប្រទេស ដែលបញ្ហាសិស្សបោះបង់សាលាផ្តោតលើកុមារធំៗ។

តារាងទី២សង្ខេបអំពីកត្តាហានិភ័យសំខាន់ៗស្តីពីការកុមារបោះបង់សាលា ដូចបានបង្ហាញនៅក្នុងឯកសារស្រាវជ្រាវរបស់សហរដ្ឋអាមេរិក និងឯកសារស្រាវជ្រាវពីប្រទេសផ្សេងទៀត។ ជាទូទៅកត្តាទាំងនេះបញ្ជាក់អំពីទិសដៅ ឬគុណភាពនៃលក្ខណៈសម្គាល់នីមួយៗទាក់ទងនឹងសិស្សបោះបង់សាលា។ ស្ទើរតែគ្រប់ករណីទាំងអស់ទៅហើយ ទំនាក់ទំនងអវិជ្ជមានរវាងកត្តាទាំងនេះ និងសិស្សបោះបង់សាលាគឺដូចគ្នាទាំងនៅប្រទេសអភិវឌ្ឍ និងប្រទេសកំពុងអភិវឌ្ឍ។ មានការលើកលែងមួយគឺយេនឌ័រ ៖ នៅសហរដ្ឋអាមេរិក និងបណ្តាប្រទេស OECD ដែលភាគច្រើនកុមារាបោះបង់សាលាច្រើនជាងកុមារី រីឯនៅប្រទេសកំពុងអភិវឌ្ឍវិញ កុមារីបោះបង់សាលាច្រើនជាងកុមារា។ ការសិក្សាច្បាស់លាស់ដែលមានបង្ហាញនៅក្នុងតារាងនេះត្រូវកត់ត្រានៅក្នុងតារាងឧបសម្ព័ន្ធ "ខ" ដើម្បីអាចនឹងកំណត់ច្បាស់លាស់ថា តើកត្តាហានិភ័យណាខ្លះត្រូវបានលើកយកមកពិភាក្សានៅក្នុងការសិក្សានីមួយៗ។ ដើម្បីឲ្យមានភាពងាយស្រួលក្នុងការបកស្រាយកត្តាហានិភ័យនៅក្នុងតារាងទាំងនេះត្រូវបានបែងចែកជា បួន "កត្តា" មានជាអាទិ៍ កត្តាផ្ទាល់ខ្លួន កត្តាគ្រួសារ កត្តាសាលារៀន និងកត្តាសហគមន៍ អាស្រ័យលើប្រភពនៃកត្តានោះ។ នៅក្នុងកត្តានីមួយៗ គេបែងចែកជាក្រុមទៅតាមអ្វីដែលមានបង្ហាញនេះ[3] ។

[3] គួរកត់សម្គាល់ថាអ្នកស្រាវជ្រាវម្នាក់ៗបានប្រើនិយមន័យខុសៗគ្នា ហេតុដូច្នេះហើយពាក្យពេចន៍នៅក្នុងតារាងពិតជាមិនដូចគ្នានឹងពាក្យពេចន៍នៅក្នុងអត្ថបទទេ។

កត្តា "ផ្ទាល់ខ្លួន" មានលក្ខណៈសម្គាល់សាវតា ដូចជា អាយុនៅពេលចុះឈ្មោះចូលរៀន និងយេនឌ័រ ទទួលខុសត្រូវលើកដំបូងដូចមនុស្សពេញវ័យនៅកន្លែងធ្វើការ និងនៅផ្ទះ ឥរិយាបថសង្គម តម្លៃ និងអាកប្បកិរិយា (ឧ. មិត្តណាខ្លះ ដែលសិស្សនោះមានទំនាក់ទំនងជាមួយ ហើយទំនាក់ទនងនោះមានលក្ខណៈយ៉ាងដូចម្តេច) លទ្ធផលសិក្សានៅសាលារៀន (ឧ. តើសិស្សនោះទទួលបានជោគជ័យក្នុងការសិក្សាយ៉ាងណាខ្លះ) ទំនាក់ទំនងនៅសាលារៀន (ឧ. ឋាមពល ឬការលើកទឹកចិត្ត ដែលកុមារបង្ហាញនៅសាលារៀន) និងឥរិយាបថសាលារៀន (ឧ. ស្ថានភាពសេដ្ឋកិច្ចសង្គមអន់ កម្រិតអប់រំរបស់ឪពុកម្តាយទាប) និងការវាស់វែងទំនាក់ទំនងគ្រួសារជាមួយសាលារៀន និងការប្តេជ្ញាចិត្តក្នុងការអប់រំកូនៗរបស់ពួកគាត់ (ឧ. ទំនាក់ទំនងតិចតួចជាមួយសាលារៀន ដោយគិតថាការអប់រំមិនសូវសំខាន់)។ កត្តា "សាលា រៀន" រួមមាន ផ្នែករចនាសម្ព័ន្ធ (ឧ. ផ្ទះរបស់កុមារនៅឆ្ងាយពីសាលារៀនពេក កង្វះអគារសិក្សា) និងផ្នែកមុខងារ (ឧ. គុណភាពបង្រៀននៅមានកម្រិត កង្វះភាពពាក់ព័ន្ធនៃកម្មវិធីសិក្សា)។ ជាចុងក្រោយនេះ កត្តា "សហគមន៍" រួមមាន កត្តារៀបរាប់អំពីតំបន់ដែលសាលារៀនទាក់ទាញសិស្សឲ្យមករៀន (ឧ. ទីក្រុង ឬជនបទ, ការកើតមានជម្លោះ ស្ថានភាពបន្ទាន់ ឬ ស្ថានភាពងាយប្រេះស្រាំផ្នែកនយោបាយ)។ ចំណុចដែលបញ្ជាក់ដោយអក្សរដិតខ្មៅនៅចន្លោះខាងស្តាំដៃទាំងពីរបង្ហាញពីកត្តានានា ដែលត្រូវបានដកស្រង់តាមរយៈការពិនិត្យឡើងវិញនូវអត្ថបទជាងមួយភាគបី។

**តារាងទី២ ៖ ចំនួន( ភាគរយ )នៃការសិក្សាដែលរកឃើញកត្តាហានិភ័យនីមួយៗថាជា ការរួមចំណែកនាំឲ្យសិស្សបោះបង់សាលា**

| កត្តា | សហរដ្ឋអាមេរិក និងប្រទេស OECD (N=16) | ប្រទេសកំពុងអភិវឌ្ឍ (N=26) |
|---|---|---|
| កត្តាផ្ទាល់ខ្លួន | | |
| *លក្ខណៈសម្គាល់សាវតាផ្ទាល់ខ្លួន* | | |
| • អាយុច្រើននៅពេលចុះឈ្មោះចូលរៀន (ហួសអាយុចូលរៀន) | -- | 5 (19%) |
| • យេនឌ័រ[4] | 3 (19%) – កុមារា | **9 (35%) – កុមារី** |
| • មានបញ្ហាពិការភាព/ឧស្សាហ៍ឈឺ | 5 (31%) | **12 (46%)** |
| *ការឆាប់ទទួលខុសត្រូវដូចមនុស្សពេញវ័យ* | | |
| • ចំណាយផ្នែកសេដ្ឋកិច្ច/ចំណាយឱកាស/ការងារ | 5 (31%) | **19 (73%)** |
| • អាពាហ៍ពិពាហ៍/ភាពជាឪពុកម្តាយ | 5 (31%) | 7 (27%) |
| *ឥរិយាបថ តម្លៃ និងអាកប្បកិរិយាក្នុងសង្គម* | | |
| • ក្រុមមិត្តភ័ក្តិសិស្សដែលប្រឈមនឹងការបោះបង់ខ្ពស់/ឥរិយាបថសង្គម | 4 (25%) | -- |
| • ការសរសើរដល់សិស្សឈប់រៀន | -- | 3 (12%) |
| *លទ្ធផលសិក្សានៅសាលារៀន* | | |
| • សមិទ្ធិផលទាប | **13 (81%)** | **9 (35%)** |
| • រៀនត្រួតថ្នាក់/ហួសអាយុចូលរៀន | **8 (50%)** | **10 (38%)** |
| *ទំនាក់ទំនងសាលារៀន* | | |
| • មិនសូវចូលរៀន | **11 (69%)** | 8 (31%) |
| • ក្តីរំពឹងតិចតួចទៅលើការអប់រំ | 3 (19%) | -- |
| • ខ្វះការប្តេជ្ញាចិត្តក្នុងការសិក្សា/មិនសូវមានចំណាប់អារម្មណ៍លើការសិក្សា | **9 (56%)** | **10 (38%)** |
| *ឥរិយាបថសាលារៀន* | | |
| • ឥរិយាបថមិនល្អ/ឥរិយាបថមិនគប្បី | **8 (50%)** | 2 (8%) |
| | | |

[4] នៅសហរដ្ឋអាមេរិក និងបណ្តាប្រទេស OECD ជារឿយៗ កុមារាបោះបង់ការសិក្សាច្រើនដោយឡែកប្រទេសកំពុងអភិវឌ្ឍកុមារីបោះបង់ច្រើនជាង។

| កត្តា | សហរដ្ឋអាមេរិក និងប្រទេស OECD (N=16) | ប្រទេសកំពុងអភិវឌ្ឍ (N=26) |
|---|---|---|
| កត្តាគ្រួសារ | | |
| *លក្ខណៈសម្គាល់សាវតាគ្រួសារ* | | |
| • ស្ថានភាពសេដ្ឋកិច្ចសង្គមអន់/ទាប | **8 (50%)** | **19 (73%)** |
| • ក្រុមជនជាតិភាគតិច/វណ្ណៈ/ភាសា | 4 (25%) | 7 (27%) |
| • កម្រិតអប់រំរបស់ឪពុកម្ដាយទាប | 4 (25%) | **12 (46%)** |
| • មិនបានរស់នៅជាមួយឪពុកម្ដាយបង្កើតរបស់ខ្លួន | 6 (38%) | 7 (27%) |
| • ឪពុកម្ដាយគ្មានការងារធ្វើ | 2 (13%) | 4 (15%) |
| • មានបងប្អូនបង្កើតច្រើន ជាពិសេស អាយុក្រោម០៥ឆ្នាំ | 3 (19%) | 5 (19%) |
| • ការរំខានក្នុងគ្រួសារ (ឧ. ការលែងលះគ្នា ឬមរណភាព) | 4 (25%) | 5 (19%) |
| • គ្រួសារចល័តច្រើន | **6 (38%)** | 7 (27%) |
| *ទំនាក់ទំនងគ្រួសារ/ការប្ដេជ្ញាចិត្តក្នុងការអប់រំ* | | |
| • បងប្អូនបង្កើតបានបោះបង់សាលា | 3 (19%) | -- |
| • មិនសូវមានទំនាក់ទំនងជាមួយសាលា | **6 (38%)** | 2 (8%) |
| • គិតថា ការអប់រំមិនសូវសំខាន់ | 4 (25%) | 5 (19%) |
| | | |
| កត្តាសាលារៀន | | |
| *រចនាសម្ព័ន្ធ* | | |
| • ការចុះឈ្មោះចូលរៀនច្រើន | 3 (19%) | -- |
| • ដង់ស៊ីតេសិស្សច្រើនសម្រាប់អ្នកចំណូលទាប និងជនជាតិភាគតិច | 3 (19%) | -- |
| • សាលារៀននៅឆ្ងាយ/សាលារៀនមានតិចតួច | 1 (6%) | **11 (42%)** |
| • ខ្វះអគារសិក្សា (ឧ. បង្គន់) និងសម្ភារៈផ្សេងៗ | -- | 4 (15%) |
| • ខ្វះសាលារៀនក្រោយបឋមសិក្សា | -- | 2 (8%) |
| *ផ្នែកមុខងារ* | | |
| • "គុណភាព" សាលារៀនកាន់តែអន់ | 1 (6%) | 6 (23%) |
| • គ្មានសុវត្ថិភាព (ឧ. ក្រុមក្មេងទំនើង ឬទណ្ឌកម្មរាងកាយ) | 3 (19%) | 6 (23%) |
| • គុណភាពបង្រៀនអន់/គ្រូអវត្តមានច្រើន | -- | 5 (19%) |
| • មិនសូវមានទំនាក់ទំនងជាមួយមនុស្សពេញវ័យនៅសាលារៀន | 4 (25%) | -- |
| • ភាសាអប់រំមិនមែនជាភាសាកំណើតរបស់កុមារ | 1 (6%) | 3 (12%) |

| កត្តា | សហរដ្ឋអាមេរិក និងប្រទេស OECD (N=16) | ប្រទេសកំពុងអភិវឌ្ឍ (N=26) |
|---|---|---|
| • កង្វះភាពពាក់ព័ន្ធនៃកម្មវិធីសិក្សា | 4 (25%) | 3 (12%) |
| • កង្វះការយកចិត្តទុកដាក់ក្នុងការបង្រៀន | 6 (38%) | -- |
| | | |
| កត្តាសហគមន៍ | | |
| • តំបន់ទីក្រុង/ជនបទ | -- | 1 (4%) |
| • ជនបទ | -- | 8 (31%) |
| • ប្រជាពលរដ្ឋក្រីក្រ ជនជាតិភាគតិច ការកើតនៅក្រៅស្រុក/ឬនៅបរទេស មានតែឪពុក ឬម្តាយ ឬឪពុកម្តាយដែលមានការអប់រំទាបមានចំនួនច្រើន | 3 (19%) | 1 (4%) |
| • ការកើតមានជម្លោះ ស្ថានភាពបន្ទាន់ ភាពផុយស្រួយនៃនយោបាយ | -- | 4 (15%) |
| • សញ្ញាណវប្បធម៌នៃពិធីប្រារព្ធបែបសាសនា ដែលត្រូវធ្វើមុនពេលចូលសិក្សា | -- | 2 (8%) |

នៅសហរដ្ឋអាមេរិក និងបណ្តាប្រទេស OECD មានកម្រងកត្តាផ្សេងៗគ្នា ក្នុងការកំណត់កុមារដែលប្រឈមនឹងការបោះបង់សាលា។ កុមារទាំងនេះជាអ្នកទទួលបានជោគជ័យតិចតួច ដោយភាគច្រើនរៀនត្រួតថ្នាក់ មករៀនមិនបានទៀងទាត់ ហាក់ដូចជាមិនសូវមានចំណាប់អារម្មណ៍ ឬការប្តេជ្ញាចិត្តក្នុងការសិក្សា ហើយភាគច្រើនគឺពាក់ព័ន្ធនឹងបញ្ហាផ្នែកវិន័យ។ ជារឿយៗ ពួកគេមកពីគ្រួសារក្រីក្រ គ្រួសារចល័ត និងមិនបានរស់នៅជាមួយឪពុកម្តាយបង្កើតរបស់ខ្លួន ហើយឪពុកម្តាយរបស់ពួកគេមិនសូវមានទំនាក់ទំនងជាមួយសាលារៀន។ នៅពេលដែលគេសួរ ពួកគាត់អះអាងថា គ្រូមិនសូវយកចិត្តទុកដាក់ក្នុងការបង្រៀន។ ដូច្នេះ នៅពេលដែលក្រុមហ៊ុន ឬអង្គការអភិវឌ្ឍពិចារណាលើគម្រោងអន្តរាគមន៍នានា ក្រុមហ៊ុន ឬអង្គការនោះគួរតែផ្តោតទៅលើការបង្កើនការចូលរួម និងសមិទ្ធិផល និងកែលម្អឥរិយាបថ។

នៅបណ្តាប្រទេសកំពុងអភិវឌ្ឍ រូបភាពនេះមើលទៅហាក់ដូចមានលក្ខណៈខុសគ្នាខ្លះៗ។ កត្តាចម្បងពីរដែលពិតជាមាននៅក្នុងការសិក្សា៧៣ភាគរយ គឺបម្រែបម្រួលសេដ្ឋកិច្ច។ កត្តាទីមួយស្ថិតក្នុងកត្តាគ្រួសារ គឺភាពក្រីក្រនៃគ្រួសារ និងកត្តាមួយទៀតស្ថិតក្នុងកត្តាផ្ទាល់ខ្លួនគឺតម្រូវឲ្យកុមាររកប្រាក់ ឬធ្វើកិច្ចការផ្ទះ។ សារៈសំខាន់នៃក្តីកង្វល់ផ្នែកហិរញ្ញវត្ថុ និងការពិតថាជារឿយៗ ពួកគាត់រារាំងកុមារមិន

ឲ្យទៅរៀនជាពិសេសនៅបណ្តាប្រទេសកំពុងអភិវឌ្ឍ ដូច្នេះវាទំនងជាសមហេតុផលដែលអ្នករៀបចំគម្រោងអន្តរាគមន៍គួរតែសម្រេចចិត្តដោយផ្ទាល់ ដើម្បីដោះស្រាយបញ្ហាតម្រូវការហិរញ្ញវត្ថុ។ ក្តីកង្វល់ហិរញ្ញវត្ថុបន្ទាប់មកទៀតគឺចំណុចមួយចំនួនដែលត្រូវបានលើកឡើងជាញឹកញាប់។ កុមារនៅក្នុងប្រទេសកំពុងអភិវឌ្ឍដែលទំនងជាបោះបង់ការសិក្សាបណ្តាលមកពីលទ្ធផលសិក្សាខ្សោយ ត្រូវរៀនត្រួតថ្នាក់ ឬហួសអាយុចូលរៀន ហើយពួកគេក៏បានបង្ហាញពីកង្វះការប្តេជ្ញាចិត្តក្នុងការសិក្សា និងកង្វះការចាប់អារម្មណ៍។ លើសពីនេះទៅទៀត សិស្សបោះបង់សាលានៅបណ្តាប្រទេសកំពុងអភិវឌ្ឍភាគច្រើនគឺជាកុមារី, មានពិការភាព ឬឈឺញឹកញាប់ មានឪពុកម្តាយដែលមានការអប់រំតិចតួច និងទៅរៀននៅសាលាដែលនៅឆ្ងាយពីផ្ទះពីផ្ទះ។ ប៉ុន្តែគួរកត់សម្គាល់ផងដែរថា ឯកសារស្រាវជ្រាវស្តីពីសិស្សបោះបង់សាលានៅបណ្តាប្រទេសកំពុងអភិវឌ្ឍ មិនបានគូសបញ្ជាក់ពីបញ្ហាឥរិយាបថ ដែលគេឃើញមានក្នុងចំណោមសិស្សប្រឈមនឹងការបោះបង់សាលានៅសហរដ្ឋអាមេរិកនិងបណ្តាប្រទេស OECD[5] ។

នៅក្នុងឯកសារស្រាវជ្រាវពីគ្រប់បណ្តាប្រទេសទាំងអស់ មានការព្រមព្រៀងជាទូទៅថា ការបោះបង់សាលាគឺជាដំណើរការមួយ ឬហេតុការណ៍មួយ ដែលសិស្សអាចចាប់ផ្តើមបោះបង់លើកដំបូងនៅថ្នាក់បឋមសិក្សា ហើយមិនបានមករៀនវិញជារៀងរហូត (Hunt ឆ្នាំ២០០៨)។ នៅសហរដ្ឋអាមេរិកមជ្ឈមណ្ឌលជាតិទប់ស្កាត់សិស្សបោះបង់សាលា(Hammond, 2007) បានកំណត់ហានិភ័យនានាដែលកើតមានចំពោះកុមារថ្នាក់បឋមសិក្សា មធ្យមសិក្សា និងវិទ្យាល័យ។ លទ្ធផលរកឃើញរបស់ពួកគេមានបង្ហាញនៅក្នុងតារាងទី៣។ **កូឡោនទំនេរ**មួយសម្រាប់ក្រុមដែលមានអាយុដូចគ្នាមានន័យថា កត្តានេះមិនត្រូវបានបង្ហាញនៅក្នុងការសិក្សាណាមួយដែលមានសារៈសំខាន់នៅក្នុងស្ថិតិ, លេខ “១” មានន័យថា ការសិក្សាមួយបានរកឃើញកត្តាសំខាន់ៗ និងសញ្ញា “*” មានន័យថា យ៉ាងហោចណាស់ការសិក្សាពីរករណីបានរកឃើញថា កត្តានេះមានសារៈសំខាន់។

ពីតារាងនេះ យើងអាចឃើញថា ហេតុផលនៃសិស្សបោះបង់សាលាមានលក្ខណៈខុសៗគ្នា។ យ៉ាងហោចណាស់ការសិក្សាពីរករណីបានបង្ហាញថា កុមារថ្នាក់បឋមសិក្សាដែលជាអ្នកទទួលជោគជ័យតិចតួច បានរៀនត្រួតថ្នាក់ ឬហួសអាយុចូលរៀន ឬអវត្តមានច្រើន និងកុមារមកពីគ្រួសារក្រីក្រ

---

[5] បញ្ហាឥរិយាបថអាចកើតមាននៅប្រទេសកំពុងអភិវឌ្ឍផងដែរ។ គ្រូបង្រៀននៅប្រទេសជាច្រើនប្រើទណ្ឌកម្មរាងកាយទៅលើការប្រព្រឹត្តខុសឆ្គង ហើយការលំបាកមួយចំនួនរបស់សិស្សក៏អាចដូចគ្នានឹងអ្វីដែលបានលើកឡើងនៅសហរដ្ឋអាមេរិកផងដែរ។

ទំនងជាបោះបង់សាលាច្រើនជាង ប៉ុន្តែលក្ខណៈសម្គាល់ផ្សេងទៀត ដូចជា អានុភាពពីមិត្តភក្តិ ឬការប្តេជ្ញាចិត្តក្នុងគ្រួសារចំពោះការអប់រំមិនទាន់មានលក្ខណៈស៊ីសង្វាក់គ្នានៅឡើយ។ ការទទួលខុសត្រូវលើកដំបូងរបស់មនុស្សពេញវ័យ អានុភាពពីមិត្តភក្តិ និងទំនាក់ទំនងគ្រួសារជាមួយនឹងការអប់រំកាន់តែមានការពាក់ព័ន្ធ នៅពេលដែលកុមារគ្រប់អាយុចូលរៀន។ ដូច្នេះសម្រាប់អ្នករៀបចំគម្រោងអន្តរាគមន៍អ្វីដែលសំខាន់នោះ គឺត្រូវដោះស្រាយកត្តាហានិភ័យ ដែលពាក់ព័ន្ធនឹងការគ្រប់អាយុចូលរៀនរបស់សិស្ស ។

**តារាងទី៣ ៖ កត្តាហានិភ័យសំខាន់ៗនៅកម្រិតសាលា( សម្រាប់សហរដ្ឋអាមេរិកប៉ុណ្ណោះ )**[6]

| កត្តាហានិភ័យ | ថ្នាក់ K-៥ | ថ្នាក់ទី ៦-៨ | ថ្នាក់ទី ៩-១២ |
|---|---|---|---|
| *លក្ខណៈសម្គាល់សារតាផ្ទាល់ខ្លួន* | | | |
| • មានបញ្ហាអសមត្ថភាពក្នុងការរៀនសូត្រ ឬការរំខានផ្លូវចិត្ត | | 1 | 1 |
| *ការឆាប់ទទួលខុសត្រូវដូចមនុស្សពេញវ័យ* | | | |
| • ធ្វើការច្រើនម៉ោង | | 1 | * |
| • ភាពជាឪពុកម្តាយ | | | * |
| ឥរិយាបថ តម្លៃ និងអាកប្បកិរិយាសង្គម | | | |
| • ក្រុមសិស្សដែលប្រឈមនឹងការបោះបង់ខ្ពស់ | | * | 1 |
| • ឥរិយាបថសង្គមដែលមានហានិភ័យខ្ពស់ | | * | 1 |
| • សិស្សនៅក្រៅសាលាមានចំនួនច្រើនក្នុងសង្គម | | | 1 |
| *លទ្ធផលសិក្សានៅសាលារៀន* | | | |
| • លទ្ធផលសិក្សាទាប | * | * | * |
| • រៀនត្រួតថ្នាក់/ហួសអាយុចូលរៀន | * | * | * |
| *ទំនាក់ទំនងសាលារៀន* | | | |
| • ការចូលរួមខ្សោយ | * | * | * |
| • ក្តីរំពឹងតិចតួចទៅលើការអប់រំ | | * | * |
| • មិនសូវខិតខំប្រឹងប្រែង | | 1 | 1 |

[6] មណ្ឌលជាតិទប់ស្កាត់សិស្សបោះបង់សាលានៅទំព័រទី៦កត់សម្គាល់ថា ។ កត្តាហានិភ័យមានតែលក្ខណៈសម្គាល់ផ្ទាល់ខ្លួន និង គ្រួសារហើយកត្តាទាំងនោះមានការខុសប្លែកខ្លះ ៗពីតារាងទី១។

| កត្តាហានិភ័យ | ថ្នាក់ K-៥ | ថ្នាក់ទី ៦-៨ | ថ្នាក់ទី ៩-១២ |
|---|---|---|---|
| • មិនសូវប្តេជ្ញាចិត្តក្នុងការសិក្សា | | 1 | * |
| • គ្មានការចូលរួមក្នុងការកម្មវិធីសិក្សាបន្ថែម | | 1 | * |
| *ឥរិយាបថសង្គម* | | | |
| • ឥរិយាបថមិនល្អ | 1 | 1 | * |
| • ការបំពានមកលើអ្នកផ្សេង | 1 | 1 | |
| *លក្ខណៈសម្គាល់សាវតាគ្រួសារ* | | | |
| • ស្ថានភាពសេដ្ឋកិច្ចសង្គមអន់ | * | * | * |
| • ចល័តភាពខ្ពស់ក្នុងគ្រួសារ | | * | |
| • ឪពុកម្តាយមានកម្រិតអប់រំទាប | 1 | 1 | * |
| • មានបងប្អូនបង្កើតច្រើន | 1 | | 1 |
| • មិនបានរស់នៅជាមួយឪពុកម្តាយបង្កើតរបស់ខ្លួន | 1 | 1 | * |
| • ការរំខានក្នុងគ្រួសារ | 1 | | |
| *ទំនាក់ទំនងគ្រួសារ/ការប្តេជ្ញាចិត្តចំពោះការអប់រំ* | | | |
| • ក្តីរំពឹងតិចតួចទៅលើការអប់រំ | | * | |
| • បងប្អូនបានបោះបង់សាលា | | 1 | 1 |
| • មិនសូវមានទំនាក់ទំនងជាមួយសាលារៀន | | * | |
| • មិនសូវពិភាក្សាអំពីសាលារៀន | | * | 1 |

កំណត់សម្គាល់៖ លេខ“១” បង្ហាញថា កត្តាហានិភ័យត្រូវបានគេរកឃើញថាមានទំនាក់ទំនងចម្បងទៅនឹងសិស្សបោះបង់សាលា នៅកម្រិតសាលារៀននេះនៅក្នុងការសិក្សាមួយ ហើយ សញ្ញា * បង្ហាញថាកត្តាហានិភ័យត្រូវបានគេរកឃើញថាមានទំនាក់ទំនងចម្បងទៅនឹងសិស្សបោះបង់សាលា នៅកម្រិតសាលារៀននេះនៅក្នុងការសិក្សាពីរ ឬច្រើន។

**៣អន្តរាគមន៍ដើម្បីទប់ ០.ស្កាត់សិស្សបោះបង់សាលា**

**៣ការបែងចែកប្រភេទអន្តរាគមន៍ ១.**

ស្របគ្នាទៅនឹងហេតុផលចម្បងជាច្រើនស្តីពីកុមារដែលបោះបង់សាលា យើងមានកម្មវិធីដ៏ច្រើន ដែលត្រូវបានគ្រោងរៀបចំធ្វើឡើង ដើម្បីទប់ស្កាត់សិស្សបោះបង់សាលា។ អន្តរាគមន៍ទាំងនេះមានចាប់ពីសកម្មភាពសាមញ្ញ ដូចជា ការផ្តល់ជំនួយហិរញ្ញវត្ថុដល់គ្រួសារក្រីក្រតាមរយៈអាហារូបករណ៍ ឬការផ្ទេរប្រាក់ ដើម្បីបរិយាយលម្អិតអំពីកម្មវិធីដែលមានអន្តរាគមន៍ច្រើនទាក់ទងនឹងការផ្លាស់ប្តូរការសិក្សា សង្គម/ផ្ទាល់ខ្លួន និងរចនាសម្ព័ន្ធ។ ឧទាហរណ៍អំពីប្រភេទទីពីរនៃកម្មវិធីស្មុគស្មាញគឺ *ការបង្កើនសាលាមធ្យមសិក្សា* ដែលត្រូវបានអនុវត្តនៅសហរដ្ឋអាមេរិក ក្នុងគោលបំណងលើកទឹកចិត្តឲ្យកុមាររៀនបន្តនៅថ្នាក់បន្ទាប់ ដោយដាក់ពួកគេឲ្យរៀននៅក្នុងថ្នាក់ដែលមានសិស្សតិច និងរ៉ាប់រងលើកម្មវិធីសិក្សារយៈពេលពីរឆ្នាំនៅក្នុងឆ្នាំសិក្សាមួយ ដោយបង្រៀនគួបន្ថែមដល់សិស្សបន្ទាប់ពីរៀនចប់ ដើម្បីជួយពួកគេក្នុងការសិក្សាអំពីឯកសារនេះ ផ្តល់ការប្រឹក្សាយោបល់អំពីបញ្ហាសង្គម និងផ្ទាល់ខ្លួន និង មានទំនាក់ទំនងជាមួយគ្រួសារ។

ជាទូទៅ គេអាចបង្ហាញអន្តរាគមន៍ទាំងនេះតាមរយៈសកម្មភាពប្រាំប្រភេទ ដែលប្រភេទនីមួយៗដោះស្រាយបញ្ហាប្រភេទខុសគ្នា។

- អន្តរាគមន៍*ផ្នែកសិក្សា* ដោះស្រាយបញ្ហាលទ្ធផលសិក្សារបស់សិស្សដោយផ្ទាល់ តាម រយៈការបង្កើនកម្មវិធីសិក្សា ដើម្បីឆ្លើយតបទៅនឹងតម្រូវការរបស់សិស្ស ផ្តល់ការបង្រៀនគួបន្ថែម ឬបញ្ចូលជាមួយថ្នាក់ពិសេស (ឧ. ការរៀនកុំព្យូទ័រ ជំនាញដោះ ស្រាយបញ្ហា)។
- អន្តរាគមន៍*ហិរញ្ញវត្ថុ* ព្យាយាមសម្រាលបន្ទុកចំណាយលើការសិក្សា ឬតម្លៃឱកាសរបស់សិស្សដើម្បីឲ្យពួកគេនៅបន្តការសិក្សា ជាជាងឲ្យពួកគេនៅផ្ទះ ឬធ្វើការដើម្បីរកប្រាក់។
- អន្តរាគមន៍*ផ្នែកសុខភាព* ផ្អែកទៅលើការសន្មតថា កុមារមិនអាចរៀនសូត្រឲ្យបានពូកែនោះទេ ប្រសិនបើពួកគេមានបញ្ហាផ្នែកសុខភាព ពីព្រោះវាប៉ះពាល់ដល់សមត្ថភាពរបស់ពួកគេក្នុងការផ្តោតការយកចិត្តទុកដាក់ក្នុងការសិក្សា ឬនាំឲ្យពួកគេអវត្តមានច្រើន ដូច្នេះយើងអាចផ្តល់ថ្នាំវ៉ាក់សាំង ថ្នាំកម្ចាត់ដង្កូវព្រូន ឬចិញ្ចឹមកុមារទាំងនោះ។
- អន្តរាគមន៍*ផ្ទាល់ខ្លួន/សង្គម* លើកឡើងពីឥរិយាបថ តម្លៃ ឬស្ថានភាពផ្ទាល់ខ្លួន ដែលរារាំងដល់ការរៀនសូត្ររបស់កុមារ ដោយប្រើបច្ចេកទេសបែបនេះដើម្បីគ្រប់គ្រងករណីដ៏ទូលំទូលាយ

ការប្រឹក្សាយោបល់ ក្រុមពិភាក្សាជាមួយមិត្តភក្តិ កម្មវិធីផ្សព្វផ្សាយតាមគ្រួសារ កម្មវិធីចុះកម្មសិក្សា ឬការបណ្តុះបណ្តាលដោយបុគ្គលិកសាលា។

- អន្តរាគមន៍*រចនាសម្ព័ន្ធ* ផ្លាស់ប្តូរគោលនយោបាយ ដែលទំនងជាជ្រៀតជ្រែកដល់ការចូលរៀន ការរៀនបានរីកចម្រើន ឬការបញ្ចប់ការសិក្សារបស់សិស្ស ដោយបង្កើតគោលនយោបាយបែបនេះជាកាលវិភាគសាលាដែលអាចផ្លាស់ប្តូរបាន ដើម្បីសម្រួលដល់ចម្ងាយធ្វើដំណើរទៅកាន់សាលារៀន ឬរដូវដាំដុះ ការឡើងថ្នាក់ដោយស្វ័យប្រវត្តិ ការតម្រូវឲ្យប្រើប្រាស់ភាសាកំណើតរបស់កុមារជាភាសាអប់រំនៅសាលាបឋមសិក្សា ឬផ្តល់អំណាចដល់ក្រុមឪពុកម្តាយ-គ្រូបង្រៀនដើម្បីពិនិត្យមើលការចូលរៀន និងគុណភាពសាលា។

តារាងទី៤ បង្ហាញពីការព្យាយាមរៀបចំកត្តាហានិភ័យជាមួយនឹងអន្តរាគមន៍ដ៏មានសក្តានុពល។ ផ្នែកនៃកត្តាហានិភ័យទាំងនេះគឺសញ្ញាសម្គាល់តាមជួរនៅជាប់នឹងប្រភេទអន្តរាគមន៍ដែលលើកឡើងពីផ្នែកកត្តាហានិភ័យ និងសកម្មភាពគំរូតាង។ ចូរកត់សម្គាល់ថា នៅក្នុងករណីភាគច្រើន អន្តរាគមន៍ច្រើនប្រភេទអាចមានសារៈប្រយោជន៍ក្នុងការដោះស្រាយបញ្ហា។ ឧទាហរណ៍ នៅពេលដែលគេឲ្យកុមារទទួលយកការទទួលខុសត្រូវដូចមនុស្សពេញវ័យ អន្តរាគមន៍នេះអាចសម្រាលការទទួលខុសត្រូវទាំងនេះបាន តាមរយៈការចេញប្រាក់ជួសកុំឲ្យកុមារនោះទៅធ្វើការ (អន្តរាគមន៍ហិរញ្ញវត្ថុ) ឬបង្កើតមណ្ឌលថែទាំកុមារនៅក្នុងសាលា (អន្តរាគមន៍រចនាសម្ព័ន្ធ)។

## តារាងទី៤ ៖ ទំនាក់ទំនងរវាងកត្តាហានិភ័យ និងប្រភេទអន្តរាគមន៍

| ផ្នែកនៃកត្តាហានិភ័យ | ប្រភេទអន្តរាគមន៍ | ឧទាហរណ៍ |
|---|---|---|
| *បុគ្គល* | | |
| លក្ខណៈសម្គាល់សាវតាបុគ្គល | ផ្នែកសិក្សា<br>សុខភាព<br>ផ្ទាល់ខ្លួន/សង្គម | ការបង្រៀនគួរដល់កុមារី<br>ការកម្ចាត់ដង្កូវព្រូន<br>ការតស៊ូមតិសម្រាប់កុមារពិការ |
| ការឆាប់ទទួលខុសត្រូវដូចមនុស្សពេញវ័យ | ហិរញ្ញវត្ថុ<br>រចនាសម្ព័ន្ធ | អហារូបករណ៍<br>ការថែទាំកុមារនៅសាលារៀន |
| ឥរិយាបថ តម្លៃ និងអាកប្បកិរិយាសង្គម | ផ្ទាល់ខ្លួន/សង្គម | ការបណ្តុះបណ្តាល |
| លទ្ធផលសិក្សានៅសាលារៀន | ផ្នែកសិក្សា | កម្មវិធីសិក្សារយៈពីរឆ្នាំនៅក្នុង ឆ្នាំប្រក្រតិទិន |
| ទំនាក់ទំនងសាលារៀន | ហិរញ្ញវត្ថុ<br>ផ្ទាល់ខ្លួន/សង្គម | ការផ្ទេរប្រាក់<br>ការប្រឹក្សាយោបល់ |
| ឥរិយាបថសាលារៀន | ផ្ទាល់ខ្លួន/សង្គម | ការគ្រប់គ្រងទិន្នន័យដ៏ទូលំទូលាយ |
| *គ្រួសារ* | | |
| លក្ខណៈសម្គាល់សាវតាគ្រួសារ | ផ្នែកសិក្សា<br>ហិរញ្ញវត្ថុ<br>ផ្ទាល់ខ្លួន/សង្គម | កម្មវិធីអក្ខរកម្មសម្រាប់មនុស្សពេញ វ័យ<br>អាហារសម្រាប់គ្រួសារ<br>ការបញ្ជូនទៅរកសេវា |
| ទំនាក់ទំនងគ្រួសារទៅនឹងការអប់រំ | ផ្ទាល់ខ្លួន/សង្គម | ការពង្រឹងសមាគមឪពុកម្តាយ និងគ្រូបង្រៀន |
| *សាលារៀន* | | |
| រចនាសម្ព័ន្ធ | រចនាសម្ព័ន្ធ | កែលម្អអគារសិក្សា |
| ចំណុចអន្តរាគមន៍ | រចនាសម្ព័ន្ធ | បង្រៀនជាភាសាកំណើតរបស់កុមារ |
| *សហគមន៍:* គ្មានអន្តរាគមន៍ត្រួតស៊ីគ្នា ហើយកត្តាទាំងនេះគួរតែត្រូវបានទទួលស្គាល់ថា ជាបរិបទសម្រាប់អន្តរាគមន៍។ | | |

តារាងនេះរាយនាមអន្តរាគមន៍ទាំងប្រាំប្រភេទ សំដៅចំពោះកត្តាហានិភ័យនៅក្នុងកត្តា*ផ្ទាល់ខ្លួន*។ តារាងនេះបង្ហាញហេតុផលត្រឹមត្រូវ ពីព្រោះកត្តាទាំងនេះត្រូវបានបង្ហាញជាសាកលថា ជាការ

ព្យាករណ៍ដ៏សំខាន់អំពីការបោះបង់សាលា ហើយកុមារគឺជា "បុគ្គល" ដែលសាលាត្រូវយកចិត្តទុកដាក់ដោយផ្ទាល់ និងគ្រប់គ្រងឲ្យបានល្អជាទីបំផុត។ ឧទាហរណ៍:

- អន្តរាគមន៍ផ្នែកសិក្សាអាចទទួលបានជោគជ័យក្នុងការធ្វើឲ្យកម្រិតនៃលទ្ធផលសិក្សារបស់កុមារប្រសើរឡើង
- អន្តរាគមន៍អាចមានន័យថា កុមារអាចចូលរៀនទៀតទាត់ និងទទួលបានជោគជ័យ ក្នុងការសិក្សាយ៉ាងឆាប់រហ័ស
- អន្តរាគមន៍ហិរញ្ញវត្ថុមិនអាចអនុញ្ញាតឲ្យគ្រួសារប្រើកុមារដើម្បីរកប្រាក់ចំណូលនោះទេ
- អន្តរាគមន៍ផ្ទាល់ខ្លួន/សង្គមដោយមនុស្សពេញវ័យអាចសម្រាលការលំបាកនៅផ្ទះ និង
- ការផ្លាស់ប្តូររចនាសម្ព័ន្ធ ដូចជា លុបចោលគោលនយោបាយស្តីពីការរៀនធ្លាក់ដោយស្វ័យប្រវត្តិចំពោះការអវត្តមានពីការសិក្សា ក្នុងអំឡុងរដូវប្រមូលផល អាចជួយឲ្យកុមារនៅរៀនតទៅមុខទៀត។

អន្តរាគមន៍បីប្រភេទលើកឡើងពីកត្តាហានិភ័យ*ក្នុងគ្រួសារ* ប៉ុន្តែ ឧទាហរណ៍លើកឡើងថា អន្តរាគមន៍បែបនេះអាចធ្វើការទប់ស្កាត់សិស្សបោះបង់សាលាដោយប្រយោល។ អន្តរាគមន៍ផ្នែកសិក្សាតាមរយៈការផ្តល់កម្មវិធីអក្ខរកម្មសម្រាប់មនុស្សពេញវ័យ អាចមានប្រយោជន៍ដល់ឪពុកម្តាយសិស្ស ប៉ុន្តែ មិនត្រូវឲ្យមានអានុភាពខ្លាំងទៅលើកុមារនោះទេ។ អន្តរាគមន៍ផ្នែកហិរញ្ញវត្ថុតាមរយៈការបញ្ជូនស្បៀងអាហារដល់ផ្ទះ នឹងមិនអាចកាត់បន្ថយភាពក្រីក្រក្នុងគ្រួសារបានទេ ហើយកុមារដែលបាន "ទទួល" អាហារមិនអាចមានឱកាសទទួលទានអាហារនោះទេ។ ខណៈពេលដែលឪពុកម្តាយសិស្សមានជម្រើសប្រើប្រាស់ការបញ្ជូននោះ អន្តរាគមន៍ផ្ទាល់ខ្លួន/សង្គមតាមរយៈការផ្តល់ការបញ្ជូនទៅរកសេវាអាច ឬមិនអាចដំណើរការបានទេ។

មានតែអន្តរាគមន៍រចនាសម្ព័ន្ធទេដែលមានបំណងផ្លាស់ប្តូរ*សាលារៀន* រួមមានការរៀបចំ និងការចូលរួមសាកល្បង ។ សកម្មភាពនានាដូចជា ការបែងចែកសិស្សជាសហគមន៍រៀនសូត្រតូចៗ ការផ្តោតកម្មវិធីសិក្សាទៅលើមុខរបរ ឬការងារ ការកែលម្អអគារសិក្សា ឬការដោះស្រាយបញ្ហាគ្រូអវត្តមានច្រើន អាចធ្វើឲ្យសិស្សកាន់តែមានចំណាប់អារម្មណ៍ និងរៀនបានលទ្ធផលល្អប្រសើរ និងទប់ស្កាត់ពួកគេមិនឲ្យបោះបង់សាលា។ ជាទូទៅ អន្តរាគមន៍ទាំងនេះមិនចង់ផ្លាស់ប្តូរអន្តរាគមន៍ក្នុង*សហគមន៍*នោះទេ (ឧ. ទីក្រុង/ជនបទ ចំណូលទាប ឬ ចល័តភាពខ្ពស់) ប៉ុន្តែទទួលយកអន្តរាគមន៍ទាំងនេះថា ជា

"អន្តរាគមន៍ដែលគេបានផ្តល់" ជាផ្នែកមួយនៃបរិបទ និងធ្វើឲ្យប្រាកដថា អន្តរាគមន៍នេះមានលក្ខណៈសមស្រប។

**៣លទ្ធផលនៃការវាយតម្លៃ ២.លម្អិតអំពីកម្មវិធីអន្តរាគមន៍សិស្សបោះបង់សាលា**
**៣ការជ្រើសរើសអន្តរាគមន៍ ១.២.**

ខណៈពេលដែលអន្តរាគមន៍ជាច្រើនដោះស្រាយបញ្ហាសិស្សបោះបង់សាលា ការពិនិត្យឡើងវិញនូវឯកសារស្រាវជ្រាវនៃកម្មវិធីសាកល្បងទប់ស្កាត់សិស្សបោះបង់សាលា (SDPP) បានរកឃើញតែ ២៦ករណី ដែលត្រូវបានវាយតម្លៃលម្អិតដើម្បីធានាថា ប្រសិទ្ធភាពនេះអាចត្រូវបានគេសន្មតថា ជាលទ្ធផលនៃអន្តរាគមន៍។ ដូចដែលបានពន្យល់ខាងដើមមកអញ្ចឹង លក្ខណៈវិនិច្ឆ័យលើប្រសិទ្ធភាពមានដូចខាងក្រោមៈ

- *ភាពពាក់ព័ន្ធនៃប្រធានបទ*- វាស់វែងការចូលរៀន ការនៅរៀន ឬការរីកចម្រើនក្នុងការសិក្សារបស់សិស្ស
- *ភាពពាក់ព័ន្ធនៃគម្រោងពេលវេលា* - បានអនុវត្ត និងវាយតម្លៃនៅចន្លោះឆ្នាំ១៩៩០ និង ២០១១
- *ភាពពាក់ព័ន្ធនៃគំរូតាង* - ផ្តោតទៅលើសិស្សនៅក្នុងសាលាដែលប្រឈមនឹងការបោះបង់សាលា
- *ភាពពាក់ព័ន្ធនៃគម្រោងសិក្សាស្រាវជ្រាវ* - ប្រើប្រាស់គម្រោងព្រាវៗប្រៀបធៀបក្រុមមិនទទួលអន្តរាគមន៍ពីគម្រោង/ក្រុមទទួលអន្តរាគមន៍ពីគម្រោង គម្រោងផ្អែកលើការពិសោធន៍ជាមួយនឹងក្រុមទទួលអន្តរាគមន៍ពីគម្រោង និងក្រុមប្រៀបធៀបដែលសមាមាត្រនឹងមូលដ្ឋានព័ត៌មាន ឬគម្រោងបញ្ចប់ការថយចុះ។ គម្រោងទាំងអស់នេះមានអត្រាវិចវិលទាប។

ចូរកត់សម្គាល់ថា ទោះបីជាលក្ខណៈវិនិច្ឆ័យទាំងនេះធានាថា អន្តរាគមន៍ត្រូវបានវាយតម្លៃយ៉ាងលម្អិតក៏ដោយ ក៏លក្ខណៈវិនិច្ឆ័យទាំងនេះមិនធានាបានថា កម្មវិធីនេះមាន*ប្រសិទ្ធភាព*នោះដែរ។ លទ្ធផលនៃការវាយតម្លៃទាំងនេះនៅតែអាចនិយាយបានថា អន្តរាគមន៍មិនបានបង្កើនចំនួនសិស្សចូលរៀន កាត់បន្ថយសិស្សបោះបង់សាលា ឬជួយឲ្យកុមាររៀនបានរីកចម្រើននៅសាលារៀននោះទេ។ លទ្ធផលរកឃើញដែលត្រូវបានពិភាក្សាខាងក្រោមនេះ បង្ហាញពីលក្ខណៈខុសគ្នា ដែលគេបានរកឃើញថាវាមានប្រសិទ្ធភាព។

តារាងទី៥ រាយនាម និងបរិយាយខ្លីៗអំពីអន្តរាគមន៍ទាំង២៦ករណី ដែលបានឆ្លើយតបទៅនឹងលក្ខណៈវិនិច្ឆ័យទាំងអស់។ អន្តរាគមន៍ដែលត្រូវបានអនុវត្តនៅសហរដ្ឋអាមេរិកមានរាយនាមតាមលំដាប់អក្ខរក្រមនៃចំណងជើងកម្មវិធីអន្តរាគមន៍ ហើយអន្តរាគមន៍ដែលត្រូវបានអនុវត្តនៅបណ្តាប្រទេសកំពុងអភិវឌ្ឍ មានរាយនាមតាមលំដាប់អក្ខរក្រមនៃឈ្មោះរបស់ប្រទេសនីមួយៗ។ តារាងបរិយាយលម្អិត និងសេចក្តីសង្ខេបដែលមានពីរទំព័រស្តីពីអន្តរាគមន៍នីមួយៗមានបង្ហាញនៅក្នុងឧបសម្ព័ន្ធ "ខ"។

## តារាងទី៥ ៖ បញ្ជីរាយនាមអន្តរាគមន៍ដែលត្រូវបានវាយតម្លៃលម្អិត

| សហរដ្ឋអាមេរិក | បណ្តាប្រទេសកំពុងអភិវឌ្ឍ |
|---|---|
| *ការបង្កើនសាលាមធ្យមសិក្សា៖* ការសិក្សាស្រាវ ជ្រាវដ៏ទូលំទូលាយនៅក្នុងថ្នាក់ដែលមានសិស្សតិចដោយប្រឹក្សាយោបល់ជាមួយគ្នា (Dynarski et al., 1998) | ប្រទេសប្រេស៊ីល *បុលសា ហ្វាមីលា:* ការផ្ទេរប្រាក់ (Glewwe & Kassouf, 2010) |
| | Burkina Faso, *BRIGHT*: កសាង និងបំពាក់ឧបករណ៍ថ្មីៗដល់សាលារៀន ប្រមូលផ្តុំសហគមន៍ ផ្តល់ធញ្ញជាតិដល់គ្រួសារដើម្បីយកទៅដាំ និងសម្ភារៈ សាលារៀន អាហារថ្ងៃត្រង់ប្រចាំថ្ងៃ និងបណ្តុះបណ្តាលដល់សិស្ស (Levy et al., 2009) |
| *សមិទ្ធិផលសម្រាប់ប្រជាពលរដ្ឋអាមេរិកឡាទីន តាមភាពជោគជ័យនៃការសិក្សា(ALAS):* ជំនាញដោះស្រាយបញ្ហា ការគ្រប់គ្រងករណី (Larson & Rumberger, 2005) | ប្រទេសកម្ពុជា: អាហារូបករណ៍ (Filmer & Schady, 2009) |
| | ប្រទេសកូឡុំប៊ី: ការផ្ទេរប្រាក់មានល័ក្ខខ័ណ្ឌ (Barrera-Osorio et al., 2008) |
| *បណ្ឌិត្យសភាការងារ:* ការងារដែលត្រូវបានរៀប ចំក្នុងអំឡុងបំពេញការងារ "សាលារៀននៅក្នុង សាលារៀន" ការចុះកម្មសិក្សា (Kemple & Snipes, 2000; Kemple, 2004) | ប្រទេសកូឡុំប៊ី, *PACES*: សក្ខីបត្រសម្រាប់បង់ថ្លៃសិក្សានៅសាលាឯកជន ល័ក្ខខ័ណ្ឌស្តីពីការរីកចម្រើននៅសាលារៀន (Angrist et al., 2002) |
| | ប្រទេសហង់ឌូរ៉ាស *PRAF*: ការផ្ទេរប្រាក់មានល័ក្ខខ័ណ្ឌ (Glewwe & Olinto, 2004) |
| *គ្រូតពិនិត្យ និងទំនាក់ទំនង:* ការបង្រៀនគួរ ការគ្រប់គ្រងករណី (Sinclair et al., 1998, 2005) | ប្រទេសឥណ្ឌា: បង្កើនការចូលរួមពីគ្រូបង្រៀន (Duflo et al., 2010) |
| | ប្រទេសឥណ្ឌា: ការបង្រៀនគួរ ឬការរៀនកុំព្យូទ័រ (Banerjee et al., 2007) |
| *វិទ្យាល័យអភិវឌ្ឍជំនាញ:* កម្មវិធីសិក្សាត្រៀមចូលមហាវិទ្យាល័យ ថ្នាក់ដែលមានសិស្សតិច សេវាគាំទ្រ (Kemple et al., 2005) | ប្រទេសចាម៉ៃកា *PATH*: ការផ្ទេរប្រាក់មានល័ក្ខខ័ណ្ឌ (Levy & Ohls, 2007) |
| | ប្រទេសកេនយ៉ា: បង់ថ្លៃឯកសណ្ឋានសាលារៀន អន្តរាគមន៍មេរោគអេដស៍/ជម្ងឺអេដស៍ (Duflo et al., 2006) |
| | ប្រទេសកេនយ៉ា: ផ្តល់ប្រាក់បន្ថែមដល់គ្រូដែលបង្រៀនឲ្យសិស្សប្រឡងបានពិន្ទុខ្ពស់ (Glewwe et al., 2003) |
| *ធ្វើការរួមគ្នា:* ជួយកិច្ចការដែលគ្រូដាក់ឲ្យធ្វើ, ក្រុមពិភាក្សា | ប្រទេសកេនយ៉ា: ផ្តល់សៀវភៅសិក្សាដល់សាលារៀន (Glewwe et al., 2007) |

| សហរដ្ឋអាមេរិក | បណ្តាប្រទេសកំពុងអភិវឌ្ឍ |
|---|---|
| (Dynarski et al., 1998) | ប្រទេសកេនយ៉ា: តាមដានកម្មវិធីអាហារូបករណ៍សម្រាប់កុមារី (Friedman et al., 2011) |
| | ប្រទេសកេនយ៉ា: ការកម្ចាត់ដង្កូវព្រូន (Miguel & Kremer, 2004) |
| | ប្រទេសម៉ាដាហ្កាស្កា: ឧបករណ៍ប្រតិបត្តិ និងការបណ្តុះបណ្តាលដល់រដ្ឋបាល គ្រូបង្រៀន និងឪពុកម្តាយ (Duflo et al. 2008) |
| | ប្រទេសម៉ាឡាវី: ការផ្ទេរប្រាក់មានល័ក្ខខ័ណ្ឌ (Baird et al., 2010) |
| | ប្រទេសម៉ិចស៊ីកូ *PROGRESA*: ការផ្ទេរប្រាក់មានល័ក្ខខ័ណ្ឌ (Schultz, 2000) |
| | ប្រទេសណេប៉ាល់: ការចែកចាយផលិតផលអនាម័យរបស់ស្ត្រី (Oster & Thornton, 2009) |
| | ប្រទេសប៉ាគីស្ថាន: ការផ្ទេរប្រាក់មានល័ក្ខខ័ណ្ឌដល់កុមារី (Chaudhury & Parajuli, 2006) |
| | ប្រទេសហ្វីលីពីន: សម្ភារៈសិក្សា ឬការផ្តល់អាហារដល់សាលារៀន ដោយមាន ឬមិនមានភាពជាដៃគូរវាងឪពុកម្តាយ និងគ្រូបង្រៀន (Tan et al., 1999) |

## ៣ការបរិយាយអំពីអន្តរាគមន៍ដែលត្រូវបានវាយតម្លៃលម្អិត ២.២.

តារាងទី៦បង្ហាញពីការចាត់ថ្នាក់កម្មវិធីដែលត្រូវបានវាយតម្លៃលម្អិត ដោយបង្ហាញនូវព័ត៌មានស្តីពីក្រុមគោលដៅ វិធីសាស្ត្រ និងប្រភេទសេវាដែលត្រូវបានដាក់បញ្ចូល។[7]កម្មវិធីសិស្សបោះបង់សាលានៅសហរដ្ឋអាមេរិក មានលក្ខណៈខុសគ្នាពីកម្មវិធីនៅប្រទេសផ្សេងទៀតនៅក្នុងក្រុមគោលដៅសម្រាប់អន្តរាគមន៍ និងនៅក្នុងប្រភេទសេវាដែលគេបានផ្តល់ ប៉ុន្តែ មានលក្ខណៈស្រដៀងគ្នានឹងវិធី សាស្ត្រនៃការវាយតម្លៃ ពោលគឺ កម្មវិធីនៅសហរដ្ឋអាមេរិក ផ្តោតទៅលើសិស្សសាលាមធ្យមសិក្សា និងវិទ្យាល័យ ចំណែកឯកម្មវិធីដែលត្រូវបានអនុវត្តនៅប្រទេសផ្សេងផ្តោតទៅលើសិស្សថ្នាក់បឋមសិក្សា និងមធ្យមសិក្សាជាគោលដៅរបស់ខ្លួន។ នេះអាចដោយសារតែកុមារត្រូវគេតម្រូវឲ្យចូលរៀន រហូតដល់យ៉ាងតិចអាយុ១៦ឆ្នាំនៅសហរដ្ឋអាមេរិក ដូច្នេះពួកគេមិនអាចបោះបង់សាលានៅថ្នាក់បឋមសិក្សាបានឡើយ ចំណែកឯនៅប្រទេសកំពុងអភិវឌ្ឍវិញមិនបានតម្រូវឲ្យពួកគេរៀនរហូតដល់អាយុ១៦ឆ្នាំបែបនេះទេ។ គម្រោងព្រាវៗប្រៀបធៀបក្រុមមិនទទួលអន្តរាគមន៍ពីគម្រោង/ក្រុមទទួលអន្តរាគមន៍ពីគម្រោងគឺវិធីសាស្ត្រវាយតម្លៃដ៏ល្អមួយនៅគ្រប់តំបន់ទាំងអស់ ដោយហេតុតែគម្រោងទាំងនេះមានសមត្ថភាពខ្លាំងក្លាក្នុងការបង្ហាញពីភាពខុសប្លែកគ្នានៃអានុភាពទៅលើក្រុមសិស្សដូចគ្នា។

[7] ឧបសម្ព័ន "គ" បញ្ចូលព័ត៌មានទាក់ទិននឹងការចំណាយលើអន្តរាគមន៍ ប៉ុន្តែទិន្នន័យដែលត្រូវបានផ្តល់នេះអាចសង្ខេបបានតែចំណាយផ្ទាល់លើផលិតផល ឬសេវាកម្ម .ឧ)ចំនួននៃការចំណាយលើអាហារូបករណ៍ ឬការផ្ទេរប្រាក់ដល់គ្រួសារថ្លៃចំណាយសុខភាព ឬឯកសណ្ឋានសិស្ស( ដែលជាផ្នែកតូចមួយនៃខ្ទង់ចំណាយកម្មវិធីសរុប។ មានន័យថាមិនបានរាប់បញ្ចូលថ្លៃរដ្ឋបាលបថ្លៃប្រតិនិងតិ្តការការ មានដូចជាប្រាក់ខែ គ្រប់គ្រងលើការផ្ទេរប្រាក់ ការកន្លែងសម្រាប់គ្រួសារដែលប្តូរទីលំនៅការបណ្តុះបណ្តាលគ្រូបង្រៀន ការបង្កើតគណៈកម្មការគ្រប់គ្រងសាលាថ្លៃចំណាយការធ្វើដំណើររបស់ គ្រូពេទ្យក្នុងការព្យាបាល ជម្ងឺ ។ ព័ត៌មានអំពីការចំណាយគឺមិនអាចប្រៀបធៀបទៅនឹងគម្រោងឬ មិនមានប្រយោជន៍ក្នុងការកំណត់ការចំណាយលើគម្រោងនាពេលខាងមុខ។

## តារាងទី៦ ៖ ការបែងចែកប្រភេទនៃកម្មវិធីអន្តរាគមន៍សិស្សបោះបង់សាលា ដែលត្រូវបានវាយតម្លៃលម្អិត

| លក្ខណៈសម្គាល់ | ចំនួនកម្មវិធីសិស្សបោះបង់សាលា | |
|---|---|---|
| | ស.រ.អ (N=6) | អន្តរជាតិ(N=20) |
| ក្រុមគោលដៅ[8] | | |
| • សាលាបឋមសិក្សា/សាលាក្រោមបឋមសិក្សា(ថ្នាក់ទី១-៥) | 0 (0%) | **13 (65%)** |
| • សាលាមធ្យមសិក្សា/លើបឋមសិក្សា (ថ្នាក់ទី៦-៨) | **4 (66%)** | **13(65%)** |
| • វិទ្យាល័យ/សាលាមធ្យមសិក្សា(ថ្នាក់ទី៩-១២) | 3 (50%) | 5(25%) |
| វិធីសាស្ត្រ | | |
| • គម្រោងព្រាវៗប្រៀបធៀបក្រុមមិនទទួលអន្តរាគមន៍ពីគម្រោង/ក្រុមទទួលអន្តរាគមន៍ពីគម្រោង | **5 (83%)** | **14(70%)** |
| • គម្រោងផ្អែកលើការពិសោធន៍ | 1 (17%) | 6(30%) |
| • ផ្សេងៗ | 0 (0%) | 0 (0%) |
| ប្រភេទសេវា[9] | | |
| • ផ្នែកសិក្សា (ឧ. ការបង្រៀនគួរ កម្មវិធីអក្ខរកម្មឪពុកម្តាយ សៀវភៅសរសេរ) | **5 (83%)** | 4(20%) |
| • ផ្នែកហិរញ្ញវត្ថុ (ឧ. ការផ្ទេរប្រាក់ អាហារសម្រាប់គ្រួសារ អាហារូបករណ៍) | 0 (0%) | **13(65%)** |
| • ផ្នែកសុខាភិបាល (ឧ. ការកម្ចាត់ដង្កូវព្រូន ការផ្តល់អាហារនៅសាលារៀន ការចាក់ថ្នាំវ៉ាក់សាំង) | 0 (0%) | 5(25%) |
| • ផ្នែកសង្គម/ផ្ទាល់ខ្លួន (ឧ. ការបណ្តុះបណ្តាល ការប្រឹក្សាយោបល់ ការគ្រប់គ្រងករណី) | **6 (100%)** | 1 (5%) |
| • ផ្នែករចនាសម្ព័ន្ធ (ឧ. សហគមន៍រៀនសូត្រតូចៗ ការពិនិត្យវត្តមានរបស់គ្រូបង្រៀន ឧបករណ៍រដ្ឋបាល និងការបណ្តុះ បណ្តាល) | 3 (50%) | 4(20%) |

[8] ក្រុមដែលមានអាយុដូចគ្នាលើសពីមួយអាចជាគោលដៅ នៅក្នុងអន្តរាគមន៍។

[9] គេអាចផ្តល់ប្រភេទសេវាកម្មលើសពីមួយនៅក្នុងអន្តរាគមន៍។

ការផ្តល់សេវានៅក្នុងកម្មវិធីសិស្សបោះបង់សាលានៅសហរដ្ឋអាមេរិក មានលក្ខណៈខុសគ្នាពីការផ្តល់សេវានៅក្នុងប្រទេសកំពុងអភិវឌ្ឍ ទាំងការជ្រើសរើសសេវាជាក់លាក់ដែលគេនឹងផ្តល់ និង សេវាចម្រុះជាច្រើនទៀត។ មាននិន្នាការខ្លាំងនៅសហរដ្ឋអាមេរិកក្នុងការផ្តល់ការគាំទ្រផ្នែកសិក្សា និងសេវាផ្ទាល់ខ្លួន/សង្គម ដើម្បីឲ្យសិស្សប្រឈមនឹងការបោះបង់សាលាអាចចាប់បានជំនាញច្បាស់លាស់នៅលើមុខវិជ្ជាដែលពួកគេបានសិក្សា និងទទួលបានជំនួយគាំទ្រដើម្បីជួយដោះស្រាយបញ្ហាផ្ទាល់ខ្លួន ឬបញ្ហាសង្គម ដែលពួកគេកំពុងជួបប្រទះ។ ជាការពិតណាស់សៀវភៅមានចំណងជើង What Works Clearinghouse (សរសេរដោយ Dynarski et al., 2008) បានផ្តល់អនុសាសន៍យ៉ាងច្បាស់ស្តីពីប្រភេទ សេវាទាំងនេះដើម្បីអភិវឌ្ឍកម្មវិធីអន្តរាគមន៍សិស្សបោះបង់សាលា។

- ផ្តល់ការគាំទ្រ និងការកែលម្អគុណភាពសិក្សាដើម្បីធ្វើឲ្យលទ្ធផលសិក្សារបស់សិស្សប្រសើរ ឡើង។
- ផ្លាស់ប្តូរបរិយាកាសរៀនសូត្រ និងដំណើរការអប់រំណែនាំដើម្បីឲ្យមានលក្ខណៈងាយស្រួល។
- ផ្តល់ការណែនាំដែលពាក់ព័ន្ធលម្អិតដើម្បីឲ្យសិស្សចូលរៀនបានប្រសើរឡើង និងផ្តល់ជំនាញដែលគេតម្រូវឲ្យបញ្ចប់ និងអនុវត្តជំនាញទាំងនោះឲ្យបានល្អ បន្ទាប់ពីពួកគេឈប់រៀន។
- ចាត់តាំងអ្នកគាំទ្រដែលជាមនុស្សពេញវ័យសម្រាប់សិស្សដែលប្រឈមនឹងការបោះបង់សាលា។
- អនុវត្តកម្មវិធីទាំងនេះដើម្បីកែលម្អឥរិយាបថក្នុងថ្នាក់រៀន និងបំណិនសង្គមរបស់សិស្ស។

សេវាទាំងបីខាងលើរៀបរាប់អំពីអ្វីដែលយើងហៅថា សេវា "ផ្នែកសិក្សា" ពីព្រោះសេវាទាំងនេះលើកស្ទួយដំណើរការរៀនសូត្រ ហើយសេវាពីរចុងក្រោយគឺជាសេវា "សង្គម/ផ្ទាល់ខ្លួន" ពីព្រោះវារៀបរាប់អំពីកិច្ចខិតខំប្រឹងប្រែងក្នុងការគាំទ្រឥរិយាបថរបស់សិស្សដោយសមស្រប។

ការប្រើប្រាស់សេវាផ្នែកសិក្សា និងសេវាផ្ទាល់ខ្លួន/សង្គមក៏ត្រូវបានផ្តល់អនុសាសន៍ផងដែរនៅក្នុងសេចក្តីសង្ខេបគោលនយោបាយស្តីពីការអប់រំពីមជ្ឈមណ្ឌលគោលនយោបាយវាយតម្លៃ និងអប់រំ(Stanley & Plucker, 2008), ដែលនិយាយថា គន្លឹះនៅក្នុងកម្មវិធីសាកល្បងទប់ស្កាត់សិស្សបោះបង់សាលាដែលទទួលបានជោគជ័យគឺ៖ ទំនាក់ទំនង ភាពពាក់ព័ន្ធ និងការយកចិត្តទុកដាក់៖

> "...សិស្សត្រូវមានអារម្មណ៍ថា ខ្លួនជាផ្នែកមួយនៃសហគមន៍សាលារៀន និងត្រូវមានទំនាក់ទំនងរឹងមាំជាមួយមនុស្សពេញវ័យម្នាក់ ឬច្រើននាក់ នៅក្នុងសាលារៀន។ ទី

ពីរ សិស្សត្រូវយល់ថា អ្វីដែលពួកគេកំពុងរៀនសូត្រគឺមានទំនាក់ទំនងគ្នា ឧទាហរណ៍ ពាក់ព័ន្ធនឹងពេលវេលា និងទីកន្លែងបច្ចុប្បន្ន ហើយទីបី សិស្សត្រូវប្រកួតប្រជែងផ្នែកបញ្ញា នៅក្នុងកម្មវិធីសិក្សាលម្អិត។" (ទំព័រទី២)

តាមបែបបទនៃអនុសាសន៍ទាំងនេះ កម្មវិធី៥ក្នុងចំណោមកម្មវិធីដែលត្រូវបានវាយ តម្លៃលម្អិតទាំង៦ នៅសហរដ្ឋអាមេរិក រួមមានសមាសភាគផ្នែកសិក្សាមួយចំនួន ហើយកម្មវិធី ទាំងអស់នេះមានសមាសភាគផ្ទាល់ខ្លួន/សង្គម។ លើសពីនេះទៅទៀត កម្មវិធីសហរដ្ឋអាមេរិក ពាក់កណ្តាលមានសមាសភាគផ្នែករចនាសម្ព័ន្ធ ការផ្លាស់ប្តូរបរិយាកាសរៀនសូត្រតាមរយៈ ការបង្កើតក្រុមថ្នាក់ដែលសិស្សតិចតួច ឬរៀបចំកម្មវិធីសិក្សាជាថ្មីដើម្បីធ្វើឲ្យវាកាន់តែមានការ ពាក់ព័ន្ធទៅដល់សិស្ស។ កម្មវិធីសហរដ្ឋអាមេរិកមិនបានផ្តល់ប្រាក់លើកទឹកចិត្ត ឬសេវាសុខភាពនោះទេ។

វាជាការសំខាន់ក្នុងការកត់សម្គាល់ថាសៀវភៅមានចំណងជើង What Works Clearinghouse បានវាយតម្លៃលើកម្មវិធីសិស្សបោះបង់សាលានៅថ្នាក់មធ្យមសិក្សា និងវិទ្យាល័យនៅសហរដ្ឋអាមេរិក នៅក្នុងបរិបទមួយដែល (ក)កុមារប្រឈមនឹងការបោះបង់សាលាបានលើកឡើងទាំងបញ្ហានៃការរៀនសូត្រ និងឥរិយាបថ (ខ) កុមារត្រូវចូលរៀនឲ្យបានយ៉ាងហោចអាយុ១៦ឆ្នាំ និង(គ) មានបុគ្គលិក និងគ្រូបង្រៀនដែលត្រូវបានចាត់តាំងនៅក្នុងកម្មវិធីសិក្សាពិសេស និងសេវាគាំទ្រ។ នេះមិនមែនជាបរិបទនៅបណ្តាប្រទេសកំពុងអភិវឌ្ឍនោះទេ ហើយដូចអ្វីដែលគេបានរំពឹងទុកអញ្ចឹង គំនិតផ្សេងៗគ្នាអំពីអន្តរាគមន៍ទាំងនេះវាស្របទៅតាមបរិបទខុសៗគ្នា។

នៅបណ្តាប្រទេសកំពុងអភិវឌ្ឍ ការផ្តល់ប្រាក់លើកទឹកចិត្តដល់គ្រួសារឲ្យបញ្ជូនកុមារទៅសាលារៀនគឺជាសេវាដែលមានការពេញចិត្តច្រើន ជាធម្មតា គេផ្តល់ប្រាក់ទៅឲ្យគ្រួសារ ហើយជួនកាល ផ្តល់ទៅឲ្យសាលារៀន។ កម្មវិធី១៣ក្នុងចំណោមកម្មវិធីដែលត្រូវបានលើកឡើងចំនួន២០(៦៥ភាគរយ) បង្ហាញពីការផ្ទេរប្រាក់មានល័ក្ខខ័ណ្ឌ អាហារូបករណ៍ សក្ខីបត្រ អាហារសម្រាប់គ្រួសារ សម្ភារៈសាលារៀន ឯកសណ្ឋានសាលា ឬការផ្តល់លើកទឹកចិត្តដល់គ្រូបង្រៀន ជាទូទៅចែងថា កុមារត្រូវចូលរៀនឲ្យបានទៀងទាត់ និង/ឬត្រូវមកចុះឈ្មោះចូលរៀននៅឆ្នាំសិក្សាបន្ទាប់។ ១០ករណីក្នុងចំណោមករណីទាំងនេះ អន្តរាគមន៍ផ្នែកហិរញ្ញវត្ថុ គឺជាប្រភេទតែមួយគត់ដែលគេបានផ្តល់។ វាកាន់តែសមហេតុផលជាងនេះទៅទៀត ដោយសារតែកត្តាហានិភ័យដែលមិនទាន់បានដោះស្រាយសម្រាប់សិស្សបោះបង់សាលានៅបណ្តាប្រទេសកំពុងអភិវឌ្ឍ ជាទូទៅគឺពាក់ព័ន្ធនឹងហិរញ្ញវត្ថុ។ កម្មវិធីអន្តរាគមន៍តិចជាងមួយភាគបី រួមមាន សេវាផ្នែកសិក្សា សេវាសុខភាព ឬការផ្លាស់ប្តូររចនាស

ម្ព័ន្ធ មានតែកម្មវិធីមួយប៉ុណ្ណោះ (Levy et al., 2009 កម្មវិធី BRIGHT នៅបើគីណា ហ្វាសូ) ផ្តល់ការគាំទ្រផ្ទាល់ខ្លួន/ សង្គម។

នៅក្នុងការពិនិត្យឡើងវិញដ៏លម្អិតនូវឯកសារស្រាវជ្រាវរបស់គាត់ស្តីពី សិស្សបោះបង់សាលានៅក្នុងប្រទេសកំពុងអភិវឌ្ឍ Hunt (2008 ទំព័រទី៤៧-៥០) រៀបរាប់អំពីគំនិតនៃអន្តរាគមន៍នៅក្នុងប្រទេសកំពុងអភិវឌ្ឍ ដែលមានបង្ហាញនៅក្នុងតារាងទី៧។ គាត់បានទាញយកគំនិតពីកិច្ចខិតខំប្រឹងប្រែងស្រាវជ្រាវទ្រង់ទ្រាយតូច និងធំផ្សេងៗគ្នា ដែលមិនបានចែងថា ការស្រាវជ្រាវនេះឆ្លើយតបទៅនឹងគោលការណ៍ណែនាំគុណភាពបែបណាមួយ ឬថែមទាំងមានការវាយតម្លៃអមមកជាមួយ។[10] គំនិតរបស់គាត់ត្រូវបានបែងចែកជាបីប្រភេទ ក្នុងចំណោមប្រភេទដែលកម្មវិធីសាកល្បងទប់ស្កាត់សិស្សបោះបង់សាលា(SDPP) កំពុងប្រើ (ឧ. ផ្នែកសិក្សា ហិរញ្ញវត្ថុ និងរចនាសម្ព័ន្ធ)។ ចូរកត់សម្គាល់ថា គាត់មិនបានលើកឡើងអំពីការប្រើប្រាស់អន្តរាគមន៍ផ្នែកសុខភាព ឬអន្តរាគមន៍ផ្ទាល់ខ្លួន/សង្គម។ តាម ធម្មតា បរិបទនៃបណ្តាប្រទេសកំពុងអភិវឌ្ឍមានលក្ខណៈខុសគ្នាពីបរិបទនៅសហរដ្ឋអាមេរិក ហើយគាត់កំពុងផ្តោតទៅលើអន្តរាគមន៍ផ្នែកអប់រំ (មិនមែនផ្នែកសុខភាព) និងបញ្ហាណាមួយដែលគេបានជួបប្រទះនៅបណ្តាប្រទេសកំពុងអភិវឌ្ឍ ដែលក្នុងនោះគេមិនបានកំណត់ថាឥរិយាបថមិនល្អជាបញ្ហាចម្បងនោះទេ។

[10] SDPP ដកស្រង់ការស្រាវជ្រាវរបស់ Hunt សម្រាប់ការជ្រើសរើសការវាយតម្លៃលើរបាយការណ៍នេះ។

### តារាងទី៧ ៖ សំណើអន្តរាគមន៍ដែលបានមកពីការស្រាវជ្រាវនៅប្រទេសកំពុងអភិវឌ្ឍ[11]

| ប្រទេសកំពុងអភិវឌ្ឍ | |
|---|---|
| **កត្តាផ្នែកសិក្សា** | |
| 1. | បង្កើត *មណ្ឌលមត្តេយ្យសិក្សា។* |
| 2. | ផ្តល់ *កម្មវិធីអក្ខរកម្មសម្រាប់ម្តាយដែលមិនបានទទួលការអប់រំ។* |
| 3. | ផ្តល់ *ទម្រង់ជម្រើសសម្រាប់ការអប់រំ* (ឧ. សាលារៀនដែលកំពុងដំណើរការ) |
| **ការគាំទ្រផ្នែកហិរញ្ញវត្ថុ** | |
| 4. | ក្នុងនៅពេលមានបញ្ហាប្រាក់ចំណូល ផ្តល់ឱ *កាសឲ្យទទួលបានឥណទាន។* |
| 5. | ផ្តល់ *ការគាំទ្រមានល័ក្ខខ័ណ្ឌ* (ឧ. រូបិយវត្ថុ អាហារ) ប្រសិនបើកុមារចុះឈ្មោះចូលរៀន និងនៅរៀនបន្ត។ |
| 6. | ផ្តល់ *ការគាំទ្រឥតល័ក្ខខ័ណ្ឌ* (ឧ. រូបិយវត្ថុ អាហារ)។ |
| 7. | ផ្តល់ *អាហារូបករណ៍។* |
| **អន្តរាគមន៍ផ្នែករចនាសម្ព័ន្ធ** | |
| 8. | រៀបចំ *កាលវិភាគសាលារៀនដែលអាចផ្លាស់ប្តូរ* ទៅតាមកាលវិភាគសិក្សារបស់កុមារ។ |
| 9. | ដាក់ចេញនូវគោលនយោបាយស្តីពី *ការឡើងដោយស្វ័យប្រវត្តិ* ជាជាងឲ្យនៅរៀនត្រួតថ្នាក់។ |
| 10. | កំណត់យក *ភាសាទីមួយ/ភាសាខ្មែរ* ជាភាសាអប់រំនៅឆ្នាំសិក្សាថ្នាក់ដំបូង។ |
| 11. | ធានាថា សហគមន៍ទាំងនេះមាន *ឱកាសទទួលបានការអប់រំថ្នាក់មធ្យមសិក្សា*។ |
| 12. | ធ្វើឲ្យ *ការត្រួតពិនិត្យ និងគណនេយ្យភាព* ប្រសើរឡើងតាមរយៈគណៈគ្រប់គ្រងសាលា រៀន។ |
| 13. | ឲ្យ *សហគមន៍* ចូលរួមក្នុងការអប់រំគ្រប់រូបភាព។ |

អន្តរាគមន៍៤ករណីក្នុងចំណោមអន្តរាគមន៍ ដែលត្រូវបានវាយតម្លៃលម្អិត២៦ករណី បានលើកឡើងពីកត្តាផ្នែកសិក្សាមួយក្នុងចំណោមកត្តាផ្នែកសិក្សាជាច្រើន ដែលមាននៅក្នុងបញ្ជីរបស់ Hunt រួមមាន កម្មវិធី BRIGHT នៅក្នុងប៊ើគីណា ហ្វាសូ ដែលត្រូវបានពិនិត្យឡើងវិញដោយ Levy et al. (2009) បានដាក់បញ្ចូលកម្មវិធីអក្ខរកម្មសម្រាប់ឪពុកម្តាយ (#2 នៅក្នុងតារាង ទី៧) និងកសាងសាលារៀននៅសហគមន៍សម្រាប់កុមារ (#3) កម្មវិធីនៅប្រទេសឥណ្ឌា ដែលត្រូវបានវាយតម្លៃដោយ Duflo et al. (2010) រួមមាន ការបង្រៀនគួរដល់កុមារដោយជំនួយការគ្រូបង្រៀន(para-teacher) ឬការរៀនកុំព្យូទ័រ (#3) និងកម្មវិធីនៅក្នុងប្រទេសហ្វីលីពីន ដែលត្រូវបានវាយតម្លៃដោយ Tan et al. (1999) បានផ្តល់ សម្ភារៈរៀនសូត្រច្រើនកម្រិតដល់គ្រូបង្រៀន (ការលើកកម្ពស់ដល់ការអប់រំទៀងទាត់ដូចដែលបានលើកឡើងនៅក្នុង #3)។ កម្មវិធីនៅប្រទេសកេនយ៉ាដែលត្រូវបាន

[11] F. Hunt, ទំព័រទី 47-ដល់ទំព័រទី 50 ។

វាយតម្លៃដោយ Glewwe et al. (2007) បានបន្ថែមជម្រើសមួយនៅក្នុងបញ្ជីរបស់ Hunt ដោយផ្តល់ជូននូវសៀវភៅសរសេរដល់សាលារៀន ដែលមិនសូវមានសៀវភៅ។ ការផ្តល់សៀវភៅនេះមានបំណងលើកកម្ពស់លទ្ធផលសិក្សារបស់កុមារ ដូច្នេះហើយបានជាគេដាក់បញ្ចូលទៅក្នុងអន្តរាគមន៍ "ផ្នែកសិក្សា" ប៉ុន្តែសៀវភៅដែលបានផ្តល់ឲ្យនោះក៏ស្ថិតនៅក្នុងប្រភេទបន្ទាប់នៃការគាំទ្រផ្នែកហិរញ្ញវត្ថុ។

កម្មវិធី១៣ ក្នុងចំណោមកម្មវិធី២៦បានដាក់ចេញនូវការគាំទ្រផ្នែកហិរញ្ញវត្ថុមួយ ឬច្រើន ដែលត្រូវបានលើកឡើងដោយ Hunt មានជាអាទិ៍:

- ការគាំទ្រតាមល័ក្ខខ័ណ្ឌត្រូវបានផ្តល់នៅបើគីណា ហ្វាសូ (Levy et al., 2009) ក្នុងទ្រង់ទ្រាយជាធញ្ញជាតិដោយឥតគិតថ្លៃ។
- ការផ្ទេរប្រាក់មានល័ក្ខខ័ណ្ឌត្រូវបានប្រើនៅប្រទេសប្រេស៊ីល(Glewwe & Kassouf, 2010) ប្រទេសកូឡុំប៊ី (Barrera-Osorio et al., 2008), ប្រទេសកូឡុំប៊ី (Angrist et al., 2002) ប្រទេស ហាង់ដូរ៉ាស់ (Glewwe & Olinto, 2004) ប្រទេសចាម៉ៃកា(Levy & Ohls, 2007) ប្រទេសម៉ាឡាវី (Baird et al., 2010), ប្រទេសមិចស៊ិកូ (Schultz, 2000), ប្រទេសប៉ាគីស្ថាន (Chaudhury & Parajuli, 2006) និងនៅក្នុងកេនយ៉ា (Glewwe et al., 2003) ជាទីដែលគ្រូបង្រៀនទទួលប្រាក់បន្ថែម ប្រសិនបើសិស្សប្រឡងបានលទ្ធផលល្អប្រសើរ និង
- អាហារូបករណ៍ត្រូវបានផ្តល់នៅក្នុងប្រទេសកម្ពុជា (Filmer & Schady, 2009) និងប្រទេសកេនយ៉ា (Friedman et al., 2011)។

ការផ្តល់សេវាហិរញ្ញវត្ថុនៅក្នុងកម្មវិធីដែលត្រូវវាយតម្លៃលម្អិតលើកទី១៣ គឺជារង្វាន់*ឥតល័ក្ខ ខ័ណ្ឌ* ពោលគឺ អន្តរាគមន៍នៅប្រទេសកេនយ៉ាដែលត្រូវបានវាយតម្លៃដោយ Duflo et al. (2006) បាន ផ្តល់ឯកសណ្ឋានសាលាដល់សិស្សគ្រប់រូប ដែលបានចុះឈ្មោះចូលរៀននៅដើមឆ្នាំ។ ក្រៅពីការគាំទ្រតាមល័ក្ខខ័ណ្ឌនេះ កម្មវិធី BRIGHT នៅបើគីណា ហ្វាសូ បានផ្តល់ការគាំទ្រឥតល័ក្ខខ័ណ្ឌ ដោយផ្តល់ សម្ភារៈសិក្សាដល់កុមារ។

ជាចុងក្រោយនេះ កម្មវិធី៣ក្នុងចំណោមកម្មវិធីដែលត្រូវបានវាយតម្លៃលម្អិតចំនួន៤ ជាមួយនឹងសមាសភាគរចនាសម្ព័ន្ធ ត្រូវបានអនុវត្តតាមសំណើរបស់ Hunt ក្នុងការប្រមូលផ្តុំឪពុកម្តាយ ឬសហគមន៍នានាដើម្បីគាំទ្រដល់ការអប់រំ: ប្រទេសបើគីណា ហ្វាសូ (Levy et al., 2009) ប្រទេសម៉ាដាហ្គាស្កា (Nguyen & Lassibille,

2008) និងប្រទេសហ្វីលីពីន (Tan et al., 1999)។ ជាការពិតណាស់កម្មវិធី BRIGHT នៅប្រទេសប៊ើគីណា ហ្វាសូ បានអនុវត្តតាមអនុសាសន៍របស់ Hunt នៅក្នុងការកសាងអគារសិក្សា និងការបណ្ដុះបណ្ដាលដៃគូក្នុងស្រុក ដើម្បីទ្រទ្រង់សាលារៀន។ គំនិតក្នុងការបង្កើនការចូលរួមពីគ្រូបង្រៀន ដោយឲ្យសិស្សថតរូបរបស់ពួកគាត់រាល់ព្រឹក និងរសៀលដែលត្រូវបានណែនាំនៅប្រទេសឥណ្ឌា និងដែលត្រូវបានវាយតម្លៃដោយ Duflo et al., (2010) គឺជាជម្រើសរចនាសម្ព័ន្ធមួយផ្សេងទៀត ប៉ុន្តែ Hunt មិនបានលើកឡើងពីគំនិតនេះនោះទេ។

## ៣ការវាយ ៣.២.តម្លៃលើប្រសិទ្ធភាពនៃកម្មវិធី

កម្មវិធី២១ ក្នុងចំណោមកម្មវិធីដែលត្រូវបានវាយតម្លៃលម្អិតចំនួន២៦ ត្រូវបានវាយតម្លៃថាមានប្រសិទ្ធភាពក្នុងការដោះស្រាយបញ្ហាយ៉ាងហោចមួយ ក្នុងចំណោមបញ្ហានានាពាក់ព័ន្ធនឹងការចូលរៀន ការនៅរៀន ឬការរៀនបានរីកចម្រើននៅសាលា។ កម្មវិធីសហរដ្ឋអាមេរិកចំនួន៦ត្រូវបានជ្រើសរើសពីកម្មវិធីដែលត្រូវបានត្រួតពិនិត្យដោយយកចិត្តទុកដាក់ដោយ What Works Clearinghouse ពីព្រោះកម្មវិធីទាំងនេះត្រូវបានបង្ហាញថាមានប្រសិទ្ធភាពក្នុងការកាត់បន្ថយអត្រាសិស្សបោះបង់សាលា ដូច្នេះយើងមិនបានដាក់បញ្ចូលកម្មវិធីទាំងនេះនៅក្នុងតារាងនេះនោះទេ។ ប៉ុន្តែ ការស្រាវជ្រាវអន្តរាគមន៍អន្តរជាតិពិតជាបានរកឃើញភាពខុសប្លែកគ្នានៃប្រសិទ្ធភាពនេះ។ តារាងទី៨បង្ហាញពីអថេរចំណុះជា**អក្សរដិតខ្មៅ** ដែលរងអានុភាពជាវិជ្ជមានដោយអន្តរាគមន៍អន្តរជាតិនីមួយៗ។ អថេរដែលមិនបង្ហាញជាអក្សរដិតខ្មៅ ក៏ត្រូវបានវាស់វែងផងដែរ ប៉ុន្តែគេមិនបានរកឃើញភាពខុសប្លែកគ្នាណាមួយ រវាងក្រុមទទួលអន្តរាគមន៍ពីគម្រោង និងក្រុមប្រៀបធៀបនោះទេ។

**តារាងទី៨ ៖ អថេរលទ្ធផលគ្រោះ**

## មរានុភាពនៃសេវាអន្តរាគមន៍អន្តរជាតិ
## ដែលត្រូវបានវាយតម្លៃយ៉ាងលម្អិត

| អន្តរាគមន៍ | ប្រសិទ្ធភាពនៃប្រភេទសេវានីមួយៗ | | | | |
|---|---|---|---|---|---|
| | ផ្នែក សិក្សា | ផ្នែកហិរញ្ញវត្ថុ | ផ្នែក សុខភាព | ផ្នែកសង្គម/ផ្ទាល់ខ្លួន | ផ្នែក រចនា សម្ព័ន្ធ |
| ប្រេស៊ីល, *Bolsa Familia*: ការផ្ទេរប្រាក់ (Glewwe & Kassouf, 2010) | | នៅរៀន<br>រៀនបានរីកចម្រើននៅសាលា | | | |
| ប៊ើគីណា ហ្វាសូ, *BRIGHT*: កសាង និង បំពាក់សម្ភារៈថ្មីៗដល់ សាលារៀន, ប្រមូលផ្តុំ សហាគមន៍, ផ្តល់ធញ្ញជាតិ ដល់គ្រួសារដើម្បី យកទៅដាំ, សម្ភារៈ សា លា អាហារថ្ងៃត្រង់ប្រចាំ ថ្ងៃ និង ការបង្រៀនគួរ ដល់សិស្ស (Levy et al., 2009) | ចូលរៀន | ចូលរៀន | ចូលរៀន | ចូលរៀន | ចូលរៀន |
| កម្ពុជា: អាហារូបករណ៍ (Filmer & Schady, 2009) | | នៅរៀន | | | |
| កូឡុំប៊ី, *PACES*: សក្ខីបត្រសម្រាប់បង់ថ្លៃសិក្សានៅសាលាឯកជន(Angrist et al., 2002) | | រៀនបានរីកចម្រើននៅសាលា,<br>នៅរៀន | | | |
| កូឡុំប៊ី: ការផ្ទេរសាច់ ប្រាក់ (Barrera-Osorio et al., 2008) | | ចូលរៀន, នៅរៀន | | | |
| ហុងឌូរ៉ាស់, *PRAF*: ការ ផ្ទេរប្រាក់ (Glewwe & Olinto, 2004) | | ចូលរៀន,<br>នៅរៀន,<br>រៀនបានរីកចម្រើននៅ<br>សា លា | | | |
| ឥណ្ឌា: ការបង្រៀនគួរ ឬរៀនកុំព្យូទ័រ (Banerjee et al., 2007) | ចូលរៀន,<br>នៅរៀន | | | | |

| អន្តរាគមន៍ | ប្រសិទ្ធភាពនៃប្រភេទសេវានីមួយៗ | | | | |
|---|---|---|---|---|---|
| | ផ្នែក សិក្សា | ផ្នែកហិរញ្ញវត្ថុ | ផ្នែក សុខភាព | ផ្នែកសង្គម/ ផ្ទាល់ខ្លួន | ផ្នែក រចនា សម្ព័ន្ធ |
| ឥណ្ឌា: បង្កើនការចូលរួមពីគ្រូបង្រៀន (Duflo et al., 2010) | | | | | ចូលរៀន , នៅរៀន |
| ចាម៉ៃកា, *PATH*: ការផ្ទេរ ប្រាក់ (Levy & Ohls, 2007) | | ចូលរៀន | | | |
| កេនយ៉ា: ការបង់ថ្លៃឯក សណ្ឋាន សាលា, អន្តរា គមន៍មេរោគអេដស៍/ជម្ងឺអេដស៍ (Duflo et al., 2006) | | នៅរៀន | នៅរៀន | | |
| កេនយ៉ា: ប្រាក់បន្ថែមសម្រាប់គ្រូបង្រៀន (Glewwe et al., 2003) | | នៅរៀន | | | |
| កេនយ៉ា: ការផ្តល់សៀវភៅសិក្សា (Glewwe et al., 2007) | ចូលរៀន, នៅរៀន, រៀនបានរីកចម្រើន នៅសាលា | | | | |
| កេនយ៉ា: កម្មវិធីអាហារូបករណ៍សម្រាប់កុមារី (Friedman et al., 2011) | | នៅរៀន, រៀនបានរីកចម្រើននៅសា លា | | | |
| កេនយ៉ា: ការកម្ចាត់ដង្កូវ ព្រូន (Miguel & Kremer, 2004) | | | ចូលរៀន | | |
| ម៉ាដាហ្គាស្កា: ឧបករណ៍ រដ្ឋបាល និង ការបណ្តុះ បណ្តាល (Duflo et al., 2008) | | | | | ចូលរៀន |
| ម៉ាឡាវី: ការផ្ទេរសាច់ ប្រាក់ទៅឲ្យកុមារី (Baird et al., 2010) | | នៅរៀន | | | |
| មិចស៊ិកូ, *PROGRESA*: ការផ្ទេរប្រាក់ (Schultz, 2000) | | នៅរៀន | | | |

| អន្តរាគមន៍ | ប្រសិទ្ធភាពនៃប្រភេទសេវានីមួយៗ | | | | |
|---|---|---|---|---|---|
| | ផ្នែកសិក្សា | ផ្នែកហិរញ្ញវត្ថុ | ផ្នែក សុខភាព | ផ្នែកសង្គម/ផ្ទាល់ខ្លួន | ផ្នែករចនា សម្ព័ន្ធ |
| ណេប៉ាល់: ផ្តល់សម្ភារ: សម្រាប់ស្ត្រីមករដូវ (Oster & Thornton 2009) | | | ចូលរៀន | | |
| ប៉ាគីស្ថាន: ការផ្ទេរសាច់ ប្រាក់ទៅឲ្យកុមារី (Chaudhury & Parajuli, 2006) | | **ចូលរៀន** | | | |
| ហ្វីលីពីន: សម្ភារ:រៀន សូត្រ ឬការផ្តល់អាហារ ដល់សាលារៀន ដោយ មានឪពុកម្តាយ-គ្រូបង្រៀនជាដៃគូ (Tan et al., 1999) | **នៅរៀន** | | នៅរៀន | | **នៅរៀន (សេវាផ្នែកសិក្សា)** |
| ចំនួន (ភាគរយ)នៃអន្តរាគមន៍មួយប្រភេទ ដែលគេរកឃើញថា មានប្រសិទ្ធភាព | 2/4 (50%) | 12/13 (92%) | 2/5 (40%) | 1/1 (100%) | 3/4 (75%) |

**អន្តរាគមន៍ផ្នែកសិក្សា។** អន្តរាគមន៍២ករណីក្នុងចំណោមអន្តរាគមន៍ផ្នែកសិក្សា៤ករណីនៅ បណ្តាប្រទេសកំពុងអភិវឌ្ឍ គឺមានប្រសិទ្ធភាពក្នុងការកាត់បន្ថយអត្រាសិស្សបោះបង់សាលា។ អន្តរាគមន៍ទាំងនេះបានដាក់បញ្ចូលសមាសភាគសិក្សាជាមួយ សមាសភាគកម្មវិធីយ៉ាងហោចមួយផ្សេង ទៀត: Levy et al., (2009) នៅក្នុងប៊ើគីណា ហ្វាសូ បានពិនិត្យឡើងវិញនូវកម្មវិធី BRIGHT ដែលត្រូវបានផ្តល់មូលនិធិដោយទីភ្នាក់ងារសហរដ្ឋអាមេរិកដើម្បីអភិវឌ្ឍន៍អន្តរជាតិ (USAID) ដែលបានផ្តល់សាលារៀនដល់ភូមិដែលគ្មានសាលារៀន។ គម្រោងនេះបានពិនិត្យទៅលើសេវាទាំង៥ប្រភេទដូចខាងក្រោម:

- ផ្នែកសិក្សា: សាលាបឋមសិក្សាដែលត្រូវបានបើកនៅក្នុងភូមិដែលទាន់មានសាលា ហើយមនុស្សពេញវ័យទទួលបានការបណ្តុះបណ្តាលអក្ខរកម្ម
- ផ្នែកហិរញ្ញវត្ថុ: តាមរយៈការចូលរួមនេះ កុមារីបានទទួលធញ្ញជាតិស្ងួត៨គីឡូក្រាម ដើម្បីយកទៅផ្ទះ ហើយសិស្សទាំងអស់ទទួលបានសៀវភៅសិក្សា និងសម្ភារ:សិក្សា
- ផ្នែកសុខភាព: ផ្តល់អាហារថ្ងៃត្រង់ប្រចាំថ្ងៃដល់សិស្សគ្រប់រូប

- ផ្នែកសង្គម/ផ្ទាល់ខ្លួនៈ ផ្តល់ការបណ្តុះបណ្តាលដល់កុមារី និង
- ផ្នែករចនាសម្ព័ន្ធៈ ការសាងសង់អគារសិក្សារួមមាន ការផ្តល់កន្លែងស្នាក់នៅសម្រាប់គ្រូបង្រៀន៣នាក់ មានបង្គន់ចែកដាច់សម្រាប់កុមារា និងកុមារី និងអណ្តូងស្នប់ ហើយសហគមន៍ត្រូវបានប្រមូលផ្តុំដើម្បីទ្រទ្រង់សាលារៀន និងផ្តល់ការបណ្តុះបណ្តាលដល់ដៃគូក្នុងស្រុក ដើម្បីឲ្យពួកគាត់អាចជួយសាលារៀនផងដែរ។

ការវាយតម្លៃនេះបង្ហាញថា ការប្រមូលសមាសភាគទាំងនេះ លើកស្ទួយឲ្យមានការចូលរួមប្រហែល១៦ ភាគរយលើសការប្រមូលសមាសភាពនៅក្នុងសាលាសម្រាប់ប្រៀបធៀប។

អន្តរាគមន៍ផ្នែកសិក្សាដែលទទួលបានជោគជ័យលើកទីពីរ គឺជាអន្តរាគមន៍ដែលត្រូវបានពិនិត្យឡើងវិញដោយ Tan et al., (1999) ជាការពិសោធន៍មួយនៅប្រទេសហ្វីលីពីនដែលផ្តល់ជម្រើសមួយក្នុងចំណោមជម្រើសបួនដល់សាលារៀនៈ

(1) សម្ភារៈរៀនសូត្រច្រើនកម្រិតដើម្បីឲ្យគ្រូយកទៅប្រើប្រាស់
(2) អាហារថ្ងៃត្រង់នៅសាលារៀន
(3) ការប្រមូលសម្ភារៈរៀនសូត្រច្រើនកម្រិតដោយមានការលើកទឹកចិត្តពីឪពុកម្តាយ-គ្រូបង្រៀនជាដៃគូ ឬ
(4) ការផ្តល់អាហារថ្ងៃត្រង់នៅសាលារៀន ដោយមានឪពុកម្តាយ-គ្រូបង្រៀនជាដៃគូ។

សម្ភារៈរៀនសូត្រច្រើនកម្រិតកាត់បន្ថយអត្រាសិស្សបោះបង់សាលាបានយ៉ាងតិច១០ភាគរយ ជាពិសេស នៅពេលដែលមានឪពុកម្តាយ-គ្រូបង្រៀនចូលរួមជាដៃគូ។

អន្តរាគមន៍ផ្នែកសិក្សាដែលមិនបានបង្ហាញលទ្ធអានុភាពវិជ្ជមាន ដែលត្រូវបានវាយតម្លៃនៅ ប្រទេសឥណ្ឌាដោយ Banerjee et al., (2007) និងត្រូវបានវាយតម្លៃនៅប្រទេសកេនយ៉ាដោយ Glewwe et al., (2007) ។ Banerjee et al បានវាយតម្លៃលើគោលវិធីសិក្សាពីរករណីនៅក្នុងសង្កាត់ដែលមានចំណូលទាបនៅទីក្រុងនៃប្រទេសឥណ្ឌាៈ (១)ផ្តល់ការបង្រៀនគួរបំប៉នបន្ថែម ២ម៉ោងរៀងរាល់ថ្ងៃ ដល់សិស្ស ឬ (២)ផ្តល់កម្មវិធីបង្រៀនកុំព្យូទ័រ២ម៉ោងក្នុងមួយសប្តាហ៍ដើម្បីបង្កើនជំនាញគណិតវិទ្យា។ អន្តរាគមន៍ទាំងនេះមិនបានបង្កើនការចូលរៀន ហើយក៏មិនបានកាត់បន្ថយអត្រាសិស្សបោះបង់សាលាដែរ។ Glewwe et al បានវាយតម្លៃលើការផ្គត់ផ្គង់សៀវភៅសិក្សាដល់សាលារៀន ដែលមិនសូវមានសៀវភៅ ហើយមិនបានរកឃើញថា ការចូលរួមនេះមានការ

កើនឡើង ឬអាចកាត់បន្ថយអត្រាត្រួតថ្នាក់ ឬអត្រាបោះបង់នោះទេ។ ដូច្នេះសេវាផ្នែកសិក្សាបានធ្វើការសន្យាមួយចំនួនជាអន្តរជាតិ ប៉ុន្តែតាមរយៈអន្តរាគមន៍ ដែលត្រូវបានវាយតម្លៃលម្អិតតែ៩ប៉ុណ្ណោះ លទ្ធផលទាំងនេះត្រូវបានដាក់បញ្ចូលគ្នាយ៉ាងច្បាស់លាស់។ ការរៀបចំគោលវិធីចម្បងទាំងនេះនៅតែមិនទាន់បានសាកល្បង ឬវាយតម្លៃឲ្យបានលម្អិតនៅឡើយទេ។

**អន្តរាគមន៍ផ្នែកហិរញ្ញវត្ថុ។** អន្តរាគមន៍១២ ក្នុងចំណោមអន្តរាគមន៍ផ្នែកហិរញ្ញវត្ថុ១៣ករណីបានបង្កើនអត្រាចូលរៀន កាត់បន្ថយអត្រាសិស្សបោះបង់សាលា និង/ឬបានធានាថា សិស្សរៀនបានរីកចម្រើននៅសាលា។ ការផ្តល់ជាប្រាក់ ឬសក្ខីបត្រដល់សិស្ស និងគ្រួសារសិស្ស ល័ក្ខខ័ណ្ឌស្តីពីការចូលរៀន ឬការចុះឈ្មោះចូលរៀនជាថ្មីនៅឆ្នាំសិក្សាបន្ទាប់ បានបង្ហាញថា ជាមធ្យោបាយដ៏មានប្រសិទ្ធភាពក្នុងការរក្សាកុមារនៅបណ្តាប្រទេសកំពុងអភិវឌ្ឍឲ្យនៅរៀនបន្តទៅមុខទៀត។ អន្តរាគមន៍ផ្នែកហិរញ្ញវត្ថុតែមួយគត់ ដែលមិនមានប្រសិទ្ធភាពនោះគឺកម្មវិធីនៅប្រទេសកេនយ៉ា ដែលផ្តល់ប្រាក់រង្វាន់បន្ថែមដល់គ្រូណា ដែលបង្រៀនឲ្យសិស្សប្រឡងបានពិន្ទុខ្ពស់តាមស្តង់ដារ (Glewwe et al., 2003) ជាប្រភេទកម្មវិធីខុសគ្នាពីប្រទេសផ្សេងទៀត ដែលភាគច្រើនជាកម្មវិធីផ្ទេរប្រាក់។

> កម្មវិធី PROGRESA នៅប្រទេសមិចស៊ីកូ ផ្តល់ការផ្ទេរប្រាក់ដល់គ្រួសារដែលមានកូនរៀនថ្នាក់ទី៣ ដល់ទី៩ នៅក្នុងសហគមន៍ជនបទក្រីក្រ ឲ្យតែកុមារចូលរៀនយ៉ាងហោចបាន៨៥ភាគរយក្នុងឆ្នាំសិក្សា។ អត្រាចុះឈ្មោះចូលរៀននៅថ្នាក់ទី៧ ជាឆ្នាំឆ្លងភូមិសិក្សា បានកើនឡើងដល់ទៅ១១.១ភាគរយ ដោយសារតែមានកម្មវិធីនេះ (Schultz, 2000)។

**អន្តរាគមន៍ផ្នែកសុខភាព។** ក្នុងចំណោមអន្តរាគមន៍ផ្នែកសុខភាពទាំង៥ករណីនៅក្នុងកម្មវិធីអន្តរជាតិ កម្មវិធីពីរបានបង្កើនចំនួនសិស្សចូលរៀន ឬបានកាត់បន្ថយអត្រាសិស្សបោះបង់សាលា ហើយកម្មវិធីបីមិនបានបង្កើនចំនួនសិស្សចូលរៀន ឬមិនបានកាត់បន្ថយអត្រាសិស្សបោះបង់សាលានោះទេ។ កម្មវិធី BRIGHT នៅប៊ើគីណា ហ្វាសូ (Levy et al., 2009) ទទួលបានជោគជ័យប្រកបដោយប្រសិទ្ធភាព នៅពេលដែលកម្មវិធីនេះបានរាប់បញ្ចូលការផ្តល់អាហារថ្ងៃត្រង់នៅសាលារៀនទៅតាមទំហំនៃសេវាដែលបានផ្តល់នោះ។ ប៉ុន្តែវាមិនច្បាស់ថាអាហារថ្ងៃត្រង់នឹងមានអានុភាពជាវិជ្ជមានឬយ៉ាងណានោះទេ។ Tan et al., (1999) ដែលបានវាយតម្លៃលើកម្ម

វិធីនៅក្នុងប្រទេសហ្វីលីពីនបានរកឃើញថា ការផ្តល់អាហារដល់សាលារៀនមិនមានអានុភាពគួរឲ្យកត់សម្គាល់ទៅលើអត្រាសិស្សបោះបង់សាលានោះទេ។

គោលវិធីកម្ចាត់ដង្កូវព្រូនដែលត្រូវបានវាយតម្លៃដោយ Miguel និង Kremer (2004) គឺជា គោលវិធីផ្នែកសុខភាពដ៏មានប្រសិទ្ធភាពទីពីរ ក្នុងការផ្តល់ថ្នាំកម្ចាត់ដង្កូវព្រូន បានកាត់បន្ថយ កម្រិតនៃការឆ្លងទៅដល់កុមារនៅសាលារៀន ដែលអាចនាំឲ្យពួកគេមិនសូវអវត្តមានច្រើន។ ទោះបីជាយ៉ាងណានោះក្តី អន្តរាគមន៍ផ្សេងទៀតផ្តោតទៅលើការកាត់បន្ថយជម្ងឺ អន្តរាគមន៍ មេរោគអេដស៍/ជម្ងឺអេដស៍ដោយបណ្តុះបណ្តាលគ្រូបង្រៀនអំពីកម្មវិធីសិក្សាមេរោគអេដស៍/ ជម្ងឺអេដស៍ និងលើកទឹកចិត្តឲ្យពួកគាត់ពិភាក្សាជាមួយសិស្សនៅប្រទេសកេនយ៉ា (ពិនិត្យឡើងវិញដោយ Duflo et al., 2006) មានអានុភាពតិចតួចទៅលើអត្រាសិស្សបោះបង់សាលា និងអន្តរាគមន៍នៅប្រទេសណេប៉ាល់ដែលគេបានចែកចាយកងដាក់ក្នុងស្បូន ទៅឲ្យកុមារីពេញវ័យមានអានុភាពតិចតួចទៅលើការចូលរៀននៅសាលា។ លទ្ធផលទាំងនេះហាក់ដូចជាលើកឡើងថា អន្តរាគមន៍ផ្នែកសុខភាពទំនងជាមានអានុភាពទៅលើស្ថានភាពសុខភាពច្រើនជាងលទ្ធផលនៃការអប់រំ។

**អន្តរាគមន៍ផ្ទាល់ខ្លួន/សង្គម។** កម្មវិធី BRIGHT នៅប្រទេសបើគីណា ហ្វាសូ បានសាកល្បងគោលវិធីផ្ទាល់ខ្លួន/សង្គមៈ កម្មវិធីនេះបានរាប់បញ្ចូលកម្មវិធីបណ្តុះបណ្តាលសម្រាប់កុមារីនៅក្នុងអន្តរាគមន៍ដោយយកចិត្តទុកដាក់ ដើម្បីលើកកម្ពស់ការអប់រំថ្នាក់បឋមសិក្សា។ ទោះបីជាកម្មវិធីទាំងមូលទទួលបានជោគជ័យក្នុងការលើកស្ទួយឲ្យមានការចូលរួមក៏ដោយ ក៏វាមិនច្បាស់ថា កម្មវិធី បណ្តុះបណ្តាលនេះមានលក្ខណៈខុសគ្នាក្នុងការប្រៀបធៀបទៅនឹងការកសាងអគារសាលារៀន និងការផ្តល់សម្ភារៈសាលារៀន ការផ្តល់ធញ្ញជាតិយកទៅដាំនៅផ្ទះ និងការផ្តល់អាហារថ្ងៃត្រង់រៀងរាល់ថ្ងៃ។ ប៉ុន្តែអ្នកស្រាវជ្រាវត្រូវការវាយតម្លៃទៅលើអន្តរាគមន៍ផ្ទាល់ខ្លួន/សង្គម ដោយគ្មានសមាសភាគដទៃដឹងច្បាស់អំពីកិច្ចប្រឹងប្រែងនៃអន្តរាគមន៍នេះឡើយ។

**អន្តរាគមន៍ផ្នែករចនាសម្ព័ន្ធ។** អន្តរាគមន៍ផ្នែករចនាសម្ព័ន្ធចំនួន៤មានលទ្ធអានុភាពវិជ្ជមានខ្លះៗ។ អន្តរាគមន៍ពីរគឺជាការវាយតម្លៃផ្នែករចនាសម្ព័ន្ធរបស់ Duflo et al., (2010) អំពីកិច្ចប្រឹងប្រែងក្នុងការកាត់បន្ថយអវត្តមានច្រើនរបស់គ្រូបង្រៀននៅប្រទេសឥណ្ឌា និងការវាយតម្លៃរបស់ Duflo et al., (2008) អំពីការផ្តល់ឧបករណ៍ និងការបណ្តុះបណ្តាលដល់រដ្ឋបាល គ្រូបង្រៀន និងឪពុកម្តាយនៅប្រទេសម៉ាដាហ្គាស្កា មានលទ្ធផលចម្រុះ។ គម្រោងនៅប្រទេសឥណ្ឌាទទួលបានជោគជ័យក្នុងការលើកទឹកចិត្តឲ្យគ្រូបង្រៀនចូលរួម ប៉ុន្តែមិនទទួលបានជោគជ័យក្នុងការឲ្យសិស្សចូលរៀនឲ្យបានច្រើន ឬកាត់បន្ថយ អត្រាសិស្សបោះបង់សាលា។ គម្រោងនៅប្រទេសម៉ាដាហ្គាស្កាបានបង្កើនការចូលរៀនរបស់សិស្ស ប្រសិនបើបុគ្គលិកសាលាក្នុងមូលដ្ឋាន

ទទួលបានការបណ្តុះបណ្តាលអំពីឧបករណ៍រដ្ឋបាលជាមួយឪពុកម្តាយ។ ការផ្តល់ឧបករណ៍នៅតែថ្នាក់ស្រុក ឬថ្នាក់ក្រោមស្រុកមិនមានអានុភាពខ្លាំងក្លាទៅលើការចូលរួមនោះទេ។

ដើម្បីបង្កើនការចូលរួមពីគ្រូបង្រៀន គេបានផ្តល់ម៉ាស៊ីនថតទៅឲ្យសាលាបឋមសិក្សាក្រៅប្រព័ន្ធចំនួនពាក់កណ្តាល ក្នុងចំណោមសាលាបឋមសិក្សាក្រៅប្រព័ន្ធចំនួន១១៣នៅប្រទេសឥណ្ឌា ដែលត្រូវបានប្រតិបត្តិការដោយអង្គការមិនមែនរដ្ឋាភិបាលមួយ។ ម៉ាស៊ីនថតនីមួយៗមានកំណត់កាលបរិច្ឆេទ និងម៉ោងនៅលើរូបថតនីមួយៗ ដែលមានមុខងារចុះលេខកូដច្បាស់លាស់ និងមិនអាចកែប្រែបាន។ គេរំពឹងថា សិស្សនឹងថតរូបគ្រូបង្រៀន និងក្រុមសិស្សនៅពេលចាប់ផ្តើម រៀន និងរៀនចប់នៅថ្ងៃនីមួយៗ។ គ្រូបង្រៀនទទួលបាន បៀវត្សរ៍ដោយផ្អែកទៅលើការចូលរួម ដែលមានបង្ហាញនៅក្នុងរូបថតនោះ (Duflo et al., 2010)។

អន្តរាគមន៍ពីរផ្សេងទៀត ដែលធ្វើការផ្លាស់ប្តូររចនាសម្ព័ន្ធបានច្របាច់បញ្ចូលការផ្លាស់ប្តូរនោះជាមួយប្រភេទសេវាផ្សេងទៀត ហើយសំណុំអន្តរាគមន៍ទាំងមូលទទួលបានជោគជ័យក្នុងការបង្កើនការចូលរួម ឬកាត់បន្ថយសិស្សបោះបង់សាលា។ ជាពិសេស កម្មវិធី BRIGHT នៅបើគីណា ហ្វាសូ (ដែលត្រូវបានវាយតម្លៃដោយ Levy et al., 2009) បានបង្កើតបរិយាកាសអប់រំផ្សេងៗគ្នាតាមរយៈការ កសាងសាលារៀន ការផ្តល់កន្លែងស្នាក់នៅដល់គ្រូបង្រៀន បង្គន់ កុងទីន(កន្លែងទទួលទានអាហារ) ព្រមទាំងការប្រមូលផ្តុំសហគមន៍ដើម្បីទ្រទ្រង់សាលារៀន និងការផ្តល់សេវាផ្នែកសិក្សា ហិរញ្ញវត្ថុ សុខភាព និងសេវាផ្ទាល់ខ្លួន/សង្គមបន្ថែមទៅលើការកែលម្អរចនាសម្ព័ន្ធ។ កុមារនៅក្នុងសាលារៀន BRIGHT បានបង្ហាញពីកំណើននៃការចូលរៀនប្រហែល១៦ភាគរយ។ ការពិសោធន៍នៅប្រទេសហ្វីលី ពីន (ដែលត្រូវបានវាយតម្លៃដោយ Tan et al., 1999) រួមមាន ការបង្កើតភាពជាដៃគូរវាងឪពុកម្តាយ និងគ្រូបង្រៀននៅក្នុងជម្រើសពីរ ក្នុងចំណោមជម្រើសបួន ហើយភាពជាដៃគូទាំងនេះទំនងជាអាចបង្កើនប្រសិទ្ធភាពនៃការផ្តល់សេវាផ្នែកសិក្សា។

ជាអកុសល ប្រភេទអន្តរាគមន៍ដែលត្រូវបានវាយតម្លៃលម្អិត២០ករណីនៅក្នុងប្រទេសកំពុងអភិវឌ្ឍមានការផ្លាស់ប្តូររចនាសម្ព័ន្ធតិចតួចលើអន្តរាគមន៍ដែលអាចធ្វើទៅបាន ដូច្នេះ វាមានការលំបាកក្នុងការធ្វើឲ្យមានលក្ខណៈទូទៅអំពីភាពជោគជ័យនៃគោលវិធីទាំងនេះ ពោលគឺ ត្រូវសាកល្បងឲ្យបានច្រើនជាងនេះ។

## ៣ការ ៣.បរិយាយនៃកម្មវិធីអន្តរាគមន៍សិស្សបោះបង់សាលាដែលមិនបានឆ្លើយតបទៅនឹង លក្ខណៈវិនិច្ឆ័យ របស់កម្មវិធីសាកល្បងទប់ស្កាត់សិស្សបោះបង់សាលា

## ៣ការជ្រើសរើសអន្តរាគមន៍ ១.៣.

អន្តរាគមន៍ថ្មីៗ៨ករណីផ្សេងទៀតនៅក្នុងបណ្តាប្រទេសកំពុងអភិវឌ្ឍ បានឆ្លើយតបទៅនឹង លក្ខណៈវិនិច្ឆ័យរបស់កម្មវិធីសាកល្បងទប់ស្កាត់សិស្សបោះបង់សាលាអំពី ភាពពាក់ព័ន្ធនៃប្រធានបទ ភាពពាក់ព័ន្ធនៃគម្រោងពេលវេលា និងភាពពាក់ព័ន្ធនៃគំរូតាង[12] ពោលគឺ រាល់អន្តរាគមន៍ទាំងអស់មានដូចតទៅៈ

- វង្វាស់ការចូលរៀន ការនៅរៀន និង/ឬការរៀនបានរីកចម្រើននៅសាលារៀន
- ការអនុវត្ត និងការវាយតម្លៃនៅចន្លោះឆ្នាំ១៩៩០ និង២០១០ និង
- ការផ្តោតទៅលើសិស្សក្នុងសាលាដែលប្រឈមនឹងការបោះបង់។

ទោះបីជាយ៉ាងនោះក្តី អន្តរាគមន៍មិនបានឆ្លើយតបទៅនឹងលក្ខណៈវិនិច្ឆ័យអំពីភាពពាក់ព័ន្ធនៃគម្រោង ដោយសារតែអន្តរាគមន៍ទាំងនេះបានប្រើប្រាស់គម្រោងព្រាវៗប្រៀបធៀបក្រុមមិនទទួលអន្តរាគមន៍ពីគម្រោង/ក្រុមទទួលអន្តរាគមន៍ពីគម្រោង ប៉ុន្តែមានការថយចុះគួរឲ្យកត់សម្គាល់ ឬ គម្រោងផ្អែកលើការពិសោធន៍ដែលមិនសមមូលទៅនឹងក្រុមមូលដ្ឋានព័ត៌មាន។ តារាងទី៩ បង្ហាញពីការបរិយាយសង្ខេបអំពីអន្តរាគមន៍ទាំងនេះ ហើយតារាងដែលមានព័ត៌មានបន្ថែមត្រូវបានរាប់បញ្ចូលជាឧបសម្ព័ន្ធ "គ"។

**តារាងទី៩ ៖ បញ្ជីកម្មវិធីអន្តរាគមន៍សិស្សបោះបង់សាលាដែលមិនបានឆ្លើយតបទៅនឹងលក្ខណៈវិនិច្ឆ័យរបស់កម្មវិធីសាកល្បងទប់ស្កាត់សិស្សបោះបង់សាលា**

| ប្រទេស | អ្នកវាយតម្លៃ | ប្រភេទសេវា |
|---|---|---|

[12] ពីព្រោះកម្មវិធីទប់ស្កាត់សិស្សបោះបង់សាលារាប់រយបានសាកល្បងនៅសហរដ្ឋអាមេរិក ប៉ុន្តែមិនត្រូវបានវាយតម្លៃលម្អិត កម្មវិធីទប់ស្កាត់សិស្សបោះបង់សាលាបានសម្រេចចិត្តផ្តោតលើកម្មវិធីនៅបណ្តាប្រទេសកំពុងអភិវឌ្ឍនៅក្នុងផ្នែកនេះ។

| | | |
|---|---|---|
| បង់ក្លាដេស៖ *អាហារសម្រាប់កម្មវិធីអប់រំ* | Ahmed & del Ninno (2002); Meng & Ryan (2007) | **ផ្នែកហិរញ្ញវត្ថុ៖** ផ្តល់គ្រាប់ពូជស្រូវសាលី ឬ អង្កប្រចាំខែតាមល័ក្ខខ័ណ្ឌស្តីពីការចូលរៀន។ |
| បង់ក្លាដេស៖ *កម្មវិធីប្រាក់ឧបត្ថម្ភសម្រាប់ស្ត្រី* | Khandker et al. (2003) | **ផ្នែកហិរញ្ញវត្ថុ៖** ការផ្ទេរប្រាក់មានល័ក្ខខ័ណ្ឌ |
| ប្រេស៊ីល | Graeff-Martins et al. (2006) | **ផ្នែកសិក្សា៖** សិក្ខាសាលាគ្រូបង្រៀន<br>**ផ្នែកផ្ទាល់ខ្លួន/សង្គម៖** អន្តរកម្មជាមួយគ្រួសារ ការប្រកួតតន្ត្រីស្តីពីសិស្សបោះបង់សាលា លេខទូរស័ព្ទទំនាក់ទំនងសុំជំនួយ កម្មវិធីស្តីពីគុណសម្បត្តិនៃការនៅរៀន ការវាយតម្លៃសុខភាពនៃខួរក្បាលរបស់ កុមារដែលអវត្តមានច្រើន |
| ឥណ្ឌា៖ *ការពិសោធន៍ Shankarpalle* | Reddy & Sinha (2010) | **ផ្នែកសិក្សា៖** សាលារៀននៅរដូវក្តៅសម្រាប់កុមារហួសអាយុចូលរៀន<br>**ផ្នែករចនាសម្ព័ន្ធ៖** យុទ្ធនាការចុះឈ្មោះកុមារគ្រប់រូប ការផ្លាស់ប្តូរគោលនយោបាយស្តីពីការឡើងថ្នាក់ ដោយស្វ័យប្រវត្តិ ការចុះឈ្មោះកុមារពេញមួយឆ្នាំ និងការអនុញ្ញាតឲ្យសាលាបឋមសិក្សាមានរហូតដល់ថ្នាក់ទី៧។ |
| ឥណ្ឌូណេស៊ី | Cameron (2009) | **ផ្នែកហិរញ្ញវត្ថុ៖** អាហារូបករណ៍តាមល័ក្ខខ័ណ្ឌស្តីពីការបន្តចុះឈ្មោះចូលរៀន |
| ប៉េរូ | Santiago & Chinen (2008) | **ផ្នែកសុខភាព៖** អាហារពេលព្រឹកនៅសាលារៀន |

| | | |
|---|---|---|
| ហ្វីលីពីន<br>*គម្រោង NODROPS* | SEAMEO (1995) | **ផ្នែកសិក្សា៖** ពង្រីកប្រព័ន្ធរៀនសូត្រជាមួយក្រុមសិក្សា និងបង្រៀនគួរ បណ្តុះបណ្តាលគ្រូបង្រៀន ជម្រើសសាលាតាមផ្ទះ កម្មវិធីសម្រាប់សិស្សបោះបង់សាលា និងការអប់រំសម្រាប់ឪពុកម្តាយ<br>**ផ្នែកហិរញ្ញវត្ថុ៖** ការផ្តល់សម្ភារៈសាលា និងការថែទាំសុខភាពដល់សិស្សប្រឈមនឹងការបោះបង់សាលាដោយឥតគិតថ្លៃ<br>**ផ្នែកសុខភាព៖** ការដាំបន្លែដើម្បីឧបត្ថម្ភអាហារសម្រន់នៅសាលាដោយឥតគិតថ្លៃ<br>**ផ្នែកផ្ទាល់ខ្លួន/សង្គម៖** ការជូនដំណឹងជាមុនអំពីសិស្សបោះបង់សាលា, ការពិនិត្យតាមដានរបស់ឪពុកម្តាយដោយយកចិត្តទុកដាក់<br>**ផ្នែករចនាសម្ព័ន្ធ៖** ក្តីកង្វល់អំពីសិស្សគេចសាលា យុទ្ធនាការស្តីពីសារៈសំខាន់នៃការអប់រំ។ |
| ហ្សាំបៀ | Chatterji et al. (2010) | **ផ្នែកសិក្សា៖** សាលារៀននៅសហគមន៍<br>**ផ្នែកសុខភាព៖** ការផ្តល់អាហារដល់សាលា និងសេវាគ្លីនិក |

## ៣ការ ២.៣.បរិយាយអំពីអន្តរាគមន៍ដែលមិនបានឆ្លើយតបទៅនឹងលក្ខណៈវិនិច្ឆ័យរបស់កម្មវិធីសាកល្បងទប់ស្កាត់សិស្សបោះបង់សាលា

តារាងទី១០សង្ខេបអំពីអន្តរាគមន៍ទាំង៨នេះ ដើម្បីធ្វើយ៉ាងណាឲ្យកុមារនៅរៀនបន្ត ដោយបង្ហាញពីក្រុមគោលដៅ វិធីសាស្ត្រវាយតម្លៃ និងប្រភេទនៃការផ្តល់សេវា។ ជាការពិតណាស់ ក្រុមអន្តរាគមន៍ដំបូងដែលបានឆ្លើយតបទៅនឹងលក្ខណៈវិនិច្ឆ័យលម្អិត ដែលភាគច្រើននៃអន្តរាគមន៍ទាំងនេះផ្តោតទៅលើកុមារថ្នាក់បឋមសិក្សា (៨៨ភាគរយ) ហើយវាពាក់ព័ន្ធនឹងអន្តរាគមន៍ផ្នែកហិរញ្ញវត្ថុ(៦២ភាគរយ) ច្រើនជាងប្រភេទផ្សេងទៀត។ ប៉ុន្តែ មានភាពខុសប្លែកគ្នាពីរ រវាងក្រុមសិក្សានេះ និងភាពខុសប្លែកគ្នានៅក្នុងក្រុមដែលត្រូវបានចាត់ថ្នាក់ដោយការវាយតម្លៃលម្អិត។ ទីមួយ ដោយសារតែគេបានវិនិច្ឆ័យថាអន្តរាគមន៍ទាំងនេះមិនឆ្លើយតបទៅនឹងលក្ខណៈវិនិច្ឆ័យវិធីសាស្ត្រ ដែលត្រូវបានបង្កើតឡើងដើម្បីធ្វើការវាយតម្លៃលម្អិតតាមការរំពឹងទុក បានជាជាទូទៅការសិក្សាទាំងនេះប្រើប្រាស់ គម្រោងផ្អែកលើការពិសោធន៍ ជាជាងការចាត់ចែងព្រាវៗ ដែលជារឿយៗមិនសមមូលនឹងក្រុមទទួលអន្តរាគមន៍ពីគម្រោង និងក្រុមមិនទទួលអន្តរាគមន៍ពីគម្រោងនៅកម្រិតមូលដ្ឋាន។ ទីពីរ ជារឿយៗ ការសិក្សាទាំងនេះកាន់តែមានទំនាក់ទំនងទៅនឹងសេវាផ្នែកសិក្សា និងសេវាផ្ទាល់ខ្លួន/សង្គម ពោលគឺ ៥០ភាគរយ នៃកម្មវិធីដែលមិនបានឆ្លើយតបទៅនឹងលក្ខណៈវិនិច្ឆ័យលើការវាយតម្លៃនៃកម្មវិធីសាកល្បងទប់ស្កាត់សិស្សបោះបង់សាលា (SDPP) មានសមាសភាគផ្នែកសិក្សាផ្ទុយគ្នានឹងអន្តរាគមន៍ដែលត្រូវបានវាយតម្លៃ

លម្អិត២១ភាគរយ ហើយ៣៨ភាគរយទៀតរួមមាន សេវាផ្ទាល់ខ្លួន/សង្គមផ្ទុយគ្នានឹងអន្តរាគមន៍ដែលត្រូវបានវាយតម្លៃលម្អិត៧ភាគរយ។

**តារាងទី១០ ៖ ការបែងចែកប្រភេទកម្មវិធីអន្តរាគមន៍សិស្សបោះបង់សាលាដែលមិនបានឆ្លើយតបទៅនឹងលក្ខណៈវិនិច្ឆ័យផ្អែកលើភស្តុតាងរបស់កម្មវិធីសាកល្បងទប់ស្កាត់សិស្សបោះបង់សាលា**

| លក្ខណៈសម្គាល់ | ចំនួន(ភាគរយ)នៃកម្មវិធីសិស្សបោះបង់ សាលា (N=8) |
|---|---|
| ក្រុមគោលដៅ[13] | |
| • សាលាបឋមសិក្សា | 7 (88%) |
| • មធ្យមសិក្សា | 3 (38%) |
| • វិទ្យាល័យ | 3 (38%) |
| វិធីសាស្ត្រ | |
| • គម្រោងព្រាវៗប្រៀបធៀបក្រុមមិនទទួលអន្តរាគមន៍ពីគម្រោង/ក្រុមទទួលអន្តរាគមន៍ពីគម្រោង | -- |
| • គម្រោងផ្អែកលើការពិសោធន៍ | 7 (88%) |
| • ផ្សេងៗ | 1 (12%) |
| ប្រភេទសេវា និងប្រសិទ្ធភាព[14] | |
| • ផ្នែកសិក្សា (ឧ. ការបង្រៀនគួរ អក្ខរកម្ម ឪពុកម្តាយ) | 4 (44%) |
| • ផ្នែកហិរញ្ញវត្ថុ (ឧ. ការផ្ទេរប្រាក់ ការផ្តល់អាហារដល់គ្រួសារ អាហារូបករណ៍) | 5 (62%) |
| • ផ្នែកសុខភាព (ឧ. ការកម្ចាត់ដង្កូវព្រូន ការផ្តល់អាហារដល់សាលារៀន ការចាក់ថ្នាំវ៉ាក់សាំង) | 3 (38%) |
| • ផ្នែកផ្ទាល់ខ្លួន/សង្គម (ឧ. ការបណ្តុះបណ្តាល ការប្រឹក្សាយោបល់ ការគ្រប់គ្រងករណី) | 3 (38%) |
| • ផ្នែករចនាសម្ព័ន្ធ (ឧ. សហគមន៍រៀនសូត្រ តូចៗ ការពិនិត្យតាមដានវត្តមានរបស់គ្រូបង្រៀន) | 2 (25%) |

[13] ក្រុមដែលមានអាយុដូចគ្នាលើសពីមួយអាចជាគោលដៅនៃអន្តរាគមន៍។

[14] គេអាចផ្តល់ប្រភេទសេវាលើសពីមួយនៅក្នុងអន្តរាគមន៍។

**អន្តរាគមន៍ផ្នែកសិក្សា។** កម្មវិធី៥ដែលមានសមាសភាគផ្នែកសិក្សា បានណែនាំសេវាខុសៗគ្នាពីអន្តរាគមន៍ដែលត្រូវបានវាយតម្លៃលម្អិត៖

- Chatterji et al. (2010) បានស្វែងរកភាពជោគជ័យនៃ *សាលាសហគមន៍* សម្រាប់កុមារកំព្រា និងកុមារដែលងាយរងគ្រោះនៅប្រទេសហ្សាំប៊ៀ។
- Graeff-Martins et al. (2006) បានពិនិត្យអន្តរាគមន៍ចម្រុះផ្នែកនៅក្នុងប្រទេសប្រេស៊ីល ដែលបានរាប់បញ្ចូល *សិក្ខាសាលាគ្រូបង្រៀន* ស្តីពីការអភិវឌ្ឍកុមារ និងការគ្រប់គ្រង ភាពច្របូកច្របល់ផ្នែកផ្លូវចិត្ត និងឥរិយាបថ។
- Reddy and Sinha (2010) បានពិនិត្យឡើងវិញនូវការពិសោធន៍ Shankarpalle នៅប្រទេស ឥណ្ឌា ដែលពាក់ព័ន្ធនឹង *សាលារៀនរដូវក្តៅសម្រាប់កុមារហួសអាយុចូលរៀន* ជាមួយនឹងការផ្លាស់ប្តូររចនាសម្ព័ន្ធជាច្រើន។
- SEAMEO (1995) បានរៀបរាប់អំពីគម្រោង NODROPS នៅក្នុងប្រទេសហ្វីលីពីន ដែលបានអនុវត្ត *ការពង្រីកប្រព័ន្ធរៀនសូត្រ* សម្រាប់កុមារ ការបណ្តុះបណ្តាលគ្រូបង្រៀនពេលចូលបម្រើការងារ និងការអប់រំក្រៅប្រព័ន្ធសម្រាប់ឪពុកម្តាយនៅក្នុងនៅក្នុងកំណែទម្រង់ដ៏ទូលំទូលាយ។

**អន្តរាគមន៍ផ្ទាល់ខ្លួន/សង្គម។** កម្មវិធី៣ ក្នុងចំណោមកម្មវិធី៥ដែលមានសមាសភាគផ្នែកសិក្សាក៏មានសមាសភាគផ្នែកផ្ទាល់ខ្លួន/សង្គម។ កម្មវិធីទាំងនេះបាននាំមកនូវទម្រង់បន្ថែមនៃអន្តរាគមន៍ដែលត្រូវបានផ្តល់នៅក្នុងអន្តរាគមន៍ដែលត្រូវបានវាយតម្លៃលម្អិត មានជាអាទិ៍ ការប្រឹក្សាយោបល់ (ក្រៅពីការអប់រំស្តីពីការបង្ការមេរោគអេដស៍/ជម្ងឺអេដស៍) នៅក្នុងប្រទេសហ្សាំប៊ៀ (Chatterji et al., 2010) អន្តរកម្មដ៏ទូលំទូលាយជាមួយឪពុកម្តាយ និងសិស្សស្តីពីបញ្ហាសិស្សបោះបង់សាលា និងការវាយតម្លៃសុខភាពផ្លូវចិត្តរបស់សិស្សដែលអវត្តមានច្រើននៅប្រទេសប្រេស៊ីល (Graeff-Martins et al., 2006) និងប្រព័ន្ធជូនដំណឹងជាមុនដើម្បីកំណត់សិស្សដែលប្រឈមនឹងការបោះបង់សាលា និងការ ពិនិត្យតាមដានជិតដល់ពីមាតាបិតាសិស្សនៅក្នុងប្រទេសហ្វីលីពីន (SEAMEO, 1995)។

**អន្តរាគមន៍ផ្នែករចនាសម្ព័ន្ធ។** កម្មវិធីទាំងពីរដែលបានរាប់បញ្ចូលអន្តរាគមន៍ផ្នែករចនាសម្ព័ន្ធបានបន្ថែមយុទ្ធនាការសាធារណៈទៅក្នុងសកម្មភាពចម្រុះ។ នៅក្នុងការពិសោធន៍ Shankarpalle នៅប្រទេសឥណ្ឌា ដែល

ត្រូវបានវាយតម្លៃដោយ Reddy និង Sinha (2010) គម្រោងនេះបានបើកយុទ្ធនាការលើកកម្ពស់ពលកម្មកុមារ និងចុះឈ្មោះចូលរៀនដល់កុមារគ្រប់រូប។ នៅក្នុងកម្មវិធី NODROPS នៅប្រទេសហ្វីលីពីនដែលត្រូវបានវាយតម្លៃដោយ SEAMEO (1995) យុទ្ធនាការនេះផ្តោតទៅលើសារៈសំខាន់នៃការអប់រំ និងបញ្ហានានាដែលបង្កឲ្យមានការបោះបង់សាលា។

សកម្មភាពរចនាសម្ព័ន្ធផ្សេងទៀតរួមមានការផ្លាស់ប្តូរគោលនយោបាយសាលារៀន ដែលត្រូវបានចាត់ទុកថាជាការរួមចំណែកនាំឲ្យមានបញ្ហាសិស្សបោះបង់សាលា។ នៅក្នុងការពិសោធន៍ Shankarpalle គោលនយោបាយថ្មី៣ត្រូវបានដាក់ចេញ ក្នុងនោះរួមមានៈ

- ការឡើងថ្នាក់ដោយស្វ័យប្រវត្តិពីថ្នាក់ទី១ ទៅថ្នាក់ទី២ បានលុបបំបាត់របាំងដ៏ធំរបស់កុមារដែលរៀនត្រួតថ្នាក់ទី១ច្រើនឆ្នាំ។
- ការចូលរៀនបន្តជាស្វ័យប្រវត្តិពេញមួយឆ្នាំ ក្រៅពីគោលនយោបាយអនុញ្ញាតឲ្យកុមារចូលរៀននៅដើមឆ្នាំសិក្សានីមួយៗ និង
- ការអនុញ្ញាតឲ្យសាលាបឋមសិក្សាមានរហូតថ្នាក់ទី៧ ដូច្នេះកុមារមានភាពងាយស្រួលក្នុងការទៅរៀននៅសាលាក្នុងមូលដ្ឋានរបស់ខ្លួន។

នៅក្នុងគម្រោង NODROPS សាលារៀននានាបានផ្លាស់ប្តូរគោលនយោបាយរបស់ខ្លួន ទាក់ទងនឹងសិស្សអវត្តមានពីសាលារៀន តាមរយៈការកត់អវត្តមានដើម្បីពិនិត្យតាមដានឲ្យបានសកម្មទៅលើសិស្សគេចសាលា។

ជាចុងក្រោយនេះ ការពិសោធន៍ Shankarpalle បានអនុវត្តកម្មវិធីថ្មីមួយ មានឈ្មោះថា "បញ្ចប់ថ្នាក់ទី១ (Clear Class One)" សម្រាប់៣រដូវក្តៅជាប់គ្នា ដើម្បីជួយឲ្យកុមារធំៗ ដែលរៀននៅថ្នាក់ទី១បានទៅរៀននៅថ្នាក់បន្ទាប់ ឬខ្ពស់ជាង ស្របតាមអាយុរបស់ពួកគេ និងឲ្យក្រុមកុមារ ដែលមានអាយុតែ៥-ទៅ ៦ឆ្នាំចូលរៀននៅថ្នាក់ទី១។

**អន្តរាគមន៍ផ្នែកសុខភាព។** កម្មវិធីផ្តល់អាហារដល់សាលាត្រូវបានផ្តល់នៅក្នុងអន្តរាគមន៍នីមួយៗក្នុងចំណោមអន្តរាគមន៍ផ្នែកសុខភាពបី មានជាអាទិ៍ នៅប្រទេសប៉េរូ ផ្តល់អាហារពេលព្រឹកនៅសាលារៀន (Santiago & Chinen, 2008) នៅប្រទេសហ្វីលីពីន គម្រោងសួនជីវចម្រុះ ដែលបានផ្តល់អាហារសម្រន់ដល់

កុមារ ដោយឥតគិតថ្លៃ (SEAMEO, 1995) និង នៅប្រទេសហ្សាំបៀ ផ្តល់អាហារថ្ងៃត្រង់នៅសាលារៀន (Chatterji et al., 2010)។ ចំពោះអាហារថ្ងៃត្រង់នៅសាលារៀន ប្រទេសហ្សាំបៀក៏មានបន្ថែមសេវាគ្លីនិកផងដែរ។ នៅប្រទេសប៉េរូ កម្មវិធីអាហារពេលព្រឹក គឺជាអន្តរាគមន៍គម្រោងតែមួយគត់ ចំណែកឯនៅប្រទេសពីរផ្សេងទៀត អន្តរាគមន៍ផ្នែកសុខភាពត្រូវច្របាច់បញ្ចូលជាមួយប្រភេទសេវាផ្សេងទៀត។

**អន្តរាគមន៍ផ្នែកហិរញ្ញវត្ថុ។** សេវាផ្នែកហិរញ្ញវត្ថុ៥នៅក្នុងអន្តរាគមន៍ទាំង៨នេះឆ្លុះបញ្ចាំងពីការ ផ្តល់សេវានៅក្នុងកម្មវិធីដែលត្រូវបានវាយតម្លៃលម្អិតដូចខាងក្រោមនេះ ៖

- ការគាំទ្រតាមល័ក្ខខ័ណ្ឌត្រូវបានផ្តល់នៅក្នុងកម្មវិធីស្បៀងអាហារសម្រាប់ការអប់រំ នៅប្រទេសបង់ក្លាដេស មានជាអាទិ៍ អង្ករ និងស្រូវសាលី នៅពេលដែលកុមារចូលរៀនបានយ៉ាងហោច៨៥ភាគរយនៃឆ្នាំសិក្សា (Ahmed & del Ninno, 2002; Meng & Ryan, 2007)
- ការផ្ទេរប្រាក់មានល័ក្ខខ័ណ្ឌ ត្រូវបានប្រើនៅក្នុងកម្មវិធីផ្តល់ប្រាក់ឧបត្ថម្ភដល់ស្ត្រីនៅប្រទេសបង់ក្លាដេស (Khandker et al., 2003)
- កម្មវិធីអាហារូបករណ៍ត្រូវបានផ្តល់នៅប្រទេសឥណ្ឌា ផ្អែកលើល័ក្ខខ័ណ្ឌនៃសិស្សបន្តចុះឈ្មោះចូលរៀននៅសាលារៀន (Cameron, 2009) និង
- ផ្តល់សម្ភារៈសិក្សាដោយឥតល័ក្ខខ័ណ្ឌដល់សិស្សនៅប្រទេសហ្វីលីពីន (SEAMEO, 1995) និងនៅប្រទេសហ្សាំបៀវិញចេញថ្លៃសម្ភារៈសិក្សា និងថ្លៃសិក្សាដល់សិស្ស (Chatterji et al., 2010)។

## ៣ការវាយ ៣.៣.តម្លៃលើប្រសិទ្ធភាពនៃកម្មវិធី

តារាងទី១១នៅទំព័រខាងក្រោមនេះសង្ខេបអំពីលទ្ធផលនៃអន្តរាគមន៍ទាំងនេះ ដោយបញ្ជាក់ពីអថេរចំណុះ ដែលគេរកឃើញថារងអានុភាពជាចម្បងដោយសារកម្មវិធីនេះ។ គួរកត់សម្គាល់ផងដែរថា អន្តរាគមន៍ទាំងអស់នេះត្រូវបានអះអាងថា មានប្រសិទ្ធភាពក្នុងការបង្កើនចំនួនសិស្សចូលរៀន ឬកាត់បន្ថយអត្រាសិស្សបោះបង់សាលា ប៉ុន្តែ យើងត្រូវយកចិត្តទុកដាក់ក្នុងការទទួលស្គាល់សេចក្តីសន្និដ្ឋាននោះ ដោយសារតែការកំណត់នៃគម្រោងវាយតម្លៃរបស់ពួកគេ។

មានហេតុផលយ៉ាងតិចបី ដែលអ្នកអនុវត្តមិនយកការចាត់ចែងព្រាវៗមកអនុវត្តក្នុងការគ្រោងរៀបចំការវាយតម្លៃលើកម្មវិធីទាំងនេះ។ ហេតុផលទីមួយគឺថា អ្នកគ្រោងរៀបចំកម្មវិធីអាចជាអ្នកនយោបាយ គ្រូពេទ្យ ឬ

គ្រូបង្រៀន ដែលចង់ផ្តល់សេវា ហើយមិនយល់ឃើញថា ការវាយតម្លៃជាការសំខាន់នៅក្នុងសេវានោះ។ ដូច្នេះ ហើយបានជាពួកគេអាចចាប់ផ្តើមធ្វើអន្តរាគមន៍ ដោយគ្មានផែនការវាយតម្លៃ ហើយអ្នកស្រាវជ្រាវ ដែលមកចូលរួមក្នុងគម្រោងនេះក្រោយគេ នឹងត្រូវធ្វើឲ្យស្ថានភាពនោះប្រសើរឡើង តាមរយៈគម្រោងផ្អែកលើការពិសោធន៍ដែលកំណត់ក្រុមប្រៀបធៀប បន្ទាប់ពីហេតុការណ៍នោះ។ ដូច្នេះ ហេតុផលទីមួយនេះអាចបង្កឲ្យមានភាពមិនស៊ីសង្វាក់គ្នានៃក្រុមទាំងនេះ។ ហេតុផលទីពីរគឺថា ការចាត់ចែងព្រាវៗអាចមានប្រយោជន៍ នៅពេលដែលអ្នកស្រាវជ្រាវត្រូវតាមដានសិស្ស ដែលទទួលបានសេវានៃកម្មវិធីទាំងនេះ និងសិស្សដែលមិនទទួលបានសេវាទាំងនេះ។ ហេតុផលចុងក្រោយ ការចាត់ចែងព្រាវៗអាចជាការលំបាកផ្នែកនយោបាយ ដែលកុមារមួយចំនួននឹងមិនទទួលបានអ្វីដែលគេជឿថា ជាអន្តរាគមន៍ដ៏មានប្រយោជន៍។ ម្ចាស់ជំនួយសម្តែងនូវការកោតសរសើរចំពោះការវាយតម្លៃលម្អិតរបស់ពួកគេ ដោយក្តីអំណរអរគុណ និងមានឆន្ទៈក្នុង ការផ្តល់មូលនិធិដល់ ហើយសហគមន៍វាយតម្លៃនេះនឹងកំណត់ទៅលើគោលវិធីកាន់តែជឿនលឿនទៅមុខ ដូចជា គម្រោងវាយតម្លៃអានុភាពនៃគម្រោង ដែលនាំឲ្យមានការវិភាគលម្អិតអំពីអន្តរាគមន៍នានាដែលផ្តល់សេវាដល់សិស្ស ឬគ្រួសារទាំងអស់ដែលមានសិទ្ធិចូលរួម។

**តារាងទី១១៖ អថេរលទ្ធផលដែលទទួលអានុភាពពីសេវាអន្តរាគមន៍នីមួយៗ ដែលមិនបានឆ្លើយតបទៅនឹងលក្ខណៈវិនិច្ឆ័យវាយតម្លៃរបស់ កម្មវិធីសាកល្បងទប់ស្កាត់សិស្សបោះបង់សាលា**

| អន្តរាគមន៍ | ប្រសិទ្ធភាពនៃប្រភេទសេវានីមួយៗ | | | | |
|---|---|---|---|---|---|
| | ផ្នែកសិក្សា | ផ្នែកហិរញ្ញវត្ថុ | ផ្នែកសុខភាព | ផ្នែកផ្ទាល់ខ្លួន/សង្គម | ផ្នែករចនាសម្ព័ន្ធ |
| បង់ក្លាដេស៖ *កម្មវិធីផ្តល់ប្រាក់ឧបត្ថម្ភដល់ស្ត្រី* (Khandker et al., 2003) | | ចូលរៀន | | | |
| បង់ក្លាដេស៖ *អាហារសម្រាប់កម្មវិធីអប់រំ* (Ahmed & del Ninno, 2002; Meng & Ryan, 2007) | | ចូលរៀន, នៅរៀន | | | |
| ប្រេស៊ីល៖ (Graeff-Martins et al., 2006) | ចូលរៀន, នៅរៀន | | | ចូលរៀន, នៅរៀន | |

| អន្តរាគមន៍ | ប្រសិទ្ធភាពនៃប្រភេទសេវានីមួយៗ | | | | |
|---|---|---|---|---|---|
| | ផ្នែកសិក្សា | ផ្នែកហិរញ្ញវត្ថុ | ផ្នែកសុខភាព | ផ្នែកផ្ទាល់ខ្លួន/សង្គម | ផ្នែករចនាសម្ព័ន្ធ |
| ឥណ្ឌា៖ *ការពិសោធន៍ Shankarpalle* (Reddy & Sinha, 2010) | នៅរៀន | | | | នៅរៀន |
| ឥណ្ឌូណេស៊ី៖ (Cameron, 2009) | | នៅរៀន | | | |
| ប៉េរូ៖ (Santiago & Chinen, 2008) | | | ចូលរៀន, នៅរៀន | | |
| ហ្វីលីពីន៖ *គម្រោងគ្មានការបោះបង់* (SEAMEO, 1995) | នៅរៀន | នៅរៀន | នៅរៀន | នៅរៀន | នៅរៀន |
| ហ្សាំប៉ៀ (Chatterji et al., 2010) | នៅរៀន | នៅរៀន | នៅរៀន | នៅរៀន | |
| ចំនួន(ភាគរយ)នៃអន្តរា គមន៍មួយប្រភេទដែល គេរកបានរកឃើញថា មានប្រសិទ្ធភាព | 4/4 (100%) | 6/6 (100% ) | 3/3 (100%) | 3/3 (100%) | 2/2 (100%) |

## ៤សេចក្តីសន្និដ្ឋាន និងអនុសាសន៍ ០.

ក្នុងរយៈពេលមួយទសវត្សរ៍កន្លងនេះ ទោះបីជាកុមារគ្រប់រូបមានឱកាសទទួលបានការអប់រំច្រើនយ៉ាងណាក៏ដោយ ក៏ទំហំនៃកុមារបោះបង់សាលានៅតែជាបញ្ហាចោទនៅឡើយ។ ទោះបីជាទំហំនៃបញ្ហានេះមានលក្ខណៈខុសគ្នាទៅតាមតំបន់ និងតាមប្រទេសក៏ដោយ ក៏ទិន្នន័យថ្មីៗស្តីពីការអប់រំបង្ហាញថា ភាគរយនៃកុមារដែលបានចូលរៀនខ្ពស់គួរឲ្យកត់សម្គាល់ ប៉ុន្តែ ពួកគេមិនបានបញ្ចប់សូម្បី វដ្តអប់រំកម្រិតមូលដ្ឋាននោះទេ។ ការរៀនមិនបានចប់បែបនេះគឺជាការខ្ជះខ្ជាយធនធានដ៏ធំមួយសម្រាប់ពួកគេផ្ទាល់ ក៏ដូចជាប្រព័ន្ធអប់រំ និងសង្គមដែលពួកគេរស់នៅផងដែរ។ ទោះបីជាមានមតិទូទៅអំពីតម្លៃនៃការវិនិយោគ ដើម្បីទប់ស្កាត់សិស្សកុំឲ្យបោះបង់សាលាក៏ដោយ ក៏នៅតែមានការយល់ស្របតិចតួចអំពីថា តើវិនិយោគទាំងនោះធ្វើឡើងក្នុងគោលបំណងអ្វី។

ហេតុផលដែលសិស្សបោះបង់សាលាគឺស្មុគស្មាញណាស់។ នៅទីបំផុត គ្មានកត្តាហានិភ័យដែលអាចព្យាករណ៍ត្រឹមត្រូវ ឬទប់ស្កាត់សិស្សបោះបង់សាលានោះទេ។ ជាការពិតណាស់ ការសិក្សាស្រាវជ្រាវបង្ហាញ

ច្បាស់ថា ការដែលសិស្សបោះបង់សាលាអាចជាមុខងារមួយនៃការប្រមូលកត្តាហានិភ័យ (ឧ. យេនឌ័រ កាតព្វកិច្ចការងារ សមិទ្ធិផលទាប ភាពក្រីក្រក្នុងគ្រួសារ គ្រួសារមិនសូវមានទំនាក់ទំនងជាមួយសាលារៀន ឬ ការរស់នៅឆ្ងាយពីសាលារៀន) ចំណែកឯកត្តាចម្រុះវិញ មានជាអាទិ៍ កត្តាផ្ទាល់ខ្លួន កត្តាគ្រួសារ កត្តាសាលារៀន និងកត្តាសហគមន៍)។ ដូច្នេះ ទោះបីជាអាចមានហេតុការណ៍ច្បាស់លាស់ ដែលជាកាតាលីករ ឬ ធាតុផ្សំដែលនាំឲ្យសិស្សបោះបង់សាលា (ឧ. វិបត្តិប្រាក់ចំណូលពីសមាជិកគ្រួសារដែលស្លាប់ទៅ) ក៏ដោយ ក៏ជាទូទៅការបោះបង់សាលាគឺជាដំណើរការមួយ ដែលត្រូវប្រព្រឹត្តទៅបន្តទៀត។

នៅក្នុងការងារដែលយើងពិនិត្យឡើងវិញលើឯកសារស្រាវជ្រាវស្តីពី កម្មវិធីសិស្សបោះបង់សាលា យើងបានរកឃើញ២៦ករណី ដែលឆ្លើយតបទៅនឹងលក្ខណៈវិនិច្ឆ័យទាំងបួនសម្រាប់ដាក់បញ្ចូលក្នុងរបាយការណ៍នេះ មានជាអាទិ៍ ភាពពាក់ព័ន្ធនៃប្រធានបទ ភាពពាក់ព័ន្ធនៃគម្រោងពេលវេលា ភាពពាក់ព័ន្ធនៃគំរូតាង និងភាពពាក់ព័ន្ធនៃទម្រង់វាយតម្លៃ៖

- ការគាំទ្រផ្នែកហិរញ្ញវត្ថុ ផ្នែករចនាសម្ព័ន្ធ និងផ្នែកសិក្សា (តាមលំដាប់) អាចជាការគាំ ទ្រដ៏មានប្រសិទ្ធភាពបំផុតក្នុងការដោះស្រាយបញ្ហាសិស្សបោះបង់សាលានៅបណ្តា ប្រទេសកំពុងអភិវឌ្ឍ។
- ការគាំទ្រផ្នែករចនាសម្ព័ន្ធកាន់តែទទួលបានជោគជ័យ នៅពេលដែលការគាំទ្រនេះ ផ្តោតទៅលើតំបន់មូលដ្ឋាន ពោលគឺរាប់បញ្ចូលទាំងគ្រូបង្រៀន និងឪពុកម្តាយសិស្ស។
- ការគាំទ្រផ្នែកសិក្សាមានភាពពាក់ព័ន្ធច្រើនជាងការផ្តល់សម្ភារៈ (ឧ. សៀវភៅសិក្សា)
- ការផ្តោតទៅលើវិធានការ ឬសកម្មភាពមួយជួយបង្ហាញយ៉ាងច្បាស់ថា សកម្មភាពនោះ ជាហេតុផលមួយដើម្បីកាត់បន្ថយអត្រាសិស្សបោះបង់សាលា ប៉ុន្តែបណ្តុំនៃសកម្មភាពទាំងនេះអាចមានអានុភាពស្មើគ្នា ឬធំជាងទៅលើការផ្លាស់អានុភាពនេះ។

ជាចុងក្រោយនេះ ការពិនិត្យឡើងវិញរបស់យើងបានបង្ហាញយ៉ាងច្បាស់អំពីតម្រូវការ ឲ្យមានអន្តរាគមន៍ដែលគ្រោងរៀបចំយ៉ាងត្រឹមត្រូវ រួមមាន វិធីពិនិត្យតាមដាន និងវាយតម្លៃលម្អិតពីផ្នែកដើមនៃការអនុវត្តកម្មវិធី ដែលអាចផ្តល់ការណែនាំផ្អែកលើការស្រាវជ្រាវស្តីពីគោលនយោបាយ កម្មវិធី និងការអនុវត្ត ដែលនាំឲ្យកុមារនៅរៀនបន្ត។

***អនុសាសន៍*** ខាងក្រោមនេះអនុវត្តតាមការពិនិត្យឡើងវិញនូវឯកសារស្រាវជ្រាវនេះ នៅពេលដែលកម្មវិធីសាកល្បងទប់ស្កាត់សិស្សបោះបង់សាលា កំពុងធ្វើផែនការសកម្មភាពគម្រោងរបស់ខ្លួនដែលនៅសល់ ៖

១.កម្មវិធីសាកល្បងទប់ស្កាត់សិស្សបោះបង់សាលា(SDPP) ត្រូវគ្រោងរៀបចំអន្តរាគមន៍នីមួយៗដើម្បីឲ្យស្របទៅនឹងបរិបទនៃតំបន់ដែលនឹងត្រូវអនុវត្ត

រាល់កត្តានិហាភ័យទាំងអស់ មិនមែនសុទ្ធតែកើតមានចំពោះកុមារនោះទេ ហើយកត្តាហានិភ័យដែលកំពុងតែកើតមាននៅតំបន់ណាមួយ អាចមានលក្ខណៈខុសគ្នាច្រើនពីកត្តាហានិភ័យនៅតំបន់មួយផ្សេងទៀត។ មុនពេលគ្រោងរៀបចំអន្តរាគមន៍ បុគ្គលិកកម្មវិធីសាកល្បងទប់ស្កាត់សិស្សបោះបង់សាលា(SDPP) ចាំបាច់ត្រូវឈ្វេងយល់អំពីស្ថានភាពនៅក្នុងប្រទេសគោលដៅនីមួយៗ។ នៅក្នុងប្រទេសមួយ អាចមានកម្លាំងការងារខុសគ្នានៅក្នុងសហគមន៍ផ្សេងៗគ្នា ដូច្នេះហើយបានជាដំណើរការគម្រោងត្រូវរាប់បញ្ចូលកិច្ចពិភាក្សាអំពីក្រុមគោលដៅ តំបន់ និងការវិភាគដែលសមស្របអំពីលក្ខណៈសម្គាល់សិស្សបោះបង់សាលានៅក្នុងក្រុម និងតំបន់ទាំងនោះ។

២.កម្មវិធីសាកល្បងទប់ស្កាត់សិស្សបោះបង់សាលា(SDPP) ត្រូវពិចារណាលើភាពពាក់ព័ន្ធនៃតម្រូវការហិរញ្ញវត្ថុដ៏ច្រើននៅក្នុងប្រទេសគោលដៅនីមួយៗក្នុងការគ្រោងរៀបចំអន្តរាគមន៍ ពោលគឺ គ្រួសារនីមួយៗអាចផ្តល់សេវាជាវត្ថុ ប៉ុន្តែមិនមែនជាលុយនោះទេ ហើយកុមារមិនអាចចូលរួមក្នុងសកម្មភាពណាមួយបានទេ បន្ទាប់ពីម៉ោងសិក្សា។

លក្ខណៈសម្គាល់ពីរនៃសិស្សបោះបង់សាលា ដែលត្រូវបានលើកឡើងញឹកញាប់បំផុត នៅក្នុងឯកសារស្រាវជ្រាវទាក់ទងនឹងប្រទេសកំពុងអភិវឌ្ឍគឺ (ក)កម្រិតនៃភាពក្រីក្រក្នុងគ្រួសារ និង(ខ)ការតម្រូវឲ្យកុមារជួយធ្វើការនៅផ្ទះ ឬរកប្រាក់។ ទោះបីជាយ៉ាងណាក៏ដោយ កម្មវិធីសាកល្បងទប់ស្កាត់សិស្សបោះបង់សាលា (SDPP) មិនទទួលខុសត្រូវលើកម្មវិធីផ្តល់ប្រាក់លើកទឹកចិត្តនោះទេ។ ផ្ទុយទៅវិញ កម្មវិធីនេះត្រូវទទួលស្គាល់ថា (ក) គ្រួសារដែលត្រូវការទំនុកបម្រុងគ្រាន់តែអាចបរិច្ចាគជាវត្ថុដល់គម្រោងសាលារៀនប៉ុណ្ណោះ ហើយ (ខ)កុមារនឹងត្រូវតម្រូវឲ្យនៅធ្វើការនៅផ្ទះដដែល និងមិនអាចចូលរៀនឲ្យបានច្រើនម៉ោងក្នុងមួយថ្ងៃច្រើនដូចដែលថ្នាក់រៀនបានតម្រូវឡើយ។

៣. កម្មវិធីសាកល្បងទប់ស្កាត់សិស្សបោះបង់សាលា(SDPP)អាចផ្តោតទៅលើកុមារី កុមារពិការ ឬកុមារមានបញ្ហាសុខភាព និងកុមារដែលរស់នៅឆ្ងាយពីសាលារៀនប្រកបដោយភាពជោគជ័យ ខណៈពេលដែលក្រុមទាំងនេះទំនងជាបោះបង់សាលាច្រើនជាងក្រុមផ្សេងទៀត។

| មានវិបត្តិកើតឡើងដូចជាជម្លោះ-គ្រោះអាសន្ន- ភាពផុយស្រួលនៃនយោបាយ | | | | | x | | | | | x |
| សញ្ញាណវប្បធម៌/ពិធីប្រពៃណីផ្សេងៗដែលនាំឲ្យអាក់ខានដល់ការសិក្សា | | | | | | | | | | |

# ឧបសម្ព័ន្ធ គ

## សេចក្តីសង្ខេបនៃការសិក្សាអំពីអន្តរាគមន៍សិស្សបោះបង់សាលាដែលឆ្លើយតបទៅនឹងលក្ខណៈវិនិច្ឆ័យរបស់កម្មវិធីសាកល្បងទប់ស្កាត់សិស្សបោះបង់សាលា(SDPP)

**តារាង គ-១ ៖ កម្មវិធីអន្តរាគមន៍សិស្សបោះបង់សាលាដែលឆ្លើយតបនូវរាល់លក្ខណៈវិនិច្ឆ័យរបស់កម្មវិធីសាកល្បងទប់ស្កាត់សិស្សបោះបង់សាលា**( SDPP )

| អ្នកនិពន្ធ | លទ្ធផល ចម្បង | ក្រុមគោលដៅ | សេវា | វិធីសាស្ត្រ | តម្លៃ | អានុភាព |
|---|---|---|---|---|---|---|
| អន្តរាគមន៍នៅក្នុងប្រទេសអភិវឌ្ឍ (តាមលំដាប់អក្សរឈ្មោះអន្តរាគមន៍) | | | | | | |
| 1) ការបង្កើនសាលាមធ្យមសិក្សា (Dynarski et al., 1998) | • នៅរៀនក្នុងសាលា<br>• រៀនបានរីកចម្រើននៅសាលា | សិស្សថ្នាក់ទី៦ ដល់ទី ៨ នៅ តាមទីប្រជុំជនចំនួន ៣ កន្លែង រាល់ សិស្សទាំងនោះរៀនយឺតក្រោយកម្រិតថ្នាក់ពី១ ទៅ២ ឆ្នាំ។ | **ការសិក្សា៖**<br>• កម្មវិធីសិក្សារយៈពេល ២ឆ្នាំ ក្នុងឆ្នាំសិក្សាមួយឆ្នាំ<br>• ការបង្រៀនគួរ<br>**ផ្ទាល់ខ្លួន/សង្គម៖**<br>• ការប្រឹក្សាយោបល់<br>• ការផ្សព្វផ្សាយដល់ក្រុមគ្រួសារ<br>**រចនាសម្ព័ន្ធ៖**<br>• ទំហំថ្នាក់តូច | គម្រោងព្រាវៗប្រៀបធៀបក្រុមមិនទទួលអន្តរាគមន៍ពីគម្រោង/ក្រុមទទួលអន្តរាគមន៍ (RCT)៖ សិស្សចំនួន ៨៤៧នាក់<br>• GA៖ ៦០% ជាជនជាតិអាមេរិកដើមកំណើតអាហ្វ្រិក, ជាង ៧០% ភេទប្រុស<br>• NJ៖ ៧៥% ជាជនជាតិអាមេរិក-អាហ្វ្រិក ២៥% ជាជនជាតិអាមេរិកឡាទី(ហ៊ីស្ប៉ានិក) ដោយ៥០%ភេទប្រុស<br>• MI៖ ៦០% ជាជនជាតិ អាមេរិកកាត់ | • ៧,០០០ដុល្លាសម្រាប់សិស្សម្នាក់ ក្នុងរយៈមួយឆ្នាំនៅ GA។<br>• ១៣,០០០ ដុល្លារក្នុងរយៈមួយ ឆ្នាំនៅ NJ។<br>• ១១,០០០ ដុល្លាក្នុងរយៈមួយឆ្នាំនៅ MI។<br>(តម្លៃគិតជាដុល្លារ ក្នុងឆ្នាំ ២០០៧) | • លទ្ធផលវិជ្ជមានលើការនៅរៀន (ការកើនឡើងជាមធ្យម ១៨%)<br>• លទ្ធផលវិជ្ជមានលើការរៀនបានរីកចម្រើននៅសាលា (ការកើនឡើងជាមធ្យម៣៥%) |

| អ្នកនិពន្ធ | លទ្ធផលចម្បង | ក្រុមគោលដៅ | សេវា | វិធីសាស្ត្រ | តម្លៃ | អានុភាព |
|---|---|---|---|---|---|---|
| | | | | អាហ្វ្រិក ដោយ ៦០% ភេទប្រុស | | |
| 2) **សមិទ្ធិផលសម្រាប់ជនជាតិអាមេរិកឡាទីន តាមរយៈភាពជោគជ័យនៃការសិក្សា** (ALAS) (Larson & Rumberger, 2005) | • នៅរៀនក្នុងសាលា<br>• រៀនបានរីកចម្រើននៅសាលា | សិស្សថ្នាក់ទី៧ ដល់ទី៨ នៅឡូសអេនជេឡេស រដ្ឋ CA (ទីប្រជុំជន) ប្រឈមនឹងការបោះបង់សាលាដោយសារការសិក្សាខ្សោយ ឬមានបញ្ហាឥរិយា បថ | **ផ្ទាល់ខ្លួន/សង្គម៖**<br>• ថ្នាក់ពិសេសស្តី អំពីជំនាញដោះ ស្រាយបញ្ហា<br>• ការគ្រប់គ្រងករណី<br>• ការតាមដានវត្តមានដឹតដល់<br>• ការផ្សព្វផ្សាយដល់ក្រុមគ្រួសារ | គម្រោងព្រាវៗប្រៀបធៀបក្រុមមិនទទួលអន្តរាគមន៍ពីគម្រោង/ក្រុម **ទទួលអន្តរាគមន៍** (RCT)៖សិស្ស ៩៤ នាក់ មាន៩៦% ជាជនជាតិអាមេរិកឡាទីន ដោយ ៦៥%ភេទប្រុស | ១,១៨៥ដុល្លារសម្រាប់សិស្សម្នាក់ក្នុងរយៈពេលមួយឆ្នាំ (២០០៥) | • លទ្ធផលវិជ្ជមានលើការនៅរៀន(កើនឡើងជាមធ្យម ៤២%)<br>• លទ្ធផលវិជ្ជមានលើការរៀនបានរីកចម្រើននៅសាលា (ការកើន ឡើងមធ្យម ១៩%) |
| 3) **ការសិក្សាស្រាវជ្រាវជាន់ខ្ពស់** (Kemple & Snipes, | • នៅរៀនក្នុងសាលា<br>• រៀនបានរីកចម្រើននៅ | សិស្សវិទ្យាល័យដែលប្រឈមនឹងការបោះបង់សាលានៅទីប្រជុំជនចំនួន ៨ | **ការសិក្សា៖**<br>• មុខវិជ្ជា ដែលបានរៀបចំទាក់ទិននឹងការងារ | **គម្រោងព្រាវៗប្រៀបធៀបក្រុមមិនទទួលអន្តរាគមន៍ពីគម្រោង/ក្រុមទទួលអន្តរាគមន៍** | ៦០០ដុល្លារអាមេរិកសម្រាប់សិស្សម្នាក់ ក្នុងរយៈមួយឆ្នាំ ច្រើនជាងការ | • លទ្ធផលជាវិជ្ជមានលើការ នៅរៀន (ការកើនឡើង |

| អ្នកនិពន្ធ | លទ្ធផលចម្បង | ក្រុមគោលដៅ | សេវា | វិធីសាស្ត្រ | តម្លៃ | អានុភាព |
|---|---|---|---|---|---|---|
| 2000; Kemple, 2004) | សាលា | កន្លែង ក្នុងរដ្ឋចំនួន៦ | **ផ្ទាល់ខ្លួន/សង្គមៈ**<br>• ចុះកម្មសិក្សាជាមួយនឹងនិយោជក តាមមូលដ្ឋាន<br>• បណ្តុះបណ្តាលដោយនិយោជកមូលដ្ឋាន<br>**រចនាសម្ព័ន្ធ**<br>• សាលានៅក្នុងក្របខណ្ឌសាលាមួយ | (RCT)៖ សិស្សចំនួន ៩៧៤ នាក់ កុមារមានអាយុ១៥ឆ្នាំ ឬក្រោម មាន៧៩%, កុមារីមាន ៥៧%ជនជាតិហ៊ីស្ពេនិក មាន៥២% ជនជាតិអាមេរិកកាត់អាហ្វ្រិក មាន៣៨% | ចំណាយជាមធ្យមសម្រាប់សិស្សម្នាក់នៅក្នុងស្រុកមួយ (ឆ្នាំ ២០០៨) | ជាមធ្យម ១៣%)<br>• លទ្ធផលជាវិជ្ជមានលើការរៀនបានរីកចម្រើននៅសាលា (ការកើនឡើងជាមធ្យម ១៣%) |
| 4) **ត្រួតពិនិត្យ និង ទំនាក់ទំនង**(Sinclair et al., 1998, 2005) | • នៅរៀនក្នុងសាលា<br>• រៀនបានរីកចម្រើននៅសាលា | សិស្សថ្នាក់ទី៦ ដល់ទី១២ នៅ Minneapolis (ទីប្រជុំជន) ដែលពិការខាងការសិក្សា ខាងស្មារតី និងកាយវិការ | **ការសិក្សាៈ**<br>• ការបង្រៀនគួរ<br>**ផ្ទាល់ខ្លួន/សង្គមៈ**<br>• ការគ្រប់គ្រងករណី<br>• ការតាមដានវត្តមានជិតដល់<br>• ការបណ្តុះបណ្តាល<br>• ការផ្សព្វផ្សាយដល់គ្រួសារ | **គម្រោងព្រាវៗប្រៀបធៀបក្រុមមិនទទួលអន្តរាគមន៍/ក្រុមទទួលអន្តរាគមន៍ (RCT)៖** មានសិស្សចំនួន ២៣៨ ជន ជាតិអាមេរិក កាត់អាហ្វ្រិកមាន៦២% ដោយ៧៨%ភេទប្រុស | ១,៤០០ដុល្លាសម្រាប់សិស្សម្នាក់ក្នុងរយៈពេលមួយឆ្នាំ (២០០១-២០០២) | • លទ្ធផលជាវិជ្ជមានលើការនៅរៀន (ការកើនឡើងជាមធ្យម ២៥%)<br>• លទ្ធផលជាវិជ្ជមានលើការរៀនបានរីកចម្រើននៅ |

| អ្នកនិពន្ធ | លទ្ធផល ចម្បង | ក្រុមគោលដៅ | សេវា | វិធីសាស្ត្រ | តម្លៃ | អានុភាព |
|---|---|---|---|---|---|---|
| | | | | | | សាលា (ការកើនឡើងជាមធ្យម៣០%) |
| 5) **វិទ្យាល័យអភិវឌ្ឍជំនាញ** (Kemple et al., 2005) | • រៀនបានរីកចម្រើននៅសាលា | សិស្សវិទ្យាល័យនៅវិទ្យាល័យក្នុងទីប្រជុំជនចំនួន១១ នៅភីឡាឌែលហ្វីយ៉ា, PA (តំបន់ប្រជុំជន) | **ការសិក្សា**<br>• កម្មវិធីសិក្សាផ្តោតលើ ការត្រៀមចូលមហាវិទ្យាល័យ ការបង្រៀនការអាន និងការណែនាំអំពី គណិតសាស្ត្រ<br>• សិក្សាក្រៅម៉ោងសម្រាប់សិស្សមានបញ្ហាវត្តមាន ឬវិន័យ<br>• បុគ្គល/សង្គមៈ<br>• សេវាជំនួយ ក្រៅម៉ោង សាលា<br>**រចនាសម្ព័ន្ធៈ**<br>• សាលាត្រូវកែទម្រង់ឡើងវិញ នៅក្នុងសហគមន៍សិក្សាតូច | គម្រោងផ្អែកលើការពិសោធន៍QEDៈ (ស៊េរីពេលវេលារំខានដោយប្រៀបធៀប, Ns មិនបានបញ្ចូលក្នុងរបាយការណ៍នោះទេ) | ៣៥០ដុល្លារ សម្រាប់សិស្សម្នាក់ក្នុងមួយឆ្នាំច្រើនជាងការចំណាយជាមធ្យមសម្រាប់សិស្សម្នាក់នៅក្នុងស្រុក (ឆ្នាំ២០០៥) | • លទ្ធផលជាវិជ្ជមានលើការរៀន បានរីកចម្រើននៅសាលា (កើនឡើងជាមធ្យម ៧%) |

| អ្នកនិពន្ធ | លទ្ធផលចម្បង | ក្រុមគោលដៅ | សេវា | វិធីសាស្ត្រ | តម្លៃ | អានុភាព |
|---|---|---|---|---|---|---|
| 6) **កម្មវិធីគាំទ្រ និងតាមដានសិស្សរយៈពេលមួយឆ្នាំ** (Dynarski et al., 1998) | • នៅរៀនក្នុងសាលា | សិស្សថ្នាក់ទី៦ ដល់ទី៩ នៅជូឡា វីស្តា រដ្ឋ CA (ទីប្រជុំជន) | **ការសិក្សា៖**<br>• ជំនួយកិច្ចការសាលា **ផ្ទាល់ខ្លួន/សង្គម៖**<br>• ការពិភាក្សាជាក្រុមក្រៅម៉ោងប្រចាំសប្តាហ៍ជាមួយនឹង មនុស្សពេញវ័យដែលទទួលបានការបណ្តុះ បណ្តាល<br>• ទស្សនកិច្ចនៅតាមមហាវិទ្យាល័យ<br>• ដំណើរចុងសប្តាហ៍ប្រចាំឆ្នាំ | គម្រោងព្រាវៗប្រៀប**ធៀបក្រុមមិនទទួលអន្តរាគមន៍ពីគម្រោង/ក្រុមទទួលអន្តរាគមន៍** (RCT)៖ មានសិស្សចំនួន ២១៩ នាក់ នៅមធ្យមសិក្សា ជនជាតិហ៊ីស្ប៉ានិកមាន ៥០% ជនជាតិអាស៊ីមាន ២៥% អាមេរិកកាត់អាហ្វ្រិកមាន ១០%, ជនជាតិ ស្បែកសមាន ១៥% ដោយ មិនបានដឹងពីចំនួនប្រុស/ស្រីទេ | ៣០៧ដុល្លារសម្រាប់សិស្សម្នាក់ក្នុងមួយខែ សម្រាប់៩ខែ ឬ ២,៧៦៣ដុល្លារអាមេរិកក្នុងមួយ រយៈឆ្នាំ (ឆ្នាំ ២០០៨) | • លទ្ធផលជាវិជ្ជមានលើការនៅរៀន (កើនឡើង ជាមធ្យម ១៣%) |

| **អន្តរាគមន៍ក្នុងប្រទេសកំពុងអភិវឌ្ឍ (តាមលំដាប់អក្សរនៃប្រទេសនីមួយៗ)** | | | | | | |
|---|---|---|---|---|---|---|
| 7) ប្រទេសប្រេស៊ីល Bolsa Familia (Glewwe & Kassouf, 2010) | • នៅរៀនក្នុងសាលា<br>• រៀនបានរីកចម្រើននៅសាលា | គ្រួសារក្រីក្រ មានកូនដែលមានអាយុចាប់ ៦ឆ្នាំ ដល់ ១៥ ឆ្នាំ (ថ្នាក់ទី១ ដល់ថ្នាក់ទី៨) នៅក្នុងប្រទេស (ជនបទ និងទីប្រជុំជន) | **ហិរញ្ញវត្ថុ៖ ការផ្ទេរប្រាក់មានលក្ខខ័ណ្ឌចំពោះគ្រួសារផ្អែកលើការ ចុះឈ្មោះ និង ការចូលរៀននៅសាលា យ៉ាងតិចមាន ៨៥% នៃម៉ោងសិក្សា** | គម្រោងផ្អែកលើការពិសោធន៍(QED)៖ ទិន្នន័យជំរឿនចាប់ពីឆ្នាំ១៩៩៨ ដល់ឆ្នាំ ២០០៥ ដោយជ្រើសរើសពីសាលា ដែលមានទិន្នន័យគ្រប់ឆ្នាំ | ៧.៥០ ដុល្លារ សម្រាប់កូនម្នាក់ក្នុងមួយខែ ដល់កូនបីនាក់ ជាអតិបរមា(២០០៥) | • ការចុះឈ្មោះកើនឡើង ចាប់ពី៥.៥% សម្រាប់ថ្នាក់ទី ១ ដល់ទី៤ និង ចាប់ពី ៦.៥% សម្រាប់ថ្នាក់ទី ៥ ដល់ទី៨<br>• អត្រាបោះបង់សាលា ធ្លាក់ចុះចាប់ពី ០.៥%សម្រាប់ ថ្នាក់ទី១ ដល់ទី៤ និងចាប់ពី ០.៤% សម្រាប់ថ្នាក់ទី ៥ដល់ទី៨<br>• អត្រាឡើងថ្នាក់កើនឡើង ចាប់ពី ០.៩% |

| | | | | | | |
|---|---|---|---|---|---|---|
| | | | | | | សម្រាប់ថ្នាក់ទី ១ ដល់ទី៤ និង ចាប់ពី ០.៣% សម្រាប់ថ្នាក់ទី ៥ ដល់ទី៨ |
| 8) ប្រទេសបួគីណាហ្វាសូ, **ការឆ្លើយតបរបស់ជនជាតិបួគីណាដើម្បីលើកកម្ពស់ភាពជោគជ័យរបស់ កុមារីដែលជាកម្មវិធីលើកកម្ពស់ការអប់រំក្នុងប្រទេសបួគីណាហ្វាសូ** (BRIGHT) (Levy et al., | • ចូលរៀននៅសាលា | កុមាររៀននៅបឋមសិក្សា (ជាពិសេសកុមារី) នៅភូមិ តាមជនបទ ចំនួន ១៣២ តាមខេត្តចំនួន ១០ មានអត្រាកុមារីបញ្ចប់ការសិក្សានៅបឋមសិក្សាទាបបំផុត | **ការសិក្សា៖**<br>• បើកសាលាមួយ ក្នុងភូមិមួយ ដែលមិនធ្លាប់សាលា<br>• ផ្តល់ការបណ្តុះ បណ្តាលអក្ខរកម្មដល់មនុស្សពេញវ័យ<br>**ហិរញ្ញវត្ថុ៖**<br>• ជាមួយនឹងការចូលរៀនបាន ៩០%កុមារីទទួលធញ្ញជាតិស្ងួត ៨ គីឡូ ដើម្បីយកទៅផ្ទះ<br>• ផ្តល់សៀវភៅពុម្ព និងសម្ភារៈ សិក្សាសាលាដល់គ្រប់កុមារទាំងអស់ | គម្រោងផ្អែកលើការពិសោធន៍(QED)៖ **ការបញ្ចប់ការថយចុះ ៖** កុមារនៅភូមិ BRIGHT ចំនួន ១៣២នាក់ប្រៀបធៀបជាមួយនឹងកុមារមកពីភូមិប្រហាក់ប្រហែលនឹងកុមារចូលរួមក្នុង BRIGHT ប៉ុន្តែមិនត្រូវបានជ្រើសរើស។ គ្រួសារចំនួន ៨,៧៩០ ដែលបានអង្កេត មានកុមារចំនួន ២១,៧៣០ នាក់ជ្រើស ប្រឡងគណិ | មិនមានព័ត៌មានអំពីថ្លៃសាលា | កុមារនៅសាលា BRIGHTបានបង្ហាញថា<br>• ការកើនឡើងប្រហែល ២០% ក្នុងការចុះឈ្មោះចូលរៀន ផ្អែកតាមទិន្នន័យអង្កេតពីគ្រួសារនិងប្រហែល ១៦% ផ្អែកតាមទិន្នន័យសាលា<br>• ការកើន |

| | | | | | | |
|---|---|---|---|---|---|---|
| 2009) | | | **សុខភាព៖**<br>• ផ្តល់អាហារថ្ងៃត្រង់ជារៀងរាល់ថ្ងៃ<br>**ផ្ទាល់ខ្លួន/សង្គម៖**<br>• ណែនាំដល់កុមារី<br><br>**រចនាសម្ព័ន្ធ៖**<br>• សាងសង់សាលាមានថ្នាក់រៀនចំនួន៣ ផ្តល់កន្លែងស្នាក់នៅដល់គ្រូចំនួន៣នាក់និងបង្គន់ផ្សេងគ្នាសម្រាប់កុមារ និងកុមារី និងម៉ាស៊ីនបូមទឹក<br>• សាងសង់អាហារដ្ឋាននៅសាលា<br>• ប្រមូលផ្តុំសហគមន៍បណ្តុះបណ្តាលដៃគូតាមដ្ឋានដែលបាន | តវិទ្យា និងភាសាបារាំង។ ទិន្នន័យស្តីអំពីការទៅរៀន និងការចុះឈ្មោះដែលបានប្រមូលតាមសាលា។ | | ឡើងប្រហែល ១៦% នៃវត្តមាន<br>• លទ្ធផលប្រឡងគណិតវិទ្យានិង ភាសាបារាំងប្រហែលខ្ពស់ជាងគម្លាតស្តង់ដារ០.៤% (ប្រសិនបើកុមារចាប់ពីភាគរយខ្ទង់៥០នោះ គេប្រហែលកើនដល់ខ្ទង់ភាគរយ៨០ក្នុងសាលា BRIGHT) ការចុះឈ្មោះរបស់កុមារីមានអានុភាពវិជ្ជ |

| | | | | | | |
|---|---|---|---|---|---|---|
| | | | | | | មានជាង កុមារា(៥%) ប៉ុន្តែលទ្ធផល ប្រឡងគ្មាន ខុសប្លែក ផ្នែកយេន ឌ័រទេ |
| 9) ប្រទេស កម្ពុជា (Filmer & Schady, 2009) | • នៅរៀនក្នុង សាលា | គ្រួសារក្រីក្រមានកូន ដែលរៀននៅ អនុ វិទ្យាល័យ (ចាប់ពី ថ្នាក់ទី៧ ដល់ ទី៩) | **ហិរញ្ញវត្ថុ៖ អាហារូបករ ណ៍សម្រាប់សិស្សក្រីក្រ ដែលប្រឈមនឹងការ បោះបង់សាលា** | គម្រោងផ្អែកលើការ ពិសោធន៍ (QED)៖ បញ្ចប់ការថយចុះ រួមទាំង អ្នកស្នើសុំអា ហារូបករណ៍ និង គ្រួសាររបស់ពួកគេ ចំនួន ៣,២២៥ នាក់ | -សាលាមាន សិស្សចុះឈ្មោះ ចូលរៀនច្រើន ជាង ២០០ នាក់៖ ផ្តល់៦០ដុល្លារ ដល់ សិស្ស២៥ នាក់ដែលប្រឈម នឹងការបោះបង់ សាលាមានកម្រិត ទាបបំផុត ផ្តល់ ៤៥ ដុល្លារ ដល់ សិស្ស ២៥នាក់ ដែលប្រឈមនឹង ការបោះបង់នៅ កម្រិតទាបបន្ទាប់ | កុមារដែល ទទួលបាន អាហារូបករ ណ៍ -កើន២០% នៃចុះឈ្មោះ ចូលរៀននៅ អនុវិទ្យាល័យ -កើនពី២០% ទៅ ២៥% ទៅ រៀន -មិនខុសពី ក្រុម ប្រៀប ធៀបលើពិន្ទុ ប្រឡង |

| | | | | | | |
|---|---|---|---|---|---|---|
| | | | | | -សាលាមាន សិស្សចុះឈ្មោះ ចូលរៀនតិចជាង ២០០ នាក់៖ ផ្តល់ ៦០ ដុល្លារ ដល់ សិស្ស១៥ នាក់ ដែលប្រឈមនឹង ការបោះបង់មាន កម្រិតទាបបំផុត ផ្តល់ ៩៥ ដុល្លារ ដល់ សិស្ស ១៥ នាក់ដែលប្រឈម នឹងការបោះបង់ កម្រិតទាបបន្ទាប់ | មុខវិជ្ជា គណិតវិទ្យា និងវាក្យស័ព្ទ |
| 10)**ប្រទេសកូឡុំប៊ី, កម្មវិធី PACES** (Angrist et al., 2002) | • រៀនបានរីកចម្រើននៅសាលា | សិស្សថ្នាក់ទី៦ ដល់ ទី ១១ នៅតំបន់ បូហ្គោតា (Bogota ) និងចាមុនឌី (Jamundi)(ទីប្រជុំជន) ក្នុងតំបន់មានស្ថានភាពសេដ្ឋកិច្ច | **ហិរញ្ញវត្ថុ៖** សក្ខីបត្រសម្រាប់សាលាឯកជន, អាចបន្តថ្មី បានលុះត្រាតែសិស្ស ប្រឡងជាប់ឡើងថ្នាក់បន្ទាប់ | គម្រោងផ្អែកលើការពិសោធន៍(QED)៖ អ្នកស្នើសុំចំនួន ១៦១៨ សម្រាប់សន្លឹកឆ្នោតសក្ខីបត្រពាក់កណ្តាលទទួលសក្ខីបត្រ និងពាក់កណ្តាល | -១៩០ ដុល្លារ ប្រហែលជាពាក់កណ្តាលនៃថ្លៃសាលាឯកជន (១៩៩៨) | បីឆ្នាំក្រោយមក អ្នកដែលទទួលសក្ខីបត្រគឺ៖ • គ្មានខុសគ្នាចំពោះអត្រានៅរៀនក្នុង |

| | | | | | | |
|---|---|---|---|---|---|---|
| | | សង្គម ទាបបំផុត ចំនួន២ (ក្នុងចំណោម៦) | | ទៀតមិនទទួលបានទេ ដោយកុមារា ៨០៧ នាក់, ជាមធ្យមមាន អាយុ ១២,៦ ឆ្នាំ | | សាលា<br>• តិចជាង៥% ទៅ ៦% រៀន ត្រួតថ្នាក់ និង ច្រើនជាង ១០% បាន បញ្ចប់ថ្នាក់ទី៨ (ពួកគេរៀន ត្រួតថ្នាក់តិច ជាងមុន)<br>• សមិទ្ធិផល ប្រឡងបាន ពិន្ទុខ្ពស់ជាង តិចតួច<br>• ទំនោររៀប អាពាហ៍ពិពា ហ៍ មានតិច តួច<br>• ធ្វើការងារ តិចជាង ១,២ ម៉ោងក្នុងមួយ សប្តាហ៍ |

| | | | | | | |
|---|---|---|---|---|---|---|
| | | | | | | • កើនចំនួន ១៥% ទៀត ចូលរៀននៅសាលាឯកជនមួយ |
| 11) **ប្រទេសកូឡុំប៊ី** (Barrera-Osorio et al., 2008) | • ចូលរៀន<br>• នៅរៀនក្នុងសាលា<br>• បញ្ចប់ការសិក្សា | សិស្សថ្នាក់ទី៦ ដល់ទី១១នៅបូហ្គោតា (ទីប្រជុំជន) | **ហិរញ្ញវត្ថុ៖ ការផ្ទេរប្រាក់មានល័ក្ខ ខ័ណ្ឌចំនួន៣ ប្រភេទ៖**<br>1) ផ្អែកលើចំនួនការចូលរៀនយ៉ាងតិច ៨០% (អន្តរាគមន៍ជាមូលដ្ឋាន)<br>2) ចំនួន ២/៣ ផ្អែកលើការចូលរៀនចំនួន ១/៣ផ្អែកលើការចុះឈ្មោះចូលរៀននៅថ្នាក់បន្ទាប់ (អន្តរាគមន៍ខាងសន្សំ)<br>3) ចំនួន ២/៣ ផ្អែកលើការចូលរៀន ចំនួន ១/៣ ផ្អែកលើការចុះឈ្មោះចូលរៀនក្នុង | **គម្រោងព្រាវៗប្រៀបធៀបក្រុមមិនទទួលអន្តរាគមន៍/ក្រុមទទួលអន្តរាគមន៍(RCT)៖** សិស្សចំនួន ១៣,៤៣៣ នាក់ត្រូវបានជ្រើសរើសព្រាវៗ ឲ្យចូលរួមជាមួយក្រុមទទួលអន្តរាគមន៍ឬក្រុមមិនទទួលអន្តរាគមន៍ពីគម្រោង | ១៥ដុល្លារអាមេរិក សម្រាប់សិស្សម្នាក់ក្នុងរយៈពេលមួយខែ (ឆ្នាំ ២០០៥) | អ្នកដែលនៅក្នុងក្រុមទទួលអន្តរាគមន៍ពីគម្រោងគឺ៖<br>• កើនចំនួនចូលរៀនចាប់ពី២,៩% ទៅ ៥,០% ដែលផ្អែកតាមជម្រើសនៃការទទួលអន្តរាគមន៍ពីគម្រោង<br>• កើនចំនួនចុះឈ្មោះចូលរៀនម្តងទៀតចាប់ពី ៤% |

| | | | | | | |
|---|---|---|---|---|---|---|
| | | | កម្មវិធីឧត្តមសិក្សា (អន្តរាគមន៍ប្រភេទទី៣) | | | (ការទទួលអន្តរាគមន៍ពីគម្រោងសន្សំ និងប្រភេទទី៣)។<br>• ទំនងជាបញ្ចប់ការសិក្សា ៥.0%<br>• ទំនងជាចុះឈ្មោះចូលរៀននៅឧត្តមសិក្សា៩,៤ % (អន្តរាគមន៍សន្សំ) និង ៤៨,៩% (អន្តរាគមន៍ប្រភេទទី៣) |
| 12) ហង់ឌូ រ៉ាស់ PRAF (Glewwe & Olinto, 2004) | • ចូលរៀននៅសាលា<br>• នៅរៀនក្នុងសាលា<br>• រៀនបានរីក | កុមារសាលាបឋមសិក្សាមានអាយុចាប់ពី ៦ឆ្នាំ ដល់១៣ ឆ្នាំ នៅទីប្រជុំជននៃតំបន់ជនបទចំនួន ៧០ | **ហិរញ្ញវត្ថុ៖ ការផ្ទេរប្រាក់មានល័ក្ខខ័ណ្ឌដល់គ្រួសារ ដើម្បីកុមារចូលរៀន ឬបង់ប្រាក់ដល់សមាគមទ្រទ្រង់សាលា** | គម្រោងព្រាវៗ**ប្រៀបធៀបក្រុមមិនទទួលអន្តរាគមន៍ពីគម្រោង/ក្រុមទទួលអន្តរាគមន៍** (RCT) ៖ ទីប្រជុំជនជា | ការផ្ទេរប្រាក់៥ ដុល្លារសម្រាប់សិស្សម្នាក់មួយខែ , ចាប់ពី១,៦០០ ដុល្លារ ដល់ | • ការផ្ទេរប្រាក់បង្កើនអត្រាចុះឈ្មោះចូលរៀនចាប់ពី ១% ទៅ |

| | | | | | | |
|---|---|---|---|---|---|---|
| | ចម្រើននៅសាលា | កន្លែងក្នុងប្រទេសហាង់ឌូរ៉ាស | **រៀន (PTA )បង្កើនគុណភាព អប់រំឲ្យ អត្រាចុះឈ្មោះចូលរៀន ប្រសើរឡើង** | ច្រើនត្រូវ បានជ្រើសរើសព្រាវៗ ជាក្រុមចំនួន៤<br>1) អន្តរាគមន៍តែផ្នែកតម្រូវការ(២០)<br>2) អន្តរាគមន៍ទាំងតម្រូវការ និងការផ្គត់ផ្គង់(២០)<br>3) អន្តរាគមន៍តែផ្នែកការផ្គត់ផ្គង់ប៉ុណ្ណោះ(១០)<br>4) ក្រុមមិនទទួលអន្តរាគមន៍ពីគម្រោងគ្មានទទួលអន្តរាគមន៍(២០)។<br>គំរូតាង រួមមានចំនួន ៥,៧៨៨គ្រួសារ និងកុមារចំនួន ៧,៦៧៨ នាក់ | ២៣,០០០ដុល្លារអាមេរិក សម្រាប់សមាគមទ្រទ្រង់សាលារៀនមួយ (ឆ្នាំ ២០០០) | ២% ដែលង្កើនការចូលរៀនត្រឹម ចាប់ ០,៨ ថ្ងៃ ក្នុងមួយខែ កាត់បន្ថយ អត្រាបោះបង់សាលាចាប់ ២% ទៅ ៣% ហើយបង្កើន អត្រាឡើង ថ្នាក់ប្រចាំឆ្នាំ ចាប់ ២% ទៅ ៤% ពិន្ទុ<br>• ការបង់ថ្លៃទៅសមាគមទ្រទ្រង់សាលារៀនមិនមានអានុភាព |
| **13) ឥណ្ឌា** (Banerjee et | • គ្មាន | សិស្សថ្នាក់ទី៣ ដល់ទី៤ នៅតំបន់ប្រាក់ | **ការសិក្សា**<br>• ការបង្រៀនគួរបន្ថែម | គម្រោងព្រាវៗប្រៀបធៀបក្រុមមិនទទួល | • គ្រូបង្រៀនទទួលប្រាក់ពី១០ | • គ្មានកម្មវិធីមានអានុភាព |

| | | | | | | |
|---|---|---|---|---|---|---|
| al., 2007) | | ចំណូលទាប នៅទីប្រជុំជន **វ៉ាដូដារា និងម៉ុមបៃ** (ទីប្រជុំជន) | ដោយស្ត្រីវ័យក្មេងតាមមូលដ្ឋានម្នាក់ពីអក្ខរកម្មមូលដ្ឋាន និងលេខនព្វន្តសម្រាប់រយៈពេល ២ម៉ោងក្នុងមួយថ្ងៃ (ពាក់កណ្ដាលនៃម៉ោងសិក្សាម៉ោងនៅសាលាមាន ៤ម៉ោង) ឬ<br>• ប្រើប្រាស់កុំព្យូទ័រជំនួយការសិក្សាកម្មវិធីគណិតវិទ្យាសម្រាប់រយៈពេល២ម៉ោងក្នុងមួយសប្តាហ៍ | អន្តរាគមន៍ពីគម្រោង/**ក្រុមចូលរួម(RCT)**៖ សិស្សចំនួន ១៤,៩៧២ នាក់ នៅសាលាចំនួន ១៦៥ បានចូលរួម កម្មវិធីរៀនគួរបន្ថែមឆ្នាំ ២០០១ (ឆ្នាំ២០០២ មិនបានបំពេញលក្ខខណ្ឌវិនិច្ឆ័យវិធីសាស្ត្រសម្រាប់ការរាប់បញ្ចូលទេ)<br>• សិស្សចំនួន ៥,៩៤៥ នាក់ នៅសាលាចំនួន ១១១ បានចូលរួមក្នុងការបង្ហាត់បង្រៀនដោយប្រើកុំព្យូទ័រជំនួយ ដល់ការសិក្សានៅឆ្នាំ២០០២ និងចំនួនដដែលនៅឆ្នាំ ២០០៣ | ដល់ ១៥ដុល្លារមួយខែ<br>• ថ្លៃកម្មវិធីកុំព្យូទ័រ ១៥,១៨ ដុល្លាសម្រាប់សិស្សម្នាក់ក្នុងមួយឆ្នាំ (ឆ្នាំ២០០៤) | លើការចូលរៀន ឬអត្រាបោះបង់សាលា<br>• ពិន្ទុប្រឡងបានកើនឡើងសម្រាប់សិស្សរៀនគួរបន្ថែមជាពិសេសសម្រាប់សិស្សដែលរៀនខ្សោយខ្លាំង<br>• ពិន្ទុប្រឡងគណិតវិទ្យា បានកើនឡើងសម្រាប់អ្នកដែលប្រើប្រាស់កុំព្យូទ័រ<br>• អានុភាពលើពិន្ទុប្រឡងបន្ថយទៅតាម |

| | | | | | | |
|---|---|---|---|---|---|---|
| | | | | | | ពេលវេលា<br>• ការជួលគ្រូបង្រៀនគឺមានប្រសិទ្ធភាពជាង |
| **14) ឥណ្ឌា** (Duflo et al., 2010) | • បញ្ចប់ការសិក្សា | គ្រូបង្រៀនក្រៅក្របខ័ណ្ឌនៅសាលាបឋមសិក្សាក្រៅផ្លូវការដែលមានគ្រូចំនួន១១៣នៅតំបន់ជនបទនៃប្រទេសឥណ្ឌា | **រចនាសម្ព័ន្ធ៖** ដើម្បីបង្កើនវត្តមានរបស់គ្រូបង្រៀន កាមេរ៉ាត្រូវបានបំពាក់ នៅសាលាចំនួនពាក់កណ្ដាលដើម្បីផ្តិតយករូបភាពគ្រូបង្រៀននិងសិស្ស នៅពេលចាប់ផ្តើម និងចុងម៉ោងបង្រៀនហើយគ្រូបង្រៀនទទួលបានប្រាក់កម្រៃផ្អែកលើវត្តមាន | **គម្រោងព្រាវៗប្រៀបធៀបក្រុមមិនទទួលអន្តរាគមន៍ពីគម្រោង/ក្រុមទទួលអន្តរាគមន៍** (RCT)៖ សាលាចំនួន ៥៧ ត្រូវបានផ្តល់កាមេរ៉ា និងការណែនាំ សាលាចំនួន៥៦ ផ្សេងទៀតត្រូវបានយកមកធ្វើការប្រៀបធៀប | ប្រហែល ២៣ ដុល្លារសម្រាប់គ្រូបង្រៀនម្នាក់ក្នុងមួយខែ (ឆ្នាំ ២០០៣) | • អវត្តមានរបស់គ្រូបង្រៀនធ្លាក់ចុះត្រឹម២១%<br>• កុមារម្នាក់នៅក្នុងសាលាទទួលអន្តរាគមន៍កើនឡើង ៩% (ឬ៣០%) ទៀតនៃថ្ងៃបង្រៀន<br>• វត្តមានរបស់កុមារមិនសូវខុសគ្នាខ្លាំង<br>• ពិន្ទុប្រឡងភាសា និងគ |

| | | | | | | |
|---|---|---|---|---|---|---|
| | | | | | | ណិត វិទ្យា របស់ កុមារ កើនឡើងត្រឹម ០,១៧នៃ គម្លាតស្តង់ដារស្ថិតិ<br>• អត្រាបោះបង់សាលា គឺទាបជាងតិចតួចធៀបនឹងសាលាទទួលអន្តរាគមន៍ពីគម្រោង<br>• ២៦% នៃសិស្សនៅសាលាទទូអន្តរាគមន៍បានបញ្ចប់ការសិក្សានៅសាលារដ្ឋច្រើនជាង និង ១០% នៅសា |

| | | | | | | |
|---|---|---|---|---|---|---|
| | | | | | | លាសម្រាប់ប្រៀបធៀប |
| 15) ប្រទេសចាម៉ៃការ Jamaica, PATH (Levy & Ohls, 2007) | • ចូលរៀន | កុមារក្រីក្រពីកំណើតរហូតដល់អាយុ១៧ឆ្នាំនៅទូទាំងប្រទេស | **ហិរញ្ញវត្ថុ៖**<br>• ការផ្ទេរប្រាក់មានល័ក្ខខ័ណ្ឌដើម្បីបង្កើនការចុះពិនិត្យថែទាំសុខភាព (អាយុចាប់ពី០ ដល់៥ឆ្នាំ) និងការចូលរៀននៅសាលា(អាយុចាប់៦ឆ្នាំ ដល់១៧ឆ្នាំ)<br>• លុបបំបាត់ការបង់ថ្លៃសាលា និងចំណាយលើចុះពិនិត្យនៅតាមមជ្ឈមណ្ឌលសុខភាព | គម្រោងផ្អែកលើការពិសោធន៍(QED)៖ គម្រោងបញ្ចប់ការថយចុះ៖ គំរូតាងនៃក្រុមគ្រួសារចំនួន២,៥០០ នៅក្រោមបន្ទាប់ក្រីក្រដែលមានសិទ្ធិសម្រាប់ PATH ប្រៀបធៀបជាមួយគ្រួសារ២,៥០០ នៅលើបន្ទាត់ក្រីក្រមិនមានសិទ្ធិចូលរួមអន្តរាគមន៍ | ៦,៥០ដុល្លាសម្រាប់កុមារម្នាក់ក្នុងមួយខែ (ឆ្នាំ ២០០៥) | អង្គការPATH មាន៖<br>• កើនឡើងចំនួនចូលរៀនពី០,៥ ថ្ងៃ ក្នុងមួយខែ<br>• កើនឡើងការចុះពិនិត្យសុខភាពសម្រាប់កុមារមានអាយុចាប់ពី ០ ដល់៦ ឆ្នាំពី ៣៨% |
| **16) ប្រទេសកេន យ៉ា** Kenya (Duflo et al., 2006) | • នៅរៀន | សិស្សសាលាបឋមសិក្សានៅស្រុកចំនួន ២ នៅភាគខាង លិចប្រទេសកេនយ៉ា គឺ តំបន់បុនហ្គោម៉ា (Bungoma) និង បុតធើ មុមីញ៉ា | **ហិរញ្ញវត្ថុ៖**<br>• បង់ថ្លៃឯកសណ្ឋានសាលាសម្រាប់ថ្នាក់ទី៦<br>**សុខភាព៖**<br>• បណ្ដុះបណ្ដាលគ្រូបង្រៀនតាមកម្មវិធីមេរោគអេដស៍/ជម្ងឺអេដស៍ | គម្រោងព្រាវៗប្រៀបធៀបក្រុមមិនទទួលអន្តរាគមន៍ពីគម្រោង/ **ក្រុមទទួលអន្តរាគមន៍** (RCT)៖ សាលាបឋមសិក្សា328 ៖សាលាមិនទទួល | • បណ្ដុះបណ្ដាលគ្រូបង្រៀន៖ ៥៥០ដុល្លារសម្រាប់មួយសាលា<br>• ការពិភាក្សាអំពីស្រោមអនាម័យ៖ | • ផ្ដល់ឯកសណ្ឋានសាលា ដើម្បីកាត់បន្ថយអត្រាបោះបង់សាលារបស់កុមារានិង |

| | | | | | | |
|---|---|---|---|---|---|---|
| | | (Butere-Mumias) | របស់រដ្ឋាភិបាល<br>• លើកទឹកចិត្តឲ្យសិស្សពិភាក្សាអំពីស្រោមអនាម័យ និងសរសេរតែងសេចក្តីស្តីពីការការពារខ្លួនរបស់ពួកគេពីមេរោគអេដស៍/ជម្ងឺអេដស៍ | អន្តរាគមន៍ ចំនួន ៨២<br>• បណ្តុះបណ្តាល គ្រូបង្រៀនចំនួន ៨១<br>• បណ្តុះបណ្តាលគ្រូបង្រៀននិងការពិភាក្សាអំពីស្រោម អនាម័យមានចំនួន ៨២<br>• ឯកសណ្ឋានសាលាមានចំនួន៨៣<br>• បណ្តុះបណ្តាលគ្រូបង្រៀន និង ឯកសណ្ឋានសាលា៨០<br>• ទទួលគ្រប់អន្តរាគន៍ទាំងបីចំនួន ៨០ | គ្មានចំណាយអ្វី<br>• ឯកសណ្ឋានសាលា៖ ៦ដុល្លាសម្រាប់សិស្សម្នាក់ (ឆ្នាំ២០០៣) | កុមារីបាន ១៥%<br>• កម្មវិធីមានឥទ្ធិពលតិចតួចលើចំណេះដឹងអាកប្បកិរិយា ឥរិយាបថរបស់សិស្ស ឬករណីមានគតិទាំងនៅវ័យជំទង់(មានផ្ទៃពោះ) |
| 17) ប្រទេសកេនយ៉ា (Glewwe et al., 2003) | • នៅរៀនក្នុងសាលា | សិស្សចាប់ពីថ្នាក់ទី៤ដល់ទី៨ | **ហិរញ្ញវត្ថុ៖**<br>គ្រូបង្រៀនបានប្រាក់បន្ថែមផ្អែកលើការអនុវត្តរបស់សាលា តាមការប្រឡងប្រចាំឆ្នាំ ក្នុងស្រុកទាំងមូល | **គម្រោងព្រាវៗប្រៀបធៀបក្រុមមិនទទួលអន្តរាគមន៍ពីគម្រោង/ក្រុមទទួលអន្តរាគមន៍** (RCT)៖ សាលាទទួលអន្តរាគមន៍ពីគម្រោងចំនួន ៥០ និងសាលា | ប្រាក់បន្ថែមគិតពី ២១% ទៅ៤៣% នៃប្រាក់បៀវត្សរ៍ប្រចាំខែ | • គ្មានភាពខុសគ្នានៃអត្រាបោះបង់សាលា ឬត្រួតថ្នាក់ រវាងសាលា ទទួលអន្តរាគមន៍និង |

| | | | | | | |
|---|---|---|---|---|---|---|
| | | | | សម្រាប់ប្រៀបធៀប ចំនួន ៥០ | | សាលាប្រៀបធៀប<br>• សិស្សនៅសាលាទទួលអន្តរាគមន៍ទទួលបានពិន្ទុប្រឡជាមធ្យមខ្ពស់ជាង |
| 18) **ប្រទេសកេនយ៉ា** (Glewwe et al., 2007) | • ចូលរៀននៅសាលា<br>• នៅរៀននៅសាលា<br>• រៀនបានរីកចម្រើននៅសាលា | សិស្សចាប់ថ្នាក់ទី ៣ ដល់ ៨ | **ការសិក្សា៖** សៀវភៅពុម្ពចំនួន ៦០% សម្រាប់ក្មេងម្នាក់ត្រូវបានផ្តល់ជាភាសាអង់គ្លេស និងវិទ្យាសាស្ត្រ ហើយចំនួន៥០% ជាសៀវភៅពុម្ពគណិតវិទ្យា | គម្រោងព្រាវៗ**ប្រៀបធៀប**ក្រុមមិនទទួលអន្តរាគមន៍ពីគម្រោង/**ក្រុមទទួលអន្តរាគមន៍** (RCT)៖ ការប្រៀបធៀបត្រូវបានធ្វើឡើងពីក្រុមចំនួន៤ មកពីសាលាចំនួន២៥ ដែលទទួលសៀវភៅជាបន្តបន្ទាប់ ប្រៀបធៀបនឹង សាលាដែលមិនបានទទួលសៀវភៅ | ២,៦៥ដុល្លា សម្រាប់សិស្សម្នាក់ | • គ្មានភស្តុតាងបញ្ជាក់ថាផ្តល់សៀវភៅពុម្ព បង្កើន ការចូលរៀន កាត់បន្ថយការរៀនត្រួតថ្នាក់ ឬ កាត់បន្ថយអត្រាបោះបង់សាលា<br>• គ្មានភស្តុតាងបញ្ជាក់ថាការផ្តល់សៀវភៅពុម្ពបង្កើន |

| | | | | | | |
|---|---|---|---|---|---|---|
| | | | | | | ពិន្ទុប្រឡងជាមធ្យមឡើយ<br>• ការផ្តល់សៀវភៅពុម្ពផ្តល់ផលប្រយោជន៍ដល់សិស្សដែលចង់រៀនខ្លាំង មិនមែនសម្រាប់សិស្សរៀនខ្សោយនោះទេ សិស្សថ្នាក់ទី៨របស់សាលាទទួលអន្តរាគមន៍ជាច្រើនបានបន្តចូលរៀននៅវិទ្យាល័យ។ |
| **19)ប្រទេសកេនយ៉ា** (Friedman et al., 2011) | • នៅរៀននៅសាលា<br>• រៀនបានរីកចម្រើននៅ | កុមារីថ្នាក់ទី៦ | **ហិរញ្ញវត្ថុ៖** ផ្តល់អាហារូបករណ៍ដល់កុមារីដែលបំពេញតាមការប្រឡងចុងឆ្នាំតាមស្តង់ | **គម្រោងព្រាវៗប្រៀបធៀបក្រុមមិនទទួលអន្តរាគមន៍ពីគម្រោង/ក្រុមទទួលអន្តរាគមន៍** | • ៦,៤០ដុល្លារក្នុងមួយឆ្នាំ ផ្តល់ទៅសាលាដើម្បីចាត់ចែងលើថ្លៃ | ៤ឆ្នាំទៅ៥ឆ្នាំបន្ទាប់ពីទទួលអាហារូបករណ៍ កុមារី៖ |

| | | | | | | |
|---|---|---|---|---|---|---|
| | សាលា | | ដាររបស់រដ្ឋដែល គាត់បានទទួលចំណាត់ថ្នាក់ ១៥% ខ្ពស់ជាងគេ | (RCT)៖ សាលាចំនួន ៦៩ (៣៤ ជាសាលាទទួលអន្តរាគមន៍(មានសិស្ស ១៦៤០នាក់) និង សាលាមិនចូលរួម សាកល្បងមាន៣៥ (មានសិស្ស ១៦៥២) | សាលា<br>• ១២,៨០ដុល្លារក្នុងមួយឆ្នាំដល់ឪពុកម្ដាយសម្រាប់ការចំណាយលើថ្លៃសាលា<br>• សរុប ៣៨ ដុល្លារ សម្រាប់រយៈពេល២ឆ្នាំ | • ៧,៨%ទំនងជាចុះឈ្មោះចូលរៀន<br>• ៨.៦% ទំនងជាបានចូលរៀនយ៉ាងហោចណាស់ដល់ថ្នាក់មធ្យមសិក្សា |
| 20) ប្រទេសកេនយ៉ា (Miguel & Kremer, 2004) | • ចូលរៀននៅសាលា | ចាប់ពីអាយុ៦ឆ្នាំ ដល់ ១៨ឆ្នាំនៅសាលាបឋមសិក្សាតាមជនបទនៅតំបន់ប៊ូស៊ី Busia (ភាគខាងជើងប្រទេសកេនយ៉ា) | **សុខភាព៖** ការប្រើប្រាស់ថ្នាំបញ្ចុះដង្កូវព្រូនម្ដង ឬពីរដងក្នុងមួយឆ្នាំដែលផ្អែកលើប្រេវ៉ាឡង់មូលដ្ឋាននៃការឆ្លងព្រូន | **គម្រោងព្រាវៗប្រៀបធៀបក្រុមមិនទទួលអន្តរាគមន៍ពីគម្រោង/ក្រុមទទួលអន្តរាគមន៍ (RCT)៖** មានសាលាចំនួន ៧៥(មានក្មេងប្រហែល៣០,០០០) បែងចែកជាបីក្រុមដែលមាន ២៥ សាលា ៖<br>1) ផ្ដល់ថ្នាំបញ្ចុះព្រូនឥតគិតថ្លៃនៅឆ្នាំ | ៣.៥០ដុល្លារសម្រាប់កុមារម្នាក់(១៩៩៩) | • អត្រាឆ្លងថយ បាន យ៉ាងច្រើន<br>• អវត្តមានថយចុះ ៥.១% ពិន្ទុនៅក្នុងក្រុមទទួលអន្តរាគមន៍ពីគម្រោង<br>• គ្មានភាពខុសគ្នាចំពោះពិន្ទុប្រឡង |

| | | | | | | |
|---|---|---|---|---|---|---|
| | | | | ១៩៩៨ និង ១៩៩៩<br>2) ផ្ដល់ថ្នាំបញ្ចុះព្រូន ឥតគិតថ្លៃនៅឆ្នាំ ១៩៩៩<br>3) ផ្ដល់ថ្នាំបញ្ចុះព្រូន ឥតគិតថ្លៃនៅឆ្នាំ ២០០១ មជ្ឈមណ្ឌលសិក្សានៅឆ្នាំ ១៩៩៨ និង ១៩៩៩។ សាលាដែលមិនបានទទួលថ្នាំបញ្ចុះព្រូន មានតួនាទីជា "សាលាមិនទទួលអន្តរាគមន៍" | | |
| 21) ម៉ាដាហ្គាស្កា (Nguyen & Lassibille, 2008) | • ចូលរៀន នៅ សាលា | សិស្សនៅសាលាបឋមសិក្សា | **រចនាសម្ព័ន្ធ៖** ឧបករណ៍ប្រតិបត្តិការ និងបណ្ដុះបណ្ដាល ដែលរួមទាំងពាក្យសុំ សម្រាប់តែអ្នកគ្រប់គ្រងថ្នាក់ស្រុក សម្រាប់បុគ្គលិកថ្នាក់ស្រុក និងឃុំ ឬក៏បុគ្គលិកថ្នាក់ស្រុក និងឃុំ ជាមួយនឹងគ្រូ | គម្រោងព្រាវៗ**ប្រៀបធៀប**ក្រុមមិនទទួលអន្តរាគមន៍ពីគម្រោង/**ក្រុមទទួលអន្តរាគមន៍** (RCT) ៖ ស្រុកទទួលអន្តរាគមន៍ ១៥ និងស្រុកមិនទទួលអន្តរាគមន៍ចំនួន ១៥ និងការជ្រើសរើស | • គ្មានព័ត៌មានដែលត្រូវបានផ្ដល់ | ទីកន្លែងដែលបណ្ដុះបណ្ដាលគ្រូបង្រៀន និង ឪពុកម្ដាយ ៖<br>-វត្តមានសិស្សកើនឡើងពី ៤.៣%<br>-ពិន្ទុប្រឡង |

| | | | | | | |
|---|---|---|---|---|---|---|
| | | | បង្រៀន និងឪពុកម្ដាយ | ឃុំ និងសាលាព្រាវៗ | | កើនឡើងពី ០.១ នៃគម្លាតស្តង់ដារ |
| 22) ម៉ាឡាវី (Baird et al., 2010) | • នៅរៀននៅសាលា | កុមារីអាយុចាប់ ១៣ ដល់ ២២ នៅ Zomba (ទីប្រជុំជន និងជនបទ) មានសិទ្ធិចូលរៀនថ្នាក់ទី ៧ | **ហិរញ្ញវត្ថុ៖** ការផ្ទេរប្រាក់មានល័ក្ខខ័ណ្ឌដល់ឪពុកម្ដាយ កុមារី និងសាលា។ កុមារីអាចទទួលប្រាក់ដែលមានល័ក្ខខ័ណ្ឌចំពោះវត្តមាន និងគ្មានល័ក្ខខ័ណ្ឌ ឬក៏ពួកគេមិនទទួលប្រាក់ | គម្រោងព្រាវៗ**ប្រៀបធៀប**ក្រុមមិនទទួលអន្តរាគមន៍ពីគម្រោង/**ក្រុមទទួលអន្តរាគមន៍** (RCT)៖ "តំបន់ដែលរាយឈ្មោះតាមលំដាប់" ចំនួន១៧៦ កុមារីចំនួន ៣,៨០៥ នាក់ត្រូវបានជ្រើសរើសដោយព្រាវៗ | • ការបង់ប្រាក់ដល់គ្រួសារ៖ ៤ ដុល្លារ ដល់១០ ដុល្លារក្នុងមួយខែ<br>• ការបង់ប្រាក់ដល់កុមារី៖ ០ ដុល្លារ ដល់ ៥ ដុល្លារក្នុងមួយខែ<br>• ការបង់ប្រាក់ដល់សាលា៖ តាមថ្លៃសាលា (ឆ្នាំ២០០៨) | កុមារីទាំងនោះក្នុងសាលានៅតាមមូលដ្ឋានដែលទទួលការផ្ទេរប្រាក់មាន៖<br>• អត្រាបោះបង់សាលាទាបជាង (៥% ធៀបនឹង ១១%)<br>• គ្មានភាពខុសគ្នាចំពោះការចូលរៀនរវាងការផ្ទេរប្រាក់ដែលមានល័ក្ខខ័ណ្ឌ និងគ្មានល័ក្ខខ័ណ្ឌ |

| | | | | | | |
|---|---|---|---|---|---|---|
| | | | | | | • គ្មានភាពខុសគ្នាក្នុង ការបញ្ចប់ការសិក្សា<br>• អត្រាអក្ខរកម្មជាភាសាអង់គ្លេសកើនឡើងនៅក្នុងស្តង់ដារទី៥ និងទី៦ |
| 23) មិុចសិកូ PROGRESA (Schultz, 2000) | • នៅរៀននៅសាលា | សិស្សថ្នាក់ទី៣ដល់ទី៩ ក្នុងសហគមន៍ក្រីក្រតាមជនបទ | **ហិរញ្ញវត្ថុ៖** ការផ្ទេរប្រាក់មានលក្ខខ័ណ្ឌ ប្រសិនបើកុមារមានវត្តមានយ៉ាងហោចណាស់បាន ៨៥% នៃម៉ោងសិក្សា | គម្រោងព្រាវៗ**ប្រៀបធៀប**ក្រុមមិនទទួលអន្តរាគមន៍ពីគម្រោង/**ក្រុមទទួលអន្តរាគមន៍** (RCT)៖ សហគមន៍ចំនួន ៤៩៥ នៅរដ្ឋក្រីក្របំផុតចំនួន០៧, ៣១៤ នៅក្នុងកម្មវិធី និង១៨១ ទទួលអន្តរាគមន៍ពីគម្រោង | បែងចែកផ្សេងៗគ្នាទៅតាមថ្នាក់ និងភេទសិស្ស ចាប់ពីថ្នាក់ទី៣ឡើង (៧,៧៤ ដុល្លារក្នុងរយៈពេល២ខែ សម្រាប់កុមារា និងកុមារី) ដល់ថ្នាក់ទី៩ (២៤,៨៦ ដុល្លារក្នុងរយៈពេល២ខែ | • អត្រាចុះឈ្មោះចូលរៀនកើនឡើងទាំងកម្រិតបឋមសិក្សា និងមធ្យមសិក្សា<br>• សម្រាប់សិស្សថ្នាក់ទី៧, ការចុះឈ្មោះចូលរៀនកើនឡើង |

| | | | | | | |
|---|---|---|---|---|---|---|
| | | | | | សម្រាប់កុមារា និង ២៨,១៨ ដុល្លារក្នុងរយៈពេល ២ខែ សម្រាប់កុមារី) (ឆ្នាំ១៩៩៨) | ១១.១% ពី អត្រាកម្មវិធី ត្រៀម ៥៨% ទៅ ៦៩% ៖ នេះជាចំណុចចម្បងនៃការបោះបង់សាលា |
| 24) ណោប៉ាល់ (Oster & Thornton, 2009 | • ចូលរៀននៅសាលា | សិស្សថ្នាក់ទី៧ ដល់ទី៨ ក្នុង និងជុំវិញ ទីក្រុងបាវ៉ាពួរ នៅជីតវ៉ាន | សុខភាព៖ ការបែងចែកផលិតផលអនាម័យទំនើប | គម្រោងព្រាវៗ**ប្រៀបធៀប**ក្រុមមិនទទួលអន្តរាគមន៍ពីគម្រោង/**ក្រុមទទួលអន្តរាគមន៍** (RCT)៖ កុមារីជំទង់ចំនួន១៩៨, ពាក់កណ្តាលនៃកុមារីទាំងនេះត្រូវបានជ្រើសរើសព្រាវៗ ឲ្យចូលក្រុមទទួលអន្តរាគមន៍ពីគម្រោង | បង់ថ្លៃទៅម្តាយ/ អាណាព្យាបាល (១,៥៥ដុល្លារ) | • គ្មានចំណុចខុសគ្នាគួរឲ្យកត់សម្គាល់នៃការចូលរៀន<br>• គ្មានចំណុចខុសគ្នានៃពិន្ទុប្រឡងតាមការវាស់ស្ទង់ដោយខ្លួនឯងពីការជឿជាក់លើខ្លួនឯង ឬសុខភាពផ្នែករោគស្ត្រី |

| | | | | | | |
|---|---|---|---|---|---|---|
| 25) ប៉ាគីស្ថាន (Chaudhury & Parajuli, 2006) | • ចូលរៀននៅសាលា | សិស្សថ្នាក់ទី៦ ដល់ទី៨ នៅស្រុក នៃខេត្តពុនចាប មានអត្រាអក្ខរកម្ម ចំនួន ៤០% ឬក្រោម ៤០% | **ហិរញ្ញវត្ថុ៖ ការផ្ទេរប្រាក់មានល័ក្ខខ័ណ្ឌដល់កុមារីក្នុងសាលារដ្ឋដែលមាន អត្រាចូលរៀនយ៉ាងតិច** ៨០%។ | គម្រោងផ្អែកលើការពិសោធន៍ QED៖ គម្រោងបញ្ចប់ការថយចុះ៖ <br>• កុមារីដែលរៀននៅសាលាចំនួន ១,៧៧៩ ក្នុងស្រុកទទួលប្រាក់ឧបត្ថម្ភ <br>• កុមារីដែលរៀននៅសាលាចំនួន ៣,១៥៦ នាក់ក្នុងស្រុកមិនទទួលបានឧបត្ថម្ភ <br>• កុមារាដែលរៀននៅសាលា ២,២៤៧នាក់ក្នុងស្រុកទទួលបានប្រាក់ឧបត្ថម្ភ/ធៀបនឹងក្រុមមិនទទួលអន្តរាគមន៍ទី២ <br>• កុមារាដែលរៀននៅសាលា៣,២៦៥ នាក់ក្នុងស្រុក មិន ទទួលប្រាក់ឧបត្ថម្ភ/ ធៀបនឹង | ប្រហែល៣ដុល្លារសម្រាប់សិស្សម្នាក់ក្នុងមួយខែ (២០០៥) | • អត្រាកំណើនពិតនៃការចុះឈ្មោះចូលរៀនរបស់កុមារីថ្នាក់ទី៦ ដល់ទី ៨ ក្នុងស្រុកដែលទទួលបានប្រាក់ឧបត្ថម្ភសម្រាប់សិស្ស ៦នាក់ ក្នុងសាលាមួយ (៩%) <br>• ការចូលរៀនសម្រាប់កុមារីចាប់ពី អាយុ ១០ឆ្នាំ ដល់ ១៤ឆ្នាំ ដែលទទួលបានប្រាក់ឧបត្ថម្ភបានកើនឡើង ១២% |

| | | | | | | |
|---|---|---|---|---|---|---|
| | | | | ក្រុមមិនទទួល<br>អន្តរាគមន៍ទី៣ | | |
| 26)<br>ហ្វីលីពីន<br>(Tan et al.,<br>1999) | • នៅរៀននៅសាលា | សិស្សថ្នាក់ទី១ ដល់ទី៦ ក្នុងសហគមន៍ក្រីក្រ | **ការសិក្សា៖**<br>• **សម្ភារៈសិក្សាច្រើនកម្រិត (MLM) និងសុខភាព៖**<br>• សាលាដែលផ្គត់ផ្គង់អាហារ (SF) ឬ<br><br>**រចនាសម្ព័ន្ធ៖**<br>• ភាពជាដៃគូរ រវាងឪពុកម្តាយ-គ្រូបង្រៀន (PTP) | គម្រោងព្រាវៗប្រៀបធៀបក្រុមមិនទទួលអន្តរាគមន៍ពីគម្រោង/**ក្រុមទទួលអន្តរាគមន៍** (RCT)៖ ស្រុកដែលមានប្រាក់ចំណូលទាបចំនួន២ នៅក្នុងក្រុមនីមួយៗក្នុងចំណោមតំបន់៥, សាលារៀនចំនួន៣ ក្នុងស្រុក១ត្រូវបានចាត់តាំងព្រាវៗជាក្រុមប្រើសម្ភារៈសិក្សាច្រើនកម្រិត (MLM) ,ក្រុមប្រើសម្ភារៈសិក្សាច្រើនកម្រិត និង ភាពជាដៃគូ រវាងឪពុកម្តាយ-គ្រូបង្រៀន (MLM+PTP) ,ក្រុមមិនទទួលអន្តរាគមន៍, សាលាចំនួន៣ក្នុង | ព័ត៌មានមិនត្រូវបានផ្តល់ | • ក្នុងសាលាដែលប្រើប្រាស់សម្ភារៈសិក្សាច្រើនកម្រិត(MLM) ឬ សម្ភារៈសិក្សាច្រើនកម្រិត និងភាពជាដៃគូរវាង ឪពុកម្តាយ-គ្រូបង្រៀន (MLM-PTP) អត្រាបោះបង់សាលាថយចុះយ៉ាងតិចត្រឹម ១០%<br>• ក្នុងសាលាដែលប្រើប្រាស់សម្ភារៈសិក្សាច្រើន |

| | | | | | | |
|---|---|---|---|---|---|---|
| | | | | តំបន់ផ្សេងទៀតត្រូវបានចាត់តាំងព្រាវជាក្រុមសាលាដែលផ្តត់ផ្គង់អាហារ (SF), ក្រុមសាលាដែលផ្តត់ផ្គង់អាហារ និង ភាពជាដៃគូ រវាងឪពុកម្តាយ-គ្រូបង្រៀន (SF+PTP) និងក្រុមមិនទទួលអន្តរាគមន៍ | | កម្រិត និង ភាពជាដៃគូរវាងឪពុកម្តាយ-គ្រូបង្រៀន (MLM-PTP) កុមារថ្នាក់ទី១ រៀនបានពិន្ទុខ្ពស់ជាងនៅពេលប្រឡងភាសាភីលីពីន និងអង់គ្លេស |

## កម្មវិធីអន្តរាគមន៍សិស្សបោះបង់សាលានៅសហរដ្ឋអាមេរិក

## ១ក. កម្មវិធីពន្លឿនការសិក្សានៅអនុវិទ្យាល័យ ៖ រដ្ឋចចជា

| ធាតុផ្សំ | ការបរិយាយ |
|---|---|
| ការដកស្រង់ ពីអត្ថបទសិក្សាស្រាវជ្រាវ | Dynarski, M., Gleason, P., Rangarajan, A., & Wood, R. (1998a). អានុភាព*នៃកម្មវិធីទប់ស្កាត់សិស្សបោះបង់សាលា៖របាយការណ៍ចុងក្រោយ។ របាយការណ៍ស្រាវជ្រាវអំពីការវាយតម្លៃកម្មវិធីជំនួយដល់ការបកស្រាយអំពីកាសិស្សបោះបង់សាលា។* ព្រីនស្តុន់ NJ: ការស្រាវជ្រាវគោលនយោយបាយរបស់ Mathematica។ **ករណីសិក្សាអំពីរដ្ឋចចជា** |
| សំណួរនៃការស្រាវជ្រាវ | តើកម្មវិធីពន្លឿនការសិក្សា (Accelerated) ដែលក្តោបលើកម្មវិធីសិក្សារយៈពីរឆ្នាំសិក្សាក្នុងឆ្នាំប្រក្រតិទិន និងផ្តល់ការគាំទ្រផ្នែកសង្គម ដែលនាំឲ្យសិស្សនៅរៀន និងរៀនបានរីកចម្រើននៅសាលាដែរឬទេ? |
| អ្នកចូលរួម | គំរូតាងនៃការសិក្សារួមមាន ក្រុម(cohort) សិស្ស១៦០នាក់ ដែលចូលរៀនក្នុងថ្នាក់ទី៧ ឬថ្នាក់ទី៨ ក្នុងសាលារៀនក្នុងស្រុក គ្រីហ្វីន-ស្ពាលឌីង(រដ្ឋចចជា) ក្នុងឆ្នាំសិក្សា១៩៩៣/១៩៩៤ ។ សិស្សទាំងអស់នេះសុទ្ធតែធ្លាប់ត្រួតថ្នាក់យ៉ាងតិចម្តង ។ អ្នកចូលរួមមានអាយុជាមធ្យម១៤ឆ្នាំ នៅពេលពួកគេចូលរួមក្នុងកម្មវិធីនេះ។ សិស្ស៦០%ជាជនជាតិអាហ្វ្រិកកាត់អាមេរិក ក្រៅពីនេះភាគច្រើនជាជនជាតិស្បែកស ។ កុមារាមានលើសពី៧០% ។ អ្នកចូលរួមប្រមាណបីភាគបួនមានបញ្ហាវិន័យក្នុងឆ្នាំសិក្សាពីមុនមក។ |
| ការកំណត់ | ការសិក្សាក្នុងរដ្ឋចចជានេះត្រូវបានធ្វើឡើងក្នុងសាលារៀនស្រុកគ្រីហ្វីន-ស្ពាលឌីង ភាគខាងត្បូងក្រុងអាត្លង់តា រដ្ឋចចជា ។ |
| អន្តរាគមន៍ | <u>កម្មវិធីពន្លឿនការសិក្សា៖</u> ក្នុងអំឡុងរយៈពេលវាយតម្លៃនេះ អនុវិទ្យាល័យគ្រីហ្វីន-ស្ពាលឌីងបានបញ្ចូលសិស្សថ្នាក់ទី៧ និងថ្នាក់ទី៨ ដែលធ្លាប់រៀនត្រួតថ្នាក់យ៉ាងតិចណាស់ម្តងទៅក្នុងកម្មវិធីនេះ ។ បន្ទាប់មក សាលារៀននោះបិទទ្វារ ។ គោលបំណងនៃកម្មវិធីនេះគឺដើម្បីដាក់បញ្ចូលខ្លឹមសារនៃកម្មវិធីសិក្សារយៈពេលពីរឆ្នាំក្នុងរយៈពេលមួយឆ្នាំ ដើម្បីឲ្យសិស្សទាំងនោះអាច "ផ្លោះ" ទៅរៀនថ្នាក់ទី៩ និងបានរៀនជាមួយមិត្តភក្តិក្នុងវ័យស្របាលគ្នា ប្រសិនបើពួកគេប្រឡងជាប់គ្រប់មុខវិជ្ជាតម្រូវ ។ ឧទាហរណ៍ សិស្សក្នុងកម្មវិធីសិក្សានេះត្រូវរៀនទាំងជីវវិទ្យា និងផែនដីវិទ្យាក្នុងឆ្នាំតែមួយ រីឯអនុវិទ្យាល័យផ្សេងទៀតក្នុងស្រុកជាមួយគ្នាដទៃទៀតត្រូវរៀនមុខវិជ្ជានីមួយៗក្នុងចំណោមមុខវិជ្ជាទាំងនេះក្នុងរយៈពេលមួយឆ្នាំពេញ។ កម្មវិធីនេះទទួលសិស្សប្រមាណ ២៥នាក់ក្នុងមួយឆ្នាំពីអនុវិទ្យាល័យទាំងបីនៅក្នុងស្រុកនោះ ។ ការសិក្សាស្រាវជ្រាវនេះធ្វើនៅក្នុងព្រះវិហារសាសនាគ្រឹស្ត ដែលមានកម្មវិធីស្រដៀងគ្នាសម្រាប់សិស្សវិទ្យា |

| ធាតុផ្សំ | ការបរិយាយ |
|---|---|
| | ល័យដែលរៀនមិនទាន់គេ។ ទាំងកម្មវិធីសម្រាប់អនុវិទ្យាល័យ និងវិទ្យាល័យ ចែករំលែកដល់គ្រូបង្រៀន បុគ្គលិករដ្ឋបាល និងបុគ្គលិកផ្សេងទៀតដូចគ្នា ។<br><br><u>ការឲ្យតម្លៃខ្លួនឯង និងជំនាញក្នុងការសម្រេចចិត្ត ៖</u> សាលាបានប្រើកម្មវិធីសិក្សា "**ជោគជ័យ**" ដែលផ្តោតលើការឲ្យតម្លៃខ្លួនឯង និងជំនាញក្នុងការសម្រេចចិត្ត ហើយបានបញ្ចូលកម្មវិធីសិក្សានេះទៅក្នុងកម្មវិធីសិក្សាស្នូលរបស់សាលា ។<br><br><u>វិធីសាស្ត្របង្រៀនមិនមែនតាមលក្ខណៈប្រពៃណី ៖</u> សាលារៀនបានសង្កត់ធ្ងន់ទៅលើការបង្រៀនដោយអនុវត្តផ្ទាល់និងបាននិយាយសម្រាលអំពីវិធីសាស្ត្របង្រៀនតាមបែបប្រពៃណី។ គេបានផ្តល់ឲ្យគ្រូបង្រៀននូវភាពងាយបត់បែនជាងគ្រូបង្រៀនថ្នាក់ស្រុកផ្សេងទៀតក្នុងការសម្រេចចិត្តថា តើត្រូវដាក់សម្ភារៈអ្វីខ្លះនៅក្នុងថ្នាក់របស់គាត់។ កម្មវិធីសិក្សានេះមិនបានដាក់កិច្ចការឲ្យទៅធ្វើនៅផ្ទះ និងមិនអនុញ្ញាតឲ្យសិស្សយកសៀវភៅទៅផ្ទះទេ ពីព្រោះថាសមាជិកបុគ្គលិកសាលាបារម្ភថា សិស្សនឹងមិនប្រគល់សម្ភារៈសិក្សាទាំងនេះមកឲ្យសាលាវិញ ។ កម្មវិធីសិក្សាអនុវិទ្យាល័យនេះផ្តល់ជូនមុខវិជ្ជាជ្រើសរើសតិចតួចប៉ុណ្ណោះ គឺមិនមានការបង្រៀនមុខវិជ្ជាសិល្បៈតន្ត្រី ឬភាសាបរទេសទេ ដើម្បីទុកពេលវេលាសម្រាប់សិក្សាមុខវិជ្ជាសំខាន់ៗផ្សេងទៀត។ សិស្សទាំងនោះអាចត្រឡប់ទៅរៀននៅសាអនុវិទ្យាល័យនៅស្រុកកំណើតរបស់ពួកគេដើម្បីចូលរួមក្នុងសកម្មភាពកម្មវិធីសិក្សាបន្ថែម ។<br><br><u>ការប្រឹក្សាយោបល់៖</u> សាលាបានជួលអ្នកប្រឹក្សាយោបល់ក្រៅម៉ោងឲ្យធ្វើការជាមួយសិស្ស និងគ្រួសារសិស្ស ។ តាមព័ត៌មានដែលបានពីការអង្កេតតាមដានសិស្សបង្ហាញថា បុគ្គលិកសាលាបានបញ្ជូនសិស្សជាច្រើនឲ្យទៅគាំទ្រសេវានៅក្រៅសាលា ។ បើតាមរបាយការណ៍សិស្សបានដឹងថា ៤២%នៃសិស្សដែលបានទទួលអន្តរាគមន៍ត្រូវបានបញ្ជូនទៅភ្នាក់ងារសេវាសង្គមដើម្បីប្រឹក្សាយោបល់ តម្រូវការផ្នែកសុខភាព ឬជំនួយផ្សេងៗទៀត ប្រៀបធៀបនឹងសិស្សក្នុងក្រុមមិនទទួលអន្តរាគមន៍ពីគម្រោងត្រឹមតែ១៥%ប៉ុណ្ណោះ ។ |
| ការប្រៀបធៀប | សិស្សក្នុងក្រុមមិនទទួលអន្តរាគមន៍ជាធម្មតានៅរៀនអនុវិទ្យាល័យមួយក្នុងចំណោមអនុវិទ្យាល័យបែបប្រពៃណីទាំងបីក្នុងសាលានៅក្នុងស្រុកគ្រីហ្វីន-ស្ពាលឌីង ។ |

| ធាតុផ្សំ | ការបរិយាយ |
| --- | --- |
| **វិធីសាស្ត្រ** | ការសិក្សាក្នុងរដ្ឋ**ចចជា** ប្រើប្រាស់គម្រោងស្រាវជ្រាវសាកល្បងប្រៀបធៀបព្រាវៗ(randomized controlled trial research design) ៖ សិស្ស៨០នាក់ត្រូវបានជ្រើសរើសព្រាវៗឲ្យចូលរៀនក្នុងក្រុមបង្កើនការរៀនសូត្រនៅអនុវិទ្យាល័យ និងផ្តល់ការអនុញ្ញាតឲ្យចូលរៀនក្នុងកម្មវិធីសិក្សាអនុវិទ្យាល័យគ្រីហ្វីន-ស្តាលឌីង រីឯសិស្ស៨០នាក់ផ្សេងទៀតត្រូវបានជ្រើសរើសព្រាវៗឲ្យចូលជាក្រុមមិនទទួលអន្តរាគមន៍ពីគម្រោង ហើយជាទូទៅរៀននៅអនុវិទ្យាល័យណាមួយក្នុងចំណោមអនុវិទ្យាល័យបែបប្រពៃណីទាំងបីនៅក្នុងស្រុកនេះ។ លទ្ធផលត្រូវបានដកស្រង់ចេញពីការអង្កេតតាមដានត្រូវបានធ្វើឡើងពីរឆ្នាំ បន្ទាប់ពីការជ្រើសរើសព្រាវៗ ៖ សិស្សក្នុងក្រុមទទួលអន្តរាគមន៍ចំនួន៦៧នាក់(៨៤%) និងសិស្សក្នុងក្រុមមិនទទួលអន្តរាគមន៍ចំនួន៧៣នាក់(៩១%)បានឆ្លើយសំណួរអំពីការអង្កេតនេះ។ ពីព្រោះអត្រាចម្លើយបង្ហាញពីអត្រារេចរិលខុសគ្នាលើសពី៥ភាគរយ ទើបការសិក្សានេះ "ឆ្លើយតបទៅនឹងបទដ្ឋានភស្តុតាងមិនបានទាំងស្រុងនោះទេ" ។ អ្នកស្រាវជ្រាវបានប្រៀបធៀបលក្ខណៈសម្គាល់ជាមូលដ្ឋាននៃអ្នកឆ្លើយតបចំពោះការអង្កេតតាមដាននៅក្នុងក្រុមស្រាវជ្រាវទាំងពីរស្តីពីការវាស់វែងប្រជាសាស្ត្រ សង្គមសេដ្ឋកិច្ច និង លទ្ធផលសិក្សានៅសាលារៀនចំនួន១៣ចំណុច ។ ការសាកល្បងលើស្ថិតិស្តីពីភាពខុសគ្នាជារួមរវាងក្រុមស្រាវជ្រាវទាំងពីរលើលក្ខណៈសម្គាល់មូលដ្ឋានទាំង១៣ បានរកឃើញថាពិតជាមានភាពខុសគ្នាគួរឲ្យកត់សម្គាល់រវាងក្រុមស្រាវជ្រាវទាំងពីរ (យ៉ាងតិចណាស់ក្នុងកម្រិតកត់សម្គាល់0,១0) ៖ សិស្សក្នុងក្រុមទទួលបានអន្តរាគមន៍ច្រើនតែមកពីគ្រួសារដែលមានទាំងឪពុកនិងម្តាយ ប៉ុន្តែមិនសូវទទួលបានជំនួយជាសាធារណៈ និងមិនសូវអវត្តមានញឹកញាប់ពីសាលារៀន ។ អ្នកស្រាវជ្រាវបានប្រើប្រាស់គំរូនៃការថយចុះ (regression) ដើម្បីកែសម្រួលភាពខុសគ្នាទាំងនេះ នៅពេលប៉ាន់ស្មានលើអានុភាពនៃកម្មវិធីនេះ ។ |

| ធាតុផ្សំ | ការបរិយាយ |
| --- | --- |
| ខ្នាតរង្វាស់ និងលទ្ធផលសំខាន់ៗ | ការនៅរៀន ៖ អានុភាពវិជ្ជមាន ។ ការសិក្សាក្នុងរដ្ឋចកចជា បានរកឃើញថាអត្រាបោះបង់សាលាមានកម្រិតទាបក្នុងចំណោមសិស្សអនុវិទ្យាល័យដែលបង្កើនការសិក្សា ៖ ៦% ធៀបនឹង១៥%នៃសិស្សក្នុងក្រុមមិនទទួលអន្តរាគមន៍ពីគម្រោង ជាភាពខុសគ្នាមួយដែលមិនសូវសំខាន់នៅក្នុងស្ថិតិ ប៉ុន្តែវាសំខាន់ណាស់នៅក្នុងការសិក្សា (ទំហំអានុភាពធំជាង០,២៥) ។<br><br>ការរៀនបានរីកចម្រើននៅសាលា៖ អានុភាពវិជ្ជមាន ។ ចំនួនឆ្នាំសិក្សាជាមធ្យមដែលត្រូវបានបញ្ចប់នៅពេលតាមដានរយៈពេល២ឆ្នាំ គឺ៨,៦សម្រាប់សិស្សអនុវិទ្យាល័យដែលបង្កើនការសិក្សា និង៧,៩សម្រាប់សិស្សក្នុងក្រុមមិនចូលរួមសាកល្បង ដែលនេះជាភាពខុសគ្នាយ៉ាងសំខាន់ក្នុងស្ថិតិ ។ |
| ថ្លៃចំណាយ | សរុប ៧ ០០០ដុល្លារ/សិស្សម្នាក់/មួយឆ្នាំ ។ (សម្រាប់តម្លៃដុល្លារក្នុងឆ្នាំ២០០៧) |
| វគ្គបណ្តុះបណ្តាលបុគ្គលិក | បុគ្គលិកអប់រំនៅកម្មវិធីសិក្សាអនុវិទ្យាល័យគ្រីហ្វីន-ស្តាលឌីងគឺជាគ្រូប្រចាំថ្នាក់មកពីស្រុកគ្រីហ្វីន-ស្តាលឌីង ។ បើតាមការឲ្យដឹងពីក្រុមអ្នកស្រាវជ្រាវវាយតម្លៃបានឲ្យដឹងថា គ្រូទាំងនេះមិនបានទទួលការបណ្តុះបណ្តាលបន្ថែមជាផ្នែកមួយនៃកិច្ចការសិក្សាស្រាវជ្រាវរបស់ពួកគាត់នោះទេ។ |

# ១២. កម្មវិធីបង្កើនការសិក្សានៅអនុវិទ្យាល័យ ៖ រដ្ឋមីជីហ្គែន

| ធាតុផ្សំ | ការបរិយាយ |
|---|---|
| ប្រភពនៃការសិក្សា | Dynarski, M., Gleason, P., Rangarajan, A., & Wood, R. (1998b). អានុភាព *នៃកម្មវិធីទប់ស្កាត់សិស្សបោះបង់សាលា៖របាយការណ៍ចុងក្រោយ។ របាយការណ៍ស្រាវជ្រាវអំពីការវាយតម្លៃកម្មវិធីជំនួយដល់ការបកស្រាយអំពីកាសិស្សបោះបង់សាលា។* ព្រីនស្តុន់ NJ: ការស្រាវជ្រាវគោលនយោបាយរបស់ Mathematica។ **ករណីសិក្សាអំពីរដ្ឋមីជីហ្គែន** |
| សំណួរនៃការស្រាវជ្រាវ | តើកម្មវិធីពន្លឿនការសិក្សា ដែលក្តោបលើកម្មវិធីសិក្សាពីរឆ្នាំសិក្សាក្នុងឆ្នាំប្រក្រតិទិន និងផ្តល់ការគាំទ្រផ្នែកសង្គម នាំឲ្យសិស្សនៅរៀន និងរៀនបានរីកចម្រើននៅសាលាដែរឬទេ ? |
| អ្នកចូលរួម | គំរូតាងនៃការសិក្សារួមមានសិស្ស១៩៨នាក់ ដែលចូលរៀនថ្នាក់ទី៦ ក្នុងសាលាសហគមន៍ភ្លីន( Flint )ក្នុងឆ្នាំសិក្សា១៩៩២/១៩៩៣ និង ១៩៩៣/១៩៩៤ ។ សិស្សទាំងអស់នេះសុទ្ធតែស្ថិតនៅក្រោមកម្រិតថ្នាក់យ៉ាងតិចពីរថ្នាក់ និងមានអាយុជាមធ្យម១៣ ឬ ១៤ឆ្នាំ នៅពេលពួកគេចូលរួមក្នុងកម្មវិធីនេះ។ សមាជិកសាលារៀនក្នុងស្រុកបានកំណត់សិស្សថ្មីសម្រាប់កម្មវិធីសិក្សានៅរាល់រដូវផ្ការីកពីសិស្សថ្នាក់ទី៥ ដែលហួសអាយុចូលរៀន២ឆ្នាំឬច្រើនជាង។ ក្នុងចំណោមក្រុមសិស្សទាំងនេះ គេបានជ្រើសរើសសិស្សត្រូវបានចាត់ទុកថា ទំនងជាអាចទទួលអត្ថប្រយោជន៍ពីកម្មវិធីបង្កើនការសិក្សានេះ ។ សិស្ស៦០%ជាជនជាតិកូនកាត់អាហ្វ្រិក-អាមេរិក ក្រៅពីនេះភាគច្រើនជាជនជាតិស្បែកស ។ កុមារាមានប្រមាណ៦០% ។ អ្នកចូលរួមប្រមាណពាក់កណ្តាលរស់នៅក្នុងគ្រួសារដែលអាស្រ័យលើជំនួយឧបត្ថម្ភពីរដ្ឋ ។ សិស្សលើសពីពីរភាគបីមានបញ្ហាវិន័យក្នុងឆ្នាំសិក្សាពីមុនមក ។ |
| ការកំណត់ | ការសិក្សាក្នុងរដ្ឋមីជីហ្គែននេះធ្វើឡើងក្នុងសាលាសហគមន៍ភ្លីន(Flint) ក្នុងស្រុកភ្លីន (Flint) រដ្ឋមីជីហ្គែន ។ |
| អន្តរាគមន៍ | <u>កម្មវិធីពន្លឿនការសិក្សា៖</u> ក្នុងអំឡុងរយៈពេលវាយតម្លៃនេះ កម្មវិធីបង្កើនការសិក្សាស្រាវជ្រាវ (AAA) បានបញ្ចូលសិស្សអនុវិទ្យា ល័យ ដែលរៀនមិនទាន់គេរយៈពេល២ ឬច្រើនឆ្នាំ។ (សាលាបន្តប្រតិបត្តិការ ប៉ុន្តែការបរិយាយនេះផ្តោតលើប្រតិបត្តិការកម្មវិធីក្នុងអំឡុងពេលវាយតម្លៃនេះ) ។ គោលបំណងនៃកម្មវិធីគឺដើម្បីបង្កើនល្បឿនកម្មវិធីសិក្សា ដើម្បីឲ្យសិស្សរៀនមិនទាន់គេអាចចូលរៀន ជាមួយមិត្តភក្តិក្នុងវ័យស្របាលគ្នានៅវិទ្យាល័យ ។ |

| ធាតុផ្សំ | ការបរិយាយ |
| --- | --- |
| | <u>កម្មវិធីស្វ័យសិក្សា ៖</u> កម្មវិធីបង្កើនការសិក្សាស្រាវជ្រាវ (AAA) ជាកម្មវិធីមួយដែលកាន់កាប់អតីតអគារអនុវិទ្យាល័យមួយជាន់ពេញ។ អាគារពីរជាន់ផ្សេងទៀតត្រូវបានកាន់កាប់ដោយសាលាឯកជន ។ ការចុះឈ្មោះចូលរៀនត្រូវកម្រិតឲ្យមានត្រឹម១០០នាក់ ។ កម្មវិធីនេះផ្តល់ជូននូវថ្នាក់រៀនដែលមានសិស្សតិចជាងអនុវិទ្យាល័យផ្សេងទៀតក្នុងស្រុកភ្លីន(Flint) និងផ្តោតសំខាន់ទៅលើការណែនាំផ្នែកប្រធានបទ និងបញ្ចូលកម្មវិធីសិក្សាក្នុងគ្រប់មុខវិជ្ជាសំខាន់ៗ ។<br><br><u>វិធីសាស្ត្របង្រៀនមិនមែនតាមបែបប្រពៃណី៖</u> គ្រូបង្រៀនភាគច្រើនបានប្រើប្រាស់វិធីសាស្ត្រមិនមែនតាមបែបប្រពៃណី ដែលវិធីសាស្ត្រថ្មីរួមមានក្រុមរៀនដែលមានការសហការគ្នា បច្ចេកទេសអប់រំណែនាំ ការបង្រៀនដោយមានការសហការ និងការបង្រៀនបន្ថែមដោយមិត្តភក្តិ។ កម្មវិធីសិក្សាមានលក្ខណៈងាយបត់បែន និងមិនអាស្រ័យទៅតាមខ្លឹមសារក្នុងសៀវភៅពុម្ពនោះទេ ។ ដើម្បីឲ្យកម្មវិធីសិក្សាមានទំនាក់ទំនងគ្នា និងទាក់ទាញការចូលរួម ទើបការណែនាំភាគច្រើនផ្តោតលើបញ្ហា និងព្រឹត្តិការណ៍បច្ចុប្បន្ន ។ កម្មវិធីបង្កើនសិក្សាស្រាវជ្រាវ(AAA)បញ្ចូលមុខវិជ្ជាសំខាន់ៗចំនួន៥ ៖ មុខវិជ្ជាភាសា គណិតវិទ្យា វិទ្យាសាស្ត្រ សិក្សាសង្គម និងសិល្បៈ។ លើសពីនេះទៀត កាលវិភាគសិក្សាជាប្រចាំទុកថ្ងៃពុធជា "ថ្ងៃពុធដ៏អស្ចារ្យ" នៅក្នុងថ្នាក់រួមមានការផ្លាស់ប្តូរប្រធានបទ ដែលត្រូវបានជ្រើសរើសទៅតាមចំណូលចិត្តរបស់សិស្សម្នាក់ៗដូចជា ពិជគណិត ភាសាអេស្ប៉ាញ ការដេរប៉ាក់ និងក្លិបវិទ្យាសាស្ត្រ ។<br><br><u>ក្រុមពិភាក្សា ៖</u> ថ្ងៃសិក្សានីមួយៗចាប់ផ្តើមដោយម៉ោងសិក្សា "រយៈពេលគ្រួសារ" ៣០នាទី ក្នុងនោះក្រុមនីមួយៗដែលមានសិស្ស១០នាក់ ជួបជាមួយបុគ្គលិកសាលា ។ មេរៀននេះអាចរួមបញ្ចូលសកម្មភាពចម្រុះដូចជា ការរៀនសូត្រដោយសហការគ្នា ការបង្រៀនគួរបន្ថែម ការប្រឹក្សាយោបល់ ការអានស្ងាត់ៗ ឬការពិភាក្សាជាក្រុម ។ ក្នុងអំឡុងម៉ោងសិក្សានេះ សិស្សមានឱកាសពិភាក្សាបញ្ហាអំពីក្តីបារម្ភរបស់ពួកគេដូចជា អំពើហិង្សាក្នុងសហគមន៍ ការសេពសារធាតុញៀន និងទំនាក់ទំនងក្នុងគ្រួសារ ។ សាលាបានជួលអ្នកផ្តល់ប្រឹក្សាពេញម៉ោង និងបុគ្គលិកសង្គមពេញម៉ោងសម្រាប់ជួយដល់សិស្ស ។ ការគាំទ្រសិស្សខ្លាំងក្លាបែបនេះអាចពន្យល់ពីមូលហេតុ |

| ធាតុផ្សំ | ការបរិយាយ |
|---|---|
| | ដែលសិស្សក្នុងក្រុមទទួលបានអន្តរាគមន៍ (៥%) មិនសូវត្រូវបានបញ្ជូនទៅទទួលសេវាពីភ្នាក់ងារផ្តល់សេវាសង្គមខាងក្រៅដូចសិស្សក្នុងក្រុមមិនទទួលអន្តរាគមន៍ (១៨%)នោះទេ ។ សាលាក៏បានជួលជំនួយការ"បុគ្គលិកគាំទ្រសិស្ស" ពីរនាក់ ដែលផ្តល់ការបង្រៀនគួរបន្ថែមក្នុងថ្នាក់ និងការគាំទ្រដល់សិស្សដទៃទៀត ។ |
| ការប្រៀបធៀប | សិស្សក្នុងក្រុមមិនទទួលអន្តរាគមន៍ជាធម្មតារៀននៅអនុវិទ្យាល័យណាមួយក្នុងចំណោមអនុវិទ្យាល័យបែបប្រពៃណីទាំងបួនក្នុងស្រុកភ្លីន (Flint)។ |
| វិធីសាស្ត្រ | ការសិក្សាក្នុងរដ្ឋមីជីហ្គែននេះប្រើប្រាស់គម្រោងស្រាវជ្រាវព្រាវៗប្រៀបធៀបការសាកល្បង (randomized controlled trial research design) ៖ សិស្ស១១២នាក់ត្រូវបានជ្រើសរើសព្រាវៗឲ្យចូលរៀនក្នុងក្រុមបង្កើនការរៀនសូត្រនៅអនុវិទ្យាល័យ និងអនុញ្ញាតឲ្យចូលរៀនក្នុងកម្មវិធីបង្កើនការសិក្សាស្រាវជ្រាវ(AAA) រីឯសិស្ស៨៦នាក់ផ្សេងទៀតត្រូវបានជ្រើសរើសព្រាវៗដើម្បីឲ្យចូលជាក្រុមមិនទទួលអន្តរាគមន៍ ហើយជាទូទៅ ចូលរៀននៅអនុវិទ្យាល័យណាមួយក្នុងចំណោមអនុវិទ្យាល័យបែបប្រពៃណីទាំងបួនក្នុងស្រុកនេះ ។ លទ្ធផលសង្ខេបនៅទីនេះត្រូវបានទាញចេញពីការអង្កេតតាមដានដែលធ្វើឡើងពីរឆ្នាំក្រោយការជ្រើសរើសព្រាវៗ ៖ សិស្សក្នុងក្រុមទទួលអន្តរាគមន៍ចំនួន១០០នាក់(៨៩,៣%) និងសិស្សក្នុងក្រុមមិនទទួលអន្តរាគមន៍ចំនួន៧២នាក់(៨៧,៣%)បានឆ្លើយសំណួរទាំងនេះ។ ដោយហេតុថាអត្រាចម្លើយបង្ហាញពីអត្រារេចរិលផ្សេងៗលើសពី៥ភាគរយ ទើបការសិក្សានេះ "ឆ្លើយតបទៅនឹងបទដ្ឋានភស្តុតាងមិនបានទាំងស្រុងនោះទេ" ។ អ្នកស្រាវជ្រាវបានប្រៀបធៀបលក្ខណៈសម្គាល់ជាមូលដ្ឋាននៃអ្នកឆ្លើយតបចំពោះការអង្កេតតាមដាននៅក្នុងក្រុមស្រាវជ្រាវទាំងពីរក្រុមលើខ្នាតវាស់វែងផ្នែកប្រជាសាស្ត្រ សង្គមសេដ្ឋកិច្ច និងលទ្ធផលសិក្សានៅសាលាចំនួន១៣ចំណុច។ តការសាកល្បងស្ថិតិនៃភាពខុសគ្នាជារួមរវាងក្រុមស្រាវជ្រាវទាំងពីរស្តីពីលក្ខណៈទាំង១៣ បង្ហាញថាមិនមានភាពខុសគ្នាគួរឲ្យកត់សម្គាល់ប៉ុន្មានទេរវាងក្រុមស្រាវជ្រាវទាំងពីរ ក្នុងកម្រិតនៃសារៈសំខាន់ ០,១០ ។ ក៏ប៉ុន្តែអ្នកស្រាវជ្រាវបានប្រើប្រាស់គំរូនៃការថយចុះ (model of regression) ដើម្បីកែសម្រួលភាពខុសគ្នាតិចតួចក្នុងលក្ខណៈសម្គាល់ដំបូងនៃសិស្សក្នុងក្រុមទទួលអន្តរាគមន៍ និងសិស្ស |

| ធាតុផ្សំ | ការបរិយាយ |
| --- | --- |
| | ក្នុងក្រុមមិនទទួលអន្តរាគមន៍ នៅពេលប៉ាន់ស្មានឥទ្ធិផលនៃកម្មវិធីនេះ ។ |
| ខ្នាតរង្វាស់ និងលទ្ធផលសំខាន់ៗ | ការនៅរៀន ៖ អានុភាពវិជ្ជមាន ។ សិស្សអនុវិទ្យាល័យបង្កើនការរៀនសូត្រ ២% បានបោះបង់សាលា បន្ទាប់ពីចូលរួមក្នុងកម្មវិធីនេះបានពីរឆ្នាំ បើធៀបនឹង៩%នៃសិស្សក្នុងក្រុមមិនទទួលអន្តរាគមន៍ ដែលនេះជាភាពខុសគ្នាខាងស្ថិតិយ៉ាងសំខាន់មួយ ។<br>ការរៀនបានរីកចម្រើននៅសាលា ៖ អានុភាពវិជ្ជមាន ។ ចំនួនឆ្នាំសិក្សាជាមធ្យមដែលត្រូវបានបញ្ចប់ការតាមដានរយៈពេល២ឆ្នាំបង្ហាញថា ៧,៣សម្រាប់ពន្លឿនការសិក្សារបស់សិស្សអនុវិទ្យាល័យ និង ៦,៨សម្រាប់សិស្សក្នុងក្រុមមិនទទួលអន្តរាគមន៍ ដែលនេះក៏ជាភាពខុសគ្នាយ៉ាងសំខាន់ខាងស្ថិតិផងដែរ ។ |
| ថ្លៃចំណាយ | សរុប ១១ ០០០ដុល្លារ/សិស្សម្នាក់/មួយឆ្នាំ ។ (សម្រាប់តម្លៃដុល្លារក្នុងឆ្នាំ២០០៧) |
| វគ្គបណ្តុះបណ្តាលបុគ្គលិក | បុគ្គលិកអប់រំនៅកម្មវិធីពន្លឿនការសិក្សាស្រាវជ្រាវ(AAA)គឺជាគ្រូប្រចាំថ្នាក់ពីសាលាសហគមន៍ភ្លីន(Flint) ក្នុងស្រុក ។ មិនមានព័ត៌មានបន្ថែមទាក់ទិននឹងវគ្គបណ្តុះបណ្តាលគ្រូបង្រៀនទាំងនេះទេ ។ |

## ១គ. កម្មវិធីពន្លឿនការសិក្សានៅអនុវិទ្យាល័យៈ រដ្ឋញូជឺស៊ី

| ធាតុផ្សំ | ការបរិយាយ |
|---|---|
| ប្រភពនៃការសិក្សា | Dynarski, M., Gleason, P., Rangarajan, A., & Wood, R. (1998c). អានុភាព *នៃកម្មវិធីទប់ស្កាត់សិស្សបោះបង់សាលាៈ របាយការណ៍ចុងក្រោយ។ របាយការណ៍ស្រាវជ្រាវអំពីការវាយតម្លៃកម្មវិធីជំនួយក្នុងការបង្ហាញអំពីការទប់ស្កាត់សិស្សបោះបង់សាលា។* **ករណីសិក្សានៅរដ្ឋញូជឺស៊ី** |
| សំណួរនៃការស្រាវជ្រាវ | តើកម្មវិធីពន្លឿនការសិក្សា ដែលក្តោបលើកម្មវិធីសិក្សាពីរឆ្នាំសិក្សាក្នុងឆ្នាំប្រក្រតិទិន និងផ្តល់ការគាំទ្រផ្នែកសង្គម នាំឲ្យសិស្សនៅរៀន និងរៀនបានរីកចម្រើននៅសាលាដែរឬទេ ? |
| អ្នកចូលរួម | គំរូតាងនៃការសិក្សារួមមានសិស្ស៦២០នាក់ ដែលចូលរៀនក្នុងថ្នាក់ទី៦ ឬថ្នាក់ទី៧ ក្នុងសាលារដ្ឋ Newark ក្នុងឆ្នាំសិក្សា១៩៩២/១៩៩៣ និងឆ្នាំសិក្សា១៩៩៣/១៩៩៤ សុទ្ធតែធ្លាប់ត្រួតថ្នាក់យ៉ាងតិចម្តង ។ សិស្សដែលចូលរួមក្នុងកម្មវិធីនេះមានអាយុជាទូទៅ១៣ឆ្នាំ ។ សិស្សបីភាគបួនជាជនជាតិអាហ្វ្រិកកាត់អាមេរិក ក្រៅពីនេះភាគច្រើនជាជនជាតិអាមេរិកឡាទីន ។ កុមារាមានប្រហែលពាក់កណ្តាល ។ សិស្សប្រហែលពាក់កណ្តាលរស់នៅក្នុងគ្រួសារដែលទទួលអំណោយពីរដ្ឋ ហើយប្រហែលពាក់កណ្តាលទៀតមានបញ្ហាផ្នែកវិន័យក្នុងឆ្នាំសិក្សាពីមុនមក។ |
| បរិបទ | ការសិក្សាក្នុងរដ្ឋញូជឺស៊ីនេះត្រូវបានធ្វើឡើងក្នុងសាលារដ្ឋ Newark នៅទីប្រជុំជនក្រុងញូវីក រដ្ឋញូជឺស៊ី ។ |
| អន្តរាគមន៍ | <u>កម្មវិធីពន្លឿនការសិក្សាៈ</u> ក្នុងអំឡុងរយៈពេលនៃការសិក្សានេះ ការពន្លឿនកម្មវិធីសិក្សានៅតាមថ្នាក់បានបញ្ចូលសិស្សថ្នាក់ទី៦ និងថ្នាក់ទី៧ ដែលធ្លាប់ត្រួតថ្នាក់យ៉ាងតិចម្តង ។ (កម្មវិធីនេះលែងមានដំណើរការទៀតហើយ)។ គោលបំណងនៃកម្មវិធីគឺដើម្បីកែសម្រួលកម្មវិធីសិក្សា ដើម្បីឲ្យសិស្សអនុវិទ្យាល័យដែលរៀនមិនទាន់គេពន្លឿនការសិក្សារបស់ពួកគេ និងអាច "រៀនទាន់" មិត្តភក្តិក្នុងវ័យស្របាលគ្នា ។ ជាធម្មតា សិស្សថ្នាក់ទី៦ស្ថិតនៅក្នុងកម្មវិធីរយៈពេលពីរឆ្នាំ និងក្តោបលើកម្មវិធីសិក្សារយៈពេលបីឆ្នាំសិក្សា ។ សិស្សថ្នាក់ទី៧ស្ថិតនៅក្នុងកម្មវិធីនេះរយៈពេល០១ឆ្នាំ និងក្តោបលើកម្មវិធីសិក្សាថ្នាក់ទី៧ និងថ្នាក់ទី៨ ។ គម្រោងពន្លឿនកម្មវិធីសិក្សានៅតាមថ្នាក់បានប្រតិបត្តិការក្នុងសាលារៀនក្នុងស្រុកចំនួន៥ សាលារៀន នៅទីក្រុងញូវីក ក្នុងនោះសាលាខ្លះត្រូវបានរៀបចំជាថ្នាក់ដំបូង (K–8 elementary schools) និងសាលាខ្លះទៀតជាអនុវិទ្យាល័យដែលមានពីថ្នាក់ទី៥ដល់ថ្នាក់ទី៨ ។ |

| ធាតុផ្សំ | ការបរិយាយ |
|---|---|
| | <u>វិធីសាស្ត្រសាលាក្នុងសាលា (school-within-a-school)៖</u> គម្រោងពន្លឿនកម្មវិធីសិក្សាតាមថ្នាក់បានប្រើប្រាស់វិធីសាស្ត្រសាលាក្នុងសាលា និងដំណើរការនៅក្រៅកម្រងថ្នាក់រៀននៅក្នុងសាលាទាំងនេះ។ កម្មវិធីនីមួយៗក្នុងចំណោមកម្មវិធីទាំងប្រាំទទួលសិស្ស៥០នាក់ និងបង្រៀនដោយក្រុមគ្រូបង្រៀនដែលមានគ្នាបួននាក់ក្នុងមួយក្រុម ដែលក្នុងនោះគ្រូម្នាក់ៗទទួលបន្ទុកលើមុខវិជ្ជាមួយក្នុងចំណោមមុខវិជ្ជាទាំងបួន ៖ ភាសាអង់គ្លេស គណិតវិទ្យា ជំនាញមូលដ្ឋាន និងវិទ្យាស្ត្រ/សិក្សាសង្គម ។ (ផ្ទុយទៅវិញ នៅក្នុងអំឡុងឆ្នាំដូចគ្នានោះ ចំពោះថ្នាក់រៀនផ្សេងទៀតសម្រាប់សិស្សនៅអនុវិទ្យាល័យក្នុងទីក្រុង Newark ជាទូទៅ គ្រូបង្រៀនបានបង្រៀនគ្រប់មុខវិជ្ជា ហើយធ្វើការជាមួយសិស្សតែមួយក្រុមពេញមួយថ្ងៃ)។ បុគ្គលិកអប់រំរបស់គម្រោងពន្លឿនការសិក្សានៅតាមថ្នាក់ប្រើប្រាស់យុទ្ធសាស្ត្របង្រៀនជាក្រុម និងសហាការគ្នាដើម្បីផ្សាភ្ជាប់កម្មវិធីសិក្សាតាមប្រធានបទគ្រប់មុខវិជ្ជាទាំងអស់។ បន្ទប់រៀននីមួយៗមានសិស្សតិច ហើយជាទូទៅមានសិស្សតែ១២ទៅ១៣នាក់ ។<br><br><u>ការផ្តោតលើវិន័យ ៖</u> កម្មវិធីនេះផ្តោតខ្លាំងទៅលើវិន័យ និងការតាមដានវត្តមានសិស្ស ។ សិស្សណាដែលមិនបានមករៀនលើសពីប្រាំបួនថ្ងៃនឹងត្រូវបញ្ឈប់ពីការសិក្សា។ គ្រូបង្រៀនដាក់កិច្ចការឲ្យសិស្សទៅធ្វើនៅផ្ទះច្រើនជាងសាលាធម្មតាផ្សេងទៀតក្នុងក្រុង Newark ដើម្បីសម្រួលឲ្យសិស្សនោះយកចិត្តទុកដាក់លើកម្មវិធីពន្លឿនសិក្សា។<br><br><u>ការប្រឹក្សាយោបល់ ៖</u> ក្នុងកម្មវិធីនេះ អ្នកប្រឹក្សាយោបល់ណែនាំពេញម៉ោងម្នាក់បានធ្វើការយ៉ាងជិតស្និទ្ធជាមួយសិស្ស និងគ្រូរបស់គម្រោងពន្លឿនការសិក្សាតាមថ្នាក់។ ស្របតាមចំណុចផ្តោតរបស់កម្មវិធីនេះលើការប្រឹក្សាយោបល់ និងការគ្រប់គ្រងករណីស្តីពីការអង្កេតតាមដានបានបង្ហាញថាមានសិស្សក្នុងក្រុមអន្តរាគមន៍(៧៤%) ច្រើនជាងសិស្សក្នុងក្រុមមិនទទួលអន្តរាគមន៍ (៥៩%)ដែលបានទទួលការប្រឹក្សាយោបល់ក្នុងអំឡុងឆ្នាំតាមដានដំបូង។ ស្រដៀងគ្នាដែរ សិស្សក្នុងក្រុមទទួលអន្តរាគមន៍(២៧%)ច្រើនជាងសិស្សក្នុងក្រុមមិនទទួលអន្តរាគមន៍ពីគម្រោង(១៥%) បានទទួលការបញ្ជូនទៅរកភ្នាក់ងារសេវាសង្គមខាងក្រៅ ក្នុងអំឡុងឆ្នាំតាមដានដំបូងនេះ។ បុគ្គលិករបស់គម្រោងពន្លឿនការសិក្សាតាមថ្នាក់ត្រូវបានគ្រប់គ្រងដោយនាយកសាលា ។ ទោះជាយ៉ាងនេះក្តី ក្រុមគម្រោងព |

| ធាតុផ្សំ | ការបរិយាយ |
|---|---|
| | ន្លឿនការសិក្សាតាមថ្នាក់នីមួយៗ មានស្វ័យភាពគ្រប់គ្រាន់ក្នុងការប្រតិបត្តិកម្មវិធីរបស់ពួកគេ ។ |
| ការប្រៀបធៀប | សិស្សក្នុងក្រុមមិនទទួលអន្តរាគមន៍ពីគម្រោងជាធម្មតារៀនក្នុងសាលាក្នុងស្រុក និងរៀនតាមកម្មវិធីសិក្សាស្តង់ដារក្នុងស្រុកនោះ។ |
| វិធីសាស្ត្រ | ការសិក្សាក្នុងរដ្ឋញ៉ូវជេស៊ីនេះប្រើប្រាស់គម្រោងស្រាវជ្រាវព្រាវៗប្រៀបធៀបការសាកល្បង។ ក្នុងចំណោមសិស្ស៦២០នាក់ក្នុងគំរូតាងស្រាវជ្រាវនេះ សិស្ស៣៩២នាក់ត្រូវបានជ្រើសរើសព្រាវៗឲ្យចូលរៀនដើម្បីពន្លឿនការសិក្សារបស់ពួកគេនៅអនុវិទ្យាល័យ និងផ្តល់ការចុះឈ្មោះចូលរៀនក្នុងគម្រោងពន្លឿនការសិក្សាតាមថ្នាក់ រីឯសិស្ស២២៨នាក់ផ្សេងទៀតត្រូវបានជ្រើសរើសព្រាវៗដើម្បីឲ្យចូលជាក្រុមមិនទទួលអន្តរាគមន៍ពីគម្រោង និងមិនបានចុះឈ្មោះក្នុងកម្មវិធីពន្លឿនការសិក្សានោះទេ ។ លទ្ធផលសង្ខេបនៅទីនេះត្រូវបានទាញចេញពីការអង្កេតតាមដានដែលធ្វើឡើងពីរឆ្នាំក្រោយមក ៖ សិស្សក្នុងក្រុមទទួលអន្តរាគមន៍ចំនួន៣៤១នាក់(៨៧%) និងសិស្សក្នុងក្រុមមិនទទួលអន្តរាគមន៍ពីគម្រោងចំនួន១៩៤នាក់(៨៥%)បានឆ្លើយសំណួរទាំងនេះ។ អ្នកស្រាវជ្រាវបានប្រៀបធៀបលក្ខណៈសម្គាល់ជាមូលដ្ឋានរបស់អ្នកឆ្លើយតបចំពោះការអង្កេតតាមដាននៅក្នុងក្រុមស្រាវជ្រាវទាំងពីរលើការវាស់វែងផ្នែកប្រជាសាស្ត្រ សង្គមសេដ្ឋកិច្ច និងលទ្ធផលសិក្សានៅសាលាចំនួន១៣ ។ តេស្តស្ថិតិនៃភាពខុសគ្នាជារួមរវាងក្រុមស្រាវជ្រាវទាំងពីរស្តីពីលក្ខណៈទាំង១៣ មិនបានបង្ហាញនូវភាពខុសគ្នាដ៏គួរឲ្យកត់សម្គាល់រវាងក្រុមស្រាវជ្រាវទាំងពីរ ក្នុងកម្រិតកត់សម្គាល់០,១០នោះទេ ។ ប៉ុន្តែអ្នកស្រាវជ្រាវបានប្រើប្រាស់គំរូបង្ហាញពីការថយចុះ(regression) ដើម្បីកែសម្រួលភាពខុសគ្នាតិចតួចក្នុងលក្ខណៈសម្គាល់ដំបូងនៃសិស្សក្នុងក្រុមទទួលអន្តរាគមន៍ និងសិស្សក្នុងក្រុមមិនទទួលអន្តរាគមន៍ពីគម្រោងនៅពេលប៉ាន់ស្មានអានុភាពនៃកម្មវិធីនេះ ។ |
| ខ្នាតរង្វាស់ និងលទ្ធផលសំខាន់ៗ | ការនៅរៀន ៖ មិនមានអានុភាព ។ កម្មវិធីពន្លឿនការសិក្សាសម្រាប់សិស្សអនុវិទ្យាល័យមិនមានអានុភាពចម្បងណាមួយនៅក្នុង ស្ថិតិស្តីពីសិស្សបោះបង់សាលានោះទេ ។ |

| ធាតុផ្សំ | ការបរិយាយ |
|---|---|
| | <u>ការរៀនបានរីកចម្រើននៅសាលា ៖</u> អានុភាពវិជ្ជមាន ។ សិស្សនៅក្នុងកម្មវិធីពន្លឿនការសិក្សានៅអនុវិទ្យាល័យបានបញ្ចប់ឆ្នាំសិក្សារយៈពេល៧,៨ ឆ្នាំ នៅពេលបញ្ចប់ការសិក្សានេះ បើធៀបនឹង៧,៥ឆ្នាំសិក្សាសម្រាប់សិស្សក្នុងក្រុមមិនទទួលអន្តរាគមន៍ ដែលនេះជាភាពខុសគ្នាដ៏សំខាន់នៅក្នុងស្ថិតិ។ |
| ចំណាយ | សរុប ១៣ ០០០ដុល្លារ/សិស្សម្នាក់/មួយឆ្នាំ ។ (សម្រាប់តម្លៃដុល្លារក្នុងឆ្នាំ២០០៧) |
| វគ្គបណ្តុះបណ្តាលបុគ្គលិក | គ្រប់បុគ្គលិករបស់គម្រោងពន្លឿនការសិក្សានៅតាមថ្នាក់បានទទួលការបណ្តុះបណ្តាលរយៈពេល១-២សប្តាហ៍ ក្នុងខែសីហាដើម្បីត្រៀមសម្រាប់ឆ្នាំសិក្សាខាងមុខ ។ គោលបំណងនៃវគ្គបណ្តុះបណ្តាលនេះគឺដើម្បីរៀបចំផែនការសម្រាប់កម្មវិធី និងធានាថាបុគ្គលិកទាំងអស់សុទ្ធតែបានអនុវត្តតាមគោលវិធីតែមួយ ។ លើសពីនេះ គ្រប់បុគ្គលិករបស់គម្រោងពន្លឿនការសិក្សាជួបជុំគ្នាជាក្រុម ពី៥ទៅ៦ដងក្នុងមួយឆ្នាំសិក្សាដើម្បីពិភាក្សាអំពីបញ្ហាកម្មវិធី ។ |

## ២. សមិទ្ធិផលសម្រាប់ប្រជាជនអាមេរិកឡាទីនតាមរយៈភាពជោគជ័យខាងការសិក្សា (ALAS)

| ធាតុផ្សំ | ការបរិយាយ |
|---|---|
| ប្រភពនៃការសិក្សា | Larson, K. A., & Rumberger, R. W. (1995). *សមិទ្ធិផលសម្រាប់ប្រជាជនអាមេរិកឡាទីនតាមរយៈភាពជោគជ័យខាងការសិក្សា (ALAS) ។* In H. Thornton (Ed.), ការនៅរៀន។ *របាយការណ៍បច្ចេកទេសគម្រោងទប់ស្កាត់សិស្សបោះបង់សាលាសម្រាប់សិស្សអនុវិទ្យាល័យ ដែលមានមានបញ្ហាពិការខាងស្មារតី និងការរៀនសូត្រ។* សាកលវិទ្យាល័យ Minnesota វិទ្យាស្ថានសមាហរណកម្មសហគមន៍។<br>*ការវិភាគបន្ថែមដោយ* Gándara, P., Larson, K. A., Mehan, H., & Rumberger, R. W. (1998). *ការបញ្ចូលសិស្សអាមេរិកឡាទីនទៅ* |

| ធាតុផ្សំ | ការបរិយាយ |
|---|---|
| | *ក្នុងបណ្ដាញសិក្សា។ ដោយ* Berkeley. *គម្រោងគោលនយោបាយអាមេរិចឡាទីន*/Chicano |
| **សំណួរនៃការស្រាវជ្រាវ** | តើការបណ្ដុះបណ្ដាលអំពីការដោះស្រាយបញ្ហា និងការគ្រប់គ្រងករណីស៊ីជម្រៅ នាំឲ្យសិស្សអនុវិទ្យាល័យអាមេរិកឡាទីនដែលនៅរៀន និងរៀនបានរីកចម្រើននៅសាលាក្នុងអត្រាខ្ពស់ជាងក្រុមសិស្សដែលមិនបានចូលរួមសាកល្បងដែរឬទេ ? |
| **អ្នកចូលរួម** | ការសិក្សានេះផ្ដោតលើក្រុមសិស្សប្រឈមខ្ពស់ចំនួន៩៤នាក់ដែលចូលរៀនថ្នាក់ទី៧ក្នុងឆ្នាំ១៩៩០។ គេចាត់ទុកថាជាសិស្សប្រឈមខ្ពស់បើគ្រូថ្នាក់ទី៦របស់ពួកគេកំណត់ចំណាត់ថ្នាក់សិស្សនោះថាមានកម្រិតទាបជាងមធ្យមនៅក្នុងថ្នាក់ ។ ស្ទើរតែគ្រប់សិស្សប្រឈមខ្ពស់ទាំងអស់ដែលចូលរួមក្នុងការសិក្សានេះជាជនជាតិអាមេរិកឡាទីន(៩៦%) ភាគច្រើនជាបុរស(៦៥%) ហើយស្ទើរតែទាំងអស់ចូលរួមក្នុងកម្មវិធីអាហារថ្ងៃត្រង់ដោយមិនគិតថ្លៃ ឬបញ្ចុះតម្លៃ(៩១%) ។ សិស្សប្រមាណ២៣% ជាសិស្សដែលចេះភាសាអស់គ្លេសតិចតួច (LEP) ប្រមាណ៣៣%ជាសិស្សដែលចេះភាសាអង់គ្លេសស្ទាត់ជំនាញ ហើយក្រៅពីនេះជាសិស្សដែលនិយាយតែភាសាអង់គ្លេស។ ជាមធ្យម សិស្សមានអាយុ១២ឆ្នាំនិង៧ខែនៅពេលគេចូលរៀនក្នុងថ្នាក់ទី៧។ សិស្សដែលមិននិយាយភាសាអង់គ្លេសមិនត្រូវបានបញ្ចូលក្នុងកម្មវិធីនេះទេ ព្រោះថាអន្តរាគមន៍ដែលកម្មវិធីផ្ដល់ជូនមិនត្រូវបានរៀបចំដើម្បីសម្របទៅតាមសិស្សទាំងនោះទេ ។ កម្មវិធីនេះក៏រួមមានគំរូតាងនៃសិស្សដែលមានបញ្ហាអសមត្ថភាពផ្នែកសិក្សា ឬចាត់ទុកថាមានបញ្ហាសតិអារម្មណ៍ ប៉ុន្តែការសិក្សាអំពីគំរូតាងនេះមិនត្រូវបានរាប់បញ្ចូលទេ ពីព្រោះការវិភាគនេះមិនបានឆ្លើយតបទៅនឹងស្តង់ដារវាយតម្លៃនោះទេ។<br><br>ការវិភាគបន្ថែម ៖ ការវិភាគនេះផ្ដោតលើគំរូតាងរងនៃសិស្សចំនួន៨១ក្នុងចំណោមសិស្ស៩៤នាក់ដែលចូលរៀនក្នុងថ្នាក់ទី៧ ក្នុងឆ្នាំ១៩៩០ ហើយនៅរៀនបន្តក្នុងសាលាគោលដៅ(ក្រុមទទួលបានអន្តរាគមន៍) ឬត្រូវបានបញ្ជូនទៅអនុវិទ្យាល័យក្នុងស្រុកជាមួយគ្នា (ក្រុមមិនទទួលអន្តរាគមន៍ពីគម្រោង) ។ |
| **បរិបទ** | ការសិក្សានេះត្រូវបានធ្វើឡើងក្នុងអនុវិទ្យាល័យដ៏ធំមួយក្នុងរដ្ឋឡូស អែនជើឡែស(Los Angeles Unified School) ។ |
| **អន្តរាគមន៍** | <u>ការបណ្ដុះបណ្ដាលអំពីការដោះស្រាយបញ្ហា ៖</u> សិស្សរបស់កម្មវិធីសមិទ្ធិផលសម្រាប់ប្រជាជនអាមេរិកឡាទីនតាមរយៈភាពជោគជ័យខាងការសិក្សា *(ALAS)* ទទួលបានការបណ្ដុះបណ្ដាលជំនាញដោះស្រាយបញ្ហាក្នុងរយៈពេល១០សប្ដាហ៍ និងការលើកទឹកចិត្ត និងការ |

| ធាតុផ្សំ | ការបរិយាយ |
|---|---|
| | ប្រឹក្សាយោបល់តាមដានរយៈពេល២ឆ្នាំលើការដោះស្រាយបញ្ហា ។ ឪពុកម្ដាយសិស្សក៏ត្រូវបានបណ្ដុះបណ្ដាលពីការដោះស្រាយបញ្ហា និងចូលរួមជាមួយសាលាផងដែរ ។<br><br><u>ការគ្រប់គ្រងករណី និងការផ្សព្វផ្សាយដល់គ្រួសារសិស្ស៖</u> សិស្សម្នាក់ៗត្រូវបានចាត់តាំងជាអ្នកប្រឹក្សាយោបល់ ដែលចាំតាមដានសិស្សផ្សេងទៀតជាបន្តបន្ទាប់ ពួកគេដើរតួជាអ្នកគ្រប់គ្រងករណី និងធានាថាគេបានផ្ដល់គ្រប់សមាសភាគនៃអន្តរាគមន៍។ មានការតាមដានវត្តមានសិស្ស ហើយបើពួកគេអវត្តមាន ពួកគេត្រូវមករៀនសងវិញ។ គេនឹងទាក់ទងទៅឪពុកម្ដាយសិស្ស ប្រសិនបើសិស្សណាម្នាក់គេចសាលា ឬអវត្តមានរយៈពេលយូរ។ កម្មវិធី (ALAS) បានផ្ដល់របាយការណ៍ព័ត៌មានត្រឡប់ប្រចាំថ្ងៃដល់សិស្ស និងឪពុកម្ដាយសិស្សទាក់ទងនឹងសមាសភាគថ្នាក់រៀន ក៏ដូចជាកិច្ចការដែលមិនបានធ្វើរៀងរាល់សប្ដាហ៍ ឬប្រចាំថ្ងៃតែម្ដង ក្នុងករណីចាំបាច់ ។<br><u>ការប្រើប្រាស់សេវាសហគមន៍៖</u> បុគ្គលិកកម្មវិធី *(ALAS) (*សមិទ្ធិផលសម្រាប់ប្រជាជនអាមេរិកឡាទីនតាមរយៈភាពជោគជ័យខាងការសិក្សា)ជួយសម្រួលដោយផ្ទាល់ដល់យុវជននិងឪពុកម្ដាយសិស្សក្នុងការប្រើប្រាស់សេវាសហគមន៍ដូចជាសេវាសុខភាពផ្លូវចិត្ត និងសេវាសង្គម ។<br><br>ការវិភាគបន្ថែម ៖ ក្រុមទទួលបានអន្តរាគមន៍រួមបញ្ចូលតែសិស្សដែលនៅរៀនជាមួយអនុវិទ្យាល័យរបស់កម្មវិធី (ALAS) (សមិទ្ធិផលសម្រាប់ប្រជាជនអាមេរិកឡាទីនតាមរយៈភាពជោគជ័យក្នុងការសិក្សា)បានពេញបីឆ្នាំ(សិស្ស៣៦នាក់)ប៉ុណ្ណោះ ។ |
| ការប្រៀបធៀប | សិស្សចំនួន៨៨នាក់ត្រូវបានជ្រើសរើសព្រាវៗឲ្យចូលក្នុងក្រុមប្រៀបធៀប ។ សិស្សទាំងនេះទទួលបានកម្មវិធីសិក្សាជាប្រចាំពីសាលាគោលដៅ ។<br><br>ការវិភាគបន្ថែម៖<br>ក្រុមប្រៀបធៀបសម្រាប់ការសិក្សានេះ(សិស្ស៨៥នាក់) រួមមានសិស្សដែលត្រូវបានជ្រើសរើសព្រាវៗឲ្យចូលជាសិស្សក្នុងក្រុមមិនទទួលអន្តរាគមន៍ នៅពេលចាប់ផ្ដើមរៀនថ្នាក់ទី៧ ទាំងសិស្សដែលត្រូវបាន ឬមិនត្រូវបានបញ្ជូនឲ្យទៅរៀននៅសាលាក្នុងស្រុកជាមួយ |

| ធាតុផ្សំ | ការបរិយាយ |
|---|---|
| | គ្នា ។ |
| វិធីសាស្ត្រ | ក្នុងចំណោមសិស្សប្រឈមខ្ពស់ទាំង៩៤នាក់ សិស្សចំនួន៤៦នាក់ត្រូវបានជ្រើសរើសព្រាវៗឲ្យចូលក្នុងក្រុមទទួលអន្តរាគមន៍ ហើយសិស្ស៤៨នាក់ផ្សេងទៀតឲ្យចូលក្នុងក្រុមសិស្សប្រៀបធៀប។ សិស្សដែលទទួលបានអន្តរាគមន៍ពីកម្មវិធី ALAS (សមិទ្ធិផលសម្រាប់ប្រជាជនអាមេរិកឡាទីនតាមរយៈភាពជោគជ័យខាងការសិក្សា) ក្នុងអំឡុងពេលរៀននៅអនុវិទ្យាល័យរយៈពេលបីឆ្នាំ (ថ្នាក់ទី៧ដល់ថ្នាក់ទី៩) ឬរហូតដល់ពួកគេរៀនចប់អនុវិទ្យាល័យ ។ |
| ខ្នាតរង្វាស់ និងលទ្ធផលសំខាន់ៗ | <u>ការនៅរៀន ៖</u> អានុភាពវិជ្ជមាន ។ នៅចុងឆ្នាំសិក្សានៃថ្នាក់ទី៩ សិស្សរបស់កម្មវិធី ALAS (សមិទ្ធិផលសម្រាប់ប្រជាជនអាមេរិកឡា ទីនតាមរយៈភាពជោគជ័យខាងការសិក្សា)មានអត្រាចុះឈ្មោះចូលរៀនបន្តច្រើនជាងសិស្សក្នុងក្រុមមិនទទួលអន្តរាគមន៍ពីគម្រោង (គឺមាន៩៨%ទល់នឹង៨៣%) ។ រយៈពេលពីរឆ្នាំបន្ទាប់ពីអន្តរាគមន៍ចប់ទៅ (ចុងថ្នាក់ទី១១) ភាគរយនៃសិស្សរបស់កម្មវិធី ALAS (សមិទ្ធិផលសម្រាប់ប្រជាជនអាមេរិកឡាទីនតាមរយៈភាពជោគជ័យខាងការសិក្សា)នៅតែមានអត្រាចុះឈ្មោះចូលរៀនបន្តខ្ពស់ជាងសិស្សក្នុងក្រុមមិនទទួលអន្តរាគមន៍ពីគម្រោង(គឺមាន៧៥%ទល់នឹង៦៧%) ប៉ុន្តែភាពខុសគ្នានេះមិនសំខាន់នៅក្នុងស្ថិតិនោះទេ ។ សម្រាប់ការវិភាគអនុក្រុមដោយ Gándara, Larson, Mehan, and Rumberger (ឆ្នាំ១៩៩៨)  គេឃើញថាភាគរយនៃសិស្សរបស់កម្មវិធី ALAS (សមិទ្ធិផលសម្រាប់ប្រជាជនអាមេរិកឡាទីនតាមរយៈភាពជោគជ័យខាងការសិក្សា) មានអត្រាចុះឈ្មោះចូលរៀនបន្តនៅចុងថ្នាក់ទី១០ខ្ពស់ជាងសិស្សក្នុងក្រុមត្រួតពិនិត្យ(គឺមាន៨៦%ទល់នឹង៦៩%) ប៉ុន្តែភាពខុសគ្នានេះមិនសំខាន់នៅក្នុងស្ថិតិនោះទេ ។<br><br><u>ការរៀនបានរីកចម្រើននៅសាលា ៖</u> សម្រាប់សិស្សដែលនៅបន្តរៀននៅសាលាក្នុងស្រុក(មិនបានបោះបង់សាលា ឬត្រូវផ្ទេរការសិក្សាទៅរៀននៅសាលាផ្សេងទៀត) គេឃើញថាសិស្សរបស់កម្មវិធី ALAS (សមិទ្ធិផលសម្រាប់ប្រជាជនអាមេរិកឡាទីនតាមរយៈភាពជោគជ័យខាងការសិក្សា) មានអត្រាបញ្ចប់ការសិក្សាថ្នាក់ទី៩ទាន់ពេលច្រើនជាងសិស្សក្រុមមិនទទួលអន្តរាគមន៍(គឺ៧២%ទល់នឹង៥៣%) ។ ភាពខុសគ្នានេះសំខាន់នៅក្នុងស្ថិតិ ។ រយៈពេលពីរឆ្នាំបន្ទាប់ពីអន្តរាគមន៍ចប់ទៅ សម្រាប់សិស្សដែលនៅបន្តរៀននៅសាលាក្នុងស្រុក គេឃើញថាសិស្សរបស់កម្មវិធី ALAS មានអត្រាបញ្ចប់ការសិក្សាថ្នាក់ទី១១ទាន់ពេលច្រើនជាងសិស្សក្នុងក្រុមមិន |

| ធាតុផ្សំ | ការបរិយាយ |
|---|---|
| | ទទួលអន្តរាគមន៍ពីគម្រោង(គឺ៣៣%ទល់នឹង២៦%) ប៉ុន្តែភាពខុសគ្នានេះមិនសំខាន់នៅក្នុងស្ថិតិនោះទេ ។ សម្រាប់ការវិភាគអនុក្រុមដោយ Gándara et al. (ឆ្នាំ១៩៩៨) គេឃើញថាសមាមាត្រសិស្សរបស់កម្មវិធីALAS រៀនចប់បានច្រើនក្រេឌីតដើម្បីបញ្ចប់អនុវិទ្យាល័យទាន់ពេលច្រើនជាងសិស្សក្រុមមិនទទួលអន្តរាគមន៍ ដោយការវាស់ស្ទង់នៅចុងថ្នាក់ទី៩(មាន៧៥%ទល់នឹង៤៥%) និងនៅចុងថ្នាក់ទី១០(មាន៩៥%ធៀបនឹង២២%) ។ |
| ថ្លៃចំណាយ | សរុប ១១៨៥ដុល្លារ/សិស្សម្នាក់/មួយឆ្នាំ ។ (សម្រាប់តម្លៃដុល្លារក្នុងឆ្នាំ២០០៥) |
| វគ្គបណ្តុះបណ្តាលបុគ្គលិក | កម្មវិធី ALAS (សមិទ្ធិផលសម្រាប់ប្រជាជនអាមេរិកឡាទីនតាមរយៈភាពជោគជ័យខាងការសិក្សា) ត្រូវបានផ្តល់ជូនដោយអ្នកគ្រប់គ្រង អ្នកប្រឹក្សាយោបល់ និងបុគ្គលិកការិយាល័យដែលធ្វើការពេញម៉ោងក្នុងសាលា ។ អ្នកគ្រប់គ្រងដែលជាគ្រូបង្រៀន អ្នកប្រឹក្សាយោបល់ ឬបុគ្គលិកសង្គមដែលមានបទពិសោធន៍ច្រើន ផ្តល់នូវបណ្តុះបណ្តាលបន្តដល់អ្នកប្រឹក្សាយោបល់របស់កម្មវិធី ALAS និងធ្វើការសម្របសម្រួលសេវារវាងសាលា គ្រួសារសិស្ស និងសហគមន៍ ។ បុគ្គលិក និងគ្រូបង្រៀនរបស់កម្មវិធី ALAS ទទួលបានការបណ្តុះបណ្តាលអំពីរបៀបបង្រៀនកម្មវិធីជំនាញដោះស្រាយបញ្ហា ។ អ្នកគ្រប់គ្រងអាច ឬមិនអាចទទួលបានការបណ្តុះបណ្តាលដោយផ្អែកលើបទពិសោធន៍ពីមុនរបស់គាត់ ។ |

## ៣. កម្មវិធីសិក្សាស្រាវជ្រាវការងារ

| សមាសធាតុ | ការបរិយាយ |
|---|---|
| ប្រភពនៃការសិក្សា | Kemple, J. J., & Snipes, J. C. (2000). *កម្មវិធីសិក្សាស្រាវជ្រាវការងារ។ អានុភាពនៃការចូលរួម និងលទ្ធផលសិក្សារបស់សិស្សក្នុងវិទ្យាល័យ។* ទីក្រុងញូវយ៉ក៖ MDRC (សាជីវកម្មស្រាវជ្រាវកម្លាំងពលកម្ម)<br><br>Kemple: J. J. (2004). *កម្មវិធីសិក្សាស្រាវជ្រាវការងារ: អានុភាពលើលទ្ធផលទីផ្សារ និងការទទួលបានការអប់រំ។* ទីក្រុងញូវយ៉ក៖ MDRC (សាជីវកម្មស្រាវជ្រាវកម្លាំងពលកម្ម) |
| សំណួរស្រាវជ្រាវ | តើការផ្តោតលើការសិក្សាមុខរបរជាក់លាក់នាំឲ្យសិស្សប្រឈមនឹងការបោះបង់ អាចនៅរៀន រៀនបានរីកចម្រើននៅសាលា និងរៀនបានចប់គ្រប់ថ្នាក់នៅសាលាដែរឬទេ? |
| អ្នកចូលរួម | ការពិនិត្យនេះផ្តោតលើអនុក្រុមយុវជនចំនួន៤៧៤នាក់ក្នុងគំរូតាងរបស់ការសិក្សាដែលត្រូវចាត់ទុកថាជាប្រឈមខ្លាំងនឹងការបោះបង់សាលាមុនពេលមានអន្តរាគមន៍ ។ យុវជនទាំងនេះតំណាងឲ្យ២៧%នៃគំរូតាងនៃការសិក្សាសរុបដែលមានសិស្ស១,៧៦៤នាក់ ។ ក្នុងចំណោមយុវជនប្រឈមខ្ពស់ទាំងនេះ ៧៩%មានអាយុតិចជាងឬស្មើ១៥ឆ្នាំ ភាគច្រើនជានារី(៥៧%) ហើយច្រើនជាជនជាតិអាមេរិកឡាទីន(៥២%) ឬអាហ្វ្រិកកាត់អាមេរិក(៣៨%) រស់នៅក្នុងគ្រួសារដែលមានតែឪពុកឬតែម្តាយ(៥០%) និងទទួលបានមូលនិធិសង្គមកិច្ច ឬការផ្គត់ផ្គង់ស្បៀងអាហារ(៣២%)។ ក្នុងរយៈពេលមួយឆ្នាំមុនការជ្រើសរើសព្រាវៗ ៣៣%នៃយុវជនប្រឈមខ្ពស់អវត្តមានពីសាលាប្រចាំឆ្នាំយ៉ាងតិច១៥% ។ ក្នុងឆ្នាំដែលមានការជ្រើសរើសព្រាវៗ ៦២%នៃយុវជនប្រឈមខ្ពស់រៀនបានពិន្ទុជាមធ្យម២.០ឬតិចជាងនេះ ហើយ៤៣%លើសអាយុបើធៀបនឹងកម្រិតថ្នាក់ដែលគេរៀន ។ |
| ការកំណត់ | សាលាទាំង៩ដែលស្ថិតក្នុងការវាយតម្លៃគឺស្ថិតនៅក្នុងតំបន់ជាយក្រុងចំនួន៨ក្នុងរដ្ឋចំនួន៦៖ Pittsburgh, PA; Baltimore, MD; Washington, DC; Miami Beach, FL; Socorro, TX; Santa Ana, CA; Watsonville, CA; and San Jose, CA។ |
| អន្តរាគមន៍ | កម្មវិធីសិក្សាស្រាវជ្រាវការងារដែលត្រូវវាយតម្លៃមានសមាសភាគសំខាន់ៗចំនួន៣ ៖ ការរៀបចំសាលាក្នុងសាលាផ្តោតលើមុខរបរ |

| សមាសធាតុ | ការបរិយាយ |
|---|---|
| | កម្មវិធីសិក្សាបូកបន្ថែមទាំងការបណ្តុះបណ្តាលវិជ្ជាជីវៈផ្តោតលើមុខរបរ និងភាពជាដៃគូជាមួយនិយោជក។<br><br>• ការរៀបចំសាលាក្នុងសាលាផ្តោតលើមុខរបរ ៖ កម្មវិធីសិក្សាស្រាវជ្រាវការងារនៅក្នុងការសិក្សានេះត្រូវបានរៀបចំនូវប្រភេទមុខរបរចំនួន៦ ៖ ពាណិជ្ជកម្ម និងហិរញ្ញវត្ថុ អគ្គិសនី និងបច្ចេកវិទ្យាអេឡិចត្រូនិក និងអវកាស  សេវាសុខភាព សេវាសាធារណៈ ការធ្វើដំណើរ និងទេសចរណ៍ ព្រមទាំងបច្ចេកវិទ្យាខ្សែភាពយន្ត ។ កម្មវិធីសិក្សាចំនួនពីរសម្រាប់សិស្សថ្នាក់ទី៩ និងកម្មវិធីចំនួន៧សម្រាប់សិស្សថ្នាក់ទី១០ ។ កម្មវិធីសិក្សាស្រាវជ្រាវការងារភាគច្រើនទទួលសិស្សពី៥០ទៅ៧៥នាក់ក្នុងមួយថ្នាក់(ជាមធ្យម ថ្នាក់រៀនរបស់កម្មវិធីនេះមានចំនួនសិស្សប្រហែលនឹងថ្នាក់រៀននៅសាលាដែលគេធ្លាប់រៀនស្រាប់) ។ ក្រុមគ្រូបង្រៀនពី២ទៅ៩នាក់បង្រៀនសិស្សពេញមួយកម្មវិធីសិក្សា ហើយសិស្សអាចមានឱកាសរៀនជាមួយគ្រូដដែលជាច្រើនឆ្នាំ ។<br><br>• កម្មវិធីសិក្សាបូកបន្ថែមការបណ្តុះបណ្តាលវិជ្ជាជីវៈផ្តោតលើមុខរបរ ៖ កម្មវិធីសិក្សាផ្តល់ថ្នាក់រៀនទាក់ទងនឹងមុខរបរជាបន្តបន្ទាប់ ហើយសិស្សជ្រើសរើសយក០២ទៅ០៨មុខវិជ្ជាក្នុងមួយឆ្នាំសិក្សា។ មុខវិជ្ជាដែលនៅសល់រួមមានកម្មវិធីសិក្សាសំខាន់ៗដែលតម្រូវឲ្យបញ្ចប់ ជាធម្មតាត្រូវបានជ្រើសរើសនៅសាលាដែលគេធ្លាប់រៀនស្រាប់ ។ អ្នកស្រាវជ្រាវបានសង្កេតឃើញថាកម្មវិធីសិក្សា និងការអនុវត្តណែនាំនេះមានលក្ខណៈស្រដៀងគ្នារវាងល័ក្ខខ័ណ្ឌអន្តរាគមន៍ និងល័ក្ខខ័ណ្ឌប្រៀបធៀប ។<br><br>• ភាពជាដៃគូជាមួយនិយោជក ៖ ទំនាក់ទំនងផ្លូវការជាមួយនិយោជកក្នុងសហគមន៍បានគាំទ្រកម្មវិធីសិក្សា និងផ្តល់ជូនសកម្មភាពទាក់ទងនឹងមុខរបរសម្រាប់សិស្ស ។ ដៃគូនិយោជកពី៣- ទៅ ៥៩នាក់មានទំនាក់ទំនងជាមួយកម្មវិធីនេះ។ គ្រប់កម្មវិធីសិក្សាបានផ្តល់ឱកាសឲ្យចុះកម្មសិក្សាសម្រាប់សិស្សតាមរយៈដៃគូនិយោជក ហើយភាគច្រើនកម្មសិក្សាធ្វើឡើងក្នុងវិស្សមកាលរដូវក្តៅនៅចន្លោះថ្នាក់ទី១១ និងទី១២ ។ កម្មវិធីសិក្សាភាគច្រើនបានកំណត់លក្ខណៈវិនិច្ឆ័យជាអប្បបរមាដើម្បីឲ្យសិស្សអាចទទួលបានកម្មសិក្សាដែលភាគច្រើនទាក់ទងនឹងការរៀនបានរីកចម្រើននៅសាលារបស់ពួកគេ។ លើសពីនេះទៀត ដៃគូនិយោជកបានផ្តល់មូលនិធិ និងធនធានដទៃទៀតជួយដល់កម្មវិធីសិក្សាដើម្បីកំណត់សកម្មភាពពាក់ព័ន្ធសម្រាប់សិស្សដែលចូលរួមជាវាគ្មិន និងគ្រូឧទ្ទេស និងដើរតួជាគណៈ |

| សមាសធាតុ | ការបរិយាយ |
| --- | --- |
| | កម្មាការប្រឹក្សាយោបល់សម្រាប់កម្មវិធីសិក្សាមួយចំនួន។ |
| ការប្រៀបធៀប | យុវជនដែលមិនត្រូវបានជ្រើសរើសព្រាវៗឲ្យចូលរៀនក្នុងកម្មវិធីសិក្សាស្រាវជ្រាវការងារគឺជាក្រុមប្រៀបធៀប។ ភាគច្រើននៃយុវជនក្នុងក្រុមប្រៀបធៀបចុះឈ្មោះចូលរៀនក្នុងកម្មវិធីសិក្សាទូទៅក្នុងវិទ្យាល័យដែលពួកគេរៀនស្រាប់។ ខ្លះទៀតចុះឈ្មោះចូលរៀនក្នុងកម្មវិធីសិក្សា magnet ឬសាលាឯកទេសដទៃទៀតនៅទូទាំងទីក្រុង ។ សិស្សប្រមាណ៣%បានចុះឈ្មោះចូលរៀនក្នុងកម្មវិធីសិក្សាស្រាវជ្រាវការងារដែលត្រូវស្ថិតក្នុងការវាយតម្លៃ បើទោះជាពួកគេស្ថិតនៅក្នុងក្រុមប្រៀបធៀបក៏ដោយ ។ |
| វិធីសាស្ត្រ | ក្រុមទទួលអន្តរាគមន៍ត្រូវបានជ្រើសរើសព្រាវៗឲ្យចូលរៀនក្នុងកម្មវិធីសិក្សាស្រាវជ្រាវការងារ ហើយ៨៦%នៃយុវជនប្រឈមខ្ពស់នឹងការបោះបង់សាលាត្រូវបានជ្រើសរើសព្រាវៗឲ្យចូលក្នុងក្រុមកម្មវិធីសិក្សានេះ ។ ក្រុមទទួលអន្តរាគមន៍អាចចូលរៀនកម្មវិធីសិក្សានេះរហូតដល់បញ្ចប់ការសិក្សា ។ |
| ខ្នាតរង្វាស់ និងលទ្ធផលសំខាន់ៗ | ការនៅរៀន ៖ អានុភាពវិជ្ជមាន ។ នៅចុងឆ្នាំសិក្សានៃថ្នាក់ទី១២ គេឃើញថា២១%នៃសិស្សក្នុងក្រុមកម្មវិធីសិក្សាស្រាវជ្រាវការងារ និង៣២%នៃក្រុមប្រៀបធៀបបានបោះបង់សាលា ។<br><br>ការរៀនបានរីកចម្រើននៅសាលា ៖ អានុភាពវិជ្ជមាន ។ នៅចុងឆ្នាំសិក្សានៃថ្នាក់ទី១២ គេឃើញថា សិស្សក្នុងកម្មវិធីសិក្សាស្រាវជ្រាវការងាររៀនបានជាមធ្យម១៩ក្រេឌីត រីឯក្រុមប្រៀបធៀបរៀនបានជាមធ្យម១៧ក្រេឌីត ហើយ៤០%នៃសិស្សក្នុងក្រុមកម្មវិធីសិក្សាស្រាវជ្រាវការងារ និង២៦%នៃសិស្សក្នុងក្រុមប្រៀបធៀបបានរៀនគ្រប់ក្រេឌីតដើម្បីបញ្ចប់ការសិក្សា ។<br><br>ការបញ្ចប់ការសិក្សា ៖ មិនមានអានុភាព ។ ៨ឆ្នាំបន្ទាប់ពីចុងឆ្នាំសិក្សាថ្នាក់ទី១២ គេមិនឃើញមានភាពខុសគ្នាសំខាន់ៗក្នុងស្ថិតិរវាងភាគរយសិស្សរបស់កម្មវិធីសិក្សាស្រាវជ្រាវការងារដែលប្រឈមខ្ពស់ និងយុវជនក្នុងក្រុមប្រៀបធៀបដែលទទួលបានវិញ្ញាបនបត្រ ឬសញ្ញាបត្រចំណេះដឹងទូទៅ (GED ) ។ ៨៣%នៃយុវជនក្នុងក្រុមទាំងពីរសុទ្ធតែបានបញ្ចប់វិញ្ញាបនបត្រ ឬសញ្ញាបត្រចំណេះដឹងទូទៅដូចគ្នា។ |
| | សរុប ៦០០ដុល្លារ/សិស្សម្នាក់/មួយឆ្នាំ ច្រើនជាងការចំណាយជាមធ្យមសម្រាប់សិស្សម្នាក់ក្នុងស្រុកជាមួយគ្នា ។ (សម្រាប់តម្លៃដុល្លារ |

| សមាសធាតុ | ការបរិយាយ |
|---|---|
| ថ្លៃចំណាយ | ក្នុងឆ្នាំ២០០៤) |
| វគ្គបណ្តុះបណ្តាលបុគ្គលិក | គ្រូបង្រៀនកម្មវិធីសិក្សាស្រាវជ្រាវការងារមានជំនាញខាងមុខវិជ្ជាកម្មវិធីសិក្សា និងបណ្តុះបណ្តាលវិជ្ជាជីវៈជាច្រើន ប៉ុន្តែជាទូទៅពួកគាត់មានជំនាញប្រហែលគ្នានឹងគ្រូបង្រៀនឯទៀតក្នុងសាលាក្នុងស្រុកដែរ។ មានការផ្តល់ឱកាសអភិវឌ្ឍឯកទេសជូនដល់គ្រូបង្រៀនរបស់កម្មវិធីរួមមានការរៀនពីរបៀបគាំទ្រសិស្សនៅក្នុងបរិយាកាសសិក្សាដ៏តូចមួយ និងយុទ្ធសាស្ត្ររៀនសូត្រដើម្បីសម្របសម្រួលការអភិវឌ្ឍមុខរបរ និងសកម្មភាពទាក់ទងនឹងនិយោជក ។ |

## ៤. កម្មវិធីត្រួតពិនិត្យ និងទំនាក់ទំនង

| ធាតុផ្សំ | ការបរិយាយ |
|---|---|
| ការដកស្រង់ ពីការសិក្សា | Sinclair, M. F., Christenson, S. L., Evelo, D. L., & Hurley, C. M. (1998). ការទប់ស្កាត់សិស្សបោះបង់សាលាសម្រាប់យុវជនពិការៈ ប្រសិទ្ធភាពនៃនិតិវិធីទំនាក់ទំនងសាលាប្រកបដោយចីរភាព ។ *កុមារពិសេស ៦៥*(១), ៧–២១ ។<br><br>Sinclair, M. F., Christenson, S. L., & Thurlow, M. L. (2005). ការលើកកម្ពស់ឲ្យបញ្ចប់ការសិក្សារបស់យុវជនពិការផ្នែកស្មារតី ឬផ្នែកឥរិយាបថ នៅមធ្យមសិក្សាទីប្រជុំជន ។ *កុមារពសេស ៧១*(៤), ៤៦៥–៤៨២ ។ |
| សំណួរស្រាវជ្រាវ | តើការតាមដានជិតដល់លើសិស្សមានតម្រូវការពិសេស បណ្តាលឲ្យពួកគេនៅបន្តរៀន រៀនបានរីកចម្រើន និងបញ្ចប់ការសិក្សាដែរឬទេ? |
| អ្នកចូលរួម | អ្នកចូលរួមក្នុងការសិក្សាឆ្នាំ ១៩៩៨ គឺជាសិស្សអប់រំពិសេស ដែលបានចុះឈ្មោះចូលរៀនថ្នាក់ទី៩ ក្នុងអំឡុងឆ្នាំសិក្សា១៩៩៤–៩៥ ដែលបានចាត់ថ្នាក់ថា អសមត្ថភាពក្នុងការរៀនសូត្រ ផ្លូវអារម្មណ៍ ឬឥរិយាបថ ។ អសមត្ថភាពក្នុងការរៀនសូត្រត្រូវបានចាត់ថ្នាក់ជាទូទៅបំផុត ដែលក្នុងនោះអ្នកចូលរួម៧៥% បានធ្វើរោគវិនិច្ឆ័យនេះ ។<br><br>ជាង៤០% នៃអ្នកចូលរួម ត្រូវបានចាត់ថ្នាក់ថា មានពិការភាពធ្ងន់ធ្ងរ ។ អ្នកចូលរួមភាគច្រើនគឺជនជាតិអាហ្វ្រិកកាត់អាមេរិក (៥៩%) ភាគច្រើនគឺជាបុរស (៦៨%) និងភាគច្រើនបានចូលរួមក្នុងកម្មវិធីអាហារថ្ងៃត្រង់មិនគិតថ្លៃ ឬបញ្ចុះតម្លៃ (៧១%) ។ ជាមធ្យម សិស្សមានអាយុ១៥ឆ្នាំ នៅពេលពួកគេបានចូលរៀនថ្នាក់ទី៩ ។<br><br>ការសិក្សាឆ្នាំ ២០០៥ នេះ បានបញ្ចូលសិស្សអប់រំពិសេស ដែលបានចូលរៀនថ្នាក់ទី៩ ក្នុងឆ្នាំ ១៩៩៦ និងឆ្នាំ ១៩៩៧ ។ ដើម្បីមានសិទ្ធិចូលរួមការសិក្សានេះ អ្នកចូលរួមត្រូវតែបានចាត់ថ្នាក់ថាមានពិការភាពខាងផ្លូវចិត្ត ឬឥរិយាបថ ។ អ្នកចូលរួមភាគច្រើន គឺជាជនជាតិអាហ្វ្រិកកាត់អាមេរិកកាំង (៦៤%) ភាគច្រើនគឺជាបុរស (៨៤%) និងភាគច្រើនបានចូលរួមក្នុងកម្មវិធីអាហារថ្ងៃត្រង់មិនគិតថ្លៃ ឬបញ្ចុះ |

| ធាតុផ្សំ | ការបរិយាយ |
|---|---|
| | តម្លៃ (៧០%) ។ ជាមធ្យម សិស្សមានអាយុ១៤,៥ឆ្នាំ នៅពេលពួកគេបានចូលរៀនថ្នាក់ទី៩ ។ |
| **បរិបទ** | ការសិក្សានេះត្រូវបានធ្វើឡើងក្នុងបណ្ដាសាលារិទ្យាល័យរដ្ឋ នៅមីននៀផូលីស (Minneapolis) ។ |
| **អន្តរាគមន៍** | អ្នកតាមដាន៖ *កម្មវិធីត្រួតពិនិត្យ និងទំនាក់ទំនង* ផ្តេកលើការតាមដានជិតដល់លើការបំពេញតួនាទីរបស់សាលា ក៏ដូចជាការបង្ហាត់បង្រៀន ការគ្រប់គ្រងករណី និងការគាំទ្រផ្សេងៗទៀត ។ កម្មវិធីនេះមានសមាសភាគសំខាន់ពីរ គឺ "ត្រួតពិនិត្យ" និង "ទំនាក់ទំនង" ។ សមាសភាគត្រួតពិនិត្យត្រូវបានរៀបចំឡើងដើម្បីបន្តវាយតម្លៃលើការចូលរួមរបស់សិស្ស តាមរយៈការតាមដានជិតដល់លើសូចនាករលទ្ធផលរៀនសូត្រ និងរីកចម្រើនរបស់សិស្ស ។ សមាសភាគទំនាក់ទំនងពាក់ព័ន្ធនឹងបុគ្គលិកកម្មវិធីដែល ផ្តល់ឲ្យមានការយកចិត្តទុកដាក់ដោយផ្ទាល់ដល់សិស្សក្នុងភាពជាដៃគូជាមួយបុគ្គលិកសាលា សមាជិកគ្រួសារ និងក្រុមផ្តល់ សេវាសហគមន៍ ។ សិស្សដែលបានចុះឈ្មោះក្នុងកម្មវិធីត្រួតពិនិត្យ និងទំនាក់ទំនងត្រូវបានចាត់តាំងជា "អ្នកតាមដាន" ដែល ពិនិត្យការរៀនសូត្ររបស់សិស្សយ៉ាងទៀងទាត់ (ជាពិសេស ពិនិត្យថាតើសិស្សមានបញ្ហាក្នុងការចូលរៀន ឥរិយាបថ ឬបញ្ហាក្នុងការសិក្សាដែរឬទេ) និងធ្វើអន្តរាគមន៍នៅពេលបញ្ហាត្រូវបានកំណត់ ។ អ្នកតាមដាននេះក៏បានគាំទ្រដល់សិស្ស សម្របសម្រួលសេវា បន្តផ្តល់ជូនការលើកទឹកចិត្ត និងព័ត៌មានត្រឡប់ និងសង្កត់ធ្ងន់ទៅលើសារៈសំខាន់នៃការនៅរៀនបន្តក្នុង សាលា ។<br>ដំណើរការត្រួតពិនិត្យ និងទំនាក់ទំនងនេះបានបន្តក្នុងការសិក្សាឆ្នាំ ២០០៥ ។ អ្នកតាមដាននៅជាមួយសិស្សនោះក្នុងវិទ្យាល័យ បើទោះបីជាសិស្សនោះបានផ្ទេរទៅរៀននៅសាលាផ្សេងទៀតក្នុងស្រុកនេះក៏ដោយ ។ |
| **ការប្រៀបធៀប** | ក្នុងឆ្នាំសិក្សា១៩៩៨ សិស្សក្រុមមិនទទួលអន្តរាគមន៍បានទទួលកម្មវិធីត្រួតពិនិត្យ និងទំនាក់ទំនងថ្នាក់ទី៧ និងថ្នាក់ទី៨ បន្ទាប់ពីចាត់ចាំងចូលក្នុងក្រុមមិនទទួលអន្តរាគមន៍ នៅពេលពួកគេបានចូលរៀនសិស្សវិទ្យាល័យ ។ សិស្សក្រុមមិនទទួលអន្តរាគមន៍ចូលរួមសាលាដែលមានបរិបទដូចគ្នានឹងសាលាដែលសិស្សក្នុងក្រុមទទួលអន្តរាគមន៍ចូលរៀន។ ក្នុងការសិក្សាឆ្នាំ២០០៥សិស្សក្រុមមិនទទួលអន្តរាគមន៍បានចូលរៀនក្នុងសាលាដូចគ្នា ជាសិស្សក្នុងក្រុមអន្តរាគមន៍ ប៉ុន្តែមិនបានចូលរួមកម្មវិធីត្រួត ពិនិត្យ និងទំនាក់ទំនងទេ ។ |
| **វិធីសាស្ត្រ** | ការសិក្សាឆ្នាំ១៩៩៨ បានប្រើប្រាស់គម្រោងស្រាវជ្រាវលើការចាត់តាំងព្រាវៗ និងបានបញ្ចូលសិស្សវិទ្យាល័យចំនួន៩៤នាក់ ដែលសិស្ស៤៧នាក់នៅក្នុងក្រុមអន្តរាគមន៍ ហើយសិស្ស៤៧នាក់ទៀតក្នុងក្រុមមិនទទួលអន្តរាគមន៍។ សិស្សទាំងនេះត្រូវបានចាត់តាំងព្រា |

| ធាតុផ្សំ | ការបរិយាយ |
|---|---|
| | វ១ មុនពេលពួកគេចូលរៀនថ្នាក់ទី៩ ។<br><br>សម្រាប់ការសិក្សា ឆ្នាំ ២០០៥ ក្រុមអន្តរាគមន៍បានចូលរួមក្នុងកម្មវិធីត្រួតពិនិត្យ និងទំនាក់ទំនងរយៈពេលបួនឆ្នាំ ដែលចាប់ផ្តើម ធ្វើការចាត់តាំងព្រាវដោយខ្លួនឯងក្នុងកម្មវិធីថ្នាក់ទី៩ ។ គំរូតាង post-attrition បានដាក់បញ្ចូលសិស្សវិទ្យាល័យចំនួន១៤៤នាក់ ដែលក្នុងនោះ៧១នាក់ក្នុងក្រុមអន្តរាគមន៍ និងសិស្ស៧៣នាក់ផ្សេងទៀតក្នុងក្រុមមិនទទួលអន្តរាគមន៍។ |
| **ខ្នាតវង្វាស់ និងលទ្ធផលសំខាន់ៗ** | ការនៅរៀនបន្តក្នុងសាលា៖ ឥទ្ធិពលវិជ្ជមាន ។ ការសិក្សាឆ្នាំ ១៩៩៨ បានរាយការណ៍ថា សិស្សថ្នាក់ទី៩ ដែលបានចុះឈ្មោះក្នុង កម្មវិធីត្រួតពិនិត្យ និងទំនាក់ទំនង ទំនងជាមានតិចជាងក្រុមមិនទទួលអន្តរាគមន៍ស្រដៀងគ្នានេះដែលបោះបង់សាលានៅចុងឆ្នាំតាមដានទី១ (ឆ្លើយតបនៅចុងឆ្នាំទី១នៃវិទ្យាល័យ) គឺ៩ភាគរយធៀបនឹង ៣០% ។ ការសិក្សាឆ្នាំ២០០៥ នេះ បានរាយការណ៍ថា សិស្សដែលបានចុះឈ្មោះកម្មវិធីត្រួតពិនិត្យ និងទំនាក់ទំនង មិនសូវទំនងជាបោះបង់សាលានៅចុងឆ្នាំតាមដានទី៤នោះទេ (ឆ្លើយតបនឹងឆ្នាំទី៤ សម្រាប់សិស្សដែលរៀនបានរីកចម្រើនធម្មតា) គឺ ៣៩% ធៀបនឹង ៥៨% ។<br><br>ការរៀនបានរីកចម្រើននៅសាលា៖ ឥទ្ធិពលវិជ្ជមាន ៖ ការសិក្សាឆ្នាំ១៩៩៨នេះបានរាយការណ៍ថា សិស្សក្នុងក្រុមកម្មវិធីត្រួតពិនិត្យ និងទំនាក់ទំនងបានទទួលបានការកោតសរសើរគួរឲ្យកត់សម្គាល់ ឆ្ពោះទៅបញ្ចប់ការសិក្សានៅវិទ្យាល័យ ក្នុងអំឡុងថ្នាក់ទី៩ច្រើនជាងសិស្សក្នុងក្រុមមិនទទួលអន្តរាគមន៍ ។ ការសិក្សាឆ្នាំ២០០៥ មិនបានរាយការណ៍អំពីលទ្ធផលក្រេឌីតនៅវិទ្យាល័យនោះទេ ។<br><br>ការបញ្ចប់ការសិក្សា៖ គ្មានអានុភាព ។ ការសិក្សាឆ្នាំ២០០៥នេះបានពិនិត្យលើកម្មវិធីត្រួតពិនិត្យ និងទំនាក់ទំនងថាតើវាមានអានុភាពលើសិស្សបញ្ចប់ការសិក្សា "តាមកាលកំណត់" ដែរឬទេ (ក្នុងរយៈពេលបួនឆ្នាំនៃការចូលរៀនថ្នាក់ទី៩)។ ការសិក្សានេះ បានបង្ហាញឲ្យឃើញថា មិនមានអានុភាពគួរឲ្យកត់សម្គាល់ ឬសំខាន់នៅក្នុងស្ថិតិលើការបញ្ចប់ការសិក្សានៅវិទ្យាល័យតាមពេលកំណត់នោះទេ ។<br><br>នៅចុងបញ្ចប់នៃរយៈពេលតាមដានបួនឆ្នាំ ដោយបានបូកទាំងការទទួលបានសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ និងវិញ្ញាបនបត្រ |

| ធាតុផ្សំ | ការបរិយាយ |
|---|---|
| | ចំណេះដឹងទូទៅ អត្រានៃការបញ្ចប់ការសិក្សាតាមពេលកំណត់ គឺប្រហែលជាដូចគ្នា សម្រាប់ក្រុមកម្មវិធីត្រួតពិនិត្យ និងទំនាក់ទំនងធៀបនឹងសិស្សក្រុមមិនទទួលអន្តរាគមន៍គឺ ៣០% ធៀបនឹង ២៩% ។ (នៅត្រង់ចំណុចនេះ សិស្សទទួលអន្តរាគមន៍៣១% និងសិស្សមិនទទួលអន្តរាគមន៍១៤% នៅតែបានចុះឈ្មោះចូលរៀន ប៉ុន្តែមិនទាន់បានបញ្ចប់ការសិក្សានៅឡើយទេ។) ការសិក្សាឆ្នាំ១៩៩៨នេះមិនបានពិនិត្យទៅលើអានុភាពលើការបញ្ចប់ការសិក្សាទេ ដោយសារតែការតាមដានមានរយៈខ្លី ។ |
| ថ្លៃចំណាយ | ១.៤០០ដុល្លារ សម្រាប់សិស្សម្នាក់ ក្នុងមួយឆ្នាំ ។ (ដុល្លារ ក្នុងឆ្នាំ២០០១-២០០២) ។ |
| ការបណ្តុះបណ្តាលបុគ្គលិក | អ្នកតាមដានបានចូលរួមក្នុងសិក្ខាសាលាតម្រង់ទិសដៅលើកដំបូង ។ ពួកគេក៏បានចូលរួមកិច្ចប្រជុំបុគ្គលិកប្រចាំសប្តាហ៍ ឬប្រចាំពីរសប្តាហ៍ម្តងស្តីពីការអភិវឌ្ឍបុគ្គលិកតាមកាលកំណត់។ អ្នកតាមដានម្នាក់ៗបានទទួលការណែនាំស្តីពីរបៀបបំពេញលើតារាងពិនិត្យតាមដានដើម្បីធានាឲ្យមាននិរន្តរភាពនៅក្នុងការតាមដាន និងការកំណត់។ អ្នកតាមដានបានដាក់ជូនកំណត់ត្រាវត្តមានជាមួយនឹងតារាងពិនិត្យតាមដានរបស់ពួកគេដើម្បីធ្វើការផ្ទៀងផ្ទាត់ ។ |

## ៥. វិទ្យាល័យអភិវឌ្ឍជំនាញ

| ធាតុផ្សំ | ការបរិយាយ |
|---|---|
| ការសិក្សាពីការស្រាវជ្រាវ | Kemple, J. J., Herlihy, C. M., & Smith, T.J. (2005). *ធ្វើឲ្យមានការរីកចម្រើនឆ្ពោះទៅរកការបញ្ចប់ការសិក្សា៖ ភស្តុតាងបានពីគំរូសវិទ្យាល័យអភិវឌ្ឍជំនាញ ។* ទីក្រុងញូវយ៉ក៖ MDRC ។ |
| សំណួរសិក្សា | តើសហគមន៍រៀនសូត្រតូចៗដែលត្រូវបានបង្កើតឡើងនៅក្នុងវិទ្យាល័យអភិវឌ្ឍជំនាញ នាំឲ្យសិស្សរៀនបានរីកចម្រើននៅសាលា និង |

| ធាតុផ្សំ | ការបរិយាយ |
| --- | --- |
| ស្រាវជ្រាវ | រៀនឆាប់ចេះជាងសិស្សនៅក្នុងសាលាប្រៀបធៀបដែរឬទេ? |
| អ្នកចូលរួម | សិស្សជាច្រើនដែលត្រូវបានជ្រើសរើសសម្រាប់វិទ្យាល័យអភិវឌ្ឍជំនាញប្រឡងបានពិន្ទុទាប និងលើសអាយុចូលរៀន។ ជាង៣/៤នៃសិស្សទាំងនេះ គឺជនជាតិអាហ្វ្រិកអាមេរិក ហើយប្រហែលជា១/៦ គឺជនជាតិអាមេរិកឡាទីន (Hispanic) ។ ការអវត្តមានច្រើនតែងតែកើតមានជាធម្មតា ដែលសិស្ស២/៣ មិនបានចូលរៀនយ៉ាងហោច ២០%នៃថ្ងៃសិក្សាតាមកាលវិភាគ ក្នុងអំឡុងឆ្នាំសិក្សាថ្នាក់ទី៩របស់ពួកគេ ។<br>បន្ថែមពីលើនេះទៅទៀត សិស្សជាច្រើនរៀនមិនបានរីកចម្រើនឆ្ពោះទៅរកការបញ្ចប់ការសិក្សានោះទេ ដែលក្នុងនោះសិស្សត្រឹមតែពាក់កណ្តាលប៉ុណ្ណោះបានឡើងថ្នាក់ទី១០ នៅចុងឆ្នាំសិក្សាទី៩របស់ពួកគេ ។ សិស្សក្នុងសាលាប្រៀបធៀបដែលត្រូវបានធ្វើការប្រៀបធៀបជាទូទៅស្រដៀងនឹងសិស្សវិទ្យាល័យអភិវឌ្ឍជំនាញផ្អែកលើលក្ខណៈសម្គាល់ទាំងនេះ ។ |
| ការកំណត់ | ការសិក្សាអំពីអានុភាពនេះត្រូវបានធ្វើឡើងនៅក្នុងវិទ្យាល័យរដ្ឋដែលត្រូវបានជ្រើសរើសក្នុងហ្វីឡាឌែលហ្វីយ៉ា (Philadelphia) ។ |
| អន្តរាគមន៍ | ការសិក្សាស្រាវជ្រាវដោយខ្លួនឯង៖ សាលារដ្ឋហ្វីឡាឌែលហ្វីយ៉ាបានអនុវត្តកម្មវិធីអភិវឌ្ឍជំនាញនៅវិទ្យាល័យទាំងប្រាំពីរ។ ស្រុកនេះបានចាប់ផ្តើមដំណើរការកម្មវិធីក្នុងឆ្នាំ១៩៩៨ ដោយមានវិទ្យាល័យមួយឬពីរ ចាប់អនុវត្តកម្មវិធីអភិវឌ្ឍជំនាញរៀងរាល់ឆ្នាំសម្រាប់កម្មវិធី៥ឆ្នាំ ។<br><br>*វិទ្យាល័យអភិវឌ្ឍជំនាញ*ក្នុងស្រុកហ្វីឡាឌែលហ្វីយ៉ាបានបង្កើតកម្មវិធីសិក្សានៅថ្នាក់ទី៩នៅជាន់ ឬអគារសិក្សាដាច់ដោយឡែកពីគេ ដែលត្រូវបង្ហាត់ដោយក្រុមនៃគ្រូបង្រៀន៤ទៅ ៥នាក់។ សាលារៀននីមួយៗបានណែនាំផែនការ និងមេរៀនតាមកាលវិភាគ ដែលមានរយៈពេល៨០ ទៅ៩០នាទី ដោយណែនាំកម្មិវិធី "double dose" សម្រាប់មុខវិជ្ជា គណិតវិទ្យា និងភាសាអង់គ្លេសសម្រាប់ថ្នាក់ទី៩ និងទី១០ ។<br><br>ផ្នែកបង្ហាត់ទ្វេដងសម្រាប់មុខវិជ្ជាគណិតវិទ្យា និងភាសាអង់គ្លេសធ្វើឲ្យសិស្សត្រៀមខ្លួន និងរៀនមុខវិជ្ជាត្រៀមចូលសាកលវិទ្យាល័យ |

| ធាតុផ្សំ | ការបរិយាយ |
|---|---|
| | ក្នុងរយៈពេលតែមួយឆ្នាំ ។ សាលា៦ក្នុងចំណោមសាលា៧បានផ្តល់កម្មវិធីបន្ថែមក្រៅម៉ោងសម្រាប់សិស្សថ្មី ឬសិស្សរៀនត្រួតថ្នាក់ទី៩ ដោយសារតែអវត្តមានញឹកញាប់ និងសិស្សមានបញ្ហាផ្នែកវិន័យ។<br><br>កម្មវិធីសិក្សាស្រាវជ្រាវការងារ៖ កម្មវិធីសម្រាប់សិស្សថ្នាក់ទី១០ ដល់ទី១២ ផ្តោតលើកម្មវិធីសិក្សាស្រាវជ្រាវការងារ ដែលសិស្សត្រូវបានបែងចែកជា "សហគមន៍រៀនសូត្រ" តូចៗ ទាក់ទងនឹងចំណាប់អារម្មណ៍ការងារយ៉ាងទូលំទូលាយ ហើយកម្មវិធីសិក្សានេះត្រូវបានរៀបចំទាក់ទងនឹងប្រធានបទអាជីពការងារ ។<br><br>កម្មវិធីបន្ទាប់ពីម៉ោងសិក្សា៖ ចំពោះសិស្សដែលមានបញ្ហាអវត្តមាន ឬវិន័យ សាលានឹងបន្ថែមកម្មវិធីក្រោយម៉ោងសិក្សាជួយ និងផ្តល់ការគាំទ្រដល់ពួកគេ។ |
| ការប្រៀបធៀប | សាលារប្រៀបធៀបផ្សេងទៀតមានសាលានៅស្រុកហ្វីឡាដែលហ្វីយ៉ាដែលមិនបានអនុវត្ត ***កម្មវិធីអភិវឌ្ឍជំនាញ*** ។ អ្នកនិពន្ធបានប្រៀបធៀបក្រុមអន្តរាគមន៍ជាមួយសិស្សនៅក្នុងសាលាប្រៀបធៀប និងជាមួយសិស្សដែលបានចូលរៀននៅសាលាអន្តរាគមន៍មុននឹងអនុវត្ត ***កម្មវិធីអភិវឌ្ឍទេពជំនាញ។*** |
| វិធីសាស្ត្រ | គំរូវិភាគសំខាន់ៗរួមមានដំបូង សិស្សថ្នាក់ទី៩មកពីវិទ្យាល័យ៥ដែលចាប់ផ្តើមអនុវត្ត ***កម្មវិធីអភិវឌ្ឍជំនាញ*** ចន្លោះឆ្នាំ ១៩៩៩ និង ២០០១ និងវិទ្យាល័យប្រៀបធៀបដែលត្រូវបានផ្គូរផ្គងចំនួន៦ ។<br>សាលាប្រៀបធៀបពីរ ទៅបួនត្រូវបានប្រៀបធៀបជាមួយសាលាអន្តរាគមន៍នីមួយៗក្នុងចំណោមសាលាអន្តរាគមន៍៥ផ្អែកលើសមាសភាគជាតិសាសន៍/ជនជាតិ និងអត្រាឡើងថ្នាក់សម្រាប់សិស្សថ្នាក់ទី៩។ សាលាមកយកប្រៀបធៀបអាចនឹងផ្គូផ្គងនឹងសាលា ដែលមាន ***កម្មវិធីអភិវឌ្ឍជំនាញ*** ជាច្រើន ។<br><br>ការសិក្សាស្រាវជ្រាវប្រៀបធៀបលទ្ធផលនៃសិស្សថ្នាក់ទី៩ដែលចូលរួម ***កម្មវិធីអភិវឌ្ឍជំនាញ*** នៅក្នុងរយៈពេលបីឆ្នាំ បន្ទាប់ពីកម្មវិធី |

| ធាតុផ្សំ | ការបរិយាយ |
|---|---|
| | នេះត្រូវបានអនុវត្ត ជាមួយសិស្សថ្នាក់ទី៩មកពីសាលាទាំងនេះក្នុងរយៈពេល៣ឆ្នាំ មុនពេលអនុវត្តកម្មវិធី និងដោយមានលទ្ធផលខុសគ្នាក្នុងរយៈពេលដូចគ្នាសម្រាប់សាលាប្រៀបធៀបដែលបានត្រូវផ្គូផ្គង។ ការសិក្សានេះពិនិត្យលើសិស្សបីក្រុម។<br>.<br>ក្រុមសិស្សទី១ រួមមានសិស្សនៅក្នុងសាលាអន្តរាគមន៍ និងសាលាប្រៀបធៀបដែលត្រូវបានផ្គូផ្គងដែលបានចុះឈ្មោះចូលរៀនថ្នាក់ទី៩ ក្នុងអំឡុងឆ្នាំទី១នៃការអនុវត្ត*កម្មវិធីអភិវឌ្ឍជំនាញ* នៅសាលាអន្តរាគមន៍។ ដូចគ្នានេះដែរ សម្រាប់ ក្រុម ២ និងក្រុម៣ រួមមានសិស្សដែលបានចុះឈ្មោះចូលរៀនថ្នាក់ទី៩ នៅឆ្នាំទី២ និងទី៣នៃការអនុវត្ត។ ដើម្បីធានាថា ទំហំគំរូតាងសម្រាប់ ពិនិត្យតាមដានឲ្យបានគ្រប់គ្រាន់ ដើម្បីវាយតម្លៃលើប្រសិទ្ធភាពនៃកម្មវិធី។<br>ការវាយតម្លៃប្រើលទ្ធផលឆ្នាំទីពីរផ្អែកលើការក្រុមទី១ និងក្រុមទី២ ។ |
| **ខ្នាតវង្វាស់ និងលទ្ធផលសំខាន់ៗ** | <u>រៀនបានរីកចំរើននៅសាលា</u>៖ ឥទ្ធិពលវិជ្ជមាន ។ សិស្សប្រើប្រាស់ *កម្មវិធីអភិវឌ្ឍជំនាញ* ទទួលបានក្រេឌីត៩,៥ ជាមធ្យម ក្នុងពីរឆ្នាំដំបូងនៅសាលា ចំណែកឯសិស្សក្នុងក្រុមប្រៀបធៀបទទួលបានតែក្រេឌីតមុខវិជ្ជា៨,៦ ។ លើសពីនេះទៀត សិស្ស*កម្មវិធីអភិវឌ្ឍជំនាញ* ទំនងជាមានឱកាសឡើងថ្នាក់ទី១០ច្រើនជាងក្រុមសិស្សដែលមិនបានចូលរួម(៦៨%ធៀបនឹង៦០%)។ ភាពខុសប្លែកទាំងពីរនេះគឺជាការសំខាន់ក្នុងស្ថិតិ។ |
| **ថ្លៃចំណាយ** | ចំណាយមធ្យមសម្រាប់សិស្សម្នាក់ក្នុងស្រុកគឺ ៣៥០ដុល្លារក្នុង១ឆ្នាំ (ដុល្លារក្នុងឆ្នាំ២០០៥) |
| **ការបណ្តុះបណ្តាលបុគ្គលិក** | គ្រូបង្រៀននៅក្នុង*កម្មវិធីអភិវឌ្ឍជំនាញនៅសាលា* គឺជាគ្រូពេញសិទ្ធិដែលធ្វើការឲ្យសាលារដ្ឋនៅហ្វ៊ីឡាដែលហ្វីយ៉ា។ "គ្រូចំកម្មវិធីសិក្សា" ជាអ្នកដែលត្រូវបានបណ្តុះបណ្តាលដោយអ្នកបង្កើតអន្តរាគមន៍ ដែលទទួលបានជំនួយបច្ចេកទេសនៅនឹងកន្លែងក្នុងការអនុវត្តគំរូ*កម្មវិធីអភិវឌ្ឍជំនាញនៅសាលា* ។ អ្នកបង្កើតអន្តរាគមន៍ក៏បានផ្តល់វិទ្យាស្ថានបណ្តុះបណ្តាលសម្រាប់រដូវក្តៅដល់បុគ្គលិកផងដែរ ។ |

## ៦- កម្មវិធីដប់ពីរនាក់រួមគ្នា

| ធាតុផ្សំ | បរិយាយ |
|---|---|
| ដកស្រង់ឯកសារស្រាវជ្រាវ | Dynarski, M., Gleason, P., Rangarajan, A., & Wood, R. (1998d).អានុភាព *នៃកម្មវិធីសាកល្បងទប់ស្កាត់សិស្សបោះបង់សាលាៈរបាយការណ៍ចុងក្រោយ។ របាយការណ៍ស្រាវជ្រាវអំពីការវាយតម្លៃកម្មវិធីជំនួយសម្រាប់សិស្សបោះបង់សាលា។* Princeton, NJ: Mathematica Policy Research, Inc. |
| សំណួរស្រាវជ្រាវ | តើ ***កម្មវិធីដប់ពីរនាក់រួមគ្នា*** ដែលជាកម្មវិធីមិត្តជួយមិត្ត និងអប់រំណែនាំមិត្តទទួលបានជោគជ័យក្នុងការងារជំរុញឲ្យសិស្សថ្នាក់ទី៨នៅរៀនបន្ត និងរៀនបានរីកចំរើននៅសាលាដែរឬទេ? |
| អ្នកចូលរួម | គំរូនៃការសិក្សារបស់សិស្ស៥០០នាក់មានពីរក្រុម។ ក្រុមធំទី១ រួមមានសិស្ស១៣០នាក់នៅក្នុងក្រុមអន្តរាគមន៍ (ក្រុមទទួលអន្តរាគមន៍ពីគម្រោង) និងសិស្ស១១៦នាក់ នៅក្នុងក្រុមមិនទទួលអន្តរាគមន៍ពីគម្រោង ដែលសុទ្ធតែជាសិស្សថ្នាក់ទី៨ ក្នុងឆ្នាំសិក្សា១៩៩២-១៩៩៣ ។ ក្រុមទី២ រួមមានសិស្ស១៣៣នាក់នៅក្រុមទទួលអន្តរាគមន៍ (ក្រុមទទួលអន្តរាគមន៍ពីគម្រោង) និង សិស្ស១២១នាក់នៅក្នុងក្រុមមិនបានចូលរួមកម្មវិធីដែលសុទ្ធតែជាសិស្សទី៨ក្នុងឆ្នាំសិក្សា១៩៩៣-១៩៩៤ ។ អ្នកចូលរួម ជាមធ្យមមានអាយុ១៤ ឆ្នាំ នៅពេលជ្រើសរើសព្រាវៗ សម្រាប់ការសិក្សាស្រាវជ្រាវនេះ។ ប្រហែលពាក់កណ្តាលនៃគំរូតាងគឺជាអំបូរនិយាយភាសាអេស្ប៉ាញ (Hispanic) ហើយមួយភាគបួនមកពីអំបូរអាស៊ី និងជាតិសាសន៍ដទៃ ចំណែកអំបូរជនជាតិស្បែកសមានប្រហែលម្នាក់ក្នុងចំណោម៧នាក់ និងអំបូរជនជាតិស្បែកខ្មៅមានប្រហែលម្នាក់ក្នុងចំណោម១០នាក់ ។<br><br>អ្នកចូលរួមតែមួយភាគបួនប៉ុណ្ណោះរស់នៅជាមួយតែឪពុក ឬ ម្តាយ ឬនៅក្នុងគ្រួសារគ្មានឪពុកម្តាយ។ សិស្សប្រហែលម្នាក់ក្នុងចំណោម៧នាក់រស់នៅក្នុងគ្រួសារដែលទទួលជំនួយពីរដ្ឋ ហើយម្នាក់ក្នុងចំណោម៥នាក់ មិននិយាយភាសាអង់គ្លេសនៅផ្ទះ ។ ប្រហែលជាងមួយភាគបីមានបញ្ហាផ្នែកវិន័យកាលពីឆ្នាំសិក្សាកន្លងទៅ។ |

| ធាតុផ្សំ | បរិយាយ |
| --- | --- |
| ការកំណត់ | ការស្រាវជ្រាវអំពី *កម្មវិធីជប់ពីរនាក់រួមគ្នា* ត្រូវបានធ្វើឡើងនៅថ្នាក់រៀនទី៩ នៅវិទ្យាល័យស្រុកស្ទីត វាត់ធីញូយៀន ដែលមានទីតាំងនៅ ជូឡា វីស្តា រដ្ឋកាលីហ្វ័រញ៉ា (នៅជិត សាន ឌីហ្គូ)។ |
| អន្តរាគមន៍ | កម្មវិធីគាំទ្រមិត្តជួយមិត្ត និងអប់រំណែនាំមិត្ត៖ ***កម្មវិធីជប់ពីរនាក់រួមគ្នា*** ជាកម្មវិធីមិត្តជួយមិត្ត និងអប់រំណែនាំមិត្តសម្រាប់សិស្សថ្នាក់ទី៨។ កម្មវិធីស្ម័គ្រចិត្ត១ឆ្នាំ ផ្តល់ក្រុមពិភាក្សាក្រៅម៉ោងសិក្សាប្រចាំសប្តាហ៍ ។ ក្រុមនីមួយៗមានសិស្ស ១២ នាក់រួមមានចំនួនស្មើគ្នាពីក្រុមប្រឈមនឹងបញ្ហាសិក្សាបីក្រុម(ប្រឈមខ្ពស់-មធ្យម និងទាប) ដែលសាលាបានកំណត់ ។ ក្រុមទាំងនោះដឹកនាំដោយអ្នកសម្របសម្រួលពេញវ័យស្ម័គ្រចិត្តដែលទទួលការបណ្តុះបណ្តាលពីរនាក់ ធ្វើការសម្របសម្រួលកិច្ចពិភាក្សា ។ ប្រធានបទ ជ្រើសរើសតាមចំណាប់អារម្មណ៍របស់សិស្ស ផ្តោតលើបញ្ហាផ្ទាល់ខ្លួន គ្រួសារ និងសង្គម ។ ក្រៅពីការចូលរួមវគ្គពិភាក្សានេះ សិក្ខាកាម ឯកភាពថានឹងចូលរួមជាទៀងទាត់ មិនអវត្តមាន និង ព្យាយាមខិតខំរៀនបានពិន្ទុឲ្យបានល្អឡើង។ អ្នកសម្របសម្រួលច្រើនតែជានិស្សិតមហាវិទ្យាល័យ ដែលជួយធ្វើកិច្ចការសាលាផងដែរ ។<br>សកម្មភាពកម្មវិធីសិក្សាបន្ថែម៖ ជួយជំរុញការសាមគ្គីក្នុងក្រុម និងអភិវឌ្ឍជំនាញធ្វើការជាក្រុម មានដូចជាកម្មវិធីចាប់ផ្តើមការបោះជំរំ ចុងសប្តាហ៍ ។ ក្រៅពីនេះក៏រួមមានសកម្មភាពផ្សេងទៀតដូចជាទស្សនកិច្ចនៅ មហាវិទ្យាល័យ និងការចូលរួមព្រឹត្តការណ៍សង្គម។ |
| ការប្រៀបធៀប | សិស្សក្នុងក្រុមមិនទទួលអន្តរាគមន៍មិនបានចូលរួមក្នុង *កម្មវិធីជប់ពីរនាក់រួមគ្នា* និងមិនបានចូលរៀននៅអនុវិទ្យាល័យដូចក្រុមទទួលអន្តរាគមន៍បំប៉នបន្ថែមនោះទេ។ សិស្សក្នុងក្រុមមិនទទួលអន្តរាគមន៍បានចូលរៀននៅថ្នាក់បំប៉នបន្ថែមសម្រាប់មុខវិជ្ជា ដូចជាអក្សរសាស្ត្រ គណិតវិទ្យា និងមុខវិជ្ជាផ្សេងទៀតច្រើនជាងក្រុមសិស្សចូលរួមកម្មវិធី (៤១%ធៀបនឹង ៣២%) ។ |
| វិធីសាស្ត្រ | ការសិក្សាស្រាវជ្រាវអំពី *កម្មវិធីជប់ពីរនាក់រួមគ្នា* ប្រើគម្រោងស្រាវជ្រាវសាកល្បងព្រាវៗ។ ការចាត់ចែងព្រាវៗត្រូវបានធ្វើឡើងនៅដើមឆ្នាំសិក្សាថ្នាក់ទី៨ ។ ដើម្បីធានាឲ្យមានសមត្ថភាពសិក្សាចម្រុះ សាលាបានបែងចែកបេក្ខជនជាប្រភេទប្រឈមកម្រិតខ្ពស់ មធ្យម និងទាប ។ នៅក្នុងប្រភេទទាំងនេះ សាលាបានប្រៀបធៀបសិស្សប្រហាក់ប្រហែលគ្នា ហើយចាត់ចំណាត់ថ្នាក់ក្រុម |

| ធាតុផ្សំ | បរិយាយ |
|---|---|
| | ទាំងនេះតាមរយៈអាទិភាពក្នុងការចូលរួមកម្មវិធីនេះ។ ដោយមិនគិតពីចំនួនបេក្ខជន នៅក្នុងចំណាត់ប្រភេទប្រឈមនីមួយៗ នៅពេលដាក់ចូលក្នុងក្រុម ***កម្មវិធីដប់ពីរនាក់រួមគ្នា*** ជាក់លាក់មួយ ចំនួនស្មើគ្នានៃក្រុមសិស្សត្រូវបានជ្រើសរើសពីក្រុមនីមួយៗ ដោយចាប់ផ្តើមពីក្រុមដែលមានអាទិភាពខ្ពស់នៅក្នុងប្រភេទក្រុមនីមួយៗ ។ បន្ទាប់មក សិស្សម្នាក់មកពីក្រុមនីមួយៗ ត្រូវបានជ្រើសរើសព្រាវៗឲ្យចូលរួមក្នុងក្រុម ចំណែកឯសិស្សម្នាក់ទៀតត្រូវបានបញ្ចូលទៅក្នុងក្រុមមិនទទួលអន្តរាគមន៍ពីគម្រោង។ ហេតុដូច្នេះហើយ ក្រុមនីមួយៗមានចំនួនសិស្សស្មើគ្នាមកពីប្រភេទនីមួយៗក្នុងចំណោមប្រភេទប្រឈមទាំង៣។<br><br>ដើម្បីជានាឲ្យមានការតាមដានបន្តគ្រប់គ្រាន់ក្នុងការវាយតម្លៃអានុភាពលើការនៅរៀនបន្ត និងការរៀនបានរីកចំរើននៅសាលា គេបានប្រើលទ្ធផលតាមដានឆ្នាំទីបី។ លទ្ធផលទាំងនេះបានមកពីការអង្កេតតាមដានដែលអនុវត្តចំពោះសិស្សនៅក្នុងក្រុមទី១ ក្នុងឆ្នាំ១៩៩៥ ដែលមានរយៈពេលប្រហែល៣ឆ្នាំ បន្ទាប់ពីការជ្រើសរើសព្រាវៗ-សិស្សក្នុងក្រុមទទួលអន្តរាគមន៍ពីគម្រោងចំនួន១១៩នាក់ និងសិស្សក្នុងក្រុមមិនទទួលអន្តរាគមន៍ពីគម្រោង១០០នាក់បានឆ្លើយតប -អត្រាឆ្លើយតបមាន ៩២% និង ៨៦% ។ ដោយសារអត្រាឆ្លើយតបបង្ហាញពីអត្រារេចរិលខុសៗគ្នាជាង៥% បានជាការសិក្សាស្រាវជ្រាវនេះត្រូវបានវាយតម្លៃថាជា "ការឆ្លើយតបទៅនឹងស្តង់ដារភស្តុតាងមិនបានពេញលេញ" ។ អ្នកស្រាវជ្រាវប្រៀបធៀបលក្ខណៈមូលដ្ឋាននៃអ្នកឆ្លើយសំណួរតាមដានឆ្នាំទី៣ក្នុងក្រុមស្រាវជ្រាវទាំងពីរតាមខ្នាតរង្វាស់ផ្នែកប្រជាសាស្ត្រ សេដ្ឋកិច្ចសង្គម និងការអនុវត្តការងារនៅសាលាទាំង១៣ ។ ការសាកល្បងស្ថិតិនៃភាពខុសគ្នាជាទូទៅរវាងក្រុមស្រាវជ្រាវអំពីលក្ខណៈមូលដ្ឋានទាំង១៣បានរកឃើញថា ក្រុមទាំងពីរមិនមានអ្វីខុសប្លែកច្រើនទេ។ |
| ខ្នាតរង្វាស់ និងលទ្ធផលបឋមសិក្សា | <u>ការនៅរៀន</u>៖ អានុភាពសំខាន់ៗ។ នៅចុងឆ្នាំទីបីនៃការតាមដាន ៨%នៃសិស្ស ***កម្មវិធីដប់ពីរនាក់រួមគ្នា*** បានបោះបង់សាលា ធៀបនឹងសិស្សក្នុងក្រុមមិនទទួលអន្តរាគមន៍ពីគម្រោងមាន១៣%។ ទោះជាភាពខុសប្លែកគ្នានេះមិនសំខាន់ ក្នុងស្ថិតិក៏ដោយ ក៏វាធំល្មមនឹងអាចចាត់ទុកបានថា សំខាន់ខ្លះដែរ។<br><br><u>រៀនបានរីកចំរើននៅសាលា</u>៖ មិនមានអានុភាព។ នៅចុងឆ្នាំតាមដានទី៣ ***កម្មវិធីដប់ពីរនាក់រួមគ្នា*** មិនមានឥទ្ធិពលអ្វីទៅលើការ |

| ធាតុផ្សំ | បរិយាយ |
|---|---|
| | រៀនបានរីកចំរើននៅសាលា តាមការវាស់វែងថ្នាក់ខ្ពស់បំផុតដែលពួកគេបានបញ្ចប់។ |
| ថ្លៃចំណាយ | ៣០៧ ដុល្លារសម្រាប់សិស្សម្នាក់ក្នុង១ខែ សម្រាប់រយៈពេល៩ខែ ឬស្មើនឹង ២ ៧៦៣ដុល្លារក្នុង១ឆ្នាំ(ដុល្លារ២០០៥) |
| ការបណ្តុះបណ្តាលបុគ្គលិក | អ្នកសម្របសម្រួល*កម្មវិធីជប់ពីរនាក់រួមគ្នា* ភាគច្រើនជានិស្សិត ឬក៏អតីតនិស្សិតបញ្ចប់ការសិក្សាពីសាកលវិទ្យាល័យស៊ែន ឌីហ្គូ ស្ទេត (San Diego State )។ ក្នុងអំឡុងពេលប្រតិបត្តិការសាកលវិទ្យាល័យបានផ្តល់មុខវិជ្ជាដែលមានគិតជាក្រេឌីតសម្រាប់បណ្តុះបណ្តាលនិស្សិតឲ្យធ្វើជា អ្នកសម្របសម្រួល*កម្មវិធីជប់ពីរនាក់រួមគ្នា* |

## កម្មវិធីទប់ស្កាត់សិស្សបោះបង់សាលានៅប្រទេសកំពុងអភិវឌ្ឍ

## ៦-ប្រទេសប្រេស៊ីលៈ កម្មវិធីគ្រួសារបូលសា ហ្វាមីលៀ (Bolsa Familia) នៃការផ្ទេរប្រាក់មានល័ក្ខខ័ណ្ឌ

| ធាតុផ្សំ | បរិយាយ |
|---|---|
| អត្ថបទដកស្រង់ស្រាវជ្រាវ | Glewwe, P. & Kassouf, L. (2010).អានុភាពនៃកម្មវិធីការផ្ទេរប្រាក់មានល័ក្ខខ័ណ្ឌគ្រួសារបូលសា អេស្កូឡា/ហ្វាមីលៀ ទៅលើអត្រាចុះឈ្មោះចូលរៀន អាត្រាការឡើងថ្នាក់ និងសិស្សបោះបង់សាលានៅប្រទេសប្រេស៊ីល។ http://www.apec.umn.edu/faculty/pglewwe/documents/BrBolsa6.pdf |
| សំណួរស្រាវជ្រាវ | តើកម្មវិធីការផ្ទេរប្រាក់មានល័ក្ខខ័ណ្ឌមានអានុភាពដល់លទ្ធផលការអប់រំរបស់សិស្សបឋមសិក្សា និងអនុវិទ្យាល័យយ៉ាងណាខ្លះ? |
| អ្នកចូលរួម | គ្រួសារក្រីក្រដែលមានកូនអាយុ ៦ ដល់ ១៥ឆ្នាំ(រៀនថ្នាក់ទី ១ ដល់ថ្នាក់ទី៨) |
| ការកំណត់ | ប្រទេសប្រេស៊ីល (នៅទូទាំងប្រទេស) |
| អន្តរាគមន៍ | <u>កម្មវិធីការផ្ទេរប្រាក់មានល័ក្ខខ័ណ្ឌ</u>៖ ដើម្បីបំពេញល័ក្ខខ័ណ្ឌកម្មវិធីគ្រួសារបូលសា *Bolsa Familia* គឺសម្រាប់គ្រួសារ ដែលមានចំណូលតិចជាង៦០ដុល្លារក្នុង១ខែ ដែលទាបជាងពាក់កណ្តាលនៃប្រាក់ខែអប្បបរិមានៅប្រទេសប្រេស៊ីល ។ អ្នកដែលមានប្រាក់ចំណូលប្រចាំខែពី៣០ដុល្លារ ទៅ៦០ដុល្លារក្នុងមួយខែ មានសិទ្ធិទទួលការឧបត្ថម្ភ ប្រសិនបើពួកគេមានកូនអាយុក្រោម ១៦ ឆ្នាំ ឬកូននៅបៅដោះ ឬក៏ជាស្ត្រីមានផ្ទៃពោះ។ គ្រួសារដែលមានប្រាក់ចំណូលប្រចាំខែក្រោម ៣០ដុល្លារត្រូវចាត់ចំណាត់ថ្នាក់ថាជាអ្នកក្រីក្រខ្លាំង ហើយនៅតែទទួលប្រាក់ឧបត្ថម្ភប្រចាំខែ២៥ដុល្លារ បើទោះជាគេគ្មានកូនតូច កូននៅបៅដោះ ឬគ្មានផ្ទៃពោះក៏ដោយ ។ ដើម្បីទទួលប្រាក់សម្រាប់កុមារ/ស្ត្រីម្នាក់ៗ កុមារម្នាក់ៗដែលមានអាយុ៦ឆ្នាំ ដល់ ១៥ ឆ្នាំ ត្រូវមកចុះឈ្មោះចូលរៀន និងយ៉ាងហោចណាស់ចូលរៀនឲ្យបាន៨៥%នៃថ្ងៃចូលរៀន ហើយ ស្ត្រីមានផ្ទៃពោះ ឬស្ត្រីបំបៅដោះកូនគ្រប់រូប ត្រូវតែទទួលសេវាថែទាំសុខភាពមុននិងក្រោយពេលសម្រាលកូន ហើយកូនដែលមានអាយុ ០ឆ្នាំដល់៧ឆ្នាំ ត្រូវតែទទួលវាក់សាំងការពារជម្ងឺតាមការណែនាំ។ ដើម្បីចុះឈ្មោះចូលរួមកម្មវិធី**បូលសា** គ្រួសារត្រូវបំពេញពាក្យសុំ ដែលមាននៅសាលាក្រុង municipio ដែលស្នើសុំព័ត៌មានអំពីប្រាក់ចំណូល និងសមាសភាគគ្រួសា |

| ធាតុផ្សំ | បរិយាយ |
|---|---|
| | រ។ ព័ត៌មាននេះនឹងកំណត់ភាពមានសិទ្ធិ ដែលអាស្រ័យទៅតាមថវិកាសាលាក្រុងសម្រាប់កម្មវិធីបូលសា។ មូលនិធិបូលសា ត្រូវបានផ្ទេរដោយផ្ទាល់ពីក្រសួងអភិវឌ្ឍសង្គម ដល់គ្រួសារតាមផ្ទះ តាមរយៈប័ណ្ណធនាគារហើយសាលាខេត្តរដ្ឋធានីមានតួនាទីគ្រាន់តែកំណត់អត្តសញ្ញាណអ្នកទទួលប្រាក់ប៉ុណ្ណោះ។ |
| **ការប្រៀបធៀប** | សិស្សដែលចូលរួមកម្មវិធីបូលសា និងមិនចូលរួមកម្មវិធីត្រូវបានប្រៀបធៀបដោយប្រើទិន្នន័យជំរឿនសាលារៀន |
| **វិធីសាស្រ្ត** | ការផ្លាស់ប្តូរដែលប្រៀបធៀបគ្នាតាមវិធីសាស្រ្តប៉ាន់ស្មានក្នុងការសិក្សាស្រាវជ្រាវចំពោះអត្រាចុះឈ្មោះចូលរៀន អត្រាបោះបង់សាលា និងអត្រាឡើងថ្នាក់ ដោយប្រើទិន្នន័យជំរឿនសាលារៀន រយៈពេល៨ឆ្នាំ (ពីឆ្នាំ១៩៩៨ដល់២០០៥) នៅគ្រប់សាលាដែលអនុវត្តកម្មវិធីបូលសា នៅពេលខុសគ្នា ។ ការសិក្សានេះបានប៉ាន់ស្មានការថយចុះរបស់ក្រុមផ្សេងទៀតដែលមិនចូលរួមកម្មវិធីដើម្បីពិនិត្យលើអានុភាពនៃចំនួនឆ្នាំ អានុភាពសាលារៀន និង និន្នាការម៉ោងសិក្សារបស់សាលារដ្ឋដែលអនុវត្តកម្មវិធីបូលសា ក្នុងឆ្នាំ២០០១ និង និន្នាការស្រដៀងគ្នាសម្រាប់សាលារៀន ដែលអនុវត្តកម្មវិធីបូលសា ក្នុងឆ្នាំ ២០០២ ឬពេលក្រោយមកទៀត ហើយនិន្នាការពេលវេលាផ្អែកលើការចុះឈ្មោះឆ្នាំ១៩៩៨។ |
| ខ្នាតរង្វាស់ និង លទ្ធផលសំខាន់ៗ | <u>ការចុះឈ្មោះចូលរៀន</u>៖ មានអានុភាពវិជ្ជមាន។ កម្មវិធីនេះបានធ្វើឲ្យការចុះឈ្មោះចូលរៀនកើនឡើង នៅប្រទេសប្រេស៊ីល ប្រហែលជា៥.៥%សម្រាប់ថ្នាក់ទី១ ដល់ទី៤ និងប្រហែលជា ៦.៥%សម្រាប់ថ្នាក់ទី៥ ដល់ទី៨ ។<br><br><u>ការនៅរៀន៖</u> មានអានុភាពវិជ្ជមាន ។ កម្មវិធីនេះបានកាត់បន្ថយអត្រាបោះបង់សាលា០.៥% សម្រាប់កុមារថ្នាក់ទី១ ដល់ទី៤ និង ០.៤%សម្រាប់កុមាររៀនថ្នាក់ទី៥ដល់ទី៨។<br><br><u>ការរៀនបានរីកចំរើននៅសាលា៖</u> មានអានុភាពវិជ្ជមាន។ កម្មវិធីបានបង្កើនអត្រាឡើងថ្នាក់ប្រហែល០.៩% សម្រាប់កុមារថ្នាក់ទី១ដល់ទី៤ និងបានប្រហែលជា០.៣%សម្រាប់កុមាររៀនថ្នាក់ទី៥ដល់ទី៨ ។ |
| **ថ្លៃចំណាយ** | គ្រួសារដែលមានចំណូលពី៣០ដុល្លារទៅ៦០ដុល្លារក្នុង១ខែទទួលបាន ៧.៥០ដុល្លារសម្រាប់ម្នាក់ៗ (រាប់ទាំងកូនអាយុ ០ឆ្នាំដល់១៥ឆ្នាំ ឬស្ត្រីមានផ្ទៃពោះ ឬក៏ស្ត្រីបំបៅដោះកូន) រហូតដល់យ៉ាងច្រើនបំផុតត្រឹម ៣នាក់(ចៀសវៀងការផ្តល់ការឧបត្ថម្ភដើម្បីបង្កើនការបង្កកំណើតបន្ថែមទៀត) ។ |

| ធាតុផ្សំ | បរិយាយ |
| --- | --- |
| | គ្រួសារដែលមានចំណូលក្រោម៣០ដុល្លារ ក្នុង១ខែទទួលបាន២៥ដុល្លារក្នុង១ខែនិងបន្ថែម៧.៥០ដុល្លារសម្រាប់ម្នាក់ៗ(យ៉ាងច្រើនបំផុតត្រឹម៣នាក់)។ (អត្រាប្តូរប្រាក់ដុល្លារឆ្នាំ២០០៥) |
| បណ្តុះបណ្តាលបុគ្គលិក | មិនមានការ បណ្តុះបណ្តាលបុគ្គលិក |

## ប្រទេសបួគីណា ហ្វាសូះ កម្មវិធី BRIGHT ដើម្បីលើកកម្ពស់វិស័យអប់រំ

| ធាតុផ្សំ | បរិយាយ |
|---|---|
| ការដកស្រង់ ពីអត្ថបទសិក្សាស្រាវជ្រាវ | Levy, D., Sloan, M., Linden, L.,&Kazianga, H. (2009).ការវាយតម្លៃអានុភាពនៃកម្មវិធី BRIGHT របស់ប្រទេសបួគីណាហ្វាសូ ។ របាយការណ៍ចុងក្រោយ ។ បោះផ្សាយដោយក្រុមហ៊ុនស្រាវជ្រាវគោលនយោបាយ Mathematica ។ |
| សំណួរស្រាវជ្រាវ | (១) តើការឆ្លើយតបរបស់ប្រទេសបួគីណា មានអានុភាពយ៉ាងណាដល់ការជម្រុញឱកាសដល់កុមារីដើម្បីសម្រេចបានកម្មវិធី BRIGHT ចំពោះការចុះឈ្មោះចូលរៀន?<br>(២)តើកម្មវិធីមានអានុភាពយ៉ាងណាដល់កម្មវិធីស្តីពីពិន្ទុប្រឡង?<br>(៣)តើអានុភាពសម្រាប់កុមារីខុសគ្នាច្រើនជាង បើធៀបនឹងកុមារាដែរឬទេ? |
| អ្នកចូលរួម | សិស្សសាលាបឋមសិក្សានៅភូមិ ចំនួន១៣២ |
| បរិបទ | <u>ប្រទេសបួគីណា ហ្វាសូ</u> ។ ខេត្ត១០ ក្នុងប្រទេសនេះដែលមានអត្រាបញ្ចប់ការសិក្សានៅកម្រិតបឋមសិក្សាសម្រាប់កុមារីទាបជាងគេមាន(Banwa, Gnagana, Komandjari, Namentenga, Oudalan,Sanmentenga, Seno, Soum, Tapoa, and Yagha) |
| អន្តរាគមន៍ | <u>សំណង់ ៖</u> កម្មវិធីសាងសង់សាលាបឋមសិក្សា១៣២ នៅតាមភូមិជនបទដែលមានអត្រាចុះឈ្មោះសម្រាប់កុមារីទាបជាងគេ។<br>សាលារៀននីមួយៗត្រូវរចនាប្លង់ទៅតាមគំរូដើមដែលរួមមាន ថ្នាក់រៀនបី កន្លែងស្នាក់នៅសម្រាប់គ្រូបីនាក់ អណ្តូងស្នប់ និងបង្គន់ចែកដាច់សម្រាប់កុមារា និងកុមារី ។<br><br><u>អាហារដ្ឋាននៅសាលា (អាហារប្រចាំថ្ងៃសម្រាប់គ្រប់គ្នា)៖</u> ផ្តល់អាហារប្រចាំថ្ងៃដល់សិស្សគ្រប់គ្នានៅក្នុងសាលាទាំងកុមារា និងកុមារី។<br><br><u>របបស្បៀងអាហារយកទៅផ្ទះ</u> ៖ កុមារីដែលចូលរៀនបាន៩០% ទទួលបានស្បៀងជាធញ្ញជាតិក្រៀមប្រហែលជា ៨គីឡូក្រាម ក្នុង |

| ធាតុផ្សំ | បរិយាយ |
|---|---|
| | មួយខែយកទៅផ្ទះ ។<br>សម្ភារៈសិក្សា និងសៀវភៅ៖ សៀវភៅ និងសម្ភារៈសិក្សាបានផ្ដល់ដល់គ្រប់សិស្សទាំងអស់គ្នា ។<br>យុទ្ធនាការប្រមូលផ្ដុំ៖ យុទ្ធនាការប្រមូលផ្ដុំបាននាំឲ្យសហគមន៍ជួបជុំគ្នាហើយអ្នកដែលពាក់ព័ន្ធនឹងប្រព័ន្ធអប់រំ ពិភាក្សាបញ្ហាដែលទាក់ទិន និងអំពីឧបសគ្គដល់ការសិក្សារបស់កុមារី។ យុទ្ធនាការរួមមានការប្រជុំផ្ដោះប្ដូរ ព័ត៌មាន ការសាកសួរដល់ផ្ទះ ការបណ្ដុះបណ្ដាលអំពីការយល់ដឹងយែនឌ័រដល់មន្ត្រីក្រសួងអធិការកិច្ចគរុកោសល្យគ្រូបង្រៀន និង សមាជិកសហគមន៍-បង្កើតទិវាអប់រំសម្រាប់កុមារី ការផ្សព្វផ្សាយតាមវិទ្យុ ផ្ទាំងក្រដាសបិទផ្សាយ និងផ្ដល់រង្វាន់ដល់អ្នកគ្រូបង្រៀន។<br>**អក្ខរកម្ម ៖ កម្មវិធីអក្ខរកម្ម រួមមានការបណ្ដុះបណ្ដាល អក្ខរកម្មមនុស្សពេញវ័យ និងការតម្រង់ទិសសម្រាប់កុមារី**<br>**ការកសាងសមត្ថភាពភាពជាដៃគូនៅមូលដ្ឋាន៖ ការបណ្ដុះបណ្ដាលរួមមានមន្ត្រីមូលដ្ឋាន នៅក្នុងក្រសួងអប់រំ អ្នកគ្រប់គ្រង មណ្ឌលថែរក្សាកុមារ និងគ្រូបង្រៀន ។ ការបណ្ដុះបណ្ដាលជាក់លាក់រួមមានទាំងការបំពេញពាក្យចុះឈ្មោះចូលរៀន។** |
| ការប្រៀប ធៀប | ទម្រង់វាយតម្លៃទាក់ទិននឹងការប្រៀបធៀបកុមារក្នុងភូមិចូលរួមកម្មវិធី BRIGHT ទាំង១៣២ភូមិ (ក្រុមចូលរួម) ជាមួយ ក្រុមកុមារចំនួន ១៦១ភូមិដែលស្រដៀងគ្នានឹងកុមារក្នុងកម្មវិធី BRIGHT ដែរក៏ប៉ុន្តែកុមារទាំងនោះមិនបានចូលរួមកម្មវិធីទេ(ក្រុមសម្រាប់ប្រៀបធៀប) |
| វិធីសាស្ត្រ | ការអង្កេតតាមផ្ទះ ៖ ការអង្កេតទល់មុខគ្នាត្រូវបានធ្វើឡើងដោយរួមបញ្ចូលសំណួរអំពីប្រជាសាស្ត្រតាមគ្រួសារ លទ្ធផលការសិក្សារបស់កុមារ (ដូចជាការចុះឈ្មោះចូលរៀន និងការទៅរៀន) និងការយល់ដឹងរបស់ឪពុកម្ដាយអំពី ការអប់រំ។  គំរូតាងគោលដៅគឺជាគំរូតាងព្រាវៗលើប្រជាពលរដ្ឋ៣០គ្រួសារ ដែលមានកុមារីគ្រប់អាយុចូលរៀនក្នុងភូមិចំនួន ២៩៣ ដែលអនុវត្តកម្មវិធី BRIGHT ក្នុងចំណោមចំនួន ៨ ៧៩០គ្រួសារសរុប។<br><br>ការអង្កេតនេះរួមមានការប្រឡងមុខវិជ្ជាគណិតវិទ្យា និងបារាំងដែលអនុវត្តគ្រប់កុមារដែលមានអាយុ ៥ ឆ្នាំដល់ ១២ ឆ្នាំ ដែលរស់នៅតាមផ្ទះដោយមិនគិតថាតើពួកគេបានចុះឈ្មោះចូលរៀនឬអត់ទេ ។ កុមារសរុប ២១ ៧៣០ នាក់ បានប្រឡង។ អត្រាឆ្លើយតប មាន ៩៧% ។ |

| ធាតុផ្សំ | បរិយាយ |
| --- | --- |
| | ការអង្កេតសាលា៖ ការអង្កេតសាលាត្រូវបានគ្រប់គ្រងជាពីរសណ្ឋាន ។ សណ្ឋានទី១ ព័ត៌មានអំពីលក្ខណៈសាលាត្រូវបានប្រមូលពីមន្ត្រីសាលា ។ នៅសណ្ឋានទីពីរ ទិន្នន័យស្តីពីការចូលរៀន និងការចុះឈ្មោះត្រូវបានប្រមូលសម្រាប់កុមារដែលបានចុះឈ្មោះចូលរៀន(ផ្អែកលើរបាយការណ៍របស់ឪពុកម្តាយសិស្សតាមរយៈការអង្កេតតាមគ្រួសារ)។ គំរូតាងគោលដៅសម្រាប់ការអង្កេតមានសាលាបឋមសិក្សាចំនួនបីនៅជិតភូមិ ដែលអនុវត្តកម្មវិធី BRIGHT ប្រហែលជា១០ គីឡូម៉ែត្រ ហើយជាទូទៅកុមារចូលរៀនយ៉ាងទៀងទាត់នៅក្នុងភូមិទាំងនោះ។ នេះជាលទ្ធផលចំនួន ៣៦០សាលារៀន។ អត្រាឆ្លើយតបសម្រាប់ការអង្កេតមាន៩៩%។<br><br>បច្ចេកទេសស្ថិតិដែលគេយកមកប្រើ ដើម្បីវាយតម្លៃអានុភាពនៃកម្មវិធីនេះគឺការបញ្ចប់ការថយចុះ ដែលផ្តល់សារៈប្រយោជន៍ដល់ភូមិទាំង២៩៣ដែលបានអនុវត្តកម្មវិធី បានផ្តល់ពិន្ទុពេញលេញដោយក្រសួងអប់រំប្រទេសបួគីណាហ្វាសូផ្អែកលើសក្តានុពលក្នុងការលើកស្ទួយលទ្ធផលអប់រំរបស់កុមារី។ |
| **ខ្នាតរង្វាស់ និងលទ្ធផលសំខាន់ៗ** | ការចុះឈ្មោះចូលរៀន៖ អានុភាពវិជ្ជមាន ។  សាលារៀនកម្មវិធី BRIGHT បានបង្ហាញពីការកែលម្អប្រហែល ២០%ក្នុងការចុះឈ្មោះចូលរៀន ផ្អែកតាមការអង្កេតតាមផ្ទះ ហើយ ១៦%ផ្អែកតាមទិន្នន័យសាលា ។ ដូច្នេះកម្មវិធី BRIGHT ទទួលខុសត្រូវក្នុងការបង្កើនអត្រាចុះឈ្មោះចូលរៀនពីប្រហែល៣៥% ទៅ ៥៥% (លទ្ធផលរាយការណ៍អំពីគ្រួសារ) ឬពី ៣១% ទៅ៤៧% (លទ្ធផលតាមសាលា)។<br><br>ការចូលរៀន៖ មានអានុភាពវិជ្ជមាន។ អានុភាពត្រង់ថាតើកុមារមានវត្តមាននៅថ្ងៃដែលយើងទៅទស្សនកិច្ចឬទេនោះគឺមាន ១៦% ។<br><br>ពិន្ទុប្រឡង៖ អានុភាពវិជ្ជមាន។ អានុភាពលើពិន្ទុមុខវិជ្ជាគណិតវិទ្យា និងភាសាបារាំងមានគម្លាតស្តង់ដារប្រហែល០.៤ ។ ការកើនពិន្ទុប្រឡងនេះគឺច្រើនជាងកម្មវិធីអន្តរាគមន៍អប់រំដែលជោគជ័យនៅបណ្តាប្រទេសកំពុងអភិវឌ្ឍផ្សេងទៀត ដែលមានទំហំអានុភាពចន្លោះពី០.១ និង០.៣ នៃគម្លាតស្តង់ដារ។ អានុភាពនៃទំហំនេះមានន័យថា សម្រាប់សិស្សដែលចាប់ផ្តើមបាន៥០% នៃគំរូតាងរបស់ |

| ធាតុផ្សំ | បរិយាយ |
| --- | --- |
| | យើង ការចូលរៀនសាលាអនុវត្តកម្មវិធី BRIGHT ត្រូវបានគេព្យាករណ៍ថានឹងឡើងដល់ទៅ៨០%។<br><br>កុមារីធៀបនឹងកុមារា៖ ពេលខ្លះកុមារីខ្លាំងជា។ កម្មវិធី BRIGHT នេះមានអានុភាពជាវិជ្ជមានសម្រាប់កុមារា និងកុមារី។ការចុះឈ្មោះចូលរៀនសម្រាប់កុមារីមានអានុភាពច្រើនជាងកុមារា៥%។ ប៉ុន្តែសម្រាប់ពិន្ទុប្រឡង ផលទទួលរវាងកុមារី និងកុមារា មិនមានអ្វីខុសប្លែកគ្នាច្រើននោះទេ។ |
| **ថ្លៃចំណាយ** | មិនមានព័ត៌មានអំពីថ្លៃចំណាយសម្រាប់សាលានីមួយៗទេ។ |
| **ការបណ្ដុះបណ្ដាលបុគ្គលិក** | ការបណ្ដុះបណ្ដាលសម្រាប់មន្ត្រីមូលដ្ឋានក្នុងក្រសួងអប់រំ និងមណ្ឌលថែរក្សាកុមារ ។ ការបណ្ដុះបណ្ដាលជាក់លាក់ រួមមានការបំពេញក្រដាសវត្តមានរបស់សាលា។ |

## ប្រទេសកម្ពុជា៖ កម្មវិធីអាហារូបករណ៍សម្រាប់គម្រោងទ្រទ្រង់វិស័យអប់រំនៅកម្ពុជា(CSP)

| ធាតុផ្សំ | បរិយាយ |
|---|---|
| ការដកស្រង់ឯកសារស្រាវជ្រាវ | Filmer, D., & Schady, N. (2009). ការចុះឈ្មោះចូលរៀន ការជ្រើសរើស និងពិន្ទុប្រឡង។ក្រុមស្រាវជ្រាវអភិវឌ្ឍ។រៀបរៀងដោយធនាគារពិភពលោក។ |
| សំណួរសិក្សា ស្រាវជ្រាវ | តើកម្មវិធីផ្តល់អាហារូបករណ៍ដល់សិស្សក្រីក្រ មានអានុភាពធំធេងដល់ការចុះឈ្មោះចូលរៀន វត្តមានក្នុងថ្នាក់ និងពិន្ទុប្រឡងដែរឬទេ? |
| អ្នកចូលរួម | សិស្ស៣៨០០នាក់។ នៅសាលារៀនធំៗដែលចូលរួមកម្មវិធីCSP ដែលមានការចុះឈ្មោះចូលរៀនសរុបលើសពី ២០០ សិស្ស៥០នាក់ ដែលទទួលពិន្ទុទាបជាងគេ ទទួលបានអាហារូបករណ៍សម្រាប់ថ្នាក់ទី៧ ទី៨ និងទី៩។ នៅសាលារៀន ដែលមានសិស្សតិចដែលមានចូលរួមកម្មវិធី CSP មានសិស្សចុះឈ្មោះចូលរៀនក្រោម២០០នាក់ ហើយសិស្ស៣០នាក់ដែលទទួលពិន្ទុទាបជាងគេទទួលបានអាហារូបករណ៍។ |
| ការកំណត់ | នៅប្រទេសកម្ពុជា(នៅទូទាំងប្រទេស) |
| អន្តរាគមន៍ | អាហារូបករណ៍ផ្តល់ដល់កុមារក្រីក្ររយៈពេល៣ឆ្នាំ នៅវគ្គអប់រំកម្រិតអនុវិទ្យាល័យ ។ ដំបូង រដ្ឋាភិបាលបានជ្រើសរើសអនុវិទ្យាល័យចំនួន១០០ សាលានៅទូទាំងប្រទេសដែលចូលរួមក្នុងកម្មវិធី។ សាលាដែលមានសិទ្ធិចូលរួមក្នុងគម្រោង CSP ត្រូវបានជ្រើសរើសឡើងដោយសារតែសាលាទាំងនោះស្ថិតនៅតំបន់ក្រីក្រ ដូចដែលបានបង្ហាញដោយផែនទីភាពក្រីក្រ និងដោយសារមានអត្រាមិនបានចុះឈ្មោះចូលរៀន និងអត្រាបោះបង់សាលាច្រើន ដូចដែលការបង្ហាញដោយទិន្នន័យរដ្ឋបាល ។ បន្ទាប់មកដោយសារសាលាបឋមសិក្សា"បំប៉នបំរុង"(សាលាមួយដែលកំណត់ថាជាសាលាបំប៉នបំរុងបាន លុះត្រាតែសាលានោះបានបញ្ជូនសិស្សបញ្ចប់ការសិក្សាទៅរៀនអនុវិទ្យាល័យកាលពីប៉ុន្មានឆ្នាំថ្មីៗនេះ) ដែលបានកំណត់ទីតាំងជាអនុវិទ្យាល័យដែលមានសិទ្ធិចូលរួម ក្នុងគម្រោង CSP។ នៅសាលាបំប៉នបំរុង សិស្សថ្នាក់ទី៦ដែលជាថ្នាក់ចុងក្រោយនៅកម្រិតបឋមសិក្សាបានបំពេញ |

| ធាតុផ្សំ | បរិយាយ |
|---|---|
| | ពាក្យសុំអាហារូបករណ៍។ ចម្លើយទាំងនេះត្រូវបានបែងចែកជា "ពិន្ទុប្រឈមនឹងការបោះបង់សាលា" ដែលទំហំនៃពិន្ទុនេះនឹងផ្តល់ដោយលក្ខណៈបុគ្គល ដែលព្យាករណ៍ពីលទ្ធភាពដែលកុមារនោះមិនបានចុះឈ្មោះចូលរៀនថ្នាក់ទី៧ បន្ទាប់ពីបញ្ចប់ថ្នាក់ទី៦។ |
| ការប្រៀបធៀប | ការប្រៀបធៀបត្រូវបានធ្វើឡើងរវាងក្រុមទទួលជំនួយ និងក្រុមមិនបានទទួលជំនួយពីគម្រោង CSP |
| វិធីសាស្ត្រ | ប្រភពទិន្នន័យបី-(១)ពិន្ទុសរុបនៃការប្រឈមនឹងការបោះបង់សាលា(២)លក្ខណៈបុគ្គលដែលទទួលបានសម្រាប់បេក្ខជនអាហារូបករណ៍(២៦ ៥៣៧) (៣)គ្រួសារ(បេក្ខជន និងគ្រួសារ ចំនួន ៣ ២២៥ នាក់ជ្រើសរើសដោយព្រាវ) ហើយទិន្នន័យនៅតាមសាលារៀនត្រូវបានយកមកប្រើប្រាស់សម្រាប់ការស្រាវជ្រាវ។ ការសិក្សាស្រាវជ្រាវក៏បានធ្វើទស្សនកិច្ចដោយមិនបានជូនដំណឹងជាមុនចំនួនបួនលើកទៅកាន់សាលាកម្មវិធី CSP ចំនួន១០០ដើម្បីផ្ទៀងផ្ទាត់វត្តមានក្នុងថ្នាក់ជាក់ស្តែង ។ ក្រៅពីនេះទៀត ការប្រឡងគណិតវិទ្យា និងអក្សរសាស្ត្រ ត្រូវបានធ្វើឡើងដើម្បីឈ្វេងយល់ពីអានុភាពនៃកម្មវិធីអន្តរាគមន៍ទៅលើពិន្ទុប្រឡង។ យុទ្ធសាស្ត្រអត្តសញ្ញាណកម្មមូលដ្ឋានដែលគេយកមកប្រើនៅក្នុងការសិក្សានេះ គឺដើម្បីបញ្ចប់ការថយចុះ។ |
| ខ្នាតរង្វាស់ និងលទ្ធផលសំខាន់ៗ | <u>ការនៅរៀន</u>៖អានុភាពវិជ្ជមាន ។ អាហារូបករណ៍គម្រោង CSP មានអានុភាពវិជ្ជមានយ៉ាងច្រើនដល់វត្តមានក្នុងថ្នាក់ប្រហែលជាទទួលពិន្ទុពី២០ ទៅ ២៥%។<br><u>ការចុះឈ្មោះចូលរៀន៖</u> អានុភាពវិជ្ជមាន។ កុមារដែលទទួលអាហារូបករណ៍បានចុះឈ្មោះចូលរៀនប្រហែលជា ២០%ច្រើនជាងពីកាលមិនទាន់មានកម្មវិធី៕<br><u>ពិន្ទុប្រឡង</u>៖ មិនមានអានុភាពអ្វីទេ។ កុមារដែលទទួលបានអាហារូបករណ៍ មិនទទួលបានពិន្ទុប្រឡង ផ្នែកគណិតវិទ្យា និងអក្សរសាស្ត្រល្អជាងក្រុមប្រៀបធៀបដែលមិនចូលរួមក្នុងគម្រោង បន្ទាប់ពីចាប់ផ្តើមគម្រោងបានរយៈពេល១៨ខែកន្លងមក។ |
| ថ្លៃចំណាយ | នៅសាលាធំៗ សិស្ស ២៥នាក់ដែលមានពិន្ទុប្រឈមនឹងការបោះបង់សាលាទាបបំផុត ទទួលបានអាហារូបករណ៍ ៦០ដុល្លារ ហើយសិស្ស២៥នាក់ទៀតដែលទទួលពិន្ទុទាបបំផុតទទួលបាន៤៥ដុល្លារ ចំណែកឯនៅសាលាតូចៗ |

| ធាតុផ្សំ | បរិយាយ |
| --- | --- |
| | សិស្ស១៥នាក់ទទួលបានអាហារូបករណ៍៦០ដុល្លារ និង ១៥នាក់ទទួលបានអាហារូបករណ៍៨៥ដុល្លារ។ |
| **ការបណ្តុះបណ្តាលបុគ្គលិក** | មិនមានការបណ្តុះបណ្តាលអ្វីទេ។ |

# ១០. ប្រទេសកូឡុំប៊ី៖ កម្មវិធីសក្ខីបត្រសាលា ដែលមានកម្មវិធីទប់ស្កាត់ការបោះបង់សាលា ក្នុងប្រទេសកូឡុំប៊ី ( PACES )

| សមាសភាគ | ការបរិយាយ |
|---|---|
| ការដកស្រង់ពីការសិក្សា | Angrist, J., Bettinger, E., Bloom, E., King, E., & Kremer, M. (2002). សក្ខីបត្រសម្រាប់ការសិក្សាឯកជន ក្នុងប្រទេស កូឡុំប៊ី៖ ភស្តុតាងបានពីការពិសោធន៍ព្រាវៗដោយធម្មជាតិមួយ ។ ការពិនិត្យឡើងវិញនូវសេដ្ឋកិច្ចអាមេរិក៩២(៥) ១៥៣៥-១៥៥៨ ។ |
| សំណួរសិក្សាស្រាវជ្រាវ | តើសិស្សឈ្នះឆ្នោត រៀនបានរីកចម្រើននៅសាលា ទទួលបានពិន្ទុប្រលងខ្ពស់ជាងមុន និងកាត់បន្ថយលទ្ធភាពដែលនាំឲ្យមានការរួមរស់ជាប្តីប្រពន្ធមិនបានរៀបការក្នុងវ័យជំទង់ ឬភាពមានការងារធ្វើដែរឬទេ? |
| អ្នកចូលរួម | ក្រុមគ្រួសារ ដែលរស់នៅក្នុងតំបន់ប្រជុំជន ដែលត្រូវបានចាត់ចូលជាក្រុមវណ្ណៈសង្គមសេដ្ឋកិច្ចទាបបំផុតចំនួនពីរ (ក្នុងចំណោម ៦) មានសិទ្ធិចូលរួមក្នុងការលេងឆ្នោតនេះ ប្រសិនបើគ្រួសារនេះមានកូនរៀនថ្នាក់ទី៦ (ការចាប់ផ្តើមនៃមធ្យមសិក្សា) ដែលមានអាយុ១៥ឆ្នាំ ឬក៏តិចជាងនេះ ។<br><br>បទសម្ភាសន៍ទាំងនេះត្រូវព្យាយាមធ្វើជាមួយបេក្ខជនលេងឆ្នោតជិត៣,០០០នាក់ និងត្រូវបានបញ្ចប់ដោយមានបេក្ខជនលេងឆ្នោតចំនួន១,៦១៨ នាក់ ដោយទទួលបានអត្រាឆ្លើយតបជារួមស្មើនឹង៥៥% ។ ក្នុងចំណោមអ្នកដែលត្រូវបានទំនាក់ទំនងតាមទូរស័ព្ទចំនួន១,៦១៨នាក់ ៨៣០នាក់បានទទួលសក្ខីបត្រ (៥១,៣%) ដែលក្នុងនោះ៨០៧ នាក់ គឺជាបុរស (៤៩,៩%) និងមានអាយុជាមធ្យម ១២,៦ ឆ្នាំ ។ |
| បរិបទ | <u>ប្រទេស កូឡុំប៊ី៖</u> សិស្សដែលត្រូវបានជ្រើសរើសចេញពីក្រុមទាំងបី មានជាអាទិ៍ ក្រុមសិស្សឆ្នាំ១៩៩៣ មកពី ចាមុនឌី (Jamundi) ជាតំបន់ជាយក្រុងមួយរបស់ទីក្រុង ខាលី (Cali) និងក្រុមសិស្សឆ្នាំ១៩៩៥ និងក្រុមសិស្សឆ្នាំ១៩៩៧មកពីទីក្រុងបូហ្គូតា (Bogota)។ |
| អន្តរាគមន៍ | <u>សក្ខីបត្រសាលា</u>៖ រហូតមកទល់ពេលបច្ចុប្បន្ននេះ កម្មវិធីទប់ស្កាត់ការបោះបង់សាលា ក្នុងប្រទេសកូឡុំប៊ី (PACES) ដែលជា |

| សមាសភាគ | ការបរិយាយ |
| --- | --- |
| | កម្មវិធីសក្ខីបត្រសាលាដ៏ធំបំផុតក្នុងប្រទេសកូឡុំប៊ី បានផ្ដល់សក្ខីបត្រដែលមានតម្លៃជាងពាក់កណ្ដាលនៃការចំណាយ នៅសាលាមធ្យមសិក្សាឯកជនដល់សិស្សចំនួន ១២៥,០០០ នាក់ ដោយកំណត់ថា សិស្សបានឡើងថ្នាក់ពីមួយឆ្នាំទៅមួយឆ្នាំតាមកាលវិភាគ ។ |
| **ការប្រៀបធៀប** | ការប្រៀបធៀប ត្រូវបានធ្វើឡើង រវាងសិស្សឈ្នះឆ្នោត និងសិស្សចាញ់ឆ្នោត ។ |
| **វិធីសាស្ត្រ** | គម្រោងផ្អែកលើការពិសោធន៍មួយ ត្រូវបានគេយកមកប្រើ ដើម្បីប្រៀបធៀបលទ្ធផលនៃការអប់រំ និងលទ្ធផលផ្សេងទៀត របស់សិស្សឈ្នះឆ្នោត និងសិស្សចាញ់ឆ្នោត ។ លទ្ធផលទាំងនេះ ផ្ដល់នូវភស្តុតាង ស្ដីពីអានុភាពនៃកម្មវិធី ដែលស្រដៀងគ្នានឹងការសិក្សាស្រាវជ្រាវដែលបានមកពីការសាកល្បងព្រាវៗ ។ |
| **ខ្នាតរង្វាស់ និងលទ្ធផលសំខាន់ៗ** | <u>ការនៅរៀន</u>៖ មិនមានឥទ្ធិពលទេ ។ "ការស្ទង់មតិមួយលើក្រុមបេក្ខជនចំនួនបីក្រុម បង្ហាញថាមិនមានការខុសគ្នាអ្វីគួរឲ្យកត់សម្គាល់នោះទេ រវាងសិស្សឈ្នះឆ្នោត និងសិស្សចាញ់ឆ្នោត ក្នុងការចុះឈ្មោះចូលរៀន ក្រោយពីការលេងឆ្នោតរយៈពេលបីឆ្នាំ ដោយសិស្សភាគច្រើន ទាំងនៅក្នុងក្រុមសិស្សឈ្នះ និងក្រុមសិស្សចាញ់ នៅតែរៀនបន្តដដែល ។ ប៉ុន្តែសិស្ស ឈ្នះឆ្នោត ចំនួន ១៥ ភាគរយ ទំនងជាចូលរៀនសាលាឯកជនច្រើនជាងចូលរៀនសាលារដ្ឋ ។<br><br><u>រៀនបានរីកចម្រើននៅក្នុងសាលា</u>៖ ឥទ្ធិពលវិជ្ជមាន ។ សិស្សឈ្នះឆ្នោត ពី៥ ទៅ៦ ភាគរយ ទំនងជាមិនរៀនត្រួតថ្នាក់នោះទេ ។ ការសិក្សាស្រាវជ្រាវ បានរកឃើញថា សិស្សស្រីទទួលរងឥទ្ធិពលល្អប្រសើរបន្តិចបន្តួចជាងសិស្សប្រុស ដោយការរៀនត្រួតថ្នាក់របស់សិស្សស្រី មិនត្រឹមតែថយចុះប៉ុណ្ណោះទេ ពួកគេថែមទាំងបន្តការរៀនសូត្រ ០,១៤ ឆ្នាំបន្ថែមទៀតក្នុងសាលា ។<br><br><u>ការបញ្ចប់ការសិក្សា</u>៖ ឥទ្ធិពលវិជ្ជមាន "...សិស្សឈ្នះឆ្នោត បានបញ្ចប់ការសិក្សា ០.១ឆ្នាំ បន្ថែមទៀតនៅសាលា និងមានចំនួន ១០% ពិន្ទុច្រើនជាងសិស្សចាញ់ឆ្នោត ទំនងជាបញ្ចប់ការសិក្សាថ្នាក់ទី៨ ដោយហេតុផលសំខាន់គឺថាពួកគេ រៀនត្រួតថ្នាក់តិចតួចប៉ុណ្ណោះ " |

| សមាសភាគ | ការបរិយាយ |
|---|---|
| | ពិន្ទុប្រឡង៖ ឥទ្ធិពលវិជ្ជមានអប្បបរមា ។ "សមិទ្ធិផលប្រលង ត្រូវបានចាត់ចូលជាផ្នែករងមួយនៃសិស្ស ដែលបានធ្វើការស្ទង់មតិ ។ លទ្ធផលតេស្តប្រឡង ស្នើឡើងថា ជាមធ្យម សិស្សឈ្នះឆ្នោត ទទួលពិន្ទុ ០.២ នៃគម្លាតស្តង់ដាស្ថិតិ ខ្ពស់ជាង សិស្សចាញ់ឆ្នោត ដែលជាចំនួនច្រើន ប៉ុន្តែគ្រាន់តែខុសគ្នាបន្ទាប់បន្សំតែប៉ុណ្ណោះ ។ ឥទ្ធិពលលើសិស្សស្រី មានលក្ខណៈធំទូលាយជាង និងត្រូវបានប៉ាន់ស្មានច្បាស់ជាងឥទ្ធិពលលើសិស្សប្រុស ។" <br><br> លទ្ធផលមិនមែនជាការអប់រំ៖ ឥទ្ធិពលវិជ្ជមាន ។ "កម្មវិធីសក្ខីបត្រ មានឥទ្ធិពលលើលទ្ធផលមិនមែនជាការអប់រំ ។ ជាក់ស្តែង សិស្សឈ្នះឆ្នោត ទំនងជានឹងមិនរៀបការ ឬរស់នៅរួមសង្វាសជាមួយគ្នានោះទេ និងធ្វើការបន្ថយម៉ោង ប្រហែល ១.២ ម៉ោង ក្នុងមួយសប្តាហ៍ (ម្តងទៀត ខុសគ្នាភាគច្រើនចំពោះសិស្សស្រី) ។ លទ្ធផលទាំងពីរនេះ ស្នើឲ្យមានការបង្កើនការយកចិត្តទុកដាក់លើការសិក្សា ក្នុងចំណោមសិស្សឈ្នះឆ្នោត ។ " <br><br> ការប្រើប្រាស់៖ ឥទ្ធិពលវិជ្ជមាន ។ សិស្សឈ្នះឆ្នោត ១៥ភាគរយ ភាគច្រើនទំនងជាចូលរៀនសាលាឯកជន ជាងចូលរៀនសាលារដ្ឋ ។ ".. ត្រឹមតែប្រហែល ៩០% ប៉ុណ្ណោះនៃសិស្សឈ្នះឆ្នោត ធ្លាប់បានប្រើសក្ខីបត្រ ឬប្រភេទនៃអាហាររូបករណ៍ផ្សេងទៀត ស្របពេលដែលសិស្សចាញ់ឆ្នោតចំនួន ២៤ភាគរយ បានទទួលអាហាររូបករណ៍ពីប្រភពផ្សេងទៀត ។" "ទោះជាយ៉ាងណាក៏ដោយ ក៏សិស្សឈ្នះឆ្នោតភាគច្រើន នឹងចូលរៀនសាលាឯកជន យ៉ាងហោចក៏ពីរទៅបីឆ្នាំដែរ ហើយហេតុផលនេះហើយបានកាត់បន្ថយការចំណាយលើការអប់រំ ជាកិច្ចឆ្លើយតបនឹងកម្មវិធីនេះ ។ <br><br>ម្យ៉ាងវិញទៀត សិស្សឈ្នះឆ្នោត ដែលត្រូវបានអូសទាញឲ្យផ្លាស់ប្តូរពីសាលារដ្ឋ មកសាលាឯកជន បានបង្កើនការចំណាយលើការអប់រំរបស់ខ្លួនយ៉ាងច្រើន ដោយសារតែសក្ខីបត្រនេះ បានគ្របដណ្តប់ត្រឹមតែប្រហែលពាក់កណ្តាលនៃការចំណាយលើសាលាឯកជន ប៉ុណ្ណោះ ។ ផ្អែកតាមសមតុល្យ ថ្លៃសិក្សាសរុប របស់សិស្សឈ្នះឆ្នោត បានលើសថ្លៃសិក្សារបស់សិស្សចាញ់ |

| សមាសភាគ | ការបរិយាយ |
|---|---|
| | ឆ្នោត ប្រហែល ៧០ភាគរយ នៃចំនួនទឹកប្រាក់ដែលពួកគេបានទទួលពីសក្ខីបត្រនេះ ។ ជាចុងក្រោយ អ្នកទទួលសក្ខីបត្រ អាចមានការលើកទឹកចិត្តច្រើនជាងនេះ ដើម្បីផ្តោតលើការសិក្សា ព្រោះសក្ខីបត្រ អាចត្រូវបានបន្តជាថ្មីទៀត បានតែចំពោះសិស្សដែលមិនបានរៀនត្រួតថ្នាក់ ប៉ុណ្ណោះ ។" |
| **ថ្លៃចំណាយ** | ១៩០ ដុល្លារ សម្រាប់សិស្សម្នាក់ ប្រហែលជាពាក់កណ្តាលនៃការចំណាយលើសាលាឯកជន ។ (ដុល្លារ ក្នុងឆ្នាំ ១៩៩៨) ។ រដ្ឋាភិបាល បានចំណាយប្រហែល ២៤ដុល្លារបន្ថែម សម្រាប់សិស្សឈ្នះឆ្នោតក្នុងម្នាក់ ច្រើនជាងការចំណាយជាធម្មតា ក្នុងការដាក់ឲ្យកុមារចូលរៀនក្នុងសាលារដ្ឋ ។ |
| **ការបណ្តុះ បណ្តាលបុគ្គលិក** | មិនមានការផ្តល់ជូនការបណ្តុះបណ្តាលបុគ្គលិកទេ ។ |

## ១១. ប្រទេសកូឡុំប៊ី៖ ការផ្ទេរប្រាក់តាមល័ក្ខខ័ណ្ឌ(CCT)

| សមាសភាគ | ការបរិយាយ |
|---|---|
| ការដកស្រង់ ពីការសិក្សា | Barrera-Osorio, F., Bertrand, M., Linden, L., & Perez-Calle, F. (មកដល់នាពេលខាងមុខ) ។ ការកែលម្អគម្រោងនៃកម្មវិធីផ្ទេរប្រាក់តាមល័ក្ខខ័ណ្ឌ៖ ភស្តុតាង បានពីការធ្វើពិសោធន៍ដែលបានពិនិត្យព្រាវៗ ក្នុងប្រទេស កូឡុំប៊ី ។ ទិន្នានុប្បវត្តិសេដ្ឋកិច្ចដែលត្រូវបានប្រើប្រាស់៖ *វិទ្យាសាស្ត្រសេដ្ឋកិច្ចដែលត្រូវបានអនុវត្ត។* |
| សំណួរសិក្សាស្រាវជ្រាវ | តើការសម្រុបតាមកម្មវិធីផ្ទេរប្រាក់តាមល័ក្ខខ័ណ្ឌ (CCT) ធ្វើឲ្យការចូលរៀនប្រសើរឡើងរបស់សិស្សដែរឬទេ? |
| អ្នកចូលរួម | កុមារសរុបចំនួន ១៣.៤៣៣នាក់ បានចូលរួមក្នុងការសិក្សានេះ ។ កុមារចំនួន ៧.៩៨៤នាក់ ក្នុងចំណោមកុមារទាំងនេះ បានទទួលការផ្ទេរប្រាក់៖ កុមារចំនួន ៣.៤២៧នាក់ បានចូលរួមក្នុង អន្តរាគមន៍"មូលដ្ឋាន" ។ កុមារចំនួន ៣.៤២៤ បានចូលរួមក្នុង អន្តរាគមន៍ "សន្សំ" ហើយកុមារចំនួន ១.១៣៣នាក់ បានចូលរួមក្នុង អន្តរាគមន៍"ប្រភេទទីបី" (tertiary" )។ ចំពោះប្រអន្តរាគមន៍មូលដ្ឋាន និងអន្តរាគមន៍សន្សំ សិស្សទាំងអស់ បានរៀនចប់យ៉ាងហោចត្រឹមថ្នាក់ទី៥ ។<br>ចំពោះអន្តរាគមន៍ប្រភេទទីបីវិញ សិស្សទាំងអស់បានរៀនចប់យ៉ាងហោចថ្នាក់ទី៨ ។ កុមារទាំងអស់ត្រូវតែបានចុះឈ្មោះចូលរៀន ប៉ុន្តែមិនទាន់បានបញ្ចប់ថ្នាក់ទី១១នៅឡើយទេ ហើយគ្រួសាររបស់កុមារ ត្រូវតែបានចាត់ថ្នាក់ ចូលទៅក្នុងក្រុមចំនួនពីរនៅខាងក្រោមគេ ក្នុងសន្ទស្សន៍ភាពក្រីក្ររបស់ប្រទេសកូឡុំប៊ី។ |
| បរិបទ | ប្រទេស កូឡុំប៊ី៖ តំបន់ សាន គ្រីស្តូបាល (San Cristobal) និងស៊ូបា(Suba) ជាតំបន់នៅក្នុងទីក្រុងបូហ្គូតា (Bogota) ។ |
| អន្តរាគមន៍ | អន្តរាគមន៍ស្របពេលតែមួយចំនួនបីពាក់ព័ន្ធនឹងការឧបត្ថម្ភប្រាក់លើការអប់រំ ត្រូវបានអនុវត្ត៖<br>អន្តរាគមន៍មូលដ្ឋាន៖ ការផ្ទេរប្រាក់តាមល័ក្ខខ័ណ្ឌពីរខែម្តង តាមលក្ខណៈប្រពៃណីដោយផ្អែកលើការចូលរៀនយ៉ាងហោច៨០% នៃឆ្នាំសិក្សា។<br>អន្តរាគមន៍សន្សំ៖ ការផ្ទេរប្រាក់តាមល័ក្ខខ័ណ្ឌពីរខែម្តង តាមលក្ខណៈប្រពៃណី ប៉ុន្តែផ្តល់ជូនតែ ២/៣ នៃមូលនិធិប៉ុណ្ណោះ ដោយផ្អែកលើការចូលរៀនល្អ និងផ្តល់ជូនមូលនិធិនៅសល់ចំនួន១/៣ នៃឆ្នាំសិក្សា សម្រាប់ការចុះឈ្មោះចូលរៀនម្តងទៀត នៅឆ្នាំសិក្សាបន្ទាប់ |

| សមាសភាគ | ការបរិយាយ |
| --- | --- |
| | ។<br><br><u>អន្តរាគមន៍ប្រភេទទីបី</u>៖ ការផ្ទេរប្រាក់តាមល័ក្ខខ័ណ្ឌពីរខែម្តង តាមលក្ខណៈប្រពៃណី ដោយផ្តល់ជូន ២/៣ នៃមូលនិធិ ផ្អែកលើការចូលរៀនមានវត្តមានល្អ ។ នៅពេលបញ្ចប់ការសិក្សា សិស្ស បានទទួលមូលនិធិ១/៣ បន្ថែមទៀត ដោយផ្តល់ជូននូវប្រាក់លើកទឹកចិត្តដើម្បីបញ្ចប់ការសិក្សា និងចុះឈ្មោះចូលរៀននៅវិទ្យាស្ថានអប់រំកម្រិតខ្ពស់ជាងនេះ(កម្រិតឧត្តមសិក្សា)។ |
| ការប្រៀបធៀប | ការប្រៀបធៀប ត្រូវបានធ្វើឡើងរវាងបួនក្រុម មានជាអាទិ៍ ក្រុម ទទួលអន្តរាគមន៍មូលដ្ឋាន អន្តរាគមន៍សន្សំ អន្តរាគមន៍ទីបី និងក្រុមមិនទទួលអន្តរាគមន៍ពីគម្រោង។ ក្រុមមិនទទួលអន្តរាគមន៍ពីគម្រោងសម្រាប់អន្តរាគមន៍មូលដ្ឋាន/អន្តរាគមន៍សន្សំ មានសិស្សចំនួន ៤.០៥៦នាក់ ។ ក្រុម មិនទទួលអន្តរាគមន៍សម្រាប់ អន្តរាគមន៍ទីបីមានសិស្សចំនួន ១.៣៩៣នាក់ ។ |
| វិធីសាស្រ្ត | ការសិក្សានេះ បានអនុវត្តកិច្ចខិតខំប្រឹងប្រែងក្នុងការជ្រើសរើសដ៏ធំមួយ ជាលទ្ធផលធ្វើឲ្យសិស្សចំនួន ១៣.៤៣៣នាក់ ត្រូវបានចាត់ទុកថាមានសិទ្ធិទទួលបានការផ្ទេរប្រាក់នេះ ។ សិស្សចំនួន៧៩៨៤នាក់ ត្រូវបានបែងចែកព្រាវៗទៅក្នុងក្រុមទទួលអន្តរាគមន៍ពីគម្រោង។ អ្នកចុះឈ្មោះដែលមានសិទ្ធិក្នុងតំបន់ សានគ្រីស្តូបាល (San Cristobal) ត្រូវបានបែងចែកព្រាវៗរវាង ក្រុមមិនទទួលអន្តរាគមន៍ពីគម្រោង, និងក្រុមអន្តរាគមន៍មូលដ្ឋាន និងក្រុមអន្តរាគមន៍សន្សំ ។ អន្តរាគមន៍ទីបីត្រូវបានវាយតម្លៃដាច់ដោយឡែក ក្នុងការធ្វើពិសោធន៍មួយ នៅស៊ូបា (Suba) ជាទីដែលសិស្សត្រូវបានចាត់តាំងព្រាវៗទៅក្នុងអន្តរាគមន៍ទីបី ឬក៏ក្រុមមិនទទួល អន្តរាគមន៍។<br><br>គំរូនៃភាពខុសគ្នាដ៏សាមញ្ញមួយ ត្រូវបានប្រើដើម្បីធ្វើការប្រៀបធៀបរវាងក្រុមតូចផ្សេងៗនៃគំរូតាងដោយគ្មានការប្រៀបធៀបរកបន្លាស់ប្តូរតាមអថេរណាមួយនោះទេ (covariates) ។ |
| ខ្នាតរង្វាស់ និងលទ្ធផលសំខាន់ៗ | ជារួមអន្តរាគមន៍ផ្តល់ប្រាក់លើកទឹកចិត្ត បានធ្វើឲ្យមានការផ្លាស់ប្តូរគួរឲ្យកត់សម្គាល់ ដូចជា៖<br><br><u>ការចូលរៀន</u>៖ អានុភាពវិជ្ជមាន ។ អន្តរាគមន៍មូលដ្ឋាន បានបង្កើនការចូលរៀន ៣,៣ ភាគរយ ស្របពេលដែលអន្តរាគមន៍សន្សំ បានបង្កើនការចូលរៀន ២,៩ភាគរយ ។ អន្តរាគមន៍ទាំងពីរនេះ មានប្រសិទ្ធភាព ហើយក៏មិនមានភស្តុតាង ដែលបង្ហាញថា អន្តរាគមន៍សន្សំ មិនសូវមានប្រសិទ្ធភាពដូចអន្តរាគមន៍មូលដ្ឋានចំពោះការបង្កើនការចូលរៀននោះទេ បើទោះបីជាការចំណាយប្រចាំខែទាបជាង |

| សមាសភាគ | ការបរិយាយ |
|---|---|
| | យ៉ាងណាក៏ដោយ ។ ផ្អែកលើអន្តរាគមន៍ប្រភេទទីបី ឥទ្ធិពលអន្តរាគមន៍ដែលត្រូវបានប៉ាន់ស្មាននេះ គឺជាការបង្កើនការចុះឈ្មោះចូលរៀន ច្រើនជាង៥ភាគរយ ។<br><br>មានឥទ្ធិពលរាលដាលនៃអន្តរាគមន៍ទាំងនៅក្នុងគ្រួសារ និងក្នុងបណ្តាញមិត្តភក្តិ ។ ចំពោះគ្រួសារ អានុភាពរាលដាល មានលក្ខណៈអវិជ្ជមាន ចំពោះកុមារ មិននៅក្នុងកម្មវិធីនេះ ។ ឧទាហរណ៍ មានភស្តុតាងបង្ហាញថាចំពោះកុមារមិនបានទទួលអន្តរាគមន៍ដែលមានបងប្អូនបង្កើតទទួលអន្តរាគមន៍មានការចូលរៀនតិចតួចជាង និងចូលរួមទីផ្សារការងារច្រើនជាង ធៀបជាមួយនឹងកុមារមិនបានចូលរួម ដែលមានបងប្អូនបង្កើតមិនបានទទួលអន្តរាគមន៍ដូចគ្នា ។ អានុភាពនេះ មានលក្ខណៈខ្លាំងជាពិសេស ចំពោះក្មេងស្រី ។<br><br><u>ការនៅរៀនក្នុងសាលា</u>៖ ឥទ្ធិពលវិជ្ជមាន ។ អន្តរាគមន៍មូលដ្ឋាននេះ ស្ទើរតែមិនមានឥទ្ធិពលទៅលើការចុះឈ្មោះចូលរៀនជាថ្មីម្តងទៀត នោះទេ ។ ទោះបីជាយ៉ាងណាក៏ដោយ ក៏អន្តរាគមន៍សន្សំ បង្កើនការចុះឈ្មោះចូលរៀនជាថ្មីបាន ៤ភាគរយ គួរឲ្យកត់សម្គាល់ផងដែរ ។ អន្តរាគមន៍សន្សំ មានឥទ្ធិពលជាពិសេសលើការធ្វើឲ្យប្រសើរឡើងនៃការចុះឈ្មោះចូលរៀនរបស់សិស្សមានចំណូលទាប និងសិស្សដែលមានអត្រាចូលរួមទាបបំផុត ។ អន្តរាគមន៍ប្រភេទទីបី បង្កើនការចុះឈ្មោះចូលរៀនជាថ្មី ៣,៧ភាគរយ ។ អន្តរាគមន៍នេះ ក៏ជាអន្តរាគមន៍ដ៏មានឥទ្ធិពលបំផុត ចំពោះសិស្សដែលទំនងនឹងមិនចុះឈ្មោះចូលរៀនជាថ្មីបំផុតនោះផងដែរ ។<br><br><u>ការចុះឈ្មោះចូលរៀន នៅស្ថាប័នឧត្តមសិក្សា</u>៖ ឥទ្ធិពលវិជ្ជមាន ។ អន្តរាគមន៍សន្សំ និងអន្តរាគមន៍ទីបី បានបង្កើនអត្រាចុះឈ្មោះចូលរៀន នៅស្ថាប័នឧត្តមសិក្សា ។ អន្តរាគមន៍សន្សំ បានបង្កើនការចុះឈ្មោះចូលរៀន ៩,៤ ភាគរយស្របពេលដែល អន្តរាគមន៍ប្រភេទទីបីបានបង្ហាញពីឥទ្ធិពលជាពិសេស ដោយបានបង្កើនការចុះឈ្មោះចូលរៀន ៤៨,៩ ភាគរយ ។<br><br><u>ការបញ្ចប់ការសិក្សា</u>៖ ឥទ្ធិពលវិជ្ជមាន ។ ឥទ្ធិពលអន្តរាគមន៍មធ្យម ជារួម ស្មើនឹង ៤,០ភាគរយ ។ |
| **ថ្លៃចំណាយ** | <u>អន្តរាគមន៍មូលដ្ឋាន</u>៖ ប្រហែល១៥ដុល្លារ ក្នុងមួយខែ ។ ការចំណាយត្រូវបានធ្វើឡើងរៀងរាល់ពីរខែម្តង ។<br><u>អន្តរាគមន៍សន្សំ</u>៖ ប្រហែល១០ដុល្លារ ក្នុងមួយខែ ត្រូវបានចំណាយផ្អែកតាមមូលដ្ឋានពីរខែម្តង ខណៈដែលផ្នែកទីបីដែលនៅសល់ត្រូវបានដាក់ក្នុងគណនីធនាគារ ។ លុះក្រោយមក មូលនិធិដែលបានកើនឡើងបន្តបន្ទាប់នេះ ត្រូវបានផ្តល់ជូនគ្រួសាររបស់សិស្ស ក្នុង |

| សមាសភាគ | ការបរិយាយ |
|---|---|
| | អំឡុងពេលដែលសិស្សត្រៀមខ្លួនចុះឈ្មោះចូលរៀនសម្រាប់ឆ្នាំសិក្សាបន្ទាប់ ។<br>អន្តរាគមន៍ប្រភេទទីបី៖ ប្រហែល ១០ដុល្លារ ត្រូវបានចំណាយប្រចាំខែ សម្រាប់សិស្សដែលមករៀនទៀតទាត់។ នៅពេលបញ្ចប់ការសិក្សា សិស្សមានសិទ្ធិទទួលការផ្ទេរប្រាក់ចំនួន៣០០ដុល្លារ។ (ដុល្លារ ក្នុងឆ្នាំ ២០០៥) |
| ការបណ្តុះបណ្តាលបុគ្គលិក | មិនមានការបណ្តុះបណ្តាលបុគ្គលិកទេ ។ |

## ១២. ប្រទេសហាន់ឌូរ៉ាស់៖ កម្មវិធី ការផ្ទេរប្រាក់មានល័ក្ខខ័ណ្ឌ (PRAF) និងការបង់ចំណាយទៅឲ្យសមាគមមាតាបិតា-គ្រូបង្រៀន (PTA)

| ធាតុផ្សំ | ការបរិយាយ |
|---|---|
| ការដកស្រង់ ពីការសិក្សា | Glewwe, P. & Olinto, P. (2004). *ការវាយតម្លៃផលប៉ះពាល់នៃការផ្ទេរប្រាក់មានល័ក្ខខ័ណ្ឌ (CCT) ទៅលើការសិក្សា៖ ការវិភាគលើការធ្វើពិសោធន៍នៃកម្មវិធី PRAF របស់ប្រទេស ហាន់ដូរ៉ាស់* ។ របាយការណ៍ចុងក្រោយ ដាក់ជូនទីភ្នាក់ងារសហរដ្ឋអាមេរិកដើម្បីអភិវឌ្ឍអន្តរជាតិ (USAID) តាមរយៈវិទ្យាស្ថានអន្តរជាតិស្រាវជ្រាវគោលនយោបាយស្បៀងអាហារ។ |
| សំណួរស្រាវជ្រាវ | តើកម្មវីធី PRAF ដែលជាកម្មវិធីផ្ទេរប្រាក់តាមល័ក្ខខ័ណ្ឌ ធ្វើឲ្យលទ្ធផលអប់រំប្រសើរឡើងដែរឬទេ? |
| អ្នកចូលរួម | កុមារអាយុពី ៦ ដល់១៣ ឆ្នាំ ក្នុងសាលាបឋមសិក្សា |
| បរិបទ | ប្រទេស ហាន់ដូរ៉ាស់ ។ ទីជនបទចំនួន៧០ ក្នុងចំណោមទីជនបទក្រីក្របំផុតជាច្រើននៅក្នុងប្រទេសនេះ ។ |
| អន្តរាគមន៍ | ការផ្ទេរប្រាក់ទៅគ្រួសារ៖ ប្រាក់លើកទឹកចិត្តផ្អែកលើតម្រូវការសម្រាប់ការអប់រំ ត្រូវបានបង្កើតឡើង តាមរយៈការប្រើប្រាស់ការទូទាត់រូបិយវត្ថុទៅឲ្យគ្រួសារសម្រាប់កុមារម្នាក់ៗដែលមានអាយុពី៦ ដល់១២ឆ្នាំ ដែលបានចុះឈ្មោះចូលរៀនបានបួនឆ្នាំដំបូងនៃបឋមសិក្សា និងចូលរៀនទៀងទាត់ ។ ចំនួនជាអតិបរមានៃកុមារមានរហូតដល់៣នាក់ក្នុងគ្រួសារនីមួយៗ មានសិទ្ធិទទួលបានការផ្ទេរប្រាក់នេះ ( នេះ គឺជាការបន្ថែមពីលើការទូទាត់ចំណាយរូបិយវត្ថុណាមួយ ដែលបានទទួលពីប្រាក់លើកទឹកចិត្តផ្អែកតម្រូវការរបស់អន្តរាគមន៍សុខភាព) ។ ដើម្បីមានសិទ្ធិទទួលបានការទូទាត់ចំណាយ កុមារ ត្រូវមកចុះឈ្មោះចូលរៀននៅត្រឹមចុងខែមីនា និងត្រូវមករៀនឲ្យបាន ៨៥%នៃម៉ោងសិក្សា ។<br><br>ការផ្ទេរប្រាក់ឲ្យសមាគមមាតាបិតា-គ្រូបង្រៀន(PTA) ៖ ប្រាក់លើកទឹកចិត្តលើការអប់រំផ្អែកលើការផ្គត់ផ្គង់ មានការទូទាត់ ចំណាយឲ្យសមាគមមាតាបិតា-គ្រូបង្រៀន ដែលបានធ្វើការជាមួយសាលាបឋមសិក្សានីមួយៗ ។ សមាគមទាំងនេះត្រូវបានតម្រូវឲ្យទទួលឋានៈស្របច្បាប់ និងឲ្យរៀបចំផែនការមួយចំនួន ដូចជាផែនការថវិកាជាដើម ដើម្បីកែលម្អគុណភាព អប់រំ ដែលសាលារបស់ពួកគេនីមួយៗ |

| ធាតុផ្សំ | ការបរិយាយ |
|---|---|
| | បានផ្តល់ឲ្យ ។<br>ការផ្ញើរប្រាក់ឲ្យស្ត្រីមានផ្ទៃពោះ៖ អន្តរាគមន៍ផ្អែកលើតម្រូវការផ្នែកសុខភាព មានការផ្ញើរប្រាក់ឲ្យស្ត្រីមានផ្ទៃពោះ និង ម្តាយ ដែលមានកូនអាយុក្រោម៣ឆ្នាំ ។ សក្ខីបត្រត្រូវបានផ្តល់ជូនតែចំពោះស្ត្រី ដែលបានទៅពិនិត្យសុខភាពនៅគ្លីនិកសុខភាពរៀងរាល់ខែតប៉ុណ្ណោះ ។<br>ការផ្ញើរប្រាក់ឲ្យក្រុមថែទាំសុខភាពបឋម៖ អន្តរាគមន៍ ផ្អែកលើការផ្គត់ផ្គង់ផ្នែកសុខភាព មានការផ្ញើរថវិកាឲ្យក្រុមថែទាំសុខភាពបឋម ដែលត្រូវបានបង្កើតឡើងដោយសមាជិកសហគមន៍ និងបុគ្គលិកថែទាំសុខភាពមូលដ្ឋាន (គិលានុបដ្ឋាយិកា ហើយប្រសិនបើអាចធ្វើទៅបានគឺ វេជ្ជបណ្ឌិតតែម្តង)។ ដើម្បីទទួលបានការផ្ញើរនេះ ក្រុមនីមួយៗបានរៀបចំផែនការ ដែលមានកិច្ចការច្បាស់លាស់ និងថវិកា ដោយមានបញ្ជាក់ពីឈ្មោះឧបករណ៍ និងថ្នាំពេទ្យ ដែលនឹងត្រូវទិញសម្រាប់មណ្ឌលសុខភាពនោះ ។ |
| ការប្រៀបធៀប | ការប្រៀបធៀប ត្រូវបានធ្វើឡើងក្នុងចំណោមក្រុមចំនួនបួនខាងក្រោមនេះ៖<br>១. មានតែអន្តរាគមន៍ផ្អែកលើតម្រូវការ (២០ក្រុង)<br>២. អន្តរាគមន៍ផ្អែកលើការផ្គត់ផ្គង់ និងតម្រូវការ (២០ក្រុង)<br>៣. មានតែអន្តរាគមន៍ផ្អែកលើការផ្គត់ផ្គង់ (១០ក្រុង)<br>៤. ក្រុមមិនទទួលអន្តរាគមន៍ដោយគ្មានអន្តរាគមន៍ (២០ក្រុង) |
| វិធីសាស្ត្រ | ក្រុងចំនួន ៧០ ត្រូវបានចាត់តាំងដោយចៃដន្យ ទៅក្នុងក្រុមចំនួនបួនផ្សេងគ្នា ។ ក្រុមចំនួនបីដំបូង បានទទួលទាំងអន្តរាគមន៍ផ្នែកអប់រំ និងសុខភាព ។ ទិន្នន័យមូលដ្ឋានត្រូវបានប្រមូល មុនពេលអនុវត្តគម្រោងក្នុងបណ្តាក្រុង នៅក្នុងក្រុម១ ក្រុម២ និងក្រុម៣ ។ ទិន្នន័យស្ទង់មតិតាមដានត្រូវបានប្រមូលក្នុងរយៈពេលពីរឆ្នាំក្រោយ។<br><br>សហគមន៍ចំនួន៨ ("ក្រុម") ក្នុងក្រុងនីមួយៗ ក្នុងចំណោមក្រុងទាំង៧០ ត្រូវបានជ្រើសរើសដោយចៃដន្យ ហើយអ្នករស់នៅតំបន់នោះចំនួន ១០នាក់ ក្នុងក្រុមនីមួយៗ ត្រូវបានជ្រើសរើសដោយចៃដន្យ សម្រាប់ការប្រមូលទិន្នន័យ ។ ព័ត៌មាន ដែលបានប្រមូល ពីក្រុមនីមួយៗ ក្នុងចំណោមក្រុមទាំង៥៦០ រួមមានដូចជា៖ ក) ថាតើសហគមន៍ មានសាលាបឋមសិក្សា មន្ទីរពេទ្យរដ្ឋ និងមធ្យោបាយដឹក |

| ធាតុផ្សំ | ការបរិយាយ |
| --- | --- |
| | ជញ្ជូនសារធារណៈដែរឬទេ ខ) អត្រាបៀវត្សប្រចាំថ្ងៃ សម្រាប់ការងារពាក់ព័ន្ធនឹងកសិកម្ម និងមិនពាក់ព័ន្ធនឹងកសិកម្មនៅតាមមូលដ្ឋាន គ)លទ្ធភាពធ្វើការងារឆ្ងាយពីសហគមន៍ ឃ) ព័ត៌មានតិចតួចស្តីពីបទឧក្រិដ្ឋនៅតាមមូលដ្ឋាន និង ង) តម្លៃ សម្រាប់ប្រភេទអាហារមួយចំនួនធំ និងអត្រាបៀវត្សប្រចាំថ្ងៃនៅតាមមូលដ្ឋាន ។<br><br>កម្រងសំណួរ ក៏ត្រូវបានប្រគល់ជូនសាលាបឋមសិក្សាចំនួនបី ដែលបានជ្រើសរើសដោយចៃដន្យ ក្នុងក្រុងនីមួយៗ នៃក្រុងទាំង៧០ ផងដែរ ហើយបានប្រមូលទិន្នន័យដូចខាងក្រោម៖ ក) ព័ត៌មានទូទៅស្តីពីសាលារៀន (ដូចជាថ្ងៃសិក្សា ចំនួនថ្នាក់ ជាដើម) ខ) លក្ខណៈសម្គាល់របស់គ្រូបង្រៀន គ) សម្ភារៈជំនួយខាងគរុកោសល្យ (ដូចជាសៀវភៅបណ្ណាល័យ វចនានុក្រម និងឯកសារជាដើម) និង ឃ) អង្គការនៅសាលា (ដូចជាសមាគមមាតាបិតា-គ្រូបង្រៀន សមាគមគ្រូបង្រៀន ជាដើម)។ |
| **ខ្នាតវង្វាស់ និងលទ្ធផលសំខាន់ៗ** | <u>ការចុះឈ្មោះចូលរៀន</u>៖ ឥទ្ធិពលវិជ្ជមាន ។ អន្តរាគមន៍ផ្អែកលើតម្រូវការ របស់កម្មវិធីនេះ បានបង្កើនអត្រាចុះឈ្មោះចូលរៀន ពី ១ ទៅ ២ភាគរយ ។<br><u>ការចូលរៀន៖</u> ឥទ្ធិពលវិជ្ជមាន ។ អន្តរាគមន៍ផ្អែកតម្រូវការ របស់កម្មវិធីនេះ បានបង្កើនវត្តមានចូលរៀននៅសាលា (ល័ក្ខខ័ណ្ឌ លើការចុះឈ្មោះចូលរៀន) បានប្រហែល ០,៨ថ្ងៃ ក្នុងមួយខែ ។<br><u>ការនៅរៀនក្នុងសាលា</u>៖ ឥទ្ធិពលវិជ្ជមាន ។ អន្តរាគមន៍ផ្អែកតម្រូវការរបស់កម្មវិធីនេះបានបន្ថយអត្រាសិស្សបោះបង់សាលាពី ២ ទៅ ៣ ភាគរយ។<br><u>ការរៀនបានរីកចម្រើននៅសាលា</u>៖ ឥទ្ធិពលវិជ្ជមាន ។ អន្តរាគមន៍ផ្អែកតម្រូវការ បានបង្កើនអត្រាឡើងថ្នាក់ប្រចាំឆ្នាំទៅរៀនថ្នាក់បន្ទាប់ទៀតពី២ ទៅ៤ភាគរយ ។<br><u>លទ្ធផលមិនពាក់ព័ន្ធនឹងការអប់រំ</u> ។ គ្មានឥទ្ធិពល ។ មិនមានឥទ្ធិពលណាមួយ ទៅលើការចូលរួមពលកម្មកុមារនោះទេ ។ លើសពីនេះទៅទៀត អន្តរាគមន៍ផ្អែកផ្គត់ផ្គង់ មិនមានឥទ្ធិពលលើលទ្ធផលណាមួយទេ ។ |
| | ការផ្ទេរប្រាក់អប់រំ មានចំនួន ៥ដុល្លារ សម្រាប់សិស្សម្នាក់ ក្នុងមួយខែ ។ គ្រួសារនីមួយៗ អាចទទួលប្រាក់ខែអាហារូបករណ៍ សម្រាប់ |

| ធាតុផ្សំ | ការបរិយាយ |
|---|---|
| ថ្លៃចំណាយ | កូនជាអតិបរមាចំនួន ៣នាក់ ។ សមាគមមាតាបិតា-គ្រូបង្រៀន មានសិទ្ធិទទួលបានប្រាក់ពី ១.៦០០ ដុល្លារ ដល់ ២៣.០០០ ដុល្លារ ។ ជាមធ្យម សមាគមឪពុកម្តាយ-គ្រូបង្រៀន បានទទួលប្រាក់ចំនួន ៩.០០០ ក្នុងមួយឆ្នាំ ។ សក្ខីបត្រ ពិនិត្យសុខភាពនីមួយៗ មានតម្លៃប្រហែល ៥ដុល្លារ ។ គ្រួសារនីមួយៗ អាចទទួលសក្ខីបត្រនេះ បានរហូតដល់ចំនួន ៣ ក្នុងមួយខែ ។ ក្រុមថែទាំសុខភាពនីមួយៗ បានទទួលប្រាក់ជាមធ្យមចំនួន ៦.០០០ ដុល្លារ ក្នុងមួយឆ្នាំ ។ ប៉ុន្តែចំនួននេះ មានការប្រែប្រួល ពី ៣.០០០ដុល្លារ ទៅ ១៥.០០០ដុល្លារ អាស្រ័យលើទំហំនៃចំនួនប្រជាជន ដែលមណ្ឌលសុខភាព បានបម្រើជូន ។(ដុល្លារឆ្នាំ២០០០) |
| ការបណ្តុះបណ្តាលបុគ្គលិក | មិនមានអានុភាពនៃផ្នែកផ្គត់ផ្គង់ទេ ដោយមូលហេតុចម្បងគឺ អន្តរាគមន៍នេះមិនដែលត្រូវបានអនុវត្តឲ្យបានពិតប្រាកដ ឡើយ ។ បើទោះបីជាគ្រូបង្រៀនបានទទួលការបណ្តុះបណ្តាល ក្នុងសហគមន៍មួយចំនួន ដែលមានអន្តរាគមន៍នេះក៏ដោយ ក៏មូលនិធិ ដែលនឹងត្រូវផ្តល់ជូនសហគមន៍ទាំងនោះ ដើម្បីធ្វើឲ្យសាលាមូលដ្ឋានរបស់ខ្លួនប្រសើរឡើង មិនដែលកើតមាននោះទេ ដោយសារជម្លោះផ្លូវច្បាប់ទាក់ទងនឹងបែបបទនៃការផ្តល់មូលនិធិទាំងនោះ ។ |

## ១៣. ប្រទេសឥណ្ឌា៖ ការបង្រៀនគួរបន្ថែម ឬការរៀនកុំព្យូទ័រ

| ធាតុផ្សំ | ការបរិយាយ |
|---|---|
| ការដកស្រង់អត្ថបទការសិក្សាស្រាវជ្រាវ | Banerjee, A., Cole, S., Duflo, E., & Linden, L. (2007). ការកែលម្អការអប់រំ៖ ភស្តុតាងចេញពីការធ្វើពិសោធន៍ព្រាវៗចំនួនពីរ នៅក្នុងប្រទេសឥណ្ឌា ។ *ទិន្នានុប្បវត្តិសេដ្ឋកិច្ចប្រចាំត្រីមាស ១២២(៣)* ១២៣៥-១២៦៤ ។ |
| សំណួរស្រាវជ្រាវ | តើកម្មវិធីបង្រៀនគួរបន្ថែម ឬកម្មវិធីរៀនកុំព្យូទ័រដ៏ទូលំទូលាយនេះធ្វើឲ្យសិស្សរៀនបានលទ្ធផលល្អប្រសើរ និងកាត់បន្ថយអត្រាសិស្សបោះបង់សាលាដែរឬទេ? |
| អ្នកចូលរួម | សិស្សចំនួន១៩.៩៧២ នាក់ ក្នុងសាលាចំនួន១៦៥បានចូលរួមក្នុងការសិក្សាអប់រំកែលម្អនេះនៅឆ្នាំ ២០០១ (ជាឆ្នាំ ដែលឆ្លើយតបទៅនឹងលក្ខណៈវិនិច្ឆ័យខាងវិធិសាស្ត្រសម្រាប់ដាក់បញ្ចូល ជាកម្មវិធីមានប្រសិទ្ធភាពមួយ) ។ សិស្សចំនួន៥.៩៨៥នាក់ក្នុងសាលាចំនួន ១១១ បានចូលរៀនកុំព្យូទ័រ ក្នុងឆ្នាំ២០០២ និងឆ្នាំ២០០៣ (ឆ្នាំទាំងពីរ បានឆ្លើយតបទៅនឹងលក្ខណៈវិនិច្ឆ័យខាងវិធីសាស្ត្រ) ។ |
| ការកំណត់ | <u>ប្រទេស ឥណ្ឌា</u>៖ កម្មវិធីអប់រំបំប៉នបន្ថែម (ហៅថាកម្មវិធី Balsakhi) ត្រូវបានបង្កើតឡើងក្នុងតំបន់ទីប្រជុំជនក្រីក្រ ក្នុងទីក្រុង ម៉ុមបៃ (Mumbai) និងទីក្រុង វាដូដារា (Vadodara) ក្នុងប្រទេសឥណ្ឌាភាគខាងលិច ។ កម្មវិធីរៀនកុំព្យូទ័រមានតែនៅ **វ៉ាដូដារ៉ា**ប៉ុណ្ណោះ។ |
| អន្តរាគមន៍ | <u>ការអប់រំបំប៉នបន្ថែម</u>៖ កម្មវិធីអប់រំបំប៉នបន្ថែមបានយកស្ត្រីក្មេងៗពីសហគមន៍ឲ្យធ្វើជាជំនួយការគ្រូបង្រៀន ។ ពួកគេ បានបំពេញការងារតាមជំនាញមូលដ្ឋាន ជាមួយសិស្សរៀនថ្នាក់ទី៣ ឬថ្នាក់ទី៤ ដែលមិនពូកែខាងអក្សរសាស្ត្រ និងគណិតវិទ្យា ។ កុមារត្រូវបានយកចេញពីថ្នាក់រៀន ដើម្បីឲ្យធ្វើការងារជាមួយគ្រូបង្រៀនទាំងនេះរយៈពេល២ម៉ោងនៃថ្ងៃសិក្សារយៈពេល៤ ម៉ោង ។<br><u>ការរៀនកុំព្យូទ័រ</u>៖ អន្តរាគមន៍ទី២នេះផ្តោតលើគណិតវិទ្យា ។ កុមាររៀនថ្នាក់ទី៤ មានពេលពីរម៉ោង (មួយម៉ោង អំឡុងថ្ងៃសិក្សា និងមួយម៉ោងទៀត អាចក្នុងអំឡុងពេលមុនចូលសាលា ឬក្រោយចេញពីសាលា) នៃម៉ោងប្រើប្រាស់កុំព្យូទ័ររួម ក្នុងសប្តាហ៍នីមួយៗ អំឡុងពេលណាដែលពួកគេលេងហ្គេមពាក់ព័ន្ធនឹងការដោះស្រាយលំហាត់គណិតវិទ្យា ដែលកម្រិតនៃភាពពិបាករបស់លំហាត់នេះ អាស្រ័យលើសមត្ថភាពរបស់កុមារ ។ គ្រូបង្រៀននៅក្នុងបន្ទប់រៀនមិនបានបង្រៀនសិស្សទេអំពីកិច្ចការនេះទេ។ |
| ការប្រៀប | សាលាចំនួន២៤ ដែលមិនមានក្នុងកម្មវិធីនេះ ក្នុងទីក្រុង វ៉ាដូដារា (Vadodara) បានដើរតួនាទីជាសាលាមិនទទួលអន្តរាគមន៍(មិនបាន |

| ធាតុផ្សំ | ការបរិយាយ |
|---|---|
| ផៀប | ប្រាប់ពីចំនួនសិស្សទេ)។ |
| វិធីសាស្ត្រ | បណ្តាសាលានៅក្នុងក្រុមអន្តរាគមន៍ ត្រូវបានចាត់តាំងព្រាវៗថាជាក្រុមទទួលអន្តរាគមន៍ពីគម្រោង។ សាលាមួយចំនួនមានជំនួយការគ្រូបង្រៀនម្នាក់នៅថ្នាក់ទី៣ ហើយសាលាមួយចំនួនផ្សេងទៀតមានជំនួយការគ្រូបង្រៀនម្នាក់នៅថ្នាក់ទី៤ ។ |
| ខ្នាតរង្វាស់ និងលទ្ធផលសំខាន់ៗ | <u>ការចូលរៀន</u>៖ គ្មានឥទ្ធិពល ។ មិនមានអន្តរាគមន៍ណាមួយបានបង្កើនវត្តមានចូលរៀនរបស់សិស្សនោះទេ។<br><br><u>ការនៅរៀនក្នុងសាលា</u>៖ គ្មានអានុភាព។ មិនមានអន្តរាគមន៍ណាមួយមានអានុភាពលើអត្រាសិស្សបោះបង់សាលានោះទេ។<br><u>ពិន្ទុប្រលង</u>៖ អានុភាពវិជ្ជមាន៖ កម្មវិធីអប់រំបំប៉នបន្ថែមបានបង្កើនពិន្ទុប្រឡង០,១៤ នៃគម្លាតស្តង់ដារក្នុងឆ្នាំទី១។ ការទទួលបានលទ្ធផលទាំងនេះភាគច្រើន គឺដោយសារតែកំណើនដ៏ច្រើនរបស់សិស្ស ដែលរៀនខ្សោយជាងគេបំផុត ។ កម្មវិធីការរៀនប្រើកុំព្យូទ័រជំនួយបានធ្វើឲ្យពិន្ទុគណិតវិទ្យាកើនឡើង០,៣៥នៃគម្លាតស្តង់ដារ អំឡុងឆ្នាំទី១នេះ និងកើនបាន ០,៤៧ នៃគម្លាតស្តង់ដារ អំឡុងឆ្នាំទី២ ។<br><br><u>តម្លៃប្រសិទ្ធភាព</u>៖ កម្មវិធីអប់រំបំប៉នបន្ថែមមានតម្លៃប្រសិទ្ធភាព។ ដោយមើលទៅលើការចំណាយផ្សេងៗក្នុងឯកតាគម្លាតស្តង់ដារ អ្នកនិពន្ធបានសន្និដ្ឋានថា ការជួលជំនួយការគ្រូបង្រៀន គឺចំណាយអស់តិចជាងកម្មវិធីទាំងពីរច្រើនណាស់។ វាក៏មានតម្លៃប្រសិទ្ធភាពច្រើនជាងការជួលគ្រូថ្មីបន្ថែមដោយឲ្យប្រាក់ខែខ្ពស់ជាងដែរ។ |
| ថ្លៃចំណាយ | ជំនួយការគ្រូបង្រៀនរកកម្រៃបានពី១០ ទៅ១៥ដុល្លារ ក្នុងមួយខែ និងថ្លៃ ២,២៥ ដុល្លារសម្រាប់សិស្សម្នាក់ក្នុងមួយឆ្នាំ ។ កម្មវិធីកុំព្យូទ័រចំណាយអស់១៥,១៨ដុល្លារ សម្រាប់សិស្សម្នាក់ ក្នុងមួយឆ្នាំ ។ (ដុល្លារ២០០៤) |
| ការបណ្តុះបណ្តាលបុគ្គលិក | ជំនួយការគ្រូបង្រៀន បានទទួលការបណ្តុះបណ្តាលរយៈពេលពីរសប្តាហ៍ នៅដើមឆ្នាំ និងការបណ្តុះបណ្តាលលើការពង្រឹងការអនុវត្តពេលណាដែលចាំបាច់ ។ គ្រូបង្រៀន ដែលធ្វើការងារជាមួយកម្មវិធីរៀនកុំព្យូទ័រនេះបានទទួលការបណ្តុះបណ្តាលផ្នែកកុំព្យូទ័ររយៈពេលប្រាំថ្ងៃ មុនពេលមកកាន់បន្ទប់កុំព្យូទ័រ ។ គ្រូបង្រៀនក្នុងសាលាមិនទទួលអន្តរាគមន៍មិនបានទទួលការបណ្តុះ បណ្តាលទេ ។ |

## ១៤. ប្រទេសឥណ្ឌាៈ ការតាមដានវត្តមានគ្រូបង្រៀន និងការប្រើប្រាស់ប្រាក់លើកទឹកចិត្ត

| ធាតុផ្សំ | ការបរិយាយ |
|---|---|
| ការដកស្រង់ពីការសិក្សា | Duflo, E., Hanna, R. &. Ryan, S. (2010). *ការងារមានប្រាក់លើកទឹកចិត្ត ៖ ធ្វើឲ្យគ្រូមកបង្រៀននៅសាលា ។*. MIT mimeo. http://econ-www.mit.edu/files/5995 |
| សំណួរសិក្សាស្រាវជ្រាវ | តើការតាមដាន និងប្រាក់លើកទឹកចិត្តអាចកាត់បន្ថយអវត្តមានគ្រូបង្រៀន និងបង្កើនការរៀនសូត្ររបស់កុមារដែរឬទេ? |
| អ្នកចូលរួម | សាលាសហគមន៍ជនបទចំនួន១១៣ ត្រូវបានចាត់តាំងព្រាវៗ ។ សាលាចំនួន៥៧ជាសាលាទទួលអន្តរាគមន៍ និងសាលា៥៦ទៀតជាសាលាមិនទទួលអន្តរាគមន៍ ។ |
| បរិបទ | <u>រាចាស្ថាន(Rajasthan) ប្រទេសឥណ្ឌា</u>៖ តំបន់ អ៊ូដាយភីរ៍ (Udaipur) គឺជាតំបន់មានប្រជាពលរដ្ឋរស់នៅតិចតួច ដែលពិបាកធ្វើដំណើរទៅតំបន់ រ៉ាចាស្ថាន (Rajasthan) ។ សាលាសហគមន៍ចំនួន៥៧ ក្នុងគំរូតាងបើកបង្រៀនប្រាំមួយម៉ោងក្នុងមួយថ្ងៃ ហើយសាលានីមួយៗ មានសិស្សប្រហែល ២០នាក់ ។ សិស្សទាំងអស់ត្រូវបានបង្រៀនក្នុងថ្នាក់រៀនមួយ ដោយគ្រូបង្រៀនម្នាក់ ត្រូវបានជ្រើសរើសចេញពីសហគមន៍មូលដ្ឋាន និងបានទទួលការអប់រំជាមធ្យមថ្នាក់ទី១០ ។ សាលារៀននេះបានបិទទ្វារ នៅពេលគ្មានវត្តមានគ្រូបង្រៀន ។ |
| អន្តរាគមន៍ | <u>វត្តមានគ្រូបង្រៀន</u>៖ ដោយសារតែទីតាំងដាច់ស្រយ៉ាលរបស់សាលាសហគមន៍ក្នុងការសិក្សានេះ ការតាមដានគ្រូបង្រៀនជាប្រចាំគឺជាការលំបាក ហើយអវត្តមានគ្រូបង្រៀនក៏មានកម្រិតខ្ពស់ផងដែរ ។ អង្គការមិនមែនរដ្ឋាភិបាលមូលដ្ឋាន ដែលបានបើកសាលាទាំងនេះ បានផ្តល់ឲ្យគ្រូចំនួន៥៧នាក់ក្នុងក្រុមទទួលអន្តរាគមន៍នូវម៉ាស៊ីនថតមួយគ្រឿង រួមជាមួយសេចក្តីណែនាំឲ្យសិស្សម្នាក់ ថតរូបគ្រូបង្រៀន នៅពេលចាប់ផ្តើម និងពេលបញ្ចប់ការបង្រៀននៃថ្ងៃសិក្សានីមួយៗ ។<br><br>ម៉ាស៊ីនថតនេះ មានកាលបរិច្ឆេទច្បាស់លាស់ និងមុខងារកំណត់ម៉ោងថត ដែលបង្កលក្ខណៈងាយស្រួលដល់ការប្រមូលទិន្នន័យច្បាស់លាស់អំពីវត្តមានគ្រូបង្រៀន ពោលគឺត្រូវបានប្រើដើម្បីគណនាប្រាក់ខែគ្រូបង្រៀន ។ គ្រូបង្រៀននីមួយៗបានទទួលប្រាក់ខែ ទៅតាមចំនួនថ្ងៃសិក្សា ដែលពួកគាត់បានមកបង្រៀនពិតប្រាកដ។ ថ្ងៃ "មកបង្រៀនពិតប្រាកដ" ត្រូវបានកំណត់ថា ជា |

| ធាតុផ្សំ | ការបរិយាយ |
|---|---|
| | ថ្ងៃដែលពួកគាត់ត្រូវបានគេថតរូបពេលចាប់ផ្ដើម និងពេលបញ្ចប់ការបង្រៀន មានរយៈពេលយ៉ាងតិច៥ម៉ោង ហើយរូបថតទាំងពីរបានបង្ហាញសិស្សយ៉ាងតិច៨នាក់ ។<br>ប្រាក់ខែ ចាប់ពី ៥០០ រូពី (Rs) ដល់ ១.៣០០ រូពី (ឬពី១១,៥០ ដុល្លារ ដល់ ២៩,៥០ ដុល្លារ) ។ គ្រូបង្រៀនបានទទួល ៥០០ រូពី ប្រសិនបើពួកគេមកបង្រៀនតិចជាង១០ថ្ងៃ ក្នុងខែដែលគេបានកំណត់ និងទទួលបាន៥០រូពី ទៀតសម្រាប់ថ្ងៃបន្ថែមណាមួយ (រហូតដល់ចំនួនថ្ងៃអតិបរិមា ២៥ ឬ២៦ ថ្ងៃអាស្រ័យលើខែនោះ) ។ |
| ការប្រៀបធៀប | ការប្រៀបធៀប ត្រូវបានធ្វើឡើងជាមួយសាលាជនបទស្រដៀងគ្នាចំនួន ៥៦ ។ ក្នុងសាលាប្រៀបធៀបទាំងនេះ គ្រូបង្រៀនបានទទួលអត្រាប្រាក់ខែថេរ (១ ០០០ រូពី) ក្នុងមួយខែ ។ ពួកគេត្រូវចងចាំថា ការមកបង្រៀនទៀងទាត់ គឺជាតម្រូវការនៃការងាររបស់ពួកគេ ហើយពួកគេអាចនឹងត្រូវបានបណ្ដេញចេញពីការងារ ក្នុងករណីដែលមកបង្រៀនមិនបានទៀងទាត់ ។ |
| វិធីសាស្ត្រ | ប្រភពនៃទិន្នន័យវត្តមានចំនួនពីរ ត្រូវបានប្រមូល ។ ទី១ ទិន្នន័យអំពីវត្តមានគ្រូបង្រៀន ត្រូវបានប្រមូល តាមរយៈការទៅពិនិត្យដោយមិនបានជូនដំណឹងជាមុនដោយចៃដន្យមួយ ក្នុងមួយខែ នៅគ្រប់សាលារៀនទាំងអស់ ។ ទី២ ម៉ាស៊ីនថត បានផ្ដល់នូវរឿងរ៉ាវ "មើលឃើញផ្ទាល់ភ្នែក" សម្រាប់បណ្ដាសាលាអន្តរាគមន៍។ តាមរយៈការប្រៀបធៀបអត្រាអវត្តមាន ដែលបានទទួលពីការត្រួតពិនិត្យដោយចៃដន្យ នៅទូទាំងសាលាទាំងពីរប្រភេទ ការសិក្សានេះ បានកំណត់ពីអានុភាពរបស់គម្រោងលើភាពអវត្តមាន ។<br><br>សម្រាប់សាលា ដែលបានដំណើរការ អំឡុងពេលការចុះត្រួតពិនិត្យនេះ អ្នកវាយឈ្មោះ បានកត់ត្រាចំនួនសិស្សអង្គុយ ក្នុងថ្នាក់រៀន ថាតើមានអ្វីសរសេរលើក្ដារខៀនដែរឬទេ ហើយថាតើគ្រូបង្រៀននិយាយជាមួយសិស្សដែរឬទេ ។ អ្នកវាយឈ្មោះ ក៏បានហៅឈ្មោះសិស្សក្នុងបញ្ជី និងពិនិត្យមើលថាតើមានកុមារអវត្តមានណាមួយបានឈប់រៀន ឬបានចុះឈ្មោះចូលរៀនក្នុងសាលារដ្ឋដែរឬទេ ហើយបន្ទាប់មកទៀត បានធ្វើបច្ចុប្បន្នភាពបញ្ជីវាយតម្លៃ ដើម្បីដាក់បញ្ចូលកុមារថ្មី ។ |

| ធាតុផ្សំ | ការបរិយាយ |
|---|---|
| | ដើម្បីកំណត់ថា តើការរៀនសូត្ររបស់កុមារ បានកើនឡើង ដោយសារតែកម្មវិធីនេះ ដែរឬក៏អត់នោះ ការប្រឡងមុន និងក្រោយពេលសិក្សា នៃការប្រឡងសមត្ថភាពមូលដ្ឋានចំនួនបី ត្រូវបានដាក់ឲ្យកុមារទាំងអស់ធ្វើ ។ កុមារដែលអាចសរសេរបានទទួលយកការប្រលងសរសេរ ។ កុមារដែលមិនអាចសរសេរ បានទទួលយកការប្រឡងផ្ទាល់មាត់ ។<br><br>ការធ្វើតេស្តផ្ទាល់មាត់ បានសួរជំនាញគណិតវិទ្យាធម្មតា (ការរាប់លេខ ការបូកលេខមួយខ្ទង់ ការចែកលេខធម្មតា) និងជំនាញវគ្គស័ព្ទ ភាសាហ៊ីនឌូ (Hindi) មូលដ្ឋាន ស្របពេលដែលការប្រឡងសរសេរ បានសួរសំណួរអំពីសមត្ថភាពទាំងនេះ បន្ថែមជាមួយជំនាញ គណិតវិទ្យាដែលស្មុគស្មាញជាងនេះ (ការបូកលេខនិងការដកលេខពីរខ្ទង់ ការគុណលេខ និងការចែកលេខ) សមត្ថភាពបង្កើតប្រយោគ និងការយល់ពីអំណាន ។<br><br>ហេតុដូច្នេះហើយ ការប្រឡងសរសេរ បានសួរទាំងសមត្ថភាពសរសេរ និងសមត្ថភាពដោះស្រាយបញ្ហាដែលតម្រូវឲ្យមានសមត្ថភាពកម្រិតខ្ពស់ជាងការប្រឡងផ្ទាល់មាត់របស់កុមារ ។ |
| **ខ្នាតរង្វាស់ និងលទ្ធផលសំខាន់ៗ** | <u>ការនៅរៀនក្នុងសាលា</u>៖ គ្មានអានុភាពគួរឲ្យកត់សម្គាល់ទេ ។ ការសិក្សានេះបានរកឃើញថា ភាពអវត្តមានរបស់សិស្សប្រចាំថ្ងៃមានលក្ខណៈស្រដៀងគ្នានឹងស្ថានភាព ដែលគ្រូបង្រៀនមានវត្តមានញឹកញាប់ និងស្ថានភាព ដែលគ្រូបង្រៀនអវត្តមានញឹកញាប់។ ជាមួយគ្នានេះផងដែរ អត្រាសិស្សបោះបង់សាលានៅសាលាទទួលអន្តរាគមន៍មានកម្រិតទាបជាង ប៉ុន្តែមិនសំខាន់នៅក្នុងស្ថិតិនោះទេ ។<br><br><u>ពិន្ទុប្រឡង</u>៖ អានុភាពវិជ្ជមាន ។ ពិន្ទុប្រឡងភាសា និងគណិតវិទ្យារបស់កុមារបានកើនឡើង០,១៧នៃគម្លាតស្តង់ដារ។ |

| ធាតុផ្សំ | ការបរិយាយ |
|---|---|
| | ការបញ្ចប់ការសិក្សា៖ អានុភាពវិជ្ជមាន ។ ២៦ ភាគរយនៃសិស្សក្នុងសាលា អន្តរាគមន៍បានបញ្ចប់ការសិក្សានៅសាលារដ្ឋប្រៀបធៀបនឹងចំនួនតែ១៦ភាគរយប៉ុណ្ណោះ នៃសិស្សក្នុងសាលាប្រៀបធៀប ដែលបានបញ្ចប់ការសិក្សា ។ ភាពខុសគ្នាចំនួន១០ភាគរយនេះ មានន័យថាកើនឡើងចំនួន៦២ភាគរយនៃអត្រាបញ្ចប់ការសិក្សា ហើយវាមានសារៈសំខាន់ ។<br><br>គ្រូអវត្តមានច្រើន៖ អានុភាពវិជ្ជមាន ។ រយៈពេលជាង៣០ខែ ក្នុងការតាមដានវត្តមានគ្រូបង្រៀន គ្រូបង្រៀនក្នុងសាលាអន្តរាគមន៍មានអត្រាអវត្តមានចំនួន២១% ធៀបនឹង ៤៤% នៃទិន្នន័យមូលដ្ឋាន និង ៤២% ក្នុងសាលាប្រៀបធៀប ។<br><br>ពេលវេលាសម្រាប់ណែនាំ៖ អានុភាពវិជ្ជមាន ។ កុមារក្នុងសាលាទទួលអន្តរាគមន៍ទទួលបានពិន្ទុ៩% (ឬ ៣០%) ដែលជាចំនួនថ្ងៃចូលរៀនច្រើនជាងកុមារក្នុងសាលាប្រៀបធៀប ។ |
| ថ្លៃចំណាយ | ប្រហែល ២៣ ដុល្លារ សម្រាប់គ្រូបង្រៀនម្នាក់ ក្នុងមួយខែ (ដុល្លារ ក្នុងឆ្នាំ ២០០៣)។ |
| ការបណ្តុះ បណ្តាលបុគ្គលិក | មិនមានការបណ្តុះបណ្តាលបុគ្គលិកទេ ។ |

## ១៥. ប្រទេស ចាម៉ៃកាៈ កម្មវិធីផ្ទេរប្រាក់មានល័ក្ខខ័ណ្ឌ PATH

| ធាតុផ្សំ | ការបរិយាយ |
|---|---|
| ការដកស្រង់ ពីការសិក្សា | Levy D. & Ohls, J. (2007). *ការវាយតម្លៃនៃ កម្មវិធី PATH របស់ប្រទេស ចាម៉ៃកា* ។ របាយការណ៍ចុងក្រោយ ។ ការសិក្សាស្រាវជ្រាវគោលនយោបាយ Mathematica, Inc |
| សំណួរសិក្សាស្រាវជ្រាវ | (១) តើកម្មវិធី PATH(កម្មវិធីអភិវឌ្ឍតាមរយៈសុខភាព និងការអប់រំ)មានឥទ្ធិពលអ្វីខ្លះទៅលើការចុះឈ្មោះចូលរៀនរបស់កុមារ?<br>(២) តើកម្មវិធីនេះមានឥទ្ធិពលអ្វីខ្លះទៅលើពិន្ទុប្រឡង?<br>(៣) តើឥទ្ធិពលនេះមានលក្ខណៈខុសគ្នាសម្រាប់កុមារីច្រើនជាងកុមារាដែរឬទេ? |
| អ្នកចូលរួម | កុមារក្រីក្រ ចាប់ពីពេលកើត រហូតអាយុ ១៧ឆ្នាំ |
| បរិបទ | <u>ប្រទេស ចាម៉ៃកា</u> ។ |
| អន្តរាគមន៍ | <u>ជំនួយឥតសំណងសម្រាប់កុមារ</u> បានផ្តល់ថវិកាផ្នែកសុខភាព និងផ្នែកអប់រំសម្រាប់កុមារក្រីក្រដែលមានសិទ្ធិទទួល រហូតអាយុ ១៧ឆ្នាំ ។ វិក្កយបត្រថវិកាផ្នែកសុខភាពសម្រាប់កុមារ រហូតអាយុ៦ឆ្នាំ (មិនបានចុះឈ្មោះចូលរៀនក្នុងសាលា) មានល័ក្ខខ័ណ្ឌ ទៅតាមការទៅពិនិត្យសុខភាពរបស់ពួកគេនៅគ្លីនិកសុខភាព រៀងរាល់ពីរខែម្តង អំឡុងឆ្នាំទី១ នៃការរស់នៅរបស់ពួកគេ និងពីរដងក្នុងមួយឆ្នាំ នាឆ្នាំបន្ទាប់មកទៀត ។<br>វិក្កយបត្រនៃថវិកាផ្នែកការអប់រំ សម្រាប់កុមារអាយុ ៦ឆ្នាំ រហូត១៧ឆ្នាំ មានល័ក្ខខ័ណ្ឌឲ្យកុមារមករៀនទៀងទាត់ (យ៉ាងហោច ៨៥ភាគរយនៃថ្ងៃសិក្សា) ។<br><u>ថវិកាជំនួយសង្គម</u> ក៏ត្រូវបានផ្តល់ជូនមនុស្សពេញវ័យទីទាល់ក្រ ក៏ប៉ុន្តែមិនត្រូវបានយកមកពិភាក្សានៅទីនេះទេ។ |
| ការប្រៀបធៀប | ការប្រៀបធៀប ត្រូវបានធ្វើឡើង រវាងគំរូតាងនៃគ្រួសារចំនួន២.៥០០គ្រួសារ ដែលមានសិទ្ធិចូលរួមកម្មវិធី PATH (កម្មវិធីអភិវឌ្ឍតាមរយៈសុខភាព និងការអប់រំ) (ក្រុមអ្នកចូលរួម) ជាមួយក្រុមគ្រួសារផ្សេងទៀត ដែលស្រដៀងនឹងក្រុមអ្នកចូលរួមនេះដែរ ប៉ុន្តែមិនត្រូវបានចាត់ទុកថាមានសិទ្ធិចូលរួមកម្មវិធី PATH នេះទេ (ក្រុមប្រៀបធៀប) ។ |

| ធាតុផ្សំ | ការបរិយាយ |
|---|---|
| វិធីសាស្ត្រ | ទិន្នន័យសម្រាប់ការវាយតម្លៃ ត្រូវបានប្រមូល តាមរយៈ៖<br>១. ការសម្ភាសន៍តាមបែបគុណភាព ត្រូវបានធ្វើឡើងជាមួយបុគ្គលិកកម្មវិធី PATH ក៏ដូចជាបុគ្គលិកសាលា និងមណ្ឌលថែទាំសុខភាព ដែលបម្រើឲ្យអតិថិជន PATH និងជាមួយបុគ្គលិកការិយាល័យប្រៃសណីយ៍ ។<br>២. ការធ្វើកិច្ចពិភាក្សាក្រុមគោលដៅជាមួយអតិថិជន PATH អំពីបទពិសោធន៍របស់ពួកគេជាមួយកម្មវិធីនេះ ។<br>៣. ទិន្នន័យដកស្រង់ចេញពីប្រព័ន្ធគ្រប់គ្រងព័ត៌មាន ដែលត្រូវបានប្រើដើម្បីប្រតិបត្តិការគម្រោងនេះ និង<br>៤. ការអង្កេតតាមគ្រួសារ ដែលត្រូវបានធ្វើឡើងជាច្រើនលើកច្រើនសា រួមមានដូចជា ការអង្កេតទិន្នន័យមូលដ្ឋាននៃគ្រួសារក្រុមអ្នកចូលរួម និងគ្រួសារក្រុមប្រៀបធៀប និងការអង្កេតតាមដានលើគ្រួសារដដែលនេះ បន្ទាប់ពីក្រុមអ្នកចូលរួមបានទទួលការបែងចែកអត្ថប្រយោជន៍ជាច្រើន។<br><br>ការវាយតម្លៃនេះត្រូវបានរៀបចំឡើង នៅក្នុងគម្រោងផ្អែកលើការពិសោធន៍ ដែលបានប្រើទិន្នន័យអង្កេតតាមគ្រួសារយ៉ាងលម្អិតដើម្បីកំណត់ថាតើ កម្មវិធី PATH បានទៅដល់ចំនួនប្រជាជនដែលជាគោលបំណងរបស់ខ្លួន និងបានបង្កើនទុនមនុស្សនៃគ្រួសារ ក្រីក្រ ដូចត្រូវបានវាស់ស្ទង់ តាមរយៈវត្តមានចូលសាលា និងការប្រើប្រាស់តំហែថែសុខភាពដែរឬអត់ ។<br>ការវាយតម្លៃនេះ ក៏បានដាក់បញ្ចូលការវិភាគតាមបែបគុណភាពផងដែរ ដោយផ្អែកលើក្រុមគោលដៅ និងបទសម្ភាសន៍ ប្រតិបត្តិ ដើម្បីវាយតម្លៃថាតើកម្មវិធីនេះត្រូវបានអនុវត្តបានល្អកម្រិតណា ។ |
| ខ្នាតរង្វាស់ និងលទ្ធផលសំខាន់ៗ | <u>ការចូលរៀន៖</u> អានុភាពវិជ្ជមាន ។ ការវិភាគទៅលើការថយចុះពហុគុណបានបង្ហាញថា កម្មវិធី PATH បង្កើនការចូលរៀន ប្រហែល ០,៥ ថ្ងៃ ក្នុងមួយខែ ។ ការកើនឡើងដែលត្រូវបានប៉ាន់ស្មាន មានប្រហែល៣ភាគរយលើកម្រិតទិន្នន័យមូលដ្ឋានហើយវាមានសារៈសំខាន់ក្នុងស្ថិតិ ។<br><u>រៀនបានរីកចម្រើននៅសាលា៖</u> គ្មានអានុភាព ។ មិនមានភស្តុងតាងបង្ហាញថា កម្មវិធី PATH មានអានុភាពលើលទ្ធផលរយៈពេលវែង ដូចជា ថ្នាក់ ឬការឡើងថ្នាក់ ។ |

| ធាតុផ្សំ | ការបរិយាយ |
|---|---|
| | លទ្ធផលមិនពាក់ព័ន្ធនឹងការអប់រំ៖ អានុភាពវិជ្ជមាន ។ កម្មវិធី PATH បានទទួលជោគជ័យក្នុងការឆ្លើយតបនឹងគោលបំណងរបស់ខ្លួន ក្នុងការបង្កើនការប្រើប្រាស់សេវាថែទាំសុខភាពសម្រាប់កុមារ ក្នុងគ្រួសារ PATH ។ លទ្ធផលទាំងនេះបានលើកឡើងថា ការទៅមណ្ឌលថែទាំសុខភាពសម្រាប់កុមារចាប់ពីពេលកើត រហូតដល់អាយុ ៦ឆ្នាំ បានកើនឡើងប្រហែល៣៨ភាគរយ ដោយសារតែមានកម្មវិធីនេះ ។ |
| **ថ្លៃចំណាយ** | អត្ថប្រយោជន៍ប្រចាំខែជាមធ្យមសម្រាប់កុមារម្នាក់ ដែលទទួលបានថវិកាផ្នែកសុខភាព ឬផ្នែកអប់រំគឺមានប្រហែល៦,៥០ ដុល្លារ (ដុល្លារ ឆ្នាំ ២០០៥) ។ |
| **ការបណ្តុះ បណ្តាល បុគ្គលិក** | មិនមានការបណ្តុះបណ្តាលបុគ្គលិកទេ ។ |

## ១៦. ប្រទេស កេនយ៉ា៖ ការចំណាយលើឯកសណ្ឋានសាលា

| ធាតុផ្សំ | បរិយាយ |
|---|---|
| ការដកស្រង់ ពីការសិក្សា | Duflo, E., Dupas, P., Kremer, M., & Sinei, S. (2006). *ការអប់រំ និងការទប់ស្កាត់មេរោគអេដស៍/ជម្ងឺអេដស៍ (HIV/AIDS)៖ ភស្តុតាងបានពីការវាយតម្លៃព្រាវៗ ក្នុងប្រទេស កេនយ៉ា ភាគខាងលិច* ។ ឯកសារការងារសិក្សាស្រាវជ្រាវគោលនយោបាយរបស់ធនាគារពិភពលោក ៤០២៤ ។ |
| សំណួរស្រាវជ្រាវ | តើអន្តរាគមន៍លើការអប់រំ និងការបង្ការមេរោគអេដស៍/ជម្ងឺអេដស៍ (*HIV/AIDS*) កាត់បន្ថយការមានគត៌នៅវ័យជំទង់ដែរឬទេ? |
| អ្នកចូលរួម | សិស្សចំនួន ៧០.០០០នាក់ បានចុះឈ្មោះចូលរៀន ចាប់ពីថ្នាក់ទី៥ ដល់ថ្នាក់ទី៨ ក្នុងសាលាបឋមសិក្សាចំនួន ៣២៨ ។ ២៤៦ សាលា បានទទួលទម្រង់អន្តរាគមន៍មួយ ក្នុងចំណោមទម្រង់ "អន្តរាគមន៍"ចំនួនប្រាំ ។ ការសិក្សានេះ ក៏មានការចូលរួមរបស់គ្រូបង្រៀនអនុវិទ្យាល័យ ប្រហែល ៣.០០០នាក់ផងដែរ ក្នុងសាលាទទួលអន្តរាគមន៍ពីគម្រោងមួយចំនួន ដែលក្នុងចំណោមនោះ គ្រូបង្រៀនចំនួន ៤៤៥នាក់ បានចូលរួមកម្មវិធីបណ្តុះបណ្តាលស្តីពីមេរោគអេដស៍ ។ |
| ការកំណត់ | <u>ប្រទេស កេនយ៉ា</u> ។ ស្រុកជនបទពីរ គឺស្រុក បុនហ្គូម៉ា (Bungoma) និងស្រុក បុតេរ៉េ ម៉ូមីអាស (Butere-Mumias) នៅភាគខាងលិចប្រទេស។ |
| អន្តរាគមន៍ | <u>ការបណ្តុះបណ្តាលគ្រូបង្រៀន</u>៖ អង្គភាពត្រួតពិនិត្យជម្ងឺអេដស៍ របស់ក្រសួងអប់រំ បានបណ្តុះបណ្តាលគ្រូបង្រៀនស្តីពីប្រធានបទខុសគ្នាៗជាច្រើន ដែលក្នុងនោះរួមមាន អង្គហេតុមូលដ្ឋានស្តីពីមេរោគអេដស៍/ជម្ងឺអេដស៍ ការបង្ហាញពីស្រោមអនាម័យ ព័ត៌មានស្តីពីការប្រឹក្សាយោបល់ និងការធ្វើតេស្តស្ម័គ្រចិត្ត និងវិធីសាស្ត្រអប់រំជម្ងឺអេដស៍ ។<br><br>អ្នកចូលរួម បានពិនិត្យឡើងវិញនូវឯកសារនៅក្នុងសៀវភៅរបស់អ្នកសម្របសម្រួលមេរោគអេដស៍/ជម្ងឺអេដស៍ បានរៀនសូត្រទាំងរបៀបពិភាក្សាបញ្ហាមេរោគអេដស៍/ជម្ងឺអេដស៍ ជាផ្នែកមួយនៃថ្នាក់រៀន ដែលបានផ្តោតលើប្រធាបបទផ្សេងទៀត និងរបៀបយកមេ |

| ធាតុផ្សំ | បរិយាយ |
|---|---|
| | រៀនទាំងមូលផ្តោតលើសកម្មភាពមេរោគអេដស៍/ជម្ងឺអេដស៍ និងបានរៀបចំផែនការមេរៀនក្រោមការគ្រប់គ្រងរបស់អ្នកសម្របសម្រួល។<br><br>នៅឯចុងបញ្ចប់នៃវគ្គបណ្តុះបណ្តាលនេះ គ្រូបង្រៀនត្រូវបានស្នើឲ្យរៀបចំ "ផែនការសកម្មភាព" មួយ សម្រាប់អប់រំអំពីមេរោគ អេដស៍/ជម្ងឺអេដស៍ នៅក្នុងសាលារបស់ពួកគេ ដោយរួមមានរបៀបដែលពួកគេនឹងជួយគ្រូបង្រៀនផ្សេងទៀតក្នុងសាលា និងរបៀបដាក់បញ្ចូលកម្មវិធីមេរោគអេដស៍/ជម្ងឺអេដស៍ទៅក្នុងកាលវិភាគ ។ ក្រៅពីការផ្តល់ជូនសកម្មភាពនៅតាមបន្ទប់រៀន គ្រូបង្រៀនដែលបានទទួលការបណ្តុះបណ្តាល ត្រូវបានផ្តល់យោបល់ឲ្យបង្កើតក្លឹបសុខភាព ដើម្បីលើកទឹកចិត្តឲ្យជៀសវាង មេរោគអេដស៍ តាមរយៈសកម្មភាពរៀនសូត្រដ៏សកម្ម ដូចជាការដើរតួសំដែង ជាដើម ។<br><br><u>ការលើកកម្ពស់ការយល់ដឹង</u>៖ ពាក់កណ្តាលនៃសាលា ដែលទទួលបានការពង្រឹងលើការបណ្តុះបណ្តាលគ្រូបង្រៀន ត្រូវបានលើកទឹកចិត្តឲ្យរៀបចំកិច្ចពិភាក្សាមួយក្នុងឆ្នាំ២០០៥ ។ សិស្សថ្នាក់ទី៧ និងទី៨ទាំងអស់គួរតែបានចូលរួមក្នុងកិច្ចពិភាក្សានេះ។ ការផ្តួចផ្តើមកិច្ចពិភាក្សានេះគឺ៖ "សិស្សសាលាគួរតែត្រូវបានបង្រៀនពីរបៀបប្រើស្រោមអនាម័យ។" បន្ទាប់ពីកិច្ចពិភាក្សាត្រូវបានបញ្ចប់រួចមក ក៏មានការប្រឡងតែងសេចក្តី។ សំណួរតែងសេចក្តី គឺ៖ "ចូរពិភាក្សាអំពីវិធីដែលអ្នកអាចការពារខ្លួនអ្នកមិនឲ្យឆ្លងមេរោគអេដស៍នាពេលនេះ និងនាពេលក្រោយក្នុងជីវិតរបស់អ្នក។" សិស្ស ក៏បានទទួលព័ត៌មានអំពីប្រេវ៉ាឡង់មេរោគអេដស៍ តាមអាយុ និងភេទផងដែរ ។<br><br><u>ឯកសណ្ឋានសាលា</u>៖ ដើម្បីកាត់បន្ថយការចំណាយលើការសិក្សា អង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុកមួយ បានចែកឯកសណ្ឋានដោយឥតគិតថ្លៃដល់សិស្សម្នាក់ៗ ដែលបានចុះឈ្មោះចូលរៀនថ្នាក់ទី៦ (អាយុជាមធ្យម ១៤ឆ្នាំ) ។ គេបានចែកជូនឯកសណ្ឋានប្រហែល ១០.០០០កំប្លេ ។ កុមារ ដែលមកចុះឈ្មោះចូលរៀន ក្នុងអំឡុងឆ្នាំសិក្សាទី២ បានទទួលឯកសណ្ឋានសិស្សមួយកំប្លេទៀត ។ |

| ធាតុផ្សំ | បរិយាយ |
|---|---|
| ការប្រៀប ធៀប | សាលា ដែលបានទទួលអន្តរាគមន៍នេះ ត្រូវបានយកមកប្រៀបធៀបជាមួយសាលាចំនួន៨២ ដែលមិនបានទទួលអន្តរាគមន៍ណាមួយនោះ ។ ជាក់ស្តែង ៩១សាលាបានទទួលត្រឹមតែការបណ្តុះបណ្តាលគ្រូបង្រៀនប៉ុណ្ណោះ។ ៩២សាលា បានទទួលការ បណ្តុះបណ្តាលគ្រូបង្រៀន និងកិច្ចពិភាក្សាអំពីស្រោមអនាម័យ។ ៨៣សាលា បានទទួលត្រឹមតែឯកសណ្ឋានសាលាតែ ប៉ុណ្ណោះ ។ ៩០សាលាបានទទួលការបណ្តុះបណ្តាលគ្រូបង្រៀន និងឯកសណ្ឋានសាលា ហើយ ៩០សាលាទៀតបានទទួលអន្តរាគមន៍ទាំងបី ។ |
| វិធីសាស្ត្រ | ការត្រួតពិនិត្យព្រាវៗលើការបណ្តុះបណ្តាលគ្រូបង្រៀនត្រូវបានធ្វើឡើង ក្រោយពេលចាត់ថ្នាក់តាមរយៈការបែងចែកសាលាតាមភូមិសាស្ត្រ ការបំពេញតួនាទីជាមធ្យមរបស់សាលាទៅលើការប្រឡងសញ្ញាបត្របឋមភូមិឆ្នាំ២០០១នៅប្រទេសកេនយ៉ា និងផលធៀបយេនឌ័រក្នុងចំណោមសិស្សបឋមសិក្សាកម្រិត២ ។<br><br>ការត្រួតពិនិត្យព្រាវៗលើឯកសណ្ឋាន ត្រូវបានធ្វើឡើងបន្ទាប់ពីចាត់ចំណាត់ថ្នាក់ថាតើសាលាបានទទួលការពង្រឹងលើការ បណ្តុះបណ្តាលគ្រូបង្រៀនស្តីពីការអប់រំមេរោគអេដស៍ដែរឬយ៉ាងណា និងតាមរយៈទីតាំងភូមិសាស្ត្រ សមិទ្ធិផលសាលា និងផលធៀបយេនឌ័រ។ ដើម្បីទទួលទិន្នន័យអំពីការចុះឈ្មោះចូលរៀន និងវត្តមានចូលរៀននៅសាលា មន្ត្រីមូលដ្ឋានរបស់អង្គការមិនមែនរដ្ឋាភិបាលបានចុះទៅសាលាចំនួន៦ អំឡុងពេលដែលពួកគាត់ហៅឈ្មោះក្នុងបញ្ជី ដែលបានចុះឈ្មោះនៅក្នុងទិន្នន័យមូលដ្ឋាននិង បានសួរពីទីកន្លែងរស់នៅរបស់សិស្សដែលមិនមករៀននោះ ។ គេប្រើក្របខ័ណ្ឌថយចុះ(regression framework) ធម្មតាមួយ ដើម្បីវាយតម្លៃលើអានុភាពនោះ។ |
| ខ្នាតរង្វាស់ និងលទ្ធផលសំខាន់ៗ | <u>ការនៅរៀនក្នុងសាលា</u>៖ អានុភាពវិជ្ជមាន ។ ការចំណាយទៅលើឯកសណ្ឋានសាលាបានជួយសិស្សឲ្យនៅរៀនបន្តកាន់តែបានយូរថែមទៀត។ អត្រាបោះបង់ការសិក្សាត្រូវបានកាត់បន្ថយ អត្រារៀបការក្នុងវ័យជំទង់ទាបជាងមុន អត្រាមានផ្ទៃពោះ អត្រាមានគតិក្នុងវ័យជំទង់ក៏មានកម្រិតទាបជាងមុនផងដែរ ។ សិស្សស្រីក្នុងសាលា២,៥ ភាគរយ ដែលបានទទួលឯកសណ្ឋានដោយឥតគិតថ្លៃ ទំនងជាមិនបោះបង់សាលានោះទេ ដែលនេះបង្ហាញពីការថយចុះចំនួន ១៥% ។ ចំពោះកុមារា អត្រាបោះបង់សាលា ក៏បានធ្លាក់ចុះចំនួន ១៥% ផងដែរ ។ |

| ធាតុផ្សំ | បរិយាយ |
| --- | --- |
| | លទ្ធផលមិនពាក់ព័ន្ធនឹងការអប់រំ៖ អានុភាពរួមបញ្ចូលគ្នា ។ ក្រោយរយៈពេលពីរឆ្នាំ កម្មវិធីបណ្តុះបណ្តាលគ្រូបង្រៀននេះមានអានុភាពតិចតួចលើចំណេះដឹងរបស់សិស្ស និងសកម្មភាពផ្លូវភេទដែលរាយការណ៍ដោយខ្លួនឯង និងការប្រើប្រាស់ស្រោម អនាម័យ ឬការមានគតិក្នុងវ័យជំទង់ ។ ទោះបីជាយ៉ាងនេះក្តី ការបណ្តុះបណ្តាលគ្រូបង្រៀនបានបង្កើនភាពអត់ធ្មត់របស់កុមារ ចំពោះអ្នកផ្ទុកមេរោគអេដស៍/ជម្ងឺអេដស៍។ ឥទ្ធិពលរួមរបស់កម្មវិធីនេះទៅលើការប្រឈមនឹងមេរោគអេដស៍មានលក្ខណៈមិនច្បាស់លាស់នោះទេ។ |
| **ថ្លៃចំណាយ** | ការតាមដានលើបណ្តុះបណ្តាលគ្រូបង្រៀន និងក្លឹបថៃទាំសុខភាពចំណាយអស់ប្រាក់ចំនួន ៥៥០ដុល្លារសម្រាប់សាលាមួយ។ មិនមានការចំណាយលើកិច្ចពិភាក្សាអំពីស្រោមអនាម័យទេ ។ ឯកសណ្ឋានមានតម្លៃប្រហែល ៦ដុល្លារសម្រាប់សិស្សម្នាក់។ (ដុល្លារឆ្នាំ២០០៣) |
| **ការបណ្តុះបណ្តាលបុគ្គលិក** | មានការបណ្តុះបណ្តាលគ្រូបង្រៀនស្តីពីកម្មវិធីសិក្សាមេរោគអេដស៍ និងជម្ងឺអេដស៍ ។ |

# ១៧. ប្រទេសកេនយ៉ា៖ ប្រាក់លើកទឹកចិត្តគ្រូបង្រៀន

| ធាតុផ្សំ | ការបរិយាយ |
|---|---|
| ការដកស្រង់ពីការសិក្សា | Glewwe, P., Ilias N.,& Kremer, M. (2003). ប្រាក់លើកទឹកចិត្តគ្រូបង្រៀន ។ Cambridge, MA ៖ បន្ទប់ពិសោធន៍សកម្មភាពនៃភាពក្រីក្រ Abdul Latif Jameel (Abdul Latif Jameel Poverty Action Lab) ។ ឯកសារលេខ ១១ ។ |
| សំណួរសិក្សាស្រាវជ្រាវ | តើកម្មវិធីផ្តល់ប្រាក់លើកទឹកចិត្តគ្រូបង្រៀនមានអនុភាពអ្វីខ្លះទៅលើលទ្ធផលរៀនសូត្ររបស់សិស្ស និងឥរិយាបថគ្រូបង្រៀន? |
| អ្នកចូលរួម | សាលាបឋមសិក្សាចំនួន ៥០ (ពីថ្នាក់ទី៤ ដល់ទី៨) |
| ការកំណត់ | ស្រុក ប៊ូសៀ (Busia) និង ស្រុក តេសូ (Teso) ក្នុងប្រទេស កេនយ៉ា ។ |
| អន្តរាគមន៍ | កម្មវិធីនេះ បានផ្តល់ឱកាសដល់សាលា ក្នុងការផ្តល់ប្រាក់បន្ថែមខាងរូបិយវត្ថុ ដល់គ្រូបង្រៀនចាប់ពីថ្នាក់ទី៤ដល់ទី៨ ផ្អែកលើការបំពេញតួនាទីនៅក្នុងសាលាជារួមលើការប្រឡងក្នុងស្រុកនៃឆ្នាំនីមួយៗ ។<br><br>គ្រូបង្រៀនទាំងអស់ ដែលបានបង្រៀនថ្នាក់ទាំងនេះ ក្នុង "សាលាទទួលពិន្ទុខ្ពស់" និងក្នុង "សាលាដែលបានកែលម្អច្រើនបំផុត" បានទទួលប្រាក់បន្ថែម ។ ជារួម រង្វាន់ ត្រូវបានប្រគល់ជូនសាលាចំនួន២៤ ក្នុងចំណោមសាលាចូលរួមចំនួន ៥០ ។ ដោយសារតែស្រុក ប៊ូសៀ (Busia) និង ស្រុក តេសូ (Teso) មានការប្រឡងក្នុងស្រុកដាច់ដោយឡែកពីគ្នា ប្រាក់បន្ថែម ត្រូវបានផ្តល់ជូនដោយឡែកពីគ្នា ក្នុងស្រុកនីមួយៗ ទៅតាមចំណែកនៃចំនួនសាលា ក្នុងស្រុកនេះ ។<br><br>ដើម្បីរារាំងសាលាពីការបង្ខំសិស្សខ្សោយឲ្យរៀនត្រួតថ្នាក់ បោះបង់សាលា ឬមិនចូលរួមប្រឡង សិស្សដែលមិនបានចូលរួមប្រឡង ត្រូវបានផ្តល់ជូនពិន្ទុទាប ។ លើសពីនេះទៀត ដើម្បីរារាំងសាលាពីការជ្រើសរើសសិស្សខ្លាំងឲ្យចូលរួមប្រឡង មានតែសិស្សដែលបាន |

| ធាតុផ្សំ | ការបរិយាយ |
|---|---|
| | ចុះឈ្មោះចូលរៀន ត្រឹមខែកុម្ភៈ ឆ្នាំ១៩៩៨ ប៉ុណ្ណោះ ត្រូវបានដាក់បញ្ចូលក្នុងការគណនាពិន្ទុជាមធ្យមរបស់សាលា ។ |
| ការប្រៀបធៀប | ការប្រៀបធៀប ត្រូវបានធ្វើឡើងរវាងសាលាចំនួន ៥០ ដែលបានទទួលអន្តរាគមន៍ និងសាលាចំនួន៥០ ដែលមិនបានទទួលអន្តរាគមន៍ ។ |
| ការប្រៀបធៀប | ក្នុងចំណោមសាលាចំនួន១០០ ដែលក្រសួងអប់រំ បានជ្រើសរើសថាជាសាលាដែលត្រូវការជំនួយជាពិសេស សាលាចំនួន ៥០ ត្រូវបានជ្រើសរើសដោយចៃដន្យ សម្រាប់ការផ្តល់អន្តរាគមន៍នេះ ស្របពេលដែលសាលាចំនួន៥០ផ្សេងទៀត បានដើរតួនាទីជាក្រុមប្រៀបធៀប ។<br><br>ទិន្នន័យ ត្រូវបានប្រមូល តាមប្រភេទជាច្រើននៃកិច្ចខិតខំប្រឹងប្រែងរបស់គ្រូបង្រៀន ដូចជា វត្តមាន កិច្ចការនៅផ្ទះ បច្ចេកទេសគរុកោសល្យ និងរៀបចំវគ្គសិក្សាត្រៀមប្រលងបន្ថែម ក៏ដូចជា ទិន្នន័យអំពីពិន្ទុតេស្តប្រលងរបស់សិស្ស ក្រោយពេលបញ្ចប់កម្មវិធី ។ កម្មវិធីនេះ បានចាប់ផ្តើមដំណើរការរយៈពេលពីរឆ្នាំ ដោយបានចាប់ផ្តើមក្នុងឆ្នាំ ១៩៩៨ ដែលមានពិន្ទុ ប្រលងឆ្នាំ ១៩៩៦ ត្រូវបានប្រើជាមូលដ្ឋានក្នុងការវាស់ស្ទង់ការរីកចម្រើន ។ |
| វិធីសាស្ត្រ | <u>ការនៅរៀនក្នុងសាលា</u>៖ គ្មានអានុភាព ។ អត្រាបោះបង់សាលា មិនមានការធ្លាក់ចុះក្នុងសាលាដែលមានកម្មវិធីនោះទេ ។<br><br><u>ការរៀនត្រួតថ្នាក់</u>៖ គ្មានអានុភាព។ អត្រារៀនត្រួតថ្នាក់មិនបានធ្លាក់ចុះគួរឲ្យកត់សម្គាល់ក្នុងសាលាផ្តល់ប្រាក់លើកទឹកចិត្តនោះទេ។<br><br><u>ពិន្ទុប្រឡង</u>៖ អានុភាពវិជ្ជមាន ។ សិស្សក្នុងសាលា ដែលមានកម្មវិធីផ្តល់ប្រាក់លើកទឹកចិត្តដល់គ្រូបង្រៀន ទំនងជាចូលរួមប្រឡង និងទទួលបានពិន្ទុខ្ពស់ក្នុងរយៈពេលខ្លីនេះ ។ |

| ធាតុផ្សំ | ការបរិយាយ |
|---|---|
| | <u>វត្តមានគ្រូបង្រៀន</u>៖ គ្មានឥទ្ធិពល ។ គ្រូបង្រៀន ក្នុងសាលាមានកម្មវិធី មិនមានអត្រាវត្តមាន ឬអត្រាកិច្ចការផ្ទះ ខ្ពស់ជាងមុន នោះទេ ។ ទោះបីជាយ៉ាងណាក៏ដោយ ក៏គ្រូបង្រៀនក្នុងសាលាមានកម្មវិធីបានបង្កើនសកម្មភាពរៀបចំតេស្តប្រឡង និងបានលើកទឹកចិត្តសិស្សឲ្យចុះឈ្មោះចូលរៀនក្នុងសាលាដើម្បីចូលរួមធ្វើតេស្តប្រឡង ផងដែរ ។<br><br><u>លទ្ធផលមិនពាក់ព័ន្ធនឹងការអប់រំ</u>៖ ឥរិយាបថគ្រូបង្រៀន (គរុកោសល្យ) មិនមានការខុសគ្នាគួរឲ្យកត់សម្គាល់ រវាងសាលាទទួលប្រាក់លើកទឹកចិត្ត និងសាលាប្រៀបធៀបទេ ។ |
| **ខ្នាតរង្វាស់ និងលទ្ធផលសំខាន់ៗ** | ICS បានផ្តល់ប្រាក់បន្ថែម ដែលមានតម្លៃចាប់ពី ២១ ដល់៤៣% នៃប្រាក់ខែប្រចាំខែគ្រូបង្រៀនធម្មតា ប្រៀបធៀបនឹងកម្មវិធីចំណាយលើលទ្ធផលការងារនៅសហរដ្ឋអាមេរិក ។ |
| **ថ្លៃចំណាយ** | មិនមានការបណ្តុះបណ្តាលបុគ្គលិកទេ ។ |

# ១៨. ប្រទេស កេនយ៉ា៖ ការផ្តល់ជូនសៀវភៅសិក្សា

| ធាតុផ្សំ | ការបរិយាយ |
| --- | --- |
| ការដកស្រង់ពីការសិក្សា | Glewwe, P., Kremer, M., & Moulin, S. (2007) *សិស្សជាច្រើនបានបោះសាលាមែនទេ? សៀវភៅសិក្សា និងពិន្ទុប្រឡងក្នុងប្រទេសកេនយ៉ា* ។ Cambridge, MA ៖ បន្ទប់ពិសោធន៍សកម្មភាពនៃភាពក្រីក្រ Abdul Latif  Jameel ។ |
| សំណួរស្រាវជ្រាវ | តើការផ្តល់ជូនសៀវភៅសិក្សាផ្លូវការបង្កើនលទ្ធផលអប់រំបានច្រើនដូចដែលបានវាស់វែងតាមរយៈពិន្ទុប្រឡងរបស់សិស្សដែរឬទេ? |
| អ្នកចូលរួម | សាលាបឋមសិក្សាដែលទទួលលទ្ធផលទាបចំនួន១០០ ។ |
| ការកំណត់ | Kenya. The Busia and Teso districts in Western Kenya<br>ប្រទេស កេនយ៉ា ។ ស្រុក ប៊ូសៀ (Busia) និង ស្រុក តេសូ (Teso) ក្នុងប្រទេសកេនយ៉ា ។ |
| អន្តរាគមន៍ | ការផ្តល់ជូនសៀវភៅសិក្សាផ្លូវការ៖ ដោយសារតែការចែកសៀវភៅសិក្សា គឺជាការអនុវត្តធម្មតាមួយ ក្នុងប្រទេស កេនយ៉ា សៀវភៅសិក្សា ៦០% ក្នុង ផលធៀបសិស្សម្នាក់ ត្រូវបានផ្តល់ជូនជាភាសាអង់គ្លេស និងវិទ្យាសាស្ត្រ ហើយ ផលធៀប៥០% ផ្នែកគណិតវិទ្យា បានផ្តល់ឲ្យសិស្ស ស្ទើរតែទាំងអស់គ្នា ចែករំលែកការទទួលបានសៀវភៅសិក្សា ។ |
| ការប្រៀបធៀប | ការប្រៀបធៀប ត្រូវបានធ្វើឡើង រវាងក្រុមចំនួនបួន ដែលមានសាលាចំនួន២៥៖ ក្រុមទី១ បានទទួល អន្តរាគមន៍ក្នុងឆ្នាំ ១៩៩៦ ក្រុមទី ២ ក្នុងឆ្នាំ ១៩៩៧ ក្រុមទី៣ ក្នុងឆ្នាំ ១៩ ៩៨ និងក្រុមទី៤ ក្នុងឆ្នាំ ២០០០ ។ ក្នុងឆ្នាំនីមួយៗ សាលាដែលមានកម្មវិធី ត្រូវបានប្រៀបធៀប ជាមួយសាលាដែលមិនទាន់បានទទួល អន្តរាគមន៍កម្មវិធីនេះ ។ |
| វិធីសាស្ត្រ | នៅចុងឆ្នាំ ១៩៩៥ ការិយាល័យស្រុករបស់ក្រសួងអប់រំបានជ្រើសរើសសាលាបឋមសិក្សាចំនួន១០០ក្នុងស្រុក ប៊ូសៀ (Busia) និង |

| ធាតុផ្សំ | ការបរិយាយ |
| --- | --- |
| | ស្រុក តេសូ (Teso) ដើម្បីចូលរួមកម្មវិធីជំនួយសាលា (School Assistance Program (SAP)) ។<br><br>សាលាទាំងនេះ ត្រូវបានជ្រើសរើស ដោយសារសាលាទាំងនេះ ត្រូវបានគេយល់ថាត្រូវការជំនួយ និង (មានករណីលើកលែងមួយ) មិនបានចូលរួមក្នុងកម្មវិធីចែកសៀវភៅសិក្សាលើកមុន ។ មេឌីយ៉ានពិន្ទុតេស្តប្រឡងមធ្យមរបស់សាលា ក្នុងចំណោមសាលា SAP ក្នុងឆ្នាំ ១៩៩៥ មានកម្រិតទាបជាងពិន្ទុតេស្តប្រឡងជាមធ្យម ក្នុងចំណោម សាលាទាំង ៣៣៣ ក្នុងស្រុក ប៊ូសៀ (Busia) និង ស្រុក តេសូ (Teso) ។<br><br>សាលាចំនួន ១០០ ត្រូវបានបែងចែកជាបួនក្រុម ដែលមួយក្រុមមានសាលាចំនួន២៥ ដោយចៃដន្យ ។ ក្រុមមួយ ត្រូវបានជ្រើសរើសឲ្យទទួលសៀវសិក្សា របស់រដ ជាផ្លូវការ នាដើមឆ្នាំ ១៩៩៦ ។ ក្នុងឆ្នាំ ១៩៩៧ មួយក្រុមផ្សេងទៀត ត្រូវបានជ្រើសរើសឲ្យទទួលថវិកាស្មើនឹង ២,៦៥ដុល្លារ សម្រាប់សិស្សម្នាក់ ដើម្បីយកទៅប្រើប្រាស់ក្នុងការទិញសម្ភារៈសិក្សា (រួមបញ្ចូលសៀវភៅសិក្សា ផងដែរ) ។ សាលាក្នុងក្រុមទី៣ និងក្រុមទី៤ បានទទួលថវិកាស្រដៀងគ្នានេះ នាដើមឆ្នាំ ១៩៩៨ និងឆ្នាំ ២០០០ ដោយឡែកៗពីគ្នា ។<br><br>ទម្រង់នៃការប្រឡងក្នុងស្រុក ត្រូវបានប្រគល់ជូនសាលាទាំងអស់ មុនពេលចែកជូនសៀវភៅសិក្សា ហើយពិន្ទុប្រឡងក្នុងស្រុក ត្រូវបានប្រមូល នៅចុងឆ្នាំកម្មវិធីពេលក្រោយ សម្រាប់ធ្វើការប្រៀបធៀបទិន្នន័យ ។ សកម្មភាពក្នុងថ្នាក់រៀន និងអត្រាសិស្សបោះបង់សាលា ក៏ត្រូវបានត្រួតពិនិត្យ ផងដែរ ។ |
| **ខ្នាតរង្វាស់ និងលទ្ធផលសំខាន់ៗ** | <u>ការនៅរៀនក្នុងសាលា</u>៖ គ្មានឥទ្ធិពល ។ គ្មានភស្តុងតាង ដែលបង្ហាញថា ការចែកសៀវភៅសិក្សា បានកាត់បន្ថយការរៀន ត្រួតថ្នាក់ ឬ អត្រាសិស្សបោះបង់សាលា ទេ ។ |

| ធាតុផ្សំ | ការបរិយាយ |
| --- | --- |
| | <u>រៀនបានរីកចម្រើននៅសាលា</u>៖ ឥទ្ធិពលវិជ្ជមាន ។ សៀវភៅសិក្សា បានបង្កើនការរីកចម្រើន ឆ្ពោះទៅសាលាអនុវិទ្យាល័យ សម្រាប់សិស្សថ្នាក់ទី៨ ។<br><br>ចំណុចនេះ បង្ហាញភស្តុតាងថា សម្រាប់សម្មតិកម្មដែលកម្មវិធីនេះ ផ្តល់អត្ថប្រយោជន៍ច្រើនបំផុតដល់សិស្សពូកែៗ ពីព្រោះ មានតែសិស្សពូកែៗទេ បានរៀនដល់ថ្នាក់ទី៨ និងមានសង្ឃឹមរីកចម្រើននៅមធ្យមសិក្សា ស្របពេលដែលសិស្សជាច្រើន រៀនថ្នាក់ទាបជាងនេះ គឺប្រាកដណាស់មិនអាចអានសៀវភៅសិក្សានេះបានទេ ។ សិស្សថ្នាក់ទី៨ ដែលជាក្រុមពូកែខាងការសិក្សា និងបានសំរាំង មាន ៥% ពិន្ទុ ទំនងជាចូលរៀននៅមធ្យមសិក្សា ក្នុងឆ្នាំកម្មវិធីទី២ ជាងសិស្សសាលាប្រៀបធៀប ។<br><br><u>Test score</u>: No effect. After one school year there was no evidence that the textbook provision increased average test scores.<br><u>ពិន្ទុតេស្តប្រឡង</u>៖ គ្មានឥទ្ធិពល ។ ក្រោយរយៈពេលមួយឆ្នាំនៃការសិក្សារួចមក មិនមានភស្តុងតាង ដែលបង្ហាញថា ការផ្តល់សៀវភៅសិក្សានេះ បានបង្កើនពិន្ទុតេស្តប្រឡងជាមធ្យមនោះទេ ។ |
| ថ្លៃចំណាយ | ក្រុមទី២ ទី៣ និងក្រុមទី៤ បានទទួលថវិកា ស្មើនឹង ២,៦៥ដុល្លារ សម្រាប់សិស្សម្នាក់ ឬជាមធ្យមចំនួន ៧២៧ដុល្លារ ក្នុងសាលាមួយ ដែល៤៣%នៃថវិកានេះ ត្រូវបានចំណាយលើសៀវភៅសិក្សា ។ មិនមានការផ្តល់ជូនព័ត៌មានពាក់ព័ន្ធនឹង ការចំណាយលើកម្មវិធី សម្រាប់ក្រុមទី១ ទេ ។ |
| ការបណ្តុះបណ្តាលបុគ្គលិក | Each grade and subject that was given textbooks also received one copy of the associated teacher´s guide.<br>មុខវិជ្ជា និងថ្នាក់នីមួយៗ ដែលទទួលបានសៀវភៅសិក្សា ក៏បានទទួលសៀវភៅមួយក្បាល នៃមគ្គុទ្ទេសក៍របស់ ជំនួយការគ្រូបង្រៀនផងដែរ ។ |

# ១៩. ប្រទេស កេនយ៉ា៖ កម្មវិធីអាហាររូបករណ៍សម្រាប់កុមារី

| ធាតុផ្សំ | ការបរិយាយ |
|---|---|
| ការដកស្រង់ ពីការសិក្សា | Friedman, W., Kremer, M., Miguel, E., and Thornton, R. (2011). *តើការអប់រំជាការរំដោះមែនដែរឬទេ*? Cambridge, MA ៖ បន្ទប់ពិសោធន៍សកម្មភាពនៃភាពក្រីក្រ Abdul Latif  Jameel ។ |
| សំណួរសិក្សាស្រាវជ្រាវ | តើកម្មវិធីអាហាររូបករណ៍ផ្អែកលើលទ្ធផលសិក្សាបង្កើនវត្តមានសិស្ស និងគ្រូបង្រៀនដែរឬទេ? |
| អ្នកចូលរួម | កុមារីថ្នាក់ទី៦ មកពីសាលាបឋមសិក្សាចំនួន៦៩ ដែលត្រូវបានតាមដានរយៈពេល ៤ ទៅ៥ឆ្នាំ ក្រោយពេលទទួលបានអាហារូបករណ៍ ។ |
| ការកំណត់ | ស្រុក ប៊ូសៀ (Busia) និង ស្រុក តេសូ (Teso) ក្នុងប្រទេស កេនយ៉ា ។ ក្មេងស្រី នៅទីកន្លែងនេះ  មិនយកចិត្តទុកដាក់ក្នុងសង្គម ហើយក៏គ្មានអំណាចខាងនយោបាយ ផងដែរ ។ ពួកគេ គឺជាស្ត្រីវ័យក្មេង នៅក្នុងសង្គម ជាទីដែលក្រុមបុរសវ័យចំណាស់ កាន់កាប់សិទ្ធិអំណាច ហើយកុមារីទាំងនេះ មកពីក្រុមជនជាតិភាគតិច Luhya និង Teso ដែលមានភាពទន់ខ្សោយខាងនយោបាយ ។<br><br>ប្រហែល ៨៥% នៃកុមារគ្រប់អាយុចូលរៀនបឋមសិក្សា នៅប្រទេស កេនយ៉ា ភាគខាងលិច បានចុះឈ្មោះចូលរៀនក្នុង សាលា ប៉ុន្តែមានតែ១/៣ នៃចំនួនសិស្សទាំងអស់ប៉ុណ្ណោះ បានបញ្ចប់បឋមសិក្សា ។ អត្រាសិស្សបោះបង់សាលា ជាធម្មតាមានកម្រិតខ្ពស់ជាង សម្រាប់សិស្សស្រី ។ ក្នុងឆ្នាំ ២០០១ អត្រាបោះបង់សាលា សម្រាប់ថ្នាក់ទី៦ មានចំនួន១០% សម្រាប់សិស្សស្រី និង ៧% ភាគរយ សម្រាស់សិស្សប្រុស ។ |
| អន្តរាគមន៍ | កម្មវិធីអាហាររូបករណ៍សម្រាប់កុមារី(GSP) ត្រូវបានអនុវត្ត ដោយកម្មវិធីអន្តរជាតិគាំទ្រកុមារ (ICS) នៅអាហ្វ្រិក ។ កម្មវិធីអាហាររូបករណ៍នេះ បានផ្តល់រង្វាន់ដល់សិស្សស្រីថ្នាក់ទី៦ ក្នុងសាលាអន្តរាគមន៍ដែលលទ្ធផលរៀនសូត្ររបស់ខ្លួនលើការប្រឡងបញ្ចប់ឆ្នាំតាមស្តង់ដាររបស់រដ្ឋាភិបាល បានដាក់ពួកគេនៅលំដាប់កំពូល ១៥% ។ |

| ធាតុផ្សំ | ការបរិយាយ |
| --- | --- |
| **ការប្រៀបធៀប** | ការប្រៀបធៀប ត្រូវបានធ្វើឡើង រវាងសាលាបឋមសិក្សាចំនួន៣៤ (សិស្សចំនួន ១.៦៤០នាក់) ដែលបានទទួលអាហារូបករណ៍ និងសាលាចំនួន៣៥ (សិស្សចំនួន ១.៦៥២នាក់) ដែលមិនបានទទួលអាហាររូបករណ៍ ។ សាលា អន្តរាគមន៍និង គ្មានអន្តរាគមន៍ កម្មវិធីអាហាររូបករណ៍របស់សិស្សស្រី ក្នុងស្រុក ប៊ូសៀ (Busia) មានលក្ខណ:ស្រដៀងគ្នា លើលក្ខណ:សម្គាល់ទិន្នន័យមូលដ្ឋានដែលអាចអង្កេតបាន ដែលបានបង្ហាញថា ការពិនិត្យព្រាវៗនេះត្រូវបានធ្វើឡើងដើម្បីបង្កើតក្រុមស្រដៀងគ្នា ។ |
| **វិធីសាស្ត្រ** | ការជ្រើសរើសព្រាវៗ ទៅក្នុងសាលាទទួលអន្តរាគមន៍ និងសាលាមិនទទួលអន្តរាគមន៍នេះ ត្រូវបានអនុវត្តដោយប្រើម៉ាស៊ីនកំណត់លេខព្រាវតាមកុំព្យូទ័រ បន្ទាប់បែងចែកថ្នាក់លើកទីមួយ តាមរយ:ការបែងចែកផ្នែករដ្ឋបាល និងការចូលរួមក្នុងកម្មវិធីអង្គការមិនមែនរដ្ឋាភិបាលកាលពីពេលមុន ។<br><br>ក្នុងចំណោមសាលាទាំង១២៧ សាលាចំនួន៦៤ ត្រូវបានអញ្ជើញឲ្យចូលរួមក្នុងកម្មវិធីនេះ ។ ដើម្បីវាយតម្លៃលើភាពឋិតថេរនៃលទ្ធផលសិក្សា និងអានុភាពរយ:ពេលវែងផ្សេងទៀតនៃកម្មវិធីនេះ ការអង្កេតតាមដានមួយ ត្រូវបានធ្វើឡើងប្រហែល៤ ទៅ៥ឆ្នាំ ក្រោយពីការប្រកួតប្រជែងកម្មវិធីអាហាររូបករណ៍សម្រាប់កុមារី។<br><br>គំរូតាងវិភាគជាចុងក្រោយ ដែលមានទិន្នន័យអង្កេតមូលដ្ឋាន ពិន្ទុប្រឡងឆ្នាំ២០០១ ឬពិន្ទុតេស្តប្រឡងឆ្នាំ ២០០២ និងទិន្នន័យអង្កេតតាមដាន រួមមានសិស្សស្រីចំនួន១.៣៨៥នាក់ ដែលស្ទើតែមានតុល្យភាព រវាងសាលាទទួលអន្តរាគមន៍ និងសាលាមិនទទួលអន្តរាគមន៍។ |
| **ខ្នាតវង្វាស់ និងលទ្ធផលសំខាន់ៗ** | <u>ការនៅរៀន</u>៖ អានុភាពវិជ្ជមាន ។ សិស្សស្រីក្នុងសាលាទទួលអន្តរាគមន៍ពីគម្រោងចំនួន៧,៨% ទំនងជានៅតែមកចុះឈ្មោះចូលរៀន រយ:ពេល៤ឆ្នាំ ក្រោយពីរង្វាន់អាហាររូបករណ៍លើកដំបូង ។<br><br><u>រៀនបានរីកចម្រើននៅសាលា</u>៖ អានុភាពវិជ្ជមាន ។ សិស្សស្រីដែលបានទទួលអាហាររូបករណ៍ចំនួន ៨,៦% ទំនងជាបានចូល |

| ធាតុផ្សំ | ការបរិយាយ |
|---|---|
| | រៀនយ៉ាងហោចនៅសាលាមធ្យមសិក្សាមួយចំនួ ។<br>ពិន្ទុប្រឡង៖ អានុភាពវិជ្ជមាន ។ កម្មវិធីនេះបានបង្កើនពិន្ទុប្រឡង០,១៩% នៃគម្លាតស្តង់ដារសម្រាប់កុមារី ដែលបានចុះឈ្មោះចូលរៀន មានសិទ្ធិទទួលអាហារូបករណ៍នេះ។ អានុភាពទាំងនេះគឺខ្លាំងបំផុតក្នុងចំណោមសិស្សក្នុងស្រុក ប៊ូសៀ(Busia) ជាស្រុកដែលកម្មវិធីនេះបានបង្កើនពិន្ទុ០,២៧ នៃគម្លាតស្ទង់ដារ។<br><br>មិនមានអានុភាពត្រូវបានរកឃើញនៅក្នុងស្រុក តេសូ (Teso) ទេ ។ ការទទួលបានពិន្ទុតេស្តប្រឡងវិជ្ជមានភាគច្រើន ក៏ត្រូវបានរកឃើញផងដែរក្នុងចំណោមកុមារីក្នុងស្រុក ប៊ូសៀ (Busia) ដែលមានឱកាសតិចតួចក្នុងការទទួលបានរង្វាន់នេះ ដោយលើកឡើងថាមានអានុភាពមកពីខាងក្រៅជាវិជ្ជមានលើការរៀនសូត្ររបស់ពួកគេ។ អានុភាពកម្មវិធីជាមធ្យមសម្រាប់កុមារីនេះឆ្លើយតបទៅនឹងតម្លៃថ្នាក់០,២ បន្ថែមទៀតនៃការរៀនសូត្រថ្នាក់បឋមសិក្សា ហើយការទទួលបាននេះមានរយៈពេលពេញមួយឆ្នាំក្រោយពីការប្រឡងបានបញ្ចប់។<br><br>ក៏មានភស្តុងតាងអំពីអានុភាពខាងក្រៅជាវិជ្ជមាននៃកម្មវិធីមកលើថ្នាក់រៀនទាំងមូលផងដែរ ពោលគឺ កុមារា (ដែលមិនមានសិទ្ធិទទួលរង្វាន់នេះ) បានឃើញមានការកើនពិន្ទុ០,០៨នៃគម្លាតស្តង់ដារលើមធ្យមភាគ ។ |
| **ថ្លៃចំណាយ** | រង្វាន់នេះ រួមមានថវិកាចំនួន ៥០០ KSh (៦,៤០ ដុល្លារ នាពេលនោះ) ដែលត្រូវបានចំណាយឲ្យសាលារបស់កុមារី ដើម្បីរ៉ាប់រងលើថ្លៃសិក្សា ហើយថវិកាជាប្រាក់សុទ្ធចំនួន ១.០០០ KSh (១២,៨០ ដុល្លារ) ត្រូវបានចំណាយឲ្យគ្រួសាររបស់កុមារីដើម្បីទូទាត់ការចំណាយលើការសិក្សាផ្សេងទៀត ក្នុងឆ្នាំនីមួយៗដែលមានរយៈពេលពីរឆ្នាំ បន្ទាប់ពីបានធ្វើការប្រកួតប្រជែង ដែលមានរយៈពេលពីរឆ្នាំចុងក្រោយនៅសាលាបឋមសិក្សា ។ ដូច្នេះ រង្វាន់សរុបសម្រាប់សិស្សទទួលជ័យជំនះ មានតម្លៃជិត៣៨ដុល្លារ ក្នុងរយៈពេលពីរឆ្នាំ ។ |
| **ការបណ្តុះបណ្តាលបុគ្គលិក** | មិនមានការបណ្តុះបណ្តាលបុគ្គលិកទេ ។ |

## ២០. ប្រទេស កេនយ៉ាៈ ការកម្ចាត់ដង្កូវព្រូន

| ធាតុផ្សំ | ការពិណ៌នា |
|---|---|
| ការដកស្រង់ ពីការសិក្សាស្រាវជ្រាវ | Miguel, E. & Kremer, M. (2004). ដង្កូវព្រូន៖ ការកំណត់អានុភាពលើការអប់រំ និងសុខភាព ក្នុងករណីមានអន្តរាគមន៍ពីខាងក្រៅ។ *សេដ្ឋកិច្ចមាត្រសាស្រ្ត* ៧២(១) ១៥៩-២១៧ ។ |
| សំណួរសិក្សាស្រាវជ្រាវ | តើការកម្ចាត់ដង្កូវព្រូនធ្វើឲ្យការចូលរៀន និងលទ្ធផលសិក្សារបស់សិស្សបានប្រសើរឡើងដែរឬទេ? |
| អ្នកចូលរួម | កុមារចំនួន ៣០.០០០នាក់ ដែលមានអាយុចន្លោះពី ៦ ដល់ ១៨ឆ្នាំ មកពីសាលាបឋមសិក្សាជនបទចំនួន៧៥ ។ |
| ការកំណត់ | ប្រទេស កេនយ៉ា។ ស្រុក ប៊ូសៀ (Busia) ភាគខាងត្បូង របស់ប្រទេសនេះ គឺជាតំបន់ក្រីក្រធ្វើស្រែចំការដែលមានប្រជាពលរដ្ឋរស់នៅច្រើនកុះករ។ តំបន់នេះ មានអត្រាឆ្លងព្រូនខ្ពស់បំផុត ។ |
| អន្តរាគមន៍ | ការផ្តល់ឱសថសម្រាប់កុមារ៖ បន្ទាប់ពីមានអនុសាសន៍ពីអង្គការសុខភាពពិភពលោក សាលាដែលមានប្រេវ៉ាឡង់ព្រូនតាមភូមិសាស្រ្តលើសពី៥០ភាគរយ ត្រូវទទួលការព្យាបាលទ្រង់ទ្រាយធំដោយប្រើថ្នាំ albendazole រៀងរាល់៦ខែ ហើយសាលាដែលមានប្រេវ៉ាឡង់ schistosomiasis លើសពី ៣០% ត្រូវទទួលការព្យាបាលទ្រង់ទ្រាយធំដោយប្រើថ្នាំ praziquantel រៀងរាល់ឆ្នាំ។<br><br>សាលាទទួលអន្តរាគមន៍ទាំងអស់ បានឆ្លើយតបនឹងការព្យាបាលផ្តាច់ដង្កូវព្រូនតាមភូមិសាស្រ្ត ទាំងក្នុងឆ្នាំ១៩៩៨ និងឆ្នាំ ១៩៩៩ ហើយសាលាចំនួន១៦ក្នុងចំណោមសាលាទទួលអន្តរាគមន៍២៥ បានឆ្លើយតបនឹងការព្យាបាលផ្តាច់ schistosomiasis ក្នុងឆ្នាំ ១៩៩៩។ បន្ទាប់ពីអនុវត្តតាមស្តង់ដារ ពិធីសារវេជ្ជសាស្រ្តមិនបានអំពាវឲ្យមានទទួលការព្យាបាលកុមារីអាយុ១៣ឆ្នាំ ឬកុមារីអាយុច្រើនជាងនេះនោះទេ ដោយសារតែការព្រួយបារម្ភអំពីអានុភាពដែលមានក្នុងថ្នាំ teratogenicity ។ |

| ធាតុផ្សំ | ការពិណ៌នា |
|---|---|
| | <u>ការអប់រំអំពីការទប់ស្កាត់ដង្កូវព្រូន៖</u> សាលាទទួលអន្តរាគមន៍ក៏បានទទួលការអប់រំអំពីការទប់ស្កាត់ដង្កូវព្រូនផងដែរ តាមរយៈការបង្រៀនផ្នែកសុខភាពសាធារណៈជាប្រចាំ តារាងបិទតាមជញ្ជាំង និងការបណ្តុះបណ្តាលគ្រូបង្រៀន ។ ការអប់រំសុខភាព បានសង្កត់ធ្ងន់ទៅលើសារៈសំខាន់នៃការលាងដៃ ដើម្បីជៀសវាងការឆ្លងព្រូន និងកូនព្រូន whipworm larvae ការពាក់ស្បែកជើងដើម្បីជៀសវាងការឆ្លងព្រូនទំពក់ (hookworm) និងការមិនហែលទឹកដែលមានឆ្លងរោគដើម្បីជៀសវាងឆ្លងជម្ងឺព្រូន schistosomiasis ។ |
| ការប្រៀបធៀប | ការប្រៀបធៀប ត្រូវបានធ្វើឡើងរវាងក្រុមចំនួនបី ដែលក្រុមនីមួយៗមានសាលាចំនួន ២៥ ។ ក្រុមទី១ បានទទួល អន្តរាគមន៍ក្នុងឆ្នាំ ១៩៩៨ និងឆ្នាំ ១៩៩៩ ក្រុមទី២ ក្នុងឆ្នាំ ១៩៩៩ និងក្រុមទី៣ ក្នុងឆ្នាំ ២០០១ ។ ដូច្នេះ ក្នុងឆ្នាំ ១៩៩៨ សាលាក្នុងក្រុមទី១ គឺជាក្រុមអន្តរាគមន៍ស្របពេលដែលក្រុមទី២ និងក្រុមទី៣ គឺជាក្រុមប្រៀបធៀប ។ ក្នុងឆ្នាំ ១៩៩៩ ក្រុមទី១ និងក្រុមទី២ គឺជាក្រុម "ទទួលអន្តរាគមន៍ ចំណែកឯក្រុមទី៣គឺជាក្រុម "ប្រៀបធៀប" ។ |
| វិធីសាស្ត្រ | ជាដំបូង សាលាត្រូវបានចាត់ថ្នាក់ តាមរយៈអង្គភាពរងផ្នែករដ្ឋបាល (តំបន់) និងតាមរយៈការចូលរួមរបស់សាលាក្នុងកម្មវិធីជំនួយដែលមិនមែនរដ្ឋាភិបាលផ្សេងៗទៀត ហើយបន្ទាប់មកទៀតត្រូវបានរៀបតាមអក្សរ ហើយរាល់សាលាទីបីទាំងអស់ត្រូវបានចាត់តាំងទៅក្នុងក្រុមគម្រោងដែលគេបានផ្តល់។<br><br>កម្រងសំណួរសិស្ស និងសាលាត្រូវបានរៀបចំ នៅដើមឆ្នាំ១៩៩៨ និងរៀបចំម្តងទៀត នៅដើមឆ្នាំ១៩៩៩ ។ មុនពេល អន្តរាគមន៍ ក្រុមទាំងនេះមានលក្ខណៈសម្គាល់ស្រដៀងគ្នាទាំងផ្នែកប្រជាសាស្ត្រ សេដ្ឋកិច្ចសង្គម និងអាហារូបត្ថម្ភ ប៉ុន្តែ ទោះបីជាមានការចាត់តាំងព្រាវៗ ដែលបានបង្កើតក្រុមដែលមានលក្ខណៈសម្គាល់ស្រដៀងគ្នាក៏ដោយ ក៏សិស្សក្នុងក្រុមទី១ ទំនងជាមានស្ថានភាពអន់ខ្សោយជាងសិស្សក្នុងក្រុមទី២ និងទី៣ ជាមួយនឹងវិសាលភាពមួយចំនួន ដែលឲ្យមានការលំអៀងយ៉ាងខ្លាំងទៅលើការរកឃើញអានុភាពកម្មវិធីដ៏សំខាន់ៗ។<br><br>មិនមានភាពខុសគ្នាសំខាន់ៗក្នុងស្ថិតិនៅក្នុងសាលាក្រុមទី១ ក្រុមទី២ និងក្រុមទី៣ ពាក់ព័ន្ធនឹងការចុះឈ្មោះចូលរៀន ចម្ងាយទៅកាន់ |

| ធាតុផ្សំ | ការពិណ៌នា |
|---|---|
| | តំបន់ ឡេកវិកធូរៀ (Lake Victoria) បង្កន់អនាម័យនៅសាលា ទម្ងន់ត្រូវនឹងអាយុរបស់សិស្ស កម្មសិទ្ធិផ្ទាល់ខ្លួនចំនួន១០ ការរាយការណ៍ពីជម្ងឺគ្រុនចាញ់ដោយខ្លួនឯង ឬដង់ស៊ីតេនៃចំនួនសិស្សសាលាបឋមសិក្សាផ្សេងៗទៀត ដែលមានទីតាំង នៅក្នុងចម្ងាយរវាង ៣គីឡូម៉ែត្រ ឬក៏ពី ៣ទៅ៦គីឡូម៉ែត្រ ។<br><br>អត្រាឆ្លងព្រូន ក្នុងតំបន់ភូមិសាស្ត្រជុំវិញ ក៏ស្មើតែមានលក្ខណៈដូចគ្នាសុទ្ធសាធផងដែរនៅក្នុងក្រុមទាំងបីនេះ។ អត្រាវត្តមានចូលរៀនក្នុងសាលាមិនមានការខុសគ្នាគួរឲ្យកត់សម្គាល់អ្វីទេ នៅដើមឆ្នាំ ១៩៩៨ មុនពេលមានអន្តរាគមន៍ឱសថ ក្នុងដំណាក់កាលទី១ បើទោះបីជាព័ត៌មានអំពីការចូលរៀនមូលដ្ឋាននេះបានមកពីបញ្ជីសាលា ដែលត្រូវបានចាត់ទុកថា មិនអាចជឿជាក់បានយ៉ាងណាក៏ដោយ ។<br><br>ការពិនិត្យព្រាវៗនៃអន្តរាគមន៍កម្ចាត់ដង្កូវព្រូន នៅទូទាំងសាលា បានផ្តល់ឲ្យនូវការប៉ាន់ស្មានអំពីឥទ្ធិពលរួមនៃកម្មវិធីនេះ ដោយការប្រៀបធៀបសាលាទទួលអន្តរាគមន៍ និងសាលាប្រៀបធៀប បើទោះជាមានផលប៉ះពាល់ខាងក្រៅសាលា យ៉ាងណាក៏ដោយ ។<br><br>ការសិក្សានេះបានប៉ាន់ស្មានលើអានុភាពខាងក្រៅនៅគ្រប់សាលា តាមរយៈការទាញយកអត្ថប្រយោជន៍ពីបម្រែបម្រួលក្នុងដង់ស៊ីតេមូលដ្ឋានរបស់សាលាទទួលអន្តរាគមន៍ដែលនាំឲ្យមានការត្រួតពិនិត្យព្រាវៗ។ ថ្វីត្បិតតែការត្រួតពិនិត្យព្រាវៗនៅតាមសាលាបានបង្កលក្ខណៈងាយស្រួលក្នុងការកំណត់អានុភាពកម្មវិធីជារួម និងអានុភាពខាងក្រៅនៅគ្រប់សាលាដោយផ្អែកលើការពិសោធន៍ក៏ដោយ ក៏ការសិក្សានេះបានពឹងផ្អែកលើវិធីសាស្ត្រមិនមែនពិសោធន៍ ដើម្បីបែងចែកអានុភាពទៅលើសាលា ដែលទទួលបានអន្តរាគមន៍ ទៅជាអានុភាពផ្ទាល់ និងអានុភាពពីខាងក្រៅនៅក្នុងសាលា។ |
| **ខ្នាតវង្វាស់ និងលទ្ធផលសំខាន់ៗ** | ការចូលរៀន៖ អានុភាពវិជ្ជមាន ។ ការកើនឡើងនៃការចូលរៀនជាមធ្យមសម្រាប់សាលាទទួលអន្តរាគមន៍ ធៀបនឹងសាលាប្រៀបធៀបទាំងពីរឆ្នាំនៃគម្រោងនេះមានចំនួន ៥,១ ភាគរយ ដោយបានកាត់បន្ថយអវត្តមានក្នុងសាលាទាំងមូល យ៉ាងហោច មួយភាគបួន ដែលមានការកើនឡើងដ៏ច្រើនជាពិសេសក្នុងចំណោមកុមារក្មេងបំផុត ។ |

| ធាតុផ្សំ | ការពិណ៌នា |
|---|---|
| | អានុភាពធំជាងនេះចំពោះកុមារតូចៗ អាចដោយសារតែមានអត្រាខ្ពស់ជាងមុននៃការឆ្លងជម្ងឺពីកម្រិតមធ្យមទៅធ្ងន់ធ្ងរ ។ ក៏មានអានុភាពដ៏ធំមួយទៅលើការកាត់បន្ថយអវត្តមានច្រើនរបស់កុមារា និងកុមារីតូចៗ ដែលផ្ទុយគ្នានឹងកុមារីធំៗ ស្របទៅតាមអន្តរាគមន៍ខុសគ្នា ។<br><br>ប៉ុន្តែ ក៏មានអានុភាពសំខាន់ៗសម្រាប់កុមារីធំៗផងដែរ ដែលប្រហែលជាអាចដោយសារតែការចូលរៀនប្រសើរជាងមុនរបស់ កុមារតូចៗទាំងនេះបានធ្វើឲ្យពួកគេចូលរៀនបានកាត់តែទៀងទាត់ថែមទៀត ។<br><br>ពិន្ទុប្រលង៖ គ្មានអានុភាព ។ មិនមានភស្តុតាងបញ្ជាក់ថា ការកម្ចាត់ដង្កូវព្រូនបានបង្កើនពិន្ទុប្រឡងរបស់សិស្សនោះទេ ។<br><br>លទ្ធផលមិនពាក់ព័ន្ធនឹងការអប់រំ៖ អានុភាពវិជ្ជមាន ។ ក្រោយពីមានអន្តរាគមន៍មក  អត្រាឆ្លងបានថយចុះ ។ អត្រាឆ្លងនៅចុងឆ្នាំទី១ មានចំនួន ២៧ភាគរយក្នុងក្រុមទី១ (អន្តរាគមន៍) និង ៥២ភាគរយក្នុងក្រុមទី២ (ប្រៀបធៀប) ។ លទ្ធផលសុខភាពផ្សេងៗទៀត (តាមរបាយការណ៍ស្តីពីជម្ងឺ និង ជម្ងឺស្លេកស្លាំង) មានលក្ខណៈប្រសើរជាងមុននៅក្នុងក្រុមទទួលអន្តរាគមន៍។ |
| ថ្លៃចំណាយ | ការចំណាយលើការព្យាបាលក្នុងមួយឆ្នាំ គឺ ៣,៥០ ដុល្លារ (ដុល្លារ ក្នុងឆ្នាំ១៩៩៩) |
| ការបណ្តុះបណ្តាលបុគ្គលិក | គ្រូបង្រៀនមកពីសាលាទទួលអន្តរាគមន៍ពីគម្រោងបានទទួលការបណ្តុះបណ្តាលអំពីរបៀបទប់ស្កាត់ដង្កូវព្រូន ។ |

# ២១. ប្រទេសម៉ាដាហ្គាស្កា៖ ការគ្រប់គ្រងលើការអប់រំថ្នាក់បឋមសិក្សា

| ធាតុផ្សំ | ការបរិយាយ |
|---|---|
| ការដកស្រង់ពីអត្ថបទសិក្សាស្រាវជ្រាវ | Nguyen, T. & Lassibille, G. (2008). *ការកែលម្អការគ្រប់គ្រងក្នុងវិស័យអប់រំ៖ ភស្តុតាងពីការធ្វើពិសោធន៍ព្រាវៗក្នុងប្រទេសម៉ាដាហ្គាស្កា* ។ Cambridge, MA: បន្ទប់ពិសោធន៍សកម្មភាពនៃភាពក្រីក្រ Abdul Latif Jameel ។ |
| សំណួរសិក្សាស្រាវជ្រាវ | តើការលើកស្ទួយពីលើចុះក្រោម និងការតាមដានមូលដ្ឋានរបស់សាលា អាចធ្វើឲ្យគុណភាព និងទិន្នផលអប់រំប្រសើរឡើងដែរឬទេ? |
| អ្នកចូលរួម | រដ្ឋបាលស្រុក និងអនុស្រុក និងគ្រូបង្រៀនមកពីសាលាបឋមសិក្សាចំនួន៣.៧៧៤ នៅក្នុងស្រុកដែលមានសាលារដ្ឋចំនួន៣០ផ្តោតការយកចិត្តទុកដាក់ទៅលើសាលាមានអត្រារៀនត្រួតថ្នាក់ខ្ពស់ជាងមុន ។ |
| ការកំណត់ | ប្រទេស ម៉ាដាហ្គាស្កា៖ គ្រប់តំបន់ទីតាំងភូមិសាស្ត្រទាំងអស់នៅក្នុងប្រទេសនេះ ។ |
| អន្តរាគមន៍ | <u>អន្តរាគមន៍ថ្នាក់ស្រុក</u>៖ ក្នុងស្រុកទទួលអន្តរាគមន៍ពីគម្រោងទាំង១៥ រដ្ឋបាលស្រុកបានទទួលឧបករណ៍ប្រតិបត្តិការ និងការបណ្តុះបណ្តាល ដែលរួមមានទម្រង់សម្រាប់ទស្សនកិច្ចត្រួតពិនិត្យសាលារៀន ឯកសារលទ្ធកម្មសម្រាប់បរិក្ខារសាលារៀន និងជំនួយ។<br><br><u>អន្តរាគមន៍ថ្នាក់អនុស្រុក</u>៖ នៅក្នុងអនុស្រុកដែលបានជ្រើសរើសព្រាវៗ បុគ្គលិកក៏ទទួលបានឧបករណ៍ និងការបណ្តុះបណ្តាលផងដែរ ។<br><br><u>អន្តរាគមន៍ថ្នាក់សាលា</u>៖ ក្នុងសាលាដែលបានជ្រើសរើសព្រាវៗនៅក្នុងអនុស្រុក គ្រូបង្រៀនបានទទួលឧបករណ៍រដ្ឋបាល និងគរុកោសល្យ (ឧទាហរណ៍ដូចជា ការធ្វើផែនការមេរៀន ការចូលរៀន និងការរីកចម្រើនរបស់សិស្ស) ហើយឪពុកម្តាយសិស្សបានចូលរួមក្នុងការតាមដានសកម្មភាពសាលាពាក់ព័ន្ធនឹងកិច្ចប្រជុំសាលា ដែលបានផ្តល់ឲ្យឪពុកម្តាយសិស្សនូវ "ប័ណ្ណរាយការណ៍" និងបានឲ្យពួកគេធ្វើការអ្វីមួយរួមគ្នាទាក់ទិននឹងការអប់រំក្នុងភូមិ ។ |

| ធាតុផ្សំ | ការបរិយាយ |
|---|---|
| ការប្រៀបធៀប | ការប្រៀបធៀប ត្រូវបានធ្វើឡើងជាមួយសាលាចំនួន១.៧២១ ចេញពីអនុស្រុកចំនួន ២០៧ ក្នុងស្រុកចំនួន១៥ ដែលមិនបានទទួលអន្តរាគមន៍ណាមួយនោះទេ ។ អានុភាពនៃអន្តរាគមន៍ពីលើចុះក្រោមតែមួយធៀបនឹងការបូកបញ្ចូលគ្នាជាមួយ គណនេយ្យភាពមូលដ្ឋាន ក៏ត្រូវបានធ្វើការប្រៀបធៀបផងដែរ ។ |
| វិធីសាស្ត្រ | ទិន្នន័យចូលរៀនរបស់សិស្ស ត្រូវបានប្រមូលអំឡុងពេលការចុះត្រួតពិនិត្យដោយមិនបានជូនដំណឹងជាមុន និងពិន្ទុប្រឡងរបស់សិស្សចេញពីការប្រឡងសមិទ្ធិផលសិក្សាដែលត្រូវបានគ្រប់គ្រងដោយឯករាជ្យ ។ បន្ថែមពីលើការចុះពិនិត្យអវត្តមានគ្រូបង្រៀន និងសិស្សដល់កន្លែង នាយកសាលា និងគ្រូបង្រៀនត្រូវបានសម្ភាសអំពីការប្រើប្រាស់ឧបករណ៍ និងការអនុវត្តខាងគរុកោសល្យ និងរដ្ឋបាលរបស់ពួកគាត់ ។ |
| ខ្នាតវង្វាស់ និងលទ្ធផលសំខាន់ៗ | <u>ចូលរៀន (អន្តរាគមន៍ថ្នាក់សាលា)</u>៖ អានុភាពវិជ្ជមាន ។ កើនឡើង៤,៣ ភាគរយក្នុងវត្តមានចូលរៀនជាមធ្យម។<br><br><u>ពិន្ទុប្រឡង (អន្តរាគមន៍ថ្នាក់សាលា)</u>៖ អានុភាពវិជ្ជមាន ។ ពិន្ទុប្រឡងរបស់សិស្សក្នុងក្រុមនេះ មាន ០,១ នៃ គម្លាតស្តង់ដារខ្ពស់ជាងពិន្ទុប្រឡងរបស់សិស្សក្នុងក្រុមសម្រាប់ប្រៀបធៀប ។<br><br><u>ឥរិយាបថរបស់រដ្ឋបាលស្រុក និងអនុស្រុក៖ អានុភាពជាអប្បបរមា</u> ។ ទោះបីជាឧបករណ៍នីមួយៗត្រូវបានប្រើដោយចៅហ្វាយស្រុករង៩០% និងជាងពាក់កណ្តាលដោយចៅហ្វាយស្រុកក៏ដោយ ក៏ជាមធ្យមពួកគាត់មិនបានចូលរួមសកម្មជាមួយឪពុកម្តាយ និងសហគមន៍មូលដ្ឋានក្នុងការពិនិត្យតាមដានសាលានោះទេ ។<br><br><u>ការរៀបចំផែនការមេរៀនរបស់គ្រូបង្រៀន (អន្តរាគមន៍ថ្នាក់សាលា)</u>៖ អានុភាពវិជ្ជមាន ។ គ្រូបង្រៀនបានរៀបចំផែនការមេរៀននិងបានវាយតម្លៃសិស្សរបស់ខ្លួន កាន់តែញឹកញាប់ជាមុន ។ ការអនុវត្តកិច្ចតែងការរបស់គ្រូបង្រៀនបានកែលម្អ០,២៦ នៃគម្លាតស្តង់ដារជាមធ្យម ហើយការអនុវត្តការវាយតម្លៃសិស្សបានកែលម្អ ០,១៤ នៃគម្លាតស្តង់ដា ។ |

| ធាតុផ្សំ | ការបរិយាយ |
| --- | --- |
| | ឥរិយាបថគ្រូបង្រៀនផ្សេងៗទៀត(អន្តរាគមន៍ថ្នាក់សាលា)៖ គ្មានអានុភាព ។ វត្តមានគ្រូបង្រៀន និងទំនាក់ទំនងរបស់សាលា ជាមួយឪពុកម្តាយមិនបានប្រសើរឡើងទេ ។ |
| **ថ្លៃចំណាយ** | គ្មានព័ត៌មានអំពីថ្លៃចំណាយ។ |
| **ការបណ្តុះបណ្តាលបុគ្គលិក** | មន្ត្រីស្រុក និងអនុស្រុកបានទទួលការបណ្តុះបណ្តាលស្តីពីឧបករណ៍ប្រតិបត្តិការ។ គ្រូបង្រៀនបានទទួលការបណ្តុះបណ្តាលស្តីពីឧបករណ៍រដ្ឋបាល និងគរុកោសល្យ ។ |

## ២២. ប្រទេស ម៉ាឡាវី៖ កម្មវិធីផ្ទេរប្រាក់មានលក្ខខ័ណ្ឌ

| ធាតុផ្សំ | ការបរិយាយ |
|---|---|
| ការដកស្រង់ពីអត្ថបទសិក្សាស្រាវជ្រាវ | Baird, S., McIntosh, C.,& özler, B. (2009). *ការរៀបចំកម្មវិធីផ្ទេរប្រាក់មានល័ក្ខខ័ណ្ឌដែលមានប្រសិទ្ធភាពខាងការចំណាយដើម្បីលើកស្ទួយការសិក្សា ក្នុងចំណោមស្ត្រីក្មេងៗ ក្នុងអនុតំបន់ សាហារ៉ាន (sub-Saharan) ទ្វីបអាហ្វ្រិក* ។ ឯកសារការងារសិក្សាស្រាវជ្រាវគោលនយោបាយធនាគារពិភពលោក ៥០៩០ ។ |
| សំណួរសិក្សាស្រាវជ្រាវ | តើកុមារីដែលទទួលការផ្ទេរប្រាក់មានល័ក្ខខ័ណ្ឌនៅរៀនបន្តក្នុងសាលាដែរឬទេ?<br>តើកុមារីដែលបានឈប់រៀន ចូលរៀនវិញដែរឬទេ នៅពេលពួកគេបានទទួលការផ្ទេរប្រាក់ដែរឬទេ? |
| អ្នកចូលរួម | ការសិក្សានេះបានចាប់ផ្តើមជាមួយគំរូតាងនៃកុមារីចំនួន៣.៨០៥នាក់ មានអាយុនៅចន្លោះពី១៣ ដល់២២ឆ្នាំ (មិនធ្លាប់រៀបការ) ដែលបានចាត់តាំងកុមារីចំនួន១.២២៥នាក់ទៅក្នុងក្រុមទទួលអន្តរាគមន៍ពីគម្រោង។<br><br>នៅចុងឆ្នាំ កុមារីសរុបចំនួន៣.៥៩៥នាក់ ត្រូវបានជ្រើសរើសសម្រាប់ការអង្កេតតាមដានមួយ ដែលក្នុងនោះកុមារីចំនួន១.១៩១ នាក់ស្ថិតក្នុងក្រុមទទួលអន្តរាគមន៍។ ក្រុមកុមារីទទួលអន្តរាគមន៍ពីគម្រោង មានកុមារីដែលបានបោះបង់សាលារួចហើយ (សិស្សបោះបង់សាលានៅទិន្នន័យមូលដ្ឋាន) និងកុមារីដែលនៅរៀនក្នុងសាលា នៅទិន្នន័យមូលដ្ឋាន (កុមារីនៅទិន្នន័យមូលដ្ឋាន) ។ ចំពោះគម្រោង SDPP មានតែលទ្ធផលសម្រាប់កុមារីនៅក្នុងទិន្នន័យមូលដ្ឋានប៉ុណ្ណោះ ដែលជាចំណាប់អារម្មណ៍ ។ |
| ការកំណត់ | <u>**ម៉ាឡាវី**</u>៖ ហ្សុមបា (Zomba) ត្រូវបានជ្រើសរើសជាទីកន្លែងសម្រាប់ការសិក្សានេះ សម្រាប់ហេតុផលមួយចំនួនដូចខាងក្រោម៖<br>• វាមានចំនួនប្រជាជនច្រើនល្មមនៅក្នុងតំបន់ភូមិសាស្ត្រតូចល្មមមួយ ដែលបង្កលក្ខណៈកាន់តែងាយស្រួលដល់ភស្តុភារការងារមូលដ្ឋាន និងធ្វើឲ្យការចំណាយលើការដឹកជញ្ជូនកាន់តែទាប ។<br>• វា គឺជាស្រុកមួយដែលមានចំនួនប្រជាជនខ្ពស់ជាងគេ ប៉ុន្តែចម្ងាយពីទីក្រុងក្នុងស្រុក (ក្រុង ហ្សុមបា Zomba Town) គឺនៅជិត។<br>• ហ្សុមបា មានអត្រាសិស្សបោះបង់សាលាខ្ពស់ និងអត្រាទទួលបានការអប់រំមានកម្រិតទាប ។ យោងតាម IHS-២ (២០០៤) បានឲ្យដឹងថា មូលហេតុចម្បងបំផុតនៃការបោះបង់សាលាគឺបញ្ហាហិរញ្ញវត្ថុ ។ |

| ធាតុផ្សំ | ការបរិយាយ |
|---|---|
| | • អត្រាមេរោគអេដស៍/ជម្ងឺអេដស៍របស់ស្ត្រី ដែលមានអាយុចាប់ពី ១៥ឆ្នាំ ដល់៤៩ឆ្នាំ មានកម្រិតខ្ពស់បំផុតនៅក្នុងប្រទេសនេះ គឺ ២៤,៦% (MDHS,២០០៤)។<br><br>គំរូតាង ត្រូវបានដកស្រង់ចេញពីតំបន់ចំនួនបី មានជាអាទិ៍ តំបន់ទីប្រជុំជន តំបន់ជនបទជិតក្រុង ហ្សុមបា (Zomba Town) និងតំបន់ជនបទឆ្ងាយពីក្រុង ហ្សុមបា (Zomba Town) ។ |
| អន្តរាគមន៍ | ការផ្ទេរប្រាក់មានល័ក្ខខ័ណ្ឌ៖ ប្រាក់លើកទឹកចិត្ត (ដូចជាការបង់ថ្លៃសិក្សា និងការផ្ទេរប្រាក់) ត្រូវបានផ្តល់ទៅឲ្យកុមារី នៅពេលបច្ចុប្បន្ននេះ និងស្ត្រីវ័យក្មេង ដែលបានបោះបង់សាលានាពេលថ្មីៗ ដើម្បីឲ្យនៅរៀនបន្ត ឬចូលរៀនវិញ ។<br><br>ការបង់ប្រាក់ទាំងនេះ រួមមានសាច់ប្រាក់ដែលបានផ្ទេរឲ្យឪពុកម្តាយ សាច់ប្រាក់ផ្ទេរឲ្យកុមារីដោយផ្ទាល់ និងការបង់ប្រាក់ផ្ទាល់ទៅលើថ្លៃសិក្សាសម្រាប់កុមារីក្នុងគោលបំណងទទួលអន្តរាគមន៍តាមល័ក្ខខ័ណ្ឌ ដើម្បីឲ្យពួកគេចូលរៀនសាលាមធ្យមសិក្សា។<br><br>ជាផ្នែកមួយនៃកម្មវិធីនេះ ការចូលរៀនរបស់អ្នកទទួលការផ្ទេរប្រាក់មានល័ក្ខខ័ណ្ឌទាំងអស់ ត្រូវបានត្រួតពិនិត្យរៀងរាល់ខែ ហើយការបង់ប្រាក់សម្រាប់ខែបន្ទាប់ត្រូវបានកាត់ចេញ ចំពោះសិស្សណាម្នាក់ ដែលមានអត្រាចូលរៀនទាបជាង៧៥%ក្នុងខែ មុន ។ មិនមានការត្រួតពិនិត្យលើវត្តមានចូលរៀនរបស់អ្នកទទួលអន្តរាគមន៍ដោយគ្មានល័ក្ខខ័ណ្ឌនោះទេ ។ |
| ការប្រៀបធៀប | ការប្រៀបធៀប ត្រូវបានធ្វើឡើងរវាងក្រុមទទួលអន្តរាគមន៍ពីគម្រោងដែលបានទទួលការផ្ទេរប្រាក់មានល័ក្ខខ័ណ្ឌ ក្រុមផ្សេងទៀតដែលបានទទួលការផ្ទេរប្រាក់គ្មានល័ក្ខខ័ណ្ឌ និងក្រុមមិនទទួលអន្តរាគមន៍ពីគម្រោងដែលមិនបានទទួលការផ្ទេរប្រាក់ ។ |
| វិធីសាស្ត្រ | គំរូតាងនៃតំបន់រាយឈ្មោះចំនួន ១៧៦ (Enumeration Areas) (EAs) ត្រូវបានដកស្រង់ព្រាវៗចេញពីតំបន់ EA សរុបចំនួន៥៥០ ក្នុងស្រុក ហ្សុមបា (Zomba) ហើយស្ថានភាពទទួលអន្តរាគមន៍នេះត្រូវបានចាត់ចែងនៅថ្នាក់ EA ។ EA ដែលបានជ្រើសរើស ចំនួន១៧៦ ត្រូវបានបែងចែកជាពីរក្រុមស្មើគ្នាគឺ ក្រុមទទួលអន្តរាគមន៍ពីគម្រោង និងក្រុមមិនទទួលអន្តរាគមន៍ពីគម្រោង ។ |

| ធាតុផ្សំ | ការបរិយាយ |
|---|---|
| | លើសនេះទៅទៀត កុមារីនៅក្នុងទិន្នន័យមូលដ្ឋានក្នុង EA ដែលទទួលអន្តរាគមន៍ពីគម្រោងនីមួយៗ ត្រូវបានចាត់តាំងព្រាវៗឲ្យទទួលការផ្ទេរប្រាក់មានល័ក្ខខ័ណ្ឌ ឬក៏ការផ្ទេរប្រាក់គ្មានល័ក្ខខ័ណ្ឌ។ ក្នុង EA ដែលទទួលអន្តរាគមន៍ពីគម្រោង សិស្សបោះបង់សាលានៅក្នុងទិន្នន័យមូលដ្ឋានទាំងអស់បានទទួលការផ្ទេរប្រាក់មានល័ក្ខខ័ណ្ឌ ។<br><br>គំរូតាងនៃ EA ដែលទទួលអន្តរាគមន៍ពីគម្រោងចំនួន៨៨ ត្រូវបានបែងចែកជាបីក្រុម ដោយផ្អែកលើស្ថានភាពទទួលអន្តរាគមន៍ពីគម្រោងរបស់កុមារីនៅក្នុងទិន្នន័យមូលដ្ឋាន ។ ក្នុង EA ចំនួន៤៦ ការកំណត់ព្រាវៗលើចំណែករបស់កុមារី បានទទួលការផ្ទេរប្រាក់មានល័ក្ខខ័ណ្ឌ ។ ក្នុង EA ចំនួន២៧ ការកំណត់ព្រាវៗលើចំណែករបស់កុមារីបានទទួលការផ្ទេរប្រាក់គ្មានល័ក្ខខ័ណ្ឌ ហើយក្នុង EA ដែលនៅសល់ចំនួន១៥ មានតែសិស្សបោះបង់សាលានៅក្នុងទិន្នន័យមូលដ្ឋានប៉ុណ្ណោះទើបបានទទួលអន្តរាគមន៍ពីគម្រោង ចំណែកឯកុមារីក្នុងទិន្នន័យមូលដ្ឋានមិនបានទទួលការផ្ទេរប្រាក់នោះទេ ។<br><br>ក្នុង EA ដែលបានជ្រើសរើសនីមួយៗ សិស្សបោះបង់សាលាដែលមានសិទ្ធិទាំងអស់ និងពី៧៥% ទៅ១០០% នៃកុមារីដែលមានសិទ្ធិត្រូវបានយកមកសាកល្បដែលភាគរយនោះអាស្រ័យលើអាយុរបស់កុមារីនៅក្នុងទិន្នន័យមូលដ្ឋាន ។<br><br>ដើម្បីប៉ាន់ស្មានអានុភាពរបស់កម្មវិធីនេះ ការសិក្សានេះបានប៉ាន់ស្មានការថយចុះនៃភាពខុសគ្នាមួយទៅភាពខុសគ្នាមួយទៀតដោយការប្រើប្រាស់អានុភាពថេរនីមួយៗ។ គេថ្លឹងថ្លែងការថយចុះនេះជាតំណាងឲ្យការសិក្សាស្រាវជ្រាវEA។ |
| ខ្នាតវង្វាស់ និងលទ្ធផលសំខាន់ៗ | លទ្ធផលសម្រាប់កុមារីនៅក្នុងទិន្នន័យមូលដ្ឋាន មានដូចខាងក្រោមៈ<br><br><u>ការចូលរៀនពាក់ព័ន្ធនឹងទំហំនៃការផ្ទេរប្រាក់</u>៖ គ្មានអានុភាព ។ "មិនមានភស្តុតាងបញ្ជាក់ថា ការកើនឡើងនៃទំហំផ្ទេរប្រាក់សរុបមានអានុភាពខ្លាំងទៅលើការចូលរៀនឲ្យលើសពីការទទួលទំហំផ្ទេរប្រាក់អប្បបរមានោះទេ ។" |

| ធាតុផ្សំ | ការបរិយាយ |
| --- | --- |
| | ការនៅរៀន៖ អានុភាពវិជ្ជមានតិចតួច ។ "អានុភាពនៃអន្តរាគមន៍ការបោះបង់សាលារយៈពេលមួយឆ្នាំចំនួន៩,៦ភាគរយ បានបង្ហាញពីការថយចុះជាង៩០%នៃសិស្សបោះបង់សាលាពីអត្រានៃក្រុមមិនទទួលអន្តរាគមន៍ពីគម្រោង១០,៩%។"<br><br>អក្ខរកម្មភាសាអង់គ្លេស៖ អានុភាពវិជ្ជមានមួយចំនួន ។ "ក្នុងចំណោមកុមារីនៅក្នុងទិន្នន័យមូលដ្ឋាន អានុភាពទាំងនេះត្រូវបានគេឃើញមាននៅកម្រិតថ្នាក់ទាបបំផុតប៉ុណ្ណោះ (ស្តង់ដារទី៥ និង៦) ហើយក្រោយមក អក្ខរកម្មបានសម្រេចកម្រិតខ្ពស់ល្មម ដែលមិនមានអានុភាពអន្តរាគមន៍ផ្នែកខាងលើណាមួយត្រូវបានគេរកឃើញនោះទេ។"<br><br>ការបញ្ចប់ការសិក្សា៖ គ្មានអានុភាព ។ "មិនមានអានុភាពគួរឲ្យកត់សម្គាល់នៅក្នុងស្ថិតិក្នុងចំណោមកុមារីនៅក្នុងទិន្នន័យមូលដ្ឋាននោះទេ។" |
| ថ្លៃចំណាយ | ចំនួនទឹកប្រាក់ដែលត្រូវផ្តល់ជូនឪពុកម្តាយ ត្រូវបានជ្រើសរើសព្រាវៗចាប់ពី ៤ ដុល្លារ ដល់១០ដុល្លារក្នុងមួយខែ ដែលអ្នកទទួលទាំងអស់នៅក្នុង EA បានទទួលចំនួនប្រាក់ស្មើគ្នា ។ ចំនួនទឹកប្រាក់ផ្ទេរម្នាក់ៗត្រូវបានកំណត់ដោយការចាប់ឆ្នោត ជាពិសេសនៅពេលដែលកុមារីបានជ្រើសរើសលេខចេញពីស្រោមសំបុត្រដើម្បីឈ្នះទឹកប្រាក់ពី១ដុល្លារ ដល់៥ដុល្លារក្នុងមួយខែ ។ ការផ្ទេរប្រាក់ ធ្វើឡើងជារៀងរាល់ខែ ។ (ដុល្លារ ក្នុងឆ្នាំ ២០០៨) |
| ការបណ្តុះបណ្តាលបុគ្គលិក | គេមិនបានផ្តល់ការបណ្តុះបណ្តាលបុគ្គលិកទេ ។ |

## ២៣. ប្រទេសមិចស៊ីកូ៖ កម្មវិធីផ្ទេរប្រាក់មានល័ក្ខខ័ណ្ឌនៃកម្មវិធីសាកល្បងទប់ស្កាត់សិស្សបោះបង់សាលា នៅប្រទេសមិចស៊ីកូ (PROGRESA)

| ធាតុផ្សំ | ការបរិយាយ |
|---|---|
| ការដកស្រង់ពីអត្ថបទសិក្សាស្រាវជ្រាវ | Schultz, T. (2000). *ការឧបត្ថម្ភធនសាលាសម្រាប់សិស្សក្រីក្រ៖ ការវាយតម្លៃលើយុទ្ធសាស្ត្រមិចស៊ីកូ ក្នុងការកាត់បន្ថយ ភាពក្រីក្រ*។ ទីក្រុងវ៉ាស៊ីនតោន ឌីស៊ី (Washington, DC)៖ វិទ្យាស្ថានអន្តរជាតិស្រាវជ្រាវគោលនយោបាយស្បៀងអាហារ។ |
| សំណួរស្រាវជ្រាវ | តើការឧបត្ថម្ភធនដល់សាលាមានអនុភាពអ្វីខ្លះទៅលើការចុះឈ្មោះចូលរៀន? |
| អ្នកចូលរួម | សិស្សថ្នាក់ទី៣ ដល់ទី៩ មកពីសហគមន៍ជនបទក្រីក្រចំនួន៥៩៥ ក្នុងប្រទេស មិចស៊ីកូបានចូលរួមក្នុងការសិក្សានេះ ។ ក្នុងចំណោមសហគមន៍ទាំងនេះ សហគមន៍ចំនួន៣១៤ស្ថិតក្នុងកម្មវិធីទប់ស្កាត់ការបោះបង់សាលានៅក្នុងប្រទេសមិចស៊ីកូ(PROGRESA) ហើយ សហគមន៍ចំនួន១៨១ផ្សេងទៀត មិនស្ថិតក្នុងកម្មវិធីនេះទេ ។ |
| ការកំណត់ | <u>ប្រទេស មិចស៊ីកូ</u> ។ រដ្ឋក្រីក្របំផុតចំនួនប្រាំពីរ មានជាអាទិ៍ រដ្ឋ ហ៊ីដាលហ្គូ(Hidalgo) មីឆៅខេន (Michoacan) ជីប្លា (Puebla) ហ្គឺរេតារ៉ូ (Queretaro) សាន លួីស ផូតូស៊ី (San Luis Potosi) វីរាក្រូស្ស (Veracruz) និងរដ្ឋហ្គឺរេរ៉ូ (Guerrero) ត្រូវបានជ្រើសរើសសម្រាប់អន្តរាគមន៍នេះ ។ |
| អន្តរាគមន៍ | <u>ការផ្ទេរប្រាក់មានល័ក្ខខ័ណ្ឌ</u>៖ កម្មវិធី (PROGRESA) បានផ្តល់ឲ្យម្តាយក្នុងសហគមន៍ជនបទក្រីក្រនូវថវិកាអប់រំ ប្រសិនបើកូនដែលរៀនថ្នាក់ទី៣ ដល់ទី៩ របស់ពួកគាត់ចូលរៀនឲ្យបានយ៉ាងហោច៨៥% នៃម៉ោងសិក្សា ។ ដើម្បីឲ្យមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ សិស្សត្រូវតែមកចុះឈ្មោះចូលរៀននាពេលថ្មីៗនេះ និងត្រូវរៀនឲ្យចប់ថ្នាក់មុន ។ |
| ការប្រៀបធៀប | ការប្រៀបធៀបត្រូវបានធ្វើឡើង រវាងកុមារក្នុងសហគមន៍ក្រីក្រដែលត្រូវបានជ្រើសរើសព្រាវៗ ដែលក្នុងនោះម្តាយរបស់ពួកគេបានទទួលថវិកានេះ និងម្តាយទាំងនោះមានលក្ខណៈសម្បត្តិគ្រប់គ្រាន់សម្រាប់ឧបត្ថម្ភធននោះ ប៉ុន្តែមិនបានទទួលវានោះទេ ។ |
| វិធីសាស្ត្រ | ទាំងចំនួនសិស្សក្នុងក្រុមទទួលអន្តរាគមន៍ និងសិស្សក្នុងក្រុមមិនទទួលអន្តរាគមន៍ត្រូវបានគេអង្កេតពីរដងក្នុងមួយឆ្នាំ មុនពេលកម្មវិធី |

| ធាតុផ្សំ | ការបរិយាយ |
|---|---|
| | នេះត្រូវបានប្រកាស និងត្រូវបានអនុវត្តអស់រយៈពេលពីរឆ្នាំ បន្ទាប់ពីកម្មវិធីនេះបានចាប់ផ្តើម ដោយបង្ហាញពីវដ្តនៃការអង្កេតសរុបចំនួន៥ ។ ការសិក្សានេះ បានផ្តោតលើអត្រាចុះឈ្មោះចូលរៀននៅក្នុងចំណោមក្រុមកុមារដែលត្រូវបានចាត់ថ្នាក់ តាមរយៈចំនួនថ្នាក់ដែលពួកគេបានរៀបចប់ ។<br><br>ការបែងចែកនៃគំរូតាងនេះបានសម្រួលដល់ការប៉ាន់ស្មានលើអនុភាពនៃកម្មវិធី។ សម្រាប់កុមារម្នាក់មានលក្ខណៈសម្បត្តិគ្រប់គ្រាន់ក្នុងការទទួលបានថវិកាអប់រំរបស់កម្មវិធី PROGRESA កុមារនោះត្រូវតែរៀនចប់ថ្នាក់ទី២ដល់ថ្នាក់ទី៨ ហើយបានចុះឈ្មោះចូលរៀននៅថ្នាក់បន្ទាប់នាពេលថ្មីៗនេះ ។<br><br>គំរូតាងចំនួនពីរត្រូវបានវិភាគពីជំរឿនមូលដ្ឋាន និងការអង្កេតតាមដាន៖ ក្រុមសមតុល្យមួយ និងគំរូតាងតាមក្រុម ។ គំរូតាងក្រុមនេះរួមមានកុមារអាយុចាប់ពី៥ ដល់១៦ឆ្នាំ ដែលត្រូវបានអង្កេតនៅក្នុងជំរឿនគ្រួសារ កាលពីខែតុលា ឆ្នាំ ១៩៩៧ ដែលបានបំពេញសំណួរស្តីពីអាយុ ការសិក្សា និងការចុះឈ្មោះចូលរៀន ដែលក្នុងនោះគេបានរាយករណ៍អំពីការរៀនសូត្ររបស់ឪពុក ម្តាយរបស់សិស្ស និងប្រៀបធៀបទីតាំងទៅនឹងឯកសារព័ត៌មានសហគមន៍ផ្សេងទៀត ។<br><br>គំរូតាងក្រុមនេះត្រូវបានដាក់កំហិតបន្ថែមទៀត ដើម្បីបញ្ចូលតែកុមារដែលគេអាចតាមដាន និងប្រៀបធៀប ក្នុងដំណាក់កាលអង្កេតមុនពេលមានកម្មវិធីបន្ទាប់ក្នុងខែមីនា ឆ្នាំ១៩៩៨ប៉ុណ្ណោះ ហើយបន្ទាប់មកនៅក្នុងការអង្កេតចំនួនបីទៀត ក្នុងខែតុលា ឆ្នាំ ១៩៩៨ ខែឧសភា ឆ្នាំ១៩៩៩ និងខែវិច្ឆិកា ឆ្នាំ១៩៩៩ ។ គំរូតាងតាមក្រុមធំទី២បានបញ្ចូលកុមារអាយុពី៥ឆ្នាំ ដល់១៨ឆ្នាំ ទាំងអស់ ដែលត្រូវបានអង្កេតយ៉ាងហោចម្តង និងអាចត្រូវបានភ្ជាប់ទៅក្នុងទិន្នន័យគ្រួសារឲ្យបានគ្រប់គ្រាន់ ដើម្បីប៉ាន់ស្មានពីគំរូនៃការចុះឈ្មោះចូលរៀនជាមូលដ្ឋាននេះ ។ |
| **ខ្នាតរង្វាស់ និងលទ្ធផលសំខា** | <u>ការចុះឈ្មោះចូលរៀន</u> ៖ អានុភាពវិជ្ជមាន ។ នៅឯកម្រិតបឋមសិក្សា អត្រាចុះឈ្មោះចូលរៀនបានកើនឡើង០,៩៦% សម្រាប់កុមារីនិង០,៧៤% សម្រាប់កុមារា ។ (អត្រាចុះឈ្មោះចូលរៀនសម្រាប់កុមារា និងកុមារីចាប់ផ្តើមបាន៩៤%)។ នៅឯកម្រិត មធ្យ |

| ធាតុផ្សំ | ការបរិយាយ |
|---|---|
| ន់ៗ | មសិក្សា អត្រាចុះឈ្មោះចូលរៀនបានកើនឡើង៩,៣ ភាគរយសម្រាប់កុមារី និង៥,៨ភាគរយ សម្រាប់កុមារា (អត្រាចុះឈ្មោះចូលរៀនសម្រាប់កុមារាចាប់ផ្តើមបាន៧៣% ហើយអត្រាចុះឈ្មោះចូលរៀនសម្រាប់កុមារីចាប់ផ្តើមបាន៦៧%) ។<br><br>ការនៅរៀន៖ អានុភាពវិជ្ជមាន ។ ភាពខុសគ្នាដ៏ធំបំផុតត្រូវបានគេរកឃើញថា កុមារដែលបានរៀនចប់ថ្នាក់ទី៦ និងមាន លក្ខណៈសម្បត្តិគ្រប់គ្រាន់ ដើម្បីចុះឈ្មោះចូលរៀននៅអនុវិទ្យាល័យ ។ ចំពោះក្រុមនេះ អត្រាចុះឈ្មោះចូលរៀនបានកើនឡើង១១,១ ភាគរយពីអត្រាមុនពេលមានកម្មវិធី ៥៨% ទៅ ៦៩% ។ ចំពោះកុមារី អត្រាចុះឈ្មោះចូលរៀនបានកើនឡើង១៤,៨ភាគរយបើប្រៀបធៀបនឹងអត្រាចុះឈ្មោះចូលរៀនរបស់កុមារា ដែលបានកើនឡើង៦,៥ភាគរយ ។<br><br>ភាពខុសគ្នាមួយទៅភាពខុសមួយទៀតជាមធ្យមមាន ៣,៦ ភាគរយ នៅគ្រប់កម្រិតថ្នាក់ទាំងអស់ សម្រាប់ភេទទាំងពីរដែលបានដាក់បញ្ចូលគ្នានេះ។ គេបានប៉ាន់ស្មានថាប្រហែល២/៣ នៃឆ្នាំសិក្សាច្រើនជាងមុន សម្រាប់អ្នកចូលរួមកម្មវិធី PROGRESA ។ |
| ថ្លៃចំណាយ | ទំហំនៃការផ្តល់ប្រាក់ឧបត្ថម្ភនេះបានកើនឡើងបួនដងពីថ្នាក់ទី៣ ដល់ថ្នាក់ទី៩ ។ ការផ្តល់ប្រាក់ឧបត្ថម្ភនេះមានចាប់ពី៧,៧៤ ដុល្លារក្នុងរយៈពេលពីរខែ សម្រាប់សិស្សថ្នាក់ទី៣ (ទាំងពីរភេទ) រហូតដល់២៤,៨៦ដុល្លារក្នុងរយៈពេលពីរខែ សម្រាប់កុមារាថ្នាក់ទី៩ និង ២៨,១៨ ដុល្លារ ក្នុងរយៈពេលពីរខែសម្រាប់កុមារីថ្នាក់ទី៩ ។<br><br>ប្រាក់ឧបត្ថម្ភនេះត្រូវបានផ្តល់ឲ្យកុមារីច្រើនជាងកុមារាបន្តិចបន្តួច នៅកម្រិតអនុវិទ្យាល័យ ដោយសារតែកុមារីមកចុះឈ្មោះចូលរៀនយឺតជាងកុមារា ប្រហែល៦% នៅក្នុងកម្រិតនេះ ។ ចំនួនទឹកប្រាក់ ដែលកុមារីថ្នាក់ទី៩បានទទួលគឺប្រហែល៤៥% នៃប្រាក់ឈ្នួលរបស់ពលករម្នាក់ក្នុងមួយថ្ងៃ នៅក្នុងសហគមន៍កសិកម្ម ។ (ដុល្លារ ឆ្នាំ១៩៩៨) |
| ការបណ្តុះបណ្តាលបុគ្គលិក | គេមិនបានផ្តល់ការបណ្តុះបណ្តាលបុគ្គលិកទេ ។ |

## ២៤. ប្រទេស នេប៉ាល់៖ ដំណើរមានរដូវ និងការអប់រំ ក្នុងប្រទេសនេប៉ាល់

| ធាតុផ្សំ | ការបរិយាយ |
|---|---|
| ការដកស្រង់ពីអត្ថបទសិក្សាស្រាវជ្រាវ | Oster, Emily and Rebecca Thornton. (2009). *ដំណើរមានរដូវ និងការអប់រំក្នុងប្រទេស នេប៉ាល់* ។ ឯកសារការងារ NBER ស៊េរីលេខ: ១៤៨៥៣ ។ |
| សំណួរសិក្សាស្រាវជ្រាវ | តើអ្វីទៅជាអានុភាពនៃការផ្តល់ផលិតផលអនាម័យទំនើបៗនៅក្នុងការអប់រំរបស់កុមារី? |
| អ្នកចូលរួម | សិស្សថ្នាក់ទី៧ និងទី៨ (កុមារីចំនួន១៩៨នាក់) ។ កុមារីពាក់កណ្តាលបានទទួលអន្តរាគមន៍នេះ ។ |
| ការកំណត់ | ប្រទេស នេប៉ាល់ ។ សាលាចំនួនបួន (សាលាក្នុងទីប្រជុំជនចំនួនពីរ និងសាលាជាយក្រុងចំនួនពីរទៀត) ក្នុង និងជុំវិញទីក្រុង បារាតជីរ (Bharatpur City) ក្នុងស្រុក ជិតវ៉ាន (Chitwan District) ត្រូវបានជ្រើសរើសសម្រាប់អន្តរាគមន៍នេះ ។ |
| អន្តរាគមន៍ | ក្មេងស្រី ក្នុងការសិក្សានេះ ត្រូវបានផ្តល់ឲ្យពែងសម្រាប់ពេលមានរដូវមួយ សម្រាប់ប្រើប្រាស់ អំឡុងពេលមករដូវប្រចាំខែរបស់ខ្លួន និងត្រូវបានតាមដាន រយៈពេល ១៥ខែ ដើម្បីវាស់ស្ទង់ឥទ្ធិពលរបស់អន្តរាគមន៍នេះ ។ ពែងសម្រាប់ស្ត្រីមានរដូវ គឺជាវត្ថុតូច មានសារធាតុស៊ីលីខុន (silicone) ហើយរាងដូចកណ្តឹង ដែលប្រើនៅផ្នែកខាងក្នុង អំឡុងពេលមានរដូវ ។ នៅពេលឈាមរដូវពេញពែងនេះ និងត្រូវចាក់វាចោល និងលាងប្រហែលជារៀងរាល់១២ម៉ោងម្តង ។ ប្រសិនបើថែរក្សាឲ្យបានត្រឹមត្រូវ ពែងនេះ អាចប្រើប្រាស់បានរហូតដល់មួយទស្សវត្សរ៍ ។ |
| ការប្រៀបធៀប | ការប្រៀបធៀប ត្រូវបានធ្វើឡើង រវាងកុមារីដែលបានទទួលពែងសម្រាប់ពេលមានរដូវ និងកុមារីដែលមិនបានទទួលពែងនេះ ។ |
| វិធីសាស្ត្រ | នៅឯកិច្ចប្រជុំដំបូង ការអង្កេតទិន្នន័យមូលដ្ឋានមួយ ត្រូវបានធ្វើឡើង ចំពោះទាំងក្មេងស្រី និងម្តាយរបស់ពួកគេ ។ ការស្ទង់មតិនេះ បានរាប់បញ្ចូលនូវសំណួរស្តីពីប្រជាសាស្ត្រមូលដ្ឋាន ការសិក្សា ដំណើរមានរដូវ និងការគោរពខ្លួនឯង ។ នៅឯចុងបញ្ចប់កិច្ចប្រជុំលើកដំបូងនេះ ការពិនិត្យព្រាវៗ ត្រូវបានអនុវត្ត តាមរយៈការចាប់ឆ្នោតសាធារណៈ។ កុមារីដែលលេខរបស់ខ្លួនត្រូវបានចាប់ចេញមកក្រៅ |

| ធាតុផ្សំ | ការបរិយាយ |
| --- | --- |
| | ត្រូវបានចាត់តាំងទៅក្នុងក្រុមអន្តរាគមន៍ជាមួយអាណាព្យាបាល ឬម្តាយរបស់ពួកគេ ។ កុមារីទទួលអន្តរាគមន៍ត្រូវបានស្នើឲ្យបន្តនៅក្នុងកិច្ចប្រជុំនេះ ហើយកុមារីទទួលអន្តរាគមន៍នីមួយៗ និងអាណាព្យាបាលជាស្ត្រីរបស់ខ្លួន បានទទួលពែងសម្រាប់ពេលមានរដូវមួយ ។<br><br>ក្រោយពេលកិច្ចប្រជុំលើកដំបូងនេះរួចមក កុមារីត្រូវបានតាមដានប្រហែលជារយៈពេល១៥ខែ (អំឡុងខែមករា ឆ្នាំ ២០០៨)។ ក្នុងខែកុម្ភៈ ឆ្នាំ២០០៨ កិច្ចប្រជុំលើកទី២ត្រូវបានរៀបចំឡើងនៅក្នុងសាលានីមួយៗ។ នៅឯកិច្ចប្រជុំនេះ ការអង្កេតតាមដានមួយ ដែលស្រដៀងនឹងការអង្កេតទិន្នន័យមូលដ្ឋានត្រូវបានធ្វើឡើង ។ កុមារី១៨៣នាក់ក្នុងការសិក្សាស្រាវជ្រាវ បានចូលរួមកិច្ចប្រជុំតាមដាន។ សំណួរដែលបានមកពីការអង្កេតមូលដ្ឋាន និងការអង្កេតតាមដានអាចឲ្យយើងវាស់វែងការផ្លាស់ប្តូរឥរិយាបថ និងអាកប្បកិរិយាជាការឆ្លើយតបទៅនឹងការទទួលពែងពេលមានរដូវ។ នៅក្នុងការអង្កេតទាំងពីរ កុមារីត្រូវបានគេសួរអំពីវត្តមានចូលរៀន និងលទ្ធផលសិក្សាក៏ដូចជាការគោរពខ្លួនឯង ការផ្តល់អំណាច និងសុខភាពរបស់ខ្លួនផងដែរ។<br><br>ការបែងចែកពែងព្រាវៗបាននាំឲ្យមានការប៉ាន់ស្មានមិនលំអៀងអំពីភាពខុសគ្នា រវាងកុមារីដែលទទួលអន្តរាគមន៍ និងកុមារី ដែលមិនទទួលអន្តរាគមន៍។ ការសិក្សានេះបានប្រើប្រាស់វិធីសាស្ត្រពីរយ៉ាង ដើម្បីធ្វើការប៉ានស្មានកាន់តែច្បាស់ថែមទៀត ជាមួយការប៉ាន់ស្មានភាពខុសគ្នាមួយទៅភាពខុសគ្នាមួយទៀត ដែល (១) ការប្រើប្រាស់ទិន្នន័យមុនពេលអន្តរាគមន៍ជា ក្រុមមិនទទួលអន្តរាគមន៍ពីគម្រោងនិង (២) ការប្រើប្រាស់ទិន្នន័យ ក្នុងអំឡុងថ្ងៃមានរដូវ និងថ្ងៃគ្មានរដូវ ។ |
| **ខ្នាតរង្វាស់ និងលទ្ធផលសំខាន់ៗ** | <u>វត្តមានចូលរៀន</u>៖ គ្មានអានុភាព ។ ទោះបីជាកុមារី៣% ទំនងជាមិនចូលរៀននៅថ្ងៃមករដូវក៏ដោយ ក៏មិនមានអានុភាពគួរឲ្យកត់សម្គាល់នៃការបែងចែកពែងសម្រាប់ពេលមានរដូវ ទៅលើ<u>វត្តមាន</u>ចូលរៀននោះទេ ។<br><br>ពិន្ទុប្រឡង៖ គ្មានអានុភាព ។ មិនមានអានុភាពលើពិន្ទុប្រឡង ការរាយការណ៍ដោយខ្លួនអំពីការវាស់វែងលើការគោរពខ្លួនឯង ឬសុខភាពរោគស្ត្រីនោះទេ។ |

| ធាតុផ្សំ | ការបរិយាយ |
|---|---|
| | ដោយឡែក អានុភាពទាបនៃផលិតផលអនាម័យទំនើបអាចដោយសារតែផលិតផលអនាម័យត្រឹមតែជួយគ្រប់គ្រងឈាមរដូវប៉ុណ្ណោះ មិនមែនជួយចុកពោះ ឬអស់កម្លាំងនោះទេ។ កុមារីនៅក្នុងការសិក្សានេះបានរាយការណ៍ថា មូលហេតុចម្បងដែលពួកគេមិនបានចូលរៀនអំឡុងពេលមករដូវរបស់ខ្លួន គឺដោយសារតែការចុកពោះ ។<br><br><u>អានុភាពផ្សេងទៀត</u>៖ បើទោះបីជាមានការខ្វះខាតអានុភាពលើការសិក្សាក៏ដោយ ក៏ការសិក្សានេះពិតជាបានគាំទ្រដល់គុណតម្លៃខ្លះៗនៃផលិតផលទាំងនេះដែរ ។ ក្នុងចំណោមកុមារីទទួលអន្តរាគមន៍ពីគម្រោង៦១ភាគរយបានប្រើប្រាស់ពែង នៅចន្លោះរវាងកិច្ចប្រជុំរកទិន្នន័យមូលដ្ឋាន និងកិច្ចប្រជុំតាមដាន ហើយការប្រើប្រាស់នេះមានកម្រិតកាន់តែខ្ពស់ ក្នុងចំណោមកុមារីមិនទទួលអន្តរាគមន៍ ដែលក្រោយមកបានទទួលពែងនេះ ។<br><br>បន្ថែមពីលើការរាយការណ៍ពីភាពធូរស្រាល និងភាពងាយស្រួល ជាមួយការផ្លាស់ទី និងការគ្រប់គ្រងឈាមរដូវ កុមារីដែលស្ថិតនៅក្នុងក្រុមទទួលអន្តរាគមន៍បានចំណាយពេលតិចជាងមុន២០នាទីរៀងរាល់ថ្ងៃ ក្នុងការបោកគក់នៅថ្ងៃដែលពួកគេមករដូវ ។ លទ្ធផលនេះបានលើកឡើងថា ពិតជាមានឧបសគ្គប្រាកដមែនសម្រាប់កុមារីទាក់ទិននឹងការមករដូវនេះ។ ប៉ុន្តែ គ្រាន់តែការ ផ្តល់ជូនផលិតផលអនាម័យទំនើបៗដល់កុមារីប៉ុណ្ណឹងមិនអាចជាដំណោះស្រាយក្នុងការលុបបំបាត់ ឬកាត់បន្ថយឧបសគ្គទាំងនោះទេ ។ |
| **ថ្លៃចំណាយ** | ការចូលរួមក្នុងការសិក្សានេះ គឺអាស្រ័យលើការចូលរួមនៅក្នុងកិច្ចប្រជុំសិក្សាលើកទី១ ដែលពេលនោះ កុមារីបានទទួលប៊ិច និងក្រដាសបកបិទ (stickers) ហើយម្តាយបានទទួល ១០០ រូពីនេប៉ាល់(១,៤៥ ដុល្លារ) |
| **ការបណ្តុះបណ្តាលបុគ្គលិក** | មិនមានការបណ្តុះបណ្តាលបុគ្គលិកទេ ។ |

## ២៥. ប្រទេសប៉ាគីស្ថាន: កម្មវិធីផ្តល់ប្រាក់ឧបត្ថម្ភដល់សាលាកុមារី

| ធាតុផ្សំ | ការបរិយាយ |
|---|---|
| ការដកស្រង់ពីអត្ថបទសិក្សាស្រាវជ្រាវ | Chaudhury, N. & Parajuli, D. (2006). ការផ្ទេរប្រាក់មានល័ក្ខខ័ណ្ឌ និងការអប់រំកុមារី៖ *អានុភាពនៃកម្មវិធីផ្តល់ប្រាក់ឧបត្ថម្ភដល់សាលាកុមារីលើការចុះឈ្មោះចូលរៀននៅសាលារដ្ឋក្នុងខេត្ត ភុនចាប (Punjab) ប្រទេសប៉ាគីស្ថាន។* ការវាយតម្លៃលើអានុភាពលេខ៩ ធនាគារពិភពលោក។ |
| សំណួរស្រាវជ្រាវ | តើកម្មវិធីផ្ទេរប្រាក់មានល័ក្ខខ័ណ្ឌបង្កើនការចុះឈ្មោះចូលរៀនរបស់កុមារីនៅក្នុងសាលារដ្ឋដែរឬទេ? |
| អ្នកចូលរួម | កុមារីទាំងអស់ដែលរៀនថ្នាក់ទី៦ ដល់ទី៨ នៅក្នុងស្រុកមួយក្នុងចំណោមស្រុកទាំង១៥របស់ខេត្ត ភុនចាប (Punjab) ដែលមានខអត្រាអក្ខរកម្ម ៤០% ឬក៏ទាបជាងនេះ មានសិទ្ធិទទួលបានប្រាក់ឧបត្ថម្ភនោះ ។ |
| ការកំណត់ | ខេត្ត ភុនចាប ប្រទេសប៉ាគីស្ថាន។ ខេត្ត ភុនចាប គឺជាខេត្តធំជាងគេបង្អស់ និងមានជាងគេបង្អស់ ក្នុងប្រទេស ប៉ាគីស្ថាន ជាទីដែលអត្រាចុះឈ្មោះចូលរៀន មានកម្រិតខ្ពស់ជាងគេ ហើយភាពខុសគ្នាខាងយេនឌ័រ ក៏មានកម្រិតទាបជាងគេដែរ នេះបើប្រៀបធៀបជាមួយខេត្តដទៃទៀត ។ បើទោះបីជាខេត្តនេះជាខេត្តនាំមុខគេ ក្នុងប្រទេស ប៉ាគីស្ថាន ទាក់ទិននឹងលទ្ធផលនៃការអប់រំ យ៉ាងណាក៏ដោយ ក៏ខេត្តនេះ នៅតែជួបប្រទះបញ្ហាជាច្រើនផងដែរ ដូចជាការបែងចែកធនធានមិនគ្រប់គ្រាន់ ចំពោះវិស័យអប់រំ ភាពកំសោយជាប្រព័ន្ធក្នុងការផ្គត់ផ្គង់ សេវាសាធារណៈ ដែលបណ្តាលមកពីការធ្វើ ប្រព័ន្ធមជ្ឈការ ច្រើនពេក ការគ្រប់គ្រងមិនគ្រប់គ្រាន់ និងការបំពេញតួនាទីខាងប្រព័ន្ធអប់រំមិនបានល្អពាក់ព័ន្ធនឹងគុណភាព ការទទួលបាន និងអភិបាលកិច្ច ។ |
| អន្តរាគមន៍ | ការផ្ទេរប្រាក់មានល័ក្ខខ័ណ្ឌ។ នៅក្នុងកម្មវិធីនេះ កុមារីម្នាក់ៗបានទទួលប្រាក់ឧបត្ថម្ភមានល័ក្ខខ័ណ្ឌ នៅពេលដែលពួកគេមកចុះឈ្មោះចូលរៀន ចាប់ពីថ្នាក់ទី៦ ដល់ថ្នាក់ទី៨ នៅសាលារដ្ឋ ក្នុងស្រុកគោលដៅ និងកុមារីទាំងនោះត្រូវមករៀនជាមធ្យមឲ្យបានយ៉ាងហោច៨០ភាគរយ ។<br><br>មូលនិធិត្រូវបានផ្ទេរទៅឲ្យគ្រួសារសិស្សដោយផ្ទាល់តាមរយៈការបញ្ញាប្រាក់តាមប្រៃសណីយ៍ចេញពីការិយាល័យអប់រំស្រុក។ |
| ការប្រៀបធៀប | ការប្រៀបធៀប ត្រូវបានធ្វើឡើងក្នុងចំណោមសាលាបួនក្រុម ដូចខាងក្រោមនេះ៖ |

| ធាតុផ្សំ | ការបរិយាយ |
|---|---|
| | ១.សាលាកុមារីក្នុងស្រុកមានកម្មវិធី (អន្តរាគមន៍៖ សាលាកុមារីចំនួន ១.៧៧៩ របស់ស្រុកអន្តរាគមន៍ចំនួន១៥)<br>២. សាលាកុមារី ក្នុងស្រុកមិនមានកម្មវិធី (ក្រុមមិនទទួលអន្តរាគមន៍ពីគម្រោង១៖ សាលាកុមារីចំនួន៣.១៥៦របស់ស្រុកមិនមានអន្តរាគមន៍ចំនួន១៩)<br>៣. សាលាកុមារា ក្នុងស្រុកមានកម្មវិធី (ក្រុមមិនទទួលអន្តរាគមន៍ពីគម្រោង២៖ សាលាសិស្សប្រុសចំនួន ២.២៤៧ របស់ស្រុកអន្តរាគមន៍ចំនួន ១៥)<br>៤. សាលាកុមារា ក្នុងស្រុកមិនមានកម្មវិធី (ក្រុមមិនទទួលអន្តរាគមន៍ពីគម្រោង៣៖ សាលាកុមារាចំនួន៣.២៦៥ របស់ស្រុកមិនមានអន្តរាគមន៍ចំនួន ១៩)។ |
| វិធីសាស្ត្រ | ការសិក្សានេះ បានរៀបចំទិន្នន័យក្រុមរបស់សាលានានា ចេញពីជំរឿនសាលារៀននៃប្រព័ន្ធគ្រប់គ្រង់ព័ត៌មានអប់រំខេត្ត ឆ្នាំ ២០០៣ (មុនពេលមានកម្មវិធីនេះ) និងនៅឆ្នាំ២០០៥ (ក្រោយពេលមានកម្មវិធីនេះ)។ ការសិក្សានេះបានពិចារណាទៅលើការប៉ាន់ស្មាននានា តាមរយៈការប្រើប្រាស់គោលវិធីផ្អែកលើការពិសោធន៍ មានជាអាទិ៍ គម្រោង double differencing (DD) និង គម្រោង triple-differencing (DDD)) ដោយបញ្ចូលគ្នាជាមួយគម្រោងវាយតម្លៃផលប៉ះពាល់នៃអន្តរាគមន៍ (regression-discontinuity design) និងប្រៀបធៀបការផ្លាស់ប្តូរតាមអថេរនីមួយៗ(covariates)។ |
| ខ្នាតរង្វាស់ និងលទ្ធផលសំខាន់ៗ | <u>ការចូលរៀន</u>៖ អានុភាពវិជ្ជមាន។ ការសិក្សានេះ បានរកឃើញអានុភាពអន្តរាគមន៍ជាមធ្យមមួយលើភាគរយនៃវត្តមានចូលរៀនរបស់កុមារីចាប់ពីអាយុ ១០ឆ្នាំ ដល់ ១៤ឆ្នាំ ប្រហែលជាបានពិន្ទុ១២ភាគរយ ។ ការប៉ានស្មាន ដែលបានមកពីការរួមបញ្ចូលគ្នានៃយុទ្ធសាស្ត្រផ្អែកលើការពិសោធន៍ គម្រោង DDD និង គម្រោងវាយតម្លៃផលប៉ះពាល់នៃអន្តរាគមន៍ (RDD) បានលើកឡើងថា អានុភាពនៃកម្មវិធីជាមធ្យមនេះ គឺជាការកើនឡើងនៃកុមារីចំនួន៦នាក់ ដែលបានចុះឈ្មោះចូលរៀននៅសាលានីមួយៗ ទាក់ទងនឹងការផ្លាស់ប្តូរទាំងស្រុង និងការកើនឡើងចំនួន៩ភាគរយតាមរយៈការផ្លាស់ប្តូរដោយប្រៀបធៀប។ |
| ការចំណាយ | ប្រហែល ៣ដុល្លារ សម្រាប់សិស្សម្នាក់ ក្នុងមួយខែ (ដុល្លារ នៅឆ្នាំ ២០០៥) |
| ការបណ្តុះបណ្តាលបុគ្គលិក | មិនមានការបណ្តុះបណ្តាលបុគ្គលិកទេ ។ |

## ២៦. ប្រទេសហ្វីលីពីនៈ សម្ភារៈរៀនសូត្រច្រើនកម្រិត អាហារថ្ងៃត្រង់នៅសាលា និង ភាពជាដៃគូរវាងមាតាបិតា-គ្រូបង្រៀន

| សមាសធាតុ | ការបរិយាយ |
|---|---|
| ការដកស្រង់ ពីអត្ថបទសិក្សាស្រាវជ្រាវ | Tan, J. P., J. Lane, & Lassibille, G. (1999). លទ្ធផលការសិក្សា ក្នុងសាលាបឋមសិក្សា នៅប្រទេសហ្វីលីពីនៈ ការវាយតម្លៃលើអានុភាពនៃការធ្វើពិសោធន៍បួនលើក។ *ការពិនិត្យឡើងវិញនូវសេដ្ឋកិច្ចធានាគារពិភពលោក (World Bank Economic Review) ១៣(៣), ៤៩៣-៥០៨* ។ |
| សំណួរស្រាវជ្រាវ | តើផ្តល់ជូនសម្ភារៈរៀនសូត្រច្រើនកម្រិត ឬអាហារថ្ងៃត្រង់នៅសាលា ដោយមាន ឬគ្មានភាពជាដៃគូរវាងមាតាបិតា-គ្រូបង្រៀន កាត់បន្ថយអត្រានៃសិស្សបោះបង់សាលា និងធ្វើឲ្យការសិក្សារបស់សិស្សប្រសើរឡើងដែរឬទេ? |
| អ្នកចូលរួម | សិស្សចំនួន ៣.៩៥៣នាក់ និងគ្រូបង្រៀនចំនួន ១៨០ នាក់ នៅសាលាបឋមសិក្សាចំនួន ២៩ (សាលាមួយក្នុងចំណោមសាលាដែលបានជ្រើសរើសធ្វើជាសាលាមិនទទួលអន្តរាគមន៍ត្រូវតែដកចេញ)។ |
| ការកំណត់ | <u>ប្រទេសហ្វីលីពីនៈ</u> គម្រោងនេះត្រូវបានអនុវត្តនៅក្នុងស្រុកមានចំណូលទាបចំនួនពីរ នៅក្នុងតំបន់នីមួយៗរបស់តំបន់ចំនួនប្រាំក្នុងប្រទេសនេះ ។ ស្រុកដែលបានជ្រើសរើសនីមួយៗ ត្រូវតែឆ្លើយតបនឹងលក្ខណៈវិនិច្ឆ័យឲ្យបានយ៉ាងហោចចំនួនបី នៃលក្ខណៈវិនិច្ឆ័យលើភាពក្រីក្រទាំងប្រាំ ពាក់ព័ន្ធនឹងការអប់រំ សុខភាព ការសង់លំនៅ ភាពគ្មានការងារ និងការប្រើប្រាស់ប្រចាំគ្រួសារ ។ |
| អន្តរាគមន៍ | អន្តរាគមន៍ចំនួនបួន ត្រូវបានអនុវត្តៈ<br>១. ការផ្តល់ជូន<u>សម្ភារៈរៀនសូត្រច្រើនកម្រិត</u> (MLM) ដែលជាសម្ភារៈគរុកោសល្យសម្រាប់គ្រូបង្រៀន ដើម្បីជួយពួកគេឲ្យពន្លឿនការបង្រៀនរបស់ខ្លួន ឲ្យស្របតាមសមត្ថភាពខុសៗគ្នារបស់សិស្សពួកគេ ។<br>២. ការផ្តល់ជូន<u>អាហារថ្ងៃត្រង់នៅសាលា</u> (SL) អាហារមិនគិតថ្លៃសម្រាប់ថ្ងៃសិក្សានៅសាលា គឺនៅក្នុងឆ្នាំសិក្សា<br>៣. <u>សម្ភារៈរៀនសូត្រច្រើនកម្រិត</u> រួមជាមួយ<u>ភាពជាដៃគូរវាងមាតាបិតា-គ្រូបង្រៀនជាដៃគូ</u> ដែលមានការប្រជុំក្រុម (ប្រចាំខែ) ទៀងទាត់ជាបន្តបន្ទាប់ និង<br>៤. <u>អាហារថ្ងៃត្រង់នៅសាលា</u> រួមជាមួយភាពជាដៃគូរវាង<u>មាតាបិតា-គ្រូបង្រៀន</u>។ |

| សមាសធាតុ | ការបរិយាយ |
|---|---|
| | វិធីសាស្ត្រទីមួយ អាចឲ្យគ្រូបង្រៀន ពន្លឿនការបង្រៀន ទៅតាមសេចក្ដីត្រូវការខុសៗគ្នារបស់សិស្ស និងមានតម្លៃថោក ជាងការបំប៉នបន្ថែមនៅសាលាឆ្ងាយណាស់ ។ ភាពជាដៃគូរវាងមាតាបិតា-គ្រូបង្រៀន មានតម្លៃស្មើរតែមិនចំណាយអ្វីទាល់តែសោះ ប៉ុន្តែអាចជួយការរៀនសូត្ររបស់សិស្ស ទាំងនៅផ្ទះ និងនៅសាលា ។ |
| ការប្រៀបធៀប | សាលាស្រដៀងគ្នានៅក្នុងស្រុកនីមួយៗ ត្រូវបានចាត់តាំងព្រាវៗ ជា (ក) សម្ភារៈរៀនសូត្រច្រើនកម្រិត (MLM) , សម្ភារៈរៀនសូត្រច្រើនកម្រិត (MLM) រួមផ្សំជាមួយភាពជាដៃគូរវាងមាតាបិតា-គ្រូបង្រៀន(PTP) និងក្រុមមិនទទួលអន្តរាគមន៍ពីគម្រោងនិង (ខ) អាហារថ្ងៃត្រង់នៅសាលា (SL) , អាហារថ្ងៃត្រង់នៅសាលា (SL) រួមផ្សំជាមួយភាពជាដៃគូរវាងមាតាបិតា-គ្រូបង្រៀន (PTP) និងក្រុមមិនទទួលអន្តរាគមន៍ពីគម្រោង។ |
| វិធីសាស្ត្រ | នៅក្នុងស្រុកនីមួយៗ មានការជ្រើសរើសសាលាចំនួនបី ស្របតាមលក្ខណៈវិនិច្ឆ័យដែលសាលានីមួយៗ៖<br>• ផ្ដល់ការណែនាំគ្រប់កម្រិតថ្នាក់ទាំងអស់នៅក្នុងវដ្តអប់រំបឋមសិក្សា ដែលមានបន្ទប់រៀនមួយសម្រាប់សិស្សក្នុងមួយថ្នាក់<br>• មានអត្រាបោះបង់សាលាខ្ពស់ ដោយផ្អែកលើរបាយការណ៍រដ្ឋបាល<br>• មិនស្ថិតនៅក្នុងតំបន់ដែលប្រឈមនឹងបញ្ហាសន្តិសុខ ឬសុវត្ថិភាព និង<br>• មិនផ្ដល់សេវាបំប៉នបន្ថែមនៅសាលាណាមួយទេ ។<br><br>ក្នុងស្រុកមួយ នៃតំបន់នីមួយៗ សាលាចំនួនបី ត្រូវបានចាត់តាំងដោយចៃដន្យ ឲ្យមានសម្ភារៈសិក្សាច្រើនកម្រិត (MLM), សម្ភារៈរៀនសូត្រច្រើនកម្រិត (MLM) រួមផ្សំជាមួយភាពជាដៃគូរវាងមាតាបិតា-គ្រូបង្រៀន PTP ឬក្រុមមិនទទួលអន្តរាគមន៍ពីគម្រោង។ នៅក្នុងស្រុកផ្សេងទៀត មានការចាត់តាំងសាលាចំនួនបី អាហារថ្ងៃត្រង់នៅសាលា (SL) , អាហារថ្ងៃត្រង់នៅសាលា (SL)-រួមផ្សំជាមួយ ភាពជាដៃគូរវាងមាតាបិតា-គ្រូបង្រៀន PTP និងក្រុមមិនទទួលអន្តរាគមន៍ពីគម្រោង។ កម្មវិធីនេះ បានបន្តពេញមួយឆ្នាំសិក្សា ។ ទិន្នន័យ ត្រូវបានប្រមូលនៅឆ្នាំមុនអន្តរាគមន៍ និងនៅឆ្នាំអន្តរាគមន៍ ។ |

| សមាសធាតុ | ការបរិយាយ |
|---|---|
| | |
| ខ្នាតរង្វាស់ និងលទ្ធផលសំខាន់ៗ | ការនៅរៀន៖ អានុភាពវិជ្ជមាន។ សាលាដែលប្រើសម្ភារៈរៀនសូត្រច្រើនកម្រិត ដោយមាន ឬគ្មានភាពជាដៃគូរវាងមាតាបិតា-គ្រូបង្រៀន (PTP) មានការធ្លាក់ចុះនៃអត្រាបោះបង់សាលាចំនួន១០% ឬក៏ច្រើនជាងនេះ ។<br><br>ពិន្ទុប្រឡង៖ អានុភាពជាប់លាប់ សម្រាប់ភាសាហ្វីលីពីន និងអង់គ្លេស ។ ការវិភាគលើការថយចុះ (Regression analyses) នានាបានបង្ហាញថា ដោយប្រៀបធៀបលើអថេរសារតា និងពិន្ទុប្រឡងលើកដំបូង សិស្សនៅសាលាដែលប្រើសម្ភារៈរៀនសូត្រច្រើនកម្រិតរួមជាមួយភាពជាដៃគូរវាងមាតាបិតា-គ្រូបង្រៀន (PTP) បានធ្វើឲ្យលទ្ធផលសិក្សាថ្នាក់ដំបូងជាភាសាហ្វីលីពីន និងអង់គ្លេសប្រសើរឡើងច្រើន។ សិស្សទាំងនេះក៏មានការរីកចម្រើនផ្នែកគណិតវិទ្យាផងដែរ ក៏ប៉ុន្តែភាពខុសគ្នាទាំងនេះមិនសំខាន់នៅក្នុងស្ថិតិនោះទេ ។<br><br>អ្នកនិពន្ធបានសន្និដ្ឋានថា ការរួមបញ្ចូលគ្នារវាងសម្ភារៈរៀនសូត្រច្រើនកម្រិត និងភាពជាដៃគូរវាងមាតាបិតា-គ្រូបង្រៀន(PTP) អាចជាអន្តរាគមន៍ដ៏មានតម្លៃប្រសិទ្ធភាពបំផុត ។ |
| ការចំណាយ | គេមិនបានផ្តល់ចំណាយទៅលើអន្តរាគមន៍នីមួយៗនោះទេ។ |
| ការបណ្តុះបណ្តាលបុគ្គលិក | គ្រូបង្រៀនដែលប្រើប្រាស់សម្ភារៈរៀនសូត្រច្រើនកម្រិតត្រូវបានផ្តល់នូវការបណ្តុះបណ្តាលរយៈពេលមួយសប្តាហ៍ មុនពេលអនុវត្ត ។ |

# ឧបសម្ព័ន្ធ ឃ៖

# សេចក្តីសង្ខេបអំពីការសិក្សាអន្តរាគមន៍ដែលមិនបានឆ្លើយតបទៅនឹងលក្ខណៈវិនិច្ឆ័យលម្អិតរបស់កម្មវិធីសាកល្បងទប់ស្កាត់សិស្សបោះបង់សាលា(SDPP)

**តារាង ឃ-១ ៖ កម្មវិធីអន្តរាគមន៍សិស្សបោះបង់សាលាអន្តរជាតិ ដែលមិនបានឆ្លើយតបនូវរាល់លក្ខណៈវិនិច្ឆ័យរបស់កម្មវិធីសាកល្បងទប់ស្កាត់សិស្សបោះបង់សាលា (SDPP) (ដាក់តាមលំដាប់អក្ខរក្រមនៃប្រទេសនីមួយ)**

| អ្នកនិពន្ធ | លទ្ធផលសំខាន់ៗ | ក្រុមគោលដៅ | សេវា | វិធីសាស្រ្ត | ថ្លៃចំណាយ | ឥទ្ធិពល |
|---|---|---|---|---|---|---|
| ១)ប្រទេស បង់ក្លាដេស **កម្មវិធីផ្តល់ប្រាក់ឧបត្ថម្ភដល់កុមារី** (Khandker et al., 2003; and Fuwa, 2001) | • វត្តមានចូលសាលា | កុមារីចាប់ពីថ្នាក់ទី៦ ដល់ទី១០ នៅតំបន់ជនបទ | **ផ្នែកហិរញ្ញវត្ថុ**<br>• ការផ្ទេរប្រាក់មានល័ក្ខខ័ណ្ឌ ប្រសិនបើកុមារីចូលរៀនយ៉ាងហោចបាន ៧៥% នៃឆ្នាំសិក្សា និងបានទទួលពិន្ទុប្រឡងប្រចាំឆ្នាំយ៉ាងហោច ៤៥% ហើយនៅលីវរហូតទទួលបាន សញ្ញាបត្រមធ្យមសិក្សា ឬក៏ឈានដល់អាយុ ១៨ឆ្នាំ<br><br>• សាលា ដែលមានសិស្សទទួលបានការផ្ទេរប្រាក់តាមល័ក្ខខ័ណ្ឌ ទទួលបានប្រាក់ឧបត្ថម្ភលើថ្លៃសាលា | QED: ការអង្កេតតាមគ្រួសារ និងសាលា មុន និងបន្ទាប់ពីការអនុវត្ត មិនសមមូលគ្នា នៅក្នុងទិន្នន័យមូលដ្ឋានទេ | បូកសរុបតម្លៃចាប់ពី០,៣៧ ដុល្លារ ក្នុងមួយខែ សម្រាប់កុមារីថ្នាក់ទី៦ រហូតដល់ ០,៨៨ដុល្លារ ក្នុងមួយខែ សម្រាប់កុមារីថ្នាក់ទី១០ | • ការចុះឈ្មោះចូលរៀនរបស់កុមារី បានកើនឡើង ២% លើសអត្រាទំនោរ នៃកំណើនដែលបានអង្កេត មុនពេលមានកម្មវិធីផ្តល់ប្រាក់ឧបត្ថម្ភ ដើម្បីឈានដល់ការលុបបំបាត់គម្លាតយេនឌ័រ<br><br>• អត្រាបោះបង់សាលា នៅមានកម្រិតខ្ពស់នៅឡើយ៖ តាមការប៉ាន់ស្មាន អត្រាបោះបង់សាលាចំពោះកុមារី ប្រហែលជា១៨% ពីថ្នាក់ទី៦ ដល់ថ្នាក់ទី៧ និងកើនឡើងដល់២៥% ពីថ្នាក់ទី៩ ដល់ទី ១០ ខ្ពស់ជាងអត្រាបោះបង់ការសិក្សារបស់កុមារាឆ្ងាយ |

| អ្នកនិពន្ធ | លទ្ធផលសំខាន់ៗ | ក្រុមគោលដៅ | សេវា | វិធីសាស្ត្រ | ថ្លៃចំណាយ | ឥទ្ធិពល |
|---|---|---|---|---|---|---|
| | | | | | | ណាស់ គឺ១៥% ពីថ្នាក់ទី៦ ដល់ថ្នាក់ទី៧ និង១៨% ពីថ្នាក់ទី៩ ដល់ថ្នាក់ទី១០ |
| ២)ប្រទេសបង់ក្លាដេស កម្មវិធីអាហារដើម្បីការអប់រំ (FFE) (Ahmed & del Ninno, 2002 and Meng & Ryan, 2007) | • វត្តមានចូលរៀនសាលា<br>• ការនៅរៀន | គ្រួសារជនបទក្រីក្រ ដែលមានកូនរៀននៅសាលាបឋមសិក្សា | **ផ្នែកហិរញ្ញវត្ថុ៖**<br>• របបអង្ករពី ១២-ទៅ ១៦ គីឡូក្រាម ឬស្រូវសាលីពី១៥ទៅ២០ គីឡូក្រាម ប្រចាំខែមិនគិតថ្លៃ អាស្រ័យលើចំនួនកុមារមានវត្តមានចូលរៀន យ៉ាងហោច ៨៥% នៃឆ្នាំសិក្សា | គម្រោងផ្អែកលើការពិសោធន៍ (QED) ឆ្នាំ ២០០២៖ កម្រងសំណួរជំរឿនភូមិ ទៅលើ ៦០០ គ្រួសារ ក្នុងភូមិចំនួន ៦០ ក្នុងកម្រងសំណួរសហជីព និងសាលាចំនួន ៣០សម្រាប់សាលាចំនួន ១១០ ក្នុងសហជីពចំនួន៣០ ដូចគ្នាត្រូវបានប្រមូលចាប់ពីខែកញ្ញា ដល់ខែតុលា ឆ្នាំ២០០០។ មិនមានទិន្នន័យមូលដ្ឋានប្រហាក់ប្រហែលទេ ។<br><br>គម្រោងផ្អែកលើការពិ | ៣ដុល្លារ សម្រាប់សិស្សម្នាក់ក្នុងមួយខែ (ដុល្លារ ឆ្នាំ ១៩៩៨) | ឆ្នាំ២០០២៖<br>• ការចុះឈ្មោះចូលរៀន នៅសាលាកម្មវិធីអាហារដើម្បីការអប់រំ (FFE) បានកើនឡើងចំនួន៣៥% ក្នុងរយៈពេលពីរឆ្នាំដំបូង ។ ការចុះឈ្មោះចូលរៀននៅសាលាមិនមានកម្មវិធីអាហារដើម្បីការអប់រំ បានកើនឡើងចំនួន ២,៥%<br><br>• ការចូលរៀននៅសាលាកម្មវិធីអាហារដើម្បីការអប់រំ (FFE) មានចំនួន ៧០% និងការចូលរៀននៅសាលាមិនមានកម្មវិធីអាហារដើម្បីការអប់រំ (FFE) មានចំនួន៥៨%<br>• អត្រាបោះបង់សាលា មាន |

| អ្នកនិពន្ធ | លទ្ធផលសំខាន់ៗ | ក្រុមគោលដៅ | សេវា | វិធីសាស្ត្រ | ថ្លៃចំណាយ | ឥទ្ធិពល |
|---|---|---|---|---|---|---|
| | | | | សោធន៍ QED, ឆ្នាំ ២០០៧៖ គំរូ Probit regression និងការប្រៀបធៀបពិន្ទុលំអៀង (propensity score matching) ត្រូវបានដាក់បញ្ចូលគ្នាជាមួយគំរូភាពខុសគ្នាពីមួយទៅមួយ(difference-in-differences )ស្តីពីអត្រាចូលរៀននៅសាលាបឋមសិក្សា ។ ខ្វះភាពសមមូលនៃក្រុមក្នុងទិន្នន័យមូលដ្ឋានដែលបានបង្ហាញ | | ប្រហែល ៦% សម្រាប់សិស្សក្នុងកម្មវិធីអាហារដើម្បីការអប់រំ (FFE) ប្រៀបធៀបនឹងអត្រាបោះបង់សាលា ចំនួន ១៥% សម្រាប់សិស្សនៅសាលាមិនមានកម្មវិធីអាហារដើម្បីការអប់រំ (FFE)<br><br>• ពិន្ទុប្រឡង ទាបជាងនៅក្នុងសាលាកម្មវិធីអាហារដើម្បីការអប់រំ (FFE) (៤៥%នៃពិន្ទុសរុប ) ធៀបនឹងសាលាមិនមានកម្មវិធីអាហារដើម្បីការអប់រំ (FFE) (៥៣%)<br>ឆ្នាំ ២០០៧៖ កម្មវិធីអាហារដើម្បីការអប់រំ (FFE)<br>• បង្កើនវត្តមានចូលរៀន ពី ១៥- ទៅ ២៧%<br>• បង្កើនរយៈពេលនៃការសិក្សា ពី០,៧ឆ្នាំ ទៅ១,០៥ ឆ្នាំ |

| អ្នកនិពន្ធ | លទ្ធផលសំខាន់ៗ | ក្រុមគោលដៅ | សេវា | វិធីសាស្ត្រ | ថ្លៃចំណាយ | ឥទ្ធិពល |
|---|---|---|---|---|---|---|
| ៣) ប្រទេសប្រេស៊ីល (Graeff-Martins et al., 2006) | • វត្តមានចូលសាលា<br>• នៅរៀន | សិស្សសាលាបឋមសិក្សាក្នុងសាលាចំនួនពីរដែលមានអត្រាបោះបង់សាលាខ្ពស់នៅ Porto Alegre (ទីប្រជុំជន) | **ការសិក្សា៖** សិក្ខាសាលាគ្រូបង្រៀនចំនួនពីរស្ដីពីការអភិវឌ្ឍរបស់កុមារ និងការគ្រប់គ្រងជម្ងឺវិបត្តិខាងឥរិយាបថ និងស្មារតី<br><br>**ផ្ទាល់ខ្លួន/សង្គម៖**<br>• លិខិតផ្ញើជូនគ្រូសារស្ដីពីសិស្សបោះបង់សាលា<br>• ជំនួបជាមួយមាតាបិតាចំនួនបីដង ស្ដីពីការបោះបង់សាលា<br>• ការប្រឡងតន្ត្រីស្ដីពីសិស្សបោះបង់សាលា<br>• ប្រព័ន្ធទូរស័ព្ទសុំជំនួយសម្រាប់មាតាបិតាពិភាក្សាអំពីបញ្ហានានា<br>• កម្មវិធីរយៈពេល១ថ្ងៃសម្រាប់សិស្សថ្នាក់ទី៧ស្ដីពីអត្ថប្រយោជន៍នៃការ | ពិសោធន៍QED៖ សាលាចំនួនពីរ ត្រូវបានជ្រើសរើសព្រាវៗ ចេញពីសាលាចំនួន១០ ក្នុងទីក្រុងដែលមានអត្រាបោះបង់សាលាខ្ពស់បំផុត ។ សិស្សចំនួន ៥៦១ នាក់ បានចុះឈ្មោះចូលរៀននៅសាលាទទួលអន្តរាគមន៍ពីគម្រោង។ សិស្ស ៧០៧នាក់ ចុះឈ្មោះចូលរៀននៅសាលាប្រៀបធៀប ។ សាលារៀនមួយមិនគ្រប់គ្រាន់ទេ ។ | មិនមានការផ្ដល់ព័ត៌មានអំពីការចំណាយទេ | • សិស្សក្នុងសាលាទទួលអន្តរាគមន៍មានអវត្តមានជាមធ្យមចំនួន៨ថ្ងៃ តិចជាងសិស្សក្នុងសាលាប្រៀបធៀបដែលមានអវត្តមាន ១១ថ្ងៃ<br><br>• សិស្សក្នុងសាលាទទួលអន្តរាគមន៍ មានអត្រាបោះបង់សាលាប្រហែល ៤% តិចជាងសិស្សក្នុងសាលាប្រៀបធៀបដែលមានចំនួន១០% ។ ការខុសគ្នានេះ គឺដោយសារតែការកើនឡើងនៃអត្រាបោះបង់សាលានៅក្នុងសាលាប្រៀបធៀប ។<br><br>• សិស្ស១៨ នាក់ ក្នុងចំណោម សិស្សបោះបង់សាលា៣៨ នាក់ (ស្មើនឹង ៤៥%) ដែលបានឆ្លងកាត់ការ |

| អ្នកនិពន្ធ | លទ្ធផលសំខាន់ៗ | ក្រុមគោលដៅ | សេវា | វិធីសាស្ត្រ | ថ្លៃចំណាយ | ឥទ្ធិពល |
|---|---|---|---|---|---|---|
| | | | នៅរៀន<br>• ការវាយតម្លៃសុខភាពផ្លូវចិត្តសម្រាប់សិស្សដែលអវត្តមានចំនួន១០ថ្ងៃជាប់គ្នា ឬច្រើនជាងនេះ បន្ទាប់ពីការបញ្ជូនទៅរកសេវា | | | វាយតម្លៃសុខភាពផ្លូវចិត្ត បានចូលរៀនវិញ |
| ៥) ប្រទេសឥណ្ឌា **ការពិសោធន៍នៅ** Shankarpalle (Reddy & Sinha, 2010) | • ការនៅរៀន | សិស្សសាលាបឋមសិក្សានៅ Shankarpalle Mandal, Andhra Pradesh (មិនមានការបរិយាយអំពីតំបន់ទីក្រុងនោះ | **ការសិក្សា៖** សាលានៅរដូវក្ដៅ ដែលរៀបចំដើម្បីឲ្យកុមារដែលលើសអាយុចូលរៀនបានចូលរៀនស្របតាមអាយុពួកគេ<br><br>**រចនាសម្ព័ន្ធ៖**<br>• យុទ្ធនាការលុបបំបាត់ពលកម្មកុមារ និងចុះឈ្មោះចូលរៀនសម្រាប់កុមារគ្រប់រូប<br>• គោលនយោបាយឡើងថ្នាក់ស្វ័យប្រវត្តិពី | ទិន្នន័យត្រូវបានប្រមូលពីរបាយការណ៍ផ្លូវការ ។ មិនមានក្រុមប្រៀបធៀបនោះទេ | មិនមានការរាយការណ៍ពីទិន្នន័យតម្លៃទេ | • សិស្សបានរៀនចប់ថ្នាក់ទី១, វ៉ារីយ៉ង់នៃចំនួនសិស្ស ចាប់ពីថ្នាក់ទី១ ដល់ទី១០ បានធ្លាក់ចុះគួរឲ្យកត់សម្គាល់<br>• ចំនួនសរុបនៃសិស្សចូលសាលា បានកើនឡើង ពី ៩.០៦៣នាក់ ក្នុងឆ្នាំសិក្សា ១៩៩៥-១៩៩៦ ដល់១២.២០៦នាក់ ក្នុងឆ្នាំសិក្សា ២០០៥-២០០៦ ។<br><br>• អត្រាបោះបង់សាលា នៅចន្លោះថ្នាក់ទី១ និងថ្នាក់ទី២ |

| អ្នកនិពន្ធ | លទ្ធផលសំខាន់ៗ | ក្រុមគោលដៅ | សេវា | វិធីសាស្ត្រ | ថ្លៃចំណាយ | ឥទ្ធិពល |
|---|---|---|---|---|---|---|
| | | ទេ) | ថ្នាក់ទី១ ទៅថ្នាក់ទី២<br>• គោលនយោបាយក្នុងការចុះឈ្មោះកុមារឲ្យចូលរៀនពេញមួយឆ្នាំ<br>• គោលនយោបាយក្នុងការអនុញ្ញាតឲ្យសាលាបឋមសិក្សាបន្ថែមថ្នាក់ទី៧ | | | បានធ្លាក់ចុះពី ២៨,៥% ក្នុងឆ្នាំសិក្សា១៩៩៦-៩៧ មកនៅត្រឹម ១០,១% ក្នុងឆ្នាំសិក្សា ២០០៤- ២០០៥<br>• អត្រាបោះបង់សាលា នៅចន្លោះថ្នាក់ទី៦ និងថ្នាក់ទី៧ បានថយចុះពី ២១,៣% ក្នុងឆ្នាំសិក្សា១៩៩៦-៩៧ មកនៅត្រឹម ១២,៦% ក្នុងឆ្នាំសិក្សា ២០០៤- ២០០៥ |
| ៥)ប្រទេសឥណ្ឌូនេស៊ី (Cameron, ២០០៩) | • ការនៅរៀនក្នុងសាលា | សិស្សបឋមសិក្សាអនុវិទ្យាល័យ និងវិទ្យាល័យនៅតាមបណ្តាភូមិជនបទក្រីក្រ | **ផ្នែកហិរញ្ញវត្ថុ៖** សិស្សទទួលអាហារូបករណ៍ត្រូវបានកំណត់ដោយគណ:កម្មាធិការសាលារៀន ។ រង្វាន់មានល័ក្ខខ័ណ្ឌផ្អែកលើការចុះឈ្មោះចូលរៀនបន្ត | គម្រោងផ្អែកលើការពិសោធន៍ QED: "ការអង្កេតភូមិ១០០" ដែលភូមិនីមួយៗមាន ១២០ គ្រួសារ ត្រូវបានប្រមូលក្នុងខែសីហា និងខែធ្នូ ឆ្នាំ១៩៩៨ ។ ក្រុមទទួលអន្តរាគមន៍ និងក្រុមប្រៀបធៀប មិនអាចប្រៀបធៀបគ្នាបានទេ | • ១០ ដុល្លារ ក្នុងមួយឆ្នាំ សម្រាប់សិស្សបឋមសិក្សាម្នាក់<br>• ២០ ដុល្លារ ក្នុងមួយឆ្នាំ សម្រាប់សិស្សអនុវិទ្យាល័យម្នាក់ | • សិស្សបោះបង់សាលា នៅអនុវិទ្យាល័យ បានធ្លាក់ចុះ៣ភាគរយ ឬ៣៨% ពីកម្រិតមុន<br>• សិស្សបោះបង់សាលា នៅបឋមសិក្សា មិនបានទទួលរងផលប៉ះពាល់ពីកម្មវិធីទេ<br>• ការប៉ានស្មានពីសិស្សបោះបង់សាលានៅវិទ្យាល័យ មិនអាចធ្វើឡើងបានទេ ដោយសារតែទំហំគំរូតាងតូចពេក |

| អ្នកនិពន្ធ | លទ្ធផលសំខាន់ៗ | ក្រុមគោលដៅ | សេវា | វិធីសាស្ត្រ | ថ្លៃចំណាយ | ឥទ្ធិពល |
|---|---|---|---|---|---|---|
| | | | | | • ៣០ ដុល្លារ ក្នុងមួយឆ្នាំ សម្រាប់សិស្ស វិទ្យាល័យម្នាក់ | |
| ៦) ប្រទេស ប៉េរូ (Santiago & Chinen, 2008) | • វត្តមានចូលសាលា<br>• ការនៅរៀន | កុមារគ្រប់អាយុចូលរៀន មត្តេយ្យសាលា និងបឋមសិក្សា បានចុះឈ្មោះចូលរៀន នៅសាលារដ្ឋ ក្នុងនាយកដ្ឋាន Ayacucho, Apurimac និង Huancaveli | **សុខភាព៖**<br>ការផ្តល់ជូនអាហារ ពេលព្រឹកនៅសាលា | គម្រៀងផ្អែកលើការពិសោធន៍ QED៖ កុមារសិក្សានៅសាលា ក្នុងនាយកដ្ឋានដែលនៅក្បែរគ្នាចំនួនពីរ (Apurimac និង Cusco) បានដើរតួនាទី ជាក្រុមប្រៀបធៀប ។ មិនមានការសាកល្បងលើភាពសមមូលនៃទិន្នន័យមូលដ្ឋាននោះទេ ។ | ១៦,៩០ ដុល្លារ សម្រាប់សិស្សម្នាក់ក្នុងមួយឆ្នាំ | • សិស្សថ្នាក់ទី១ ដល់ទី៦ ក្នុងក្រុមទទួលអន្តរាគមន៍ ជាមធ្យម មានវត្តមានចូលរៀន ពី ៩០ទៅ៩៥% ក្នុងខែនីមួយៗ ប្រៀបធៀបនឹង៨០ទៅ៨៧% ក្នុងក្រុមប្រៀបធៀប ។<br>• សិស្សថ្នាក់ទី១ ដល់ទី៦ ក្នុងក្រុមទទួលអន្តរាគមន៍បានបង្ហាញពីការធ្លាក់ចុះនៃអត្រាបោះបង់សាលា ពីឆ្នាំ ១៩៩៥ ដល់ឆ្នាំ ១៩៩៨ (មិនមានការបង្ហាញពីភាពខុសគ្នាពីសាលាប្រៀបធៀបនោះទេ)<br>• លទ្ធផលនៃការប្រឡងប្រចាំថ្នាក់ទី៤ ត្រូវបានដាក់បញ្ចូលគ្នាជាមួយថ្នាក់ច្រើនក្នុង |

| អ្នកនិពន្ធ | លទ្ធផលសំខាន់ៗ | ក្រុមគោលដៅ | សេវា | វិធីសាស្ត្រ | ថ្លៃចំណាយ | ឥទ្ធិពល |
|---|---|---|---|---|---|---|
| | | ca (ជនបទ) | | | | សាលាមួយ ដែលទទួលអត្ថប្រយោជន៍ពីសាលាទទួលអន្តរាគមន៍ពីគម្រោង។ |
| ៧) ប្រទេសហ្វីលីពីន គម្រោង Project No Drops (SEAMEO, 1995) | • នៅរៀនក្នុងសាលា | សិស្សសាលាបឋមសិក្សា ដែលប្រឈមនឹងការបោះបង់សាលា (ជនបទ និងទីក្រុង) | **ការសិក្សា៖**<br>• ប្រព័ន្ធសិក្សា ដែលបានពង្រីក សម្រាប់កុមារនៅសាលា (ឧទាហរណ៍ សិក្សាជាក្រុមមិត្តអប់រំមិត្ត រៀនសូត្រជាមួយមិត្តភក្តិជិតស្និទ្ធ និងការបង្រៀនគួរបន្ថែមតាមផ្ទះ)<br>• វគ្គបណ្តុះបណ្តាលដ៏ទូលំទូលាយដល់គ្រូបង្រៀនដែលចូលបម្រើការងារ<br>• ការរួមបញ្ចូលគ្នានៃការរៀនសូត្រតាមសាលា និងការរៀនសូត្រតាមផ្ទះ សម្រាប់សិស្សបោះបង់សាលាបណ្តោះអាសន្ន | QED៖ សាលាប្រៀបធៀបចំនួន៦ត្រូវបានជ្រើសរើសដោយក្រុមមន្ត្រីសាលា ដែលត្រូវយកសាលា១មក ផ្គូផ្គងជាមួយសាលាទទួលអន្តរាគមន៍នីមួយៗ ។ មិនមានទិន្នន័យស្តីពីភាពសមមូលគ្នានៅក្នុងទិន្នន័យមូលដ្ឋានទេ | មិនមានការផ្តល់ទិន្នន័យស្តីពីការចំណាយទេ | • មិនមានការបញ្ចូលស្ថិតិទៅក្នុងកុំព្យូទ័រទេ ទោះជាយ៉ាងនោះក្តី អត្រាបោះបង់សាលាបានធ្លាក់ចុះនៅក្នុងសាលាទទួលអន្តរាគមន៍ទាំង៦ (ក្នុងសាលាចំនួន៩ ទៅ០) ខណៈពេលដែលអត្រាបោះបង់សាលាបានធ្លាក់ចុះ នៅក្នុងសាលាប្រៀបធៀបចំនួន៣ (ក្នុងសាលាចំនួន១ ទៅ០) ហើយបានកើនឡើងនៅសាលាប្រៀបធៀប ចំនួន៣ ផ្សេងទៀត ។<br>• សិស្ស នៅក្នុងសាលាទទួលអន្តរាគមន៍ឈានដល់កម្រិតអក្ខរកម្មតាមមុខងារញឹកញាប់ជាងសិស្សនៅក្នុងសាលា |

| អ្នកនិពន្ធ | លទ្ធផលសំខាន់ៗ | ក្រុមគោលដៅ | សេវា | វិធីសាស្ត្រ | ថ្លៃចំណាយ | ឥទ្ធិពល |
|---|---|---|---|---|---|---|
| | | | ឬតាមរដូវកាល<br>• ការរៀនសូត្រសង្ខេបៗ និងការរៀនសូត្របែបលឿនសម្រាប់សិស្សបោះបង់សាលាអចិន្ត្រៃយ៍<br>• ការអប់រំក្រៅប្រព័ន្ធសម្រាប់ឪពុកម្តាយសិស្ស<br>**ផ្នែកហិរញ្ញវត្ថុ៖**<br>• ការផ្តត់ផ្គង់សម្ភារៈសិក្សា និងការថែទាំ សុខភាពដោយឥតគិតថ្លៃដល់សិស្សបោះបង់សាលា<br>**<u>សុខភាព</u>៖**<br>• ការធ្វើសួនជីវៈចម្រុះដើម្បីផ្គត់ផ្គង់អាហារសម្រន់ដោយឥតគិតថ្លៃ<br><br>**ផ្ទាល់ខ្លួន/សង្គម៖** | | | ប្រៀបធៀប ។ |

| អ្នកនិពន្ធ | លទ្ធផលសំខាន់ៗ | ក្រុមគោលដៅ | សេវា | វិធីសាស្ត្រ | ថ្លៃចំណាយ | ឥទ្ធិពល |
|---|---|---|---|---|---|---|
| | | | • ប្រព័ន្ធជូនដំណឹងជាមុនសម្រាប់គ្រូបង្រៀនក្នុងការកំណត់អត្តសញ្ញាណសិស្សដែលប្រឈមនឹងការបោះបង់សាលា<br>• ការតាមដានជិតដល់របស់ឪពុកម្តាយ<br><br>**រចនាសម្ព័ន្ធ៖**<br>• ក្តីកង្វល់អំពីសិស្សគេចសាលា<br>• យុទ្ធនាការស្តីពីសារៈសំខាន់នៃការអប់រំ | | | |
| ៨) ហ្សាមបៀ (Chatterji et al., 2010) | • ការនៅរៀន | កុមារកំព្រា និងកុមារងាយរងគ្រោះ ដែលមានអាយុពី ៨ ដល់១៩ | **ការសិក្សា៖**<br>• សាលាសហគមន៍<br><br>**ផ្នែកហិរញ្ញវត្ថុ៖**<br>• ការចំណាយលើថ្លៃសិក្សា | QED៖ OVCs ចំនួន ២.៩២២នាក់ ដែលក្នុងនោះសិស្ស ទទួលអន្តរាគមន៍ចំនួន ១.២៥២នាក់ និងសិស្សមិនទទួលអន្តរាគមន៍ | មិនមានការផ្តល់ជូនទិន្នន័យតម្លៃទេ | • នៅពេលតាមដាន យើងឃើញថា សិស្សទទួលអន្តរាគមន៍ទំនងជានៅបន្តការសិក្សាច្រើនជាង។<br>• សិស្សទទួលអន្តរាគមន៍ទំនងជារៀននៅថ្នាក់ដែល |

| អ្នកនិពន្ធ | លទ្ធផលសំខាន់ៗ | ក្រុមគោលដៅ | សេវា | វិធីសាស្ត្រ | ថ្លៃចំណាយ | ឥទ្ធិពល |
|---|---|---|---|---|---|---|
| | | ឆ្នាំ នៅ Lusaka (ទីក្រុង) | • ការផ្តល់ជូននូវការផ្គត់ផ្គង់បរិក្ខារសាលា<br><br>**សុខភាព**<br>• ការផ្តល់អាហារនៅសាលា<br>• សេវាគ្លីនិក<br>**ផ្ទាល់ខ្លួន/សង្គមះ**<br>• ការប្រឹក្សាយោបល់<br>• ការអប់រំស្តីពីការទប់ស្កាត់មេរោគអេដស៍ | ដែលត្រូវបានគេប្រៀបធៀបចំនួន១.៦៨០នាក់ ។ គំនិត "អ្នកជិតខាងនៅក្បែរបំផុត" ត្រូវបានប្រើ ដើម្បីបង្កើតក្រុមប្រៀបធៀប ។ ការអង្កេតពីស្ថានភាព ត្រូវបានធ្វើឡើង ក្នុងឆ្នាំ ២០០៣ និង២០០៦ ។ គ្មានការវាស់វែងលើភាពសមមូលគ្នានៅក្នុងទិន្នន័យមូលដ្ឋានទេ។ | | សមស្របទៅនឹងអាយុរបស់ខ្លួន |